







# លើកកម្ពស់ការយល់ដឹង និងភ្ជាប់ទំនាក់ទំនង សង្គមស៊ីវិលជាមួយកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍ តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

## ឯកសារបណ្តុះបណ្តាលសម្រាប់ គ្រូ និងសិក្ខាកាម

# សេចក្តីថ្លែងអំណរគុណ

សៀវភៅសម្រាប់គ្រូបង្គោល និងសិក្ខាកាមដែលមានចំណងជើងថា “ **លើកកម្ពស់ការយល់ដឹង និងភ្ជាប់ទំនាក់ទំនងសង្គមស៊ីវិលស្តីពី កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ** ” ត្រូវបានចងក្រងឡើងដោយមានការគាំទ្រ និងជ្រោមជ្រែងពីសំណាក់អង្គការសង្គមស៊ីវិលពាក់ព័ន្ធជាច្រើន។

ជាបឋមយើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ**លេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងធនាគារពិភពលោក** ដែលបានជួយឧបត្ថម្ភគាំទ្រផ្នែកហិរញ្ញវត្ថុ ។ ទន្ទឹមនឹងនេះ ក៏សូមថ្លែងអំណរគុណចំពោះថ្នាក់ដឹកនាំលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដែលមានឆន្ទៈខ្ពស់ក្នុងការលើកកម្ពស់ឱ្យមានការចូលរួមពីសង្គមស៊ីវិល ក្នុងការគាំទ្រអនុវត្តកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។

ជាមួយគ្នានេះ ក៏សូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅចំពោះ ក្រុមការងាររបស់លេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដែលបានផ្តល់ការប្រឹក្សាយោបល់ និងជួយកែសម្រួលអត្ថន័យលើឯកសារមួយចំនួន ដើម្បីឱ្យសៀវភៅនេះមានខ្លឹមសារពេញលេញសម្រាប់ការបោះពុម្ព។

ក្នុងនេះដែរក៏សូមថ្លែងអំណរគុណដល់សិក្ខាកាមជា **តំណាងអង្គការសង្គមស៊ីវិល**ទាំងអស់ដែលបានជួយផ្តល់ជាមតិយោបល់ ក្នុងកំឡុងពេលនៃការបណ្តុះបណ្តាលសាកល្បងលើឯកសារមេរៀន និងវិធីសាស្ត្របង្រៀន ក៏ដូចជានៅក្នុងវគ្គបណ្តុះបណ្តាលលើកកម្ពស់ការយល់ដឹងដល់អង្គការសង្គមស៊ីវិលស្តីពីកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (២០១០-២០១៩) ដែលជាវិភាគទានមួយដ៏ធំធេងក្នុងការជម្រុញឱ្យសៀវភៅនេះមានគុណភាពកាន់តែប្រសើរឡើង។

ជាចុងក្រោយ សូមជម្រាបថា សមិទ្ធិផលដែលសម្រេចនេះ គឺបានការចូលរួម និងខំប្រឹងប្រែងពីសំណាក់ក្រុមការងារអង្គការផេកកម្ពុជា និងកិច្ចសហការជាមួយវិទ្យាស្ថានបំរើអ្នកសម្របសម្រួលការងារអភិវឌ្ឍ (VBNK) រួមមាន: ១) លោក ឈ ចន្ទសុផល ប្រធានគម្រោង ២) លោក អាសីវ ឱរិក្ស

ទីប្រឹក្សាជាន់ខ្ពស់ ៣) លោក យី សុខថា ប្រធានក្រុមការងារ/ជំនាញអភិបាលកិច្ច ៤) លោក លឹម ប៊ុន ប្រធានក្រុមគ្រូឧទ្ទេស ៥) លោក ទន់ យូហៀង ប្រធានក្រុមគ្រូឧទ្ទេស ៦) លោកស្រី ម៉ូវ លាន ប្រធានក្រុម គ្រូឧទ្ទេស ៧) លោក ប៊ឹង សំអឿន គ្រូឧទ្ទេស ៨) លោកស្រី ប៊ី ឱឡែន គ្រូឧទ្ទេស ៩) លោក អ៊ុក ពិសិដ្ឋ គ្រូឧទ្ទេស ១០) លោកស្រី សំ សាវ៉ូន គ្រូឧទ្ទេស ១១) លោកស្រី ហួត រតនៈ អ្នកសម្របសម្រួលប្រព័ន្ធ ផ្សព្វផ្សាយនិងផលិតសម្ភារៈផ្សព្វផ្សាយ ១២) លោក ផាន ភ័ព្វបារមី មន្ត្រីផលិតសម្ភារៈអប់រំផ្សព្វផ្សាយ និង ១៣) លោក ហេង សន្ថា មន្ត្រីផលិតសម្ភារៈអប់រំផ្សព្វផ្សាយ។

# សេចក្តីផ្តើម

រាជរដ្ឋាភិបាលកម្ពុជាបានបោះជំហានទៅមុខជាវិជ្ជមានលើការអនុវត្តកំណែទម្រង់វិមជ្ឈការ និង វិសហមជ្ឈការ ដែលមានលក្ខណៈស៊ីជម្រៅនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ បានប្រកាសឱ្យប្រើប្រាស់នាខែឧសភា ឆ្នាំ២០០៨ ហើយការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ បានប្រព្រឹត្តិទៅនៅខែឧសភា ឆ្នាំ២០០៩។ គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដោយមានការចូលរួមយ៉ាងសកម្មពីបណ្តាក្រសួងពាក់ព័ន្ធ បានបញ្ចប់ការរៀបចំកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិនេះនៅក្នុងខែឧសភា ឆ្នាំ២០១០ ហើយបានគូសបញ្ជាក់យ៉ាងច្បាស់ពីផែនការការងារ និងក្របខណ្ឌនៃពេលវេលារយៈពេល១០ឆ្នាំ សំដៅគាំទ្រដល់ការអនុវត្តច្បាប់រៀបចំអង្គការ។ កំណែទម្រង់រដ្ឋបាលនៅថ្នាក់ក្រោមជាតិតាមរយៈការអនុវត្តកម្មវិធីជាតិនេះ នឹងមានផលប៉ះពាល់ដល់តួនាទី ទំនាក់ទំនង និងការចូលរួមរបស់អង្គការសង្គមស៊ីវិលជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិនៅក្នុងបណ្តាឆ្នាំដែលនឹងឈានចូលមកដល់នាពេលអនាគតដ៏ខ្លីខាងមុខនេះ។

កំណែទម្រង់ដ៏មានលក្ខណៈស៊ីជម្រៅនេះ នឹងទទួលបានជោគជ័យនៅពេលដែលរដ្ឋាភិបាល និង សង្គមស៊ីវិលសហការរួមគ្នា ដើម្បីកសាងភាពជាដៃគូប្រកបដោយប្រសិទ្ធភាពក្នុងបរិយាកាសជឿទុកចិត្តគ្នាទៅវិញទៅមក សំដៅបង្កលក្ខណៈឱ្យប្រជាពលរដ្ឋមានឱកាសចូលរួមក្នុងការធ្វើសេចក្តីសម្រេចចិត្តនៅគ្រប់លំដាប់ថ្នាក់រដ្ឋបាល និងមានសំឡេងនៅក្នុងកិច្ចអភិវឌ្ឍមូលដ្ឋានរបស់ខ្លួន ។ សៀវភៅនេះបានរៀបចំឡើងជា ៣ជំពូកសំខាន់ៗ ដែលរួមបញ្ចូលទាំងប្លង់មេរៀនសម្រាប់ជាជំនួយដល់ការបណ្តុះបណ្តាលបន្តផងដែរ ហើយជំពូកនីមួយៗត្រូវការរយៈពេលបណ្តុះបណ្តាលចំនួនមួយថ្ងៃ។

យើងសង្ឃឹមថា សៀវភៅសម្រាប់គ្រូ និងសិក្ខាកាមស្តីពី "**លើកកម្ពស់ការយល់ដឹង និងភ្ជាប់ទំនាក់ទំនងសង្គមស៊ីវិលស្តីពី កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ** "នេះគឺជាផ្នែកមួយនៃការរួមចំណែកដ៏សំខាន់សម្រាប់ជួយគាំទ្រដល់ការលើកកម្ពស់ការយល់ដឹង និង អាចឱ្យសង្គមស៊ីវិលត្រៀមលក្ខណៈ ដើម្បីចូលរួមចំណែកក្នុងការអនុវត្តកម្មវិធីជាតិ ក៏ដូចជាការគាំទ្រ និង ជម្រុញឱ្យមានការចូលរួមពីប្រជាពលរដ្ឋនៅក្នុងដំណើរការកំណែទម្រង់អភិបាលកិច្ចនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងន័យលើកកម្ពស់ការផ្តល់សេវាសាធារណៈ ដើម្បីឆ្លើយតមតាមសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋ និងរួមចំណែកក្នុងការកាត់បន្ថយភាពក្រីក្រ។

យើងខ្ញុំរង់ចាំទទួលមតិកែលំអក្នុងន័យស្ថាបនាពីគ្រប់មិត្តអ្នកអាន ដើម្បីធ្វើឱ្យខ្លឹមសារនៃសៀវភៅនេះ កាន់តែមានភាពល្អប្រសើរឡើង។

ភ្នំពេញ ថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០១០

# របៀបប្រើប្រាស់សៀវភៅ

សៀវភៅសម្រាប់គ្រូ និងសិក្ខាកាមនេះ ត្រូវបានរៀបចំ និងមានការកែសម្រួល បន្ទាប់ពីវគ្គបណ្តុះបណ្តាលសាកល្បង និងវគ្គបណ្តុះបណ្តាល " **លើកកម្ពស់ការយល់ដឹងដល់អង្គការសង្គមស៊ីវិលស្តីពី កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ**" ដែលបានរៀបចំឡើងចាប់ពី ថ្ងៃទី១០ ដល់ ថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១០ នៅក្នុង៦តំបន់នៃព្រះរាជាណាចក្រកម្ពុជា ដែលមានសិក្ខាកាមជា តំណាងអង្គការសង្គមស៊ីវិលមកពីរាជធានីភ្នំពេញ និងខេត្តទាំង ២៣ទូទាំងប្រទេស។ សៀវភៅនេះចងក្រងឡើងគឺសម្រាប់ប្រើប្រាស់ជាជំនួយស្មារតីដល់គ្រូបង្គោល និងសិក្ខាកាម ដែលមានគោលបំណងរៀបចំវគ្គបណ្តុះបណ្តាលបន្តលើប្រធានបទនេះ ដោយផ្អែកទៅតាមតម្រូវការចាំបាច់ និងស្ថានភាពជាក់ស្តែងនៃស្ថាប័នរបស់ខ្លួន។ ការពិពណ៌នាពីការប្រើប្រាស់សៀវភៅនេះក្នុងគោលបំណង:

- ជួយដល់សិក្ខាកាម ដែលមានចំណងក្លាយជាគ្រូបង្គោលឱ្យកាន់តែយល់ច្បាស់ពីដំណើរការវិធីសាស្ត្រនៃការសម្របសម្រួលមេរៀន ការប្រើប្រាស់សម្ភារៈជំនួយក្នុងការសម្របសម្រួល និង ការទំនាក់ទំនងគ្នានៃមេរៀននីមួយៗ។
- ផ្តល់ឱ្យសិក្ខាកាមនូវគោលគំនិតសម្រាប់ការពិចារណាក្នុងកំឡុងពេលចូលរួមវគ្គបណ្តុះបណ្តាល តាមរយៈឧបករណ៍មួយចំនួនដែលមាននៅក្នុងសៀវភៅនេះ។

ទិដ្ឋភាពទូទៅនៃសៀវភៅនេះរួមមាន សេចក្តីថ្លែងអំណរគុណ សេចក្តីផ្តើម របៀបប្រើប្រាស់សៀវភៅ កាលវិភាគគំរូសម្រាប់វគ្គបណ្តុះបណ្តាល មាតិកាសៀវភៅ និងជំពូកទាំង៣ ដោយភ្ជាប់ជាមួយនូវឧបសម្ព័ន្ធ។ ចំពោះខ្លឹមសារសំខាន់ៗនៃជំពូកនីមួយៗ ដែលមាននៅក្នុងសៀវភៅនេះរួមមាន :

### ជំពូកទី១: ប្រវត្តិដំណើរការវិមជ្ឈការ និង វិសហមជ្ឈការនៅកម្ពុជា

ជំពូកនេះមាន ៤មេរៀន ដែលពិពណ៌នាអំពី : ១) ប្រវត្តិកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ នៅកម្ពុជា ២) អភិបាលកិច្ច និងទស្សនទានកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ៣) តួនាទី និងការរួមចំណែករបស់សង្គមស៊ីវិល និង ៤) ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

## ជំពូកទី២: ការណែនាំអំពីកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

ជំពូកនេះមាន ៣មេរៀន ដែលពិពណ៌នាអំពី: ១) ការណែនាំពីកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ២)ការគ្រប់គ្រងកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ៣) លិខិតបទដ្ឋានគតិយុត្តដែលគាំទ្រដល់ការអនុវត្តកំណែទម្រង់រដ្ឋបាលថ្នាក់ក្រោមជាតិ។

## ជំពូកទី៣: ការភ្ជាប់ទំនាក់ទំនងសង្គមស៊ីវិលក្នុងការអនុវត្តកម្មវិធីជាតិ

ជំពូកនេះ មាន៤មេរៀន ដែលពិពណ៌នាអំពី: ១) ការយល់ឃើញរបស់អង្គការសង្គមស៊ីវិលក្នុងការភ្ជាប់ទំនាក់ទំនងជាមួយក្រុមប្រឹក្សាថ្នាក់ក្រោមជាតិ ២) ការចូលរួមរបស់អង្គការសង្គមស៊ីវិលក្នុងការអនុវត្តកម្មវិធីជាតិ ៣) ការលើកកម្ពស់បណ្ដាញសង្គមស៊ីវិល និងព័ត៌មាននៅរដ្ឋបាលថ្នាក់ក្រោមជាតិ ៤) ការរំលឹកមេរៀន និងទស្សនវិស័យរបស់សិក្ខាកាមក្នុងការលើកកម្ពស់ការយល់ដឹងបន្តដល់សង្គមស៊ីវិលអំពីកម្មវិធីជាតិ។

នៅក្នុងជំពូក និងមេរៀននីមួយៗ មានខ័ណ្ឌទំព័រដាច់ដោយលែកពីគ្នា ហើយចែកចេញជា ៥ផ្នែកសំខាន់ៗ គឺ:

១) ជាឯកសាររៀបរាប់អំពីគោលបំណង និងការរំពឹងទុកនៃមេរៀន។ ចំពោះកំណត់ចំណាំ គឺជាកំណត់ត្រាសំខាន់ៗ និងអធិប្បាយអំពីកំណត់សំគាល់សម្រាប់ជាជំនួយស្មារតីដល់គ្រូក្នុងពេលពន្យល់ ឬរំលឹកដល់គ្រូពីចំនុចដែលត្រូវចាប់អារម្មណ៍ចំពោះមេរៀននីមួយៗ។

២) ជាឯកសារបង្ហាញ (Powerpoint) ដែលរៀបចំឡើងផ្អែកលើឯកសារចែកជូន (Handout) ដោយ សង្ខេបយកតែចំណុចសំខាន់ៗនៃមេរៀនមកបង្ហាញ។ ការប្រើប្រាស់ឯកសារបង្ហាញនេះជួយដល់គ្រូក្នុងការគ្រប់គ្រងពេលវេលា និងផ្ដោតលើខ្លឹមសារមេរៀន។ ឯកសារបង្ហាញនេះកាត់តែមានប្រសិទ្ធភាពក្នុងករណីដែលមានសម្ភារៈបង្ហាញ ដូចជាម៉ាស៊ីនបញ្ចាំងស្លាយ (LCD) កំព្យូទ័រ និងមានអគ្គីសនីគ្រប់គ្រាន់ ។ ក្នុងករណីដែលពុំមានសម្ភារៈ និងអគ្គីសនី គឺអាចប្រើក្រដាសផ្ទាំងធំជំនួសវិញ។

៣) ជាឯកសារសម្រាប់ចែកសិក្ខាកាម (Handout) គឺជាឯកសារមេរៀនលំអិតអំពីប្រធានបទនៃមេរៀននីមួយៗ ដែលមានលក្ខណៈស្របគ្នាជាមួយឯកសារបង្ហាញ។ ឯកសារមេរៀនលំអិតនេះនឹងផ្តល់ឱ្យសិក្ខាកាមយល់បានកាន់តែច្បាស់ថែមទៀតទៅលើការបង្ហាញ និងការពន្យល់របស់គ្រូ។

៤) ជាឯកសារផ្ទាំងរូបភាព (ឯកសារអប់រំ - Information Education Communication – IEC Material) សម្រាប់ប្រើប្រាស់ជាជំនួយដល់គ្រូក្នុងការពន្យល់ដល់សិក្ខាកាម ហើយក៏ជាឯកសារមួយ សម្រាប់ជាមូលដ្ឋានជួយឱ្យសិក្ខាកាមមើលឃើញកាន់តែច្បាស់ និងជួយដល់សិក្ខាកាមឱ្យមានការចងចាំទៅលើខ្លឹមសាររបស់មេរៀនបានល្អ។

៥) ប្លង់មេរៀន គឺជាឯកសារគោលសម្រាប់ជាជំនួយស្មារតីដែលប្រាប់ពីដំណើរការ និងវិធីសាស្ត្របង្រៀន ឬ អាចហៅបានថាជាការណែនាំ ឬ ជាមគ្គុទ្ទេសសម្រាប់គ្រូសម្របសម្រួលដែលមានការពន្យល់លំអិតពីជំហាន និងរបៀបសម្របសម្រួលមេរៀននីមួយៗ ។ ឯកសារនេះនឹងជួយដល់ការសម្របសម្រួលឱ្យមានលក្ខណៈកាន់តែល្អប្រសើរ និង គ្រប់ជ្រុងជ្រោយតាមរយៈការរំលេចឱ្យឃើញពីសម្ភារៈដែលត្រូវប្រើប្រាស់ ក្នុងអំឡុងពេលនៃដំណើរការសម្របសម្រួលដូចជាឯកសារយោង ឬ ឯកសារផ្ទាំងរូបភាព និងថេរៈវេលាសម្រាប់ការសម្របសម្រួលនៅក្នុងមេរៀននីមួយៗ ។ល។

## ☆ ឧបសម្ព័ន្ធ

ចំពោះឧបសម្ព័ន្ធ ត្រូវបានចែកចេញជាឧបសម្ព័ន្ធ "ក " និង ឧបសម្ព័ន្ធ"ខ"។ ឧបសម្ព័ន្ធទាំងពីរស្ថិតនៅផ្នែកខាងក្រោយបំផុតនៃសៀវភៅនេះ។

- **ឧបសម្ព័ន្ធ "ក"** រួមមាន :

**១) ឯកសារស្តីពី : ការណែនាំពីការបើកវគ្គបណ្តុះបណ្តាល** : គឺជាការណែនាំ/ឯកសារគោលប្រើប្រាស់ជាជំនួយស្មារតីសម្រាប់ណែនាំគ្រូអំពីរបៀបចាប់ផ្តើម ឬ បើកវគ្គបណ្តុះបណ្តាលថាតើត្រូវធ្វើយ៉ាងដូចម្តេច? នៅក្នុងការណែនាំនេះក៏មានរៀបរាប់អំពីគោលបំណង និង លទ្ធផលរំពឹងទុក របស់វគ្គទាំងមូល ហើយក៏មានការណែនាំអំពីរបៀបសម្របសម្រួល

និង ចង្អុលប្រាប់ថាតើត្រូវមានសម្ភារៈអ្វីខ្លះសម្រាប់គាំទ្រ ឬ ប្រើប្រាស់ក្នុងការចាប់ផ្តើម ឬ បើកវគ្គនេះ ។

២) **ឯកសារស្តីពី : ការរំលឹកមេរៀនប្រចាំថ្ងៃ :** គឺជាគំរូប្លង់សេចក្តីណែនាំ/ឯកសារគោលប្រើប្រាស់ជាជំនួយស្មារតីសម្រាប់ណែនាំ ឬ ជាមគ្គុទ្ទេសដល់អ្នកសម្របសម្រួលអំពីរបៀបនៃការរំលឹកមេរៀនប្រចាំថ្ងៃ ថាតើត្រូវរៀបចំយ៉ាងដូចម្តេចដើម្បីឱ្យការរំលឹកមេរៀននេះប្រព្រឹត្តទៅដោយរលូន និងប្រកបដោយវិជ្ជាជីវៈ។ គំរូឯកសារស្តីពីការរំលឹកមេរៀនប្រចាំថ្ងៃមានចំនួនពីរដែលអ្នកសម្របសម្រួលអាចប្រើប្រាស់ ក្នុងន័យជាជម្រើសផ្លាស់ប្តូរវិធីសាស្រ្តទៅតាមស្ថានភាពជាក់ស្តែង។

៣) **ឯកសារស្តីពី : ការណែនាំពីការបិទ ឬបញ្ចប់វគ្គបណ្តុះបណ្តាល** : គឺជាគំរូឯកសារគោលប្រើប្រាស់ជាជំនួយស្មារតីសម្រាប់ណែនាំគ្រូអំពីរបៀបបិទ ឬ បញ្ចប់វគ្គបណ្តុះបណ្តាល ថាតើត្រូវរៀបចំធ្វើយ៉ាងដូចម្តេច?

៤) **ឯកសារស្តីពី : ការវាយតម្លៃប្រចាំថ្ងៃ** គឺជាគំរូទម្រង់វាយតម្លៃប្រចាំថ្ងៃ ដែលគ្រូត្រូវយកមកប្រើប្រាស់ដើម្បីវាស់ស្ទង់អំពីចំណេះដឹង ការផ្លាស់ប្តូរ និងមតិយោបល់ត្រលប់របស់សិក្ខាកាមក្នុងថ្ងៃនីមួយៗ ក្នុងន័យស្ទាប់ស្ទង់កំរិតយល់ដឹង និងវិធីសាស្រ្តសម្របសម្រួលរបស់គ្រូឆ្លើយតបនឹងសេចក្តីត្រូវការរបស់សិក្ខាកាមដែរឬទេ?

៥) **ឯកសារស្តីពី : ការវាយតម្លៃបញ្ចប់វគ្គ** គឺជាគំរូទម្រង់វាយតម្លៃ ដែលគ្រូត្រូវយកមកប្រើប្រាស់ដើម្បីវាស់ស្ទង់អំពីចំណេះដឹង ការផ្លាស់ប្តូរ និងមតិយោបល់ត្រលប់របស់សិក្ខាកាមជូនដល់អ្នករៀបចំវគ្គបណ្តុះបណ្តាល ដើម្បីឆ្លុះបញ្ចាំពីដំណើរការរៀបចំរបស់ខ្លួន និងជួយដល់អ្នករៀបចំធ្វើការកែលម្អនៅពេលក្រោយ។

- **ឧបសម្ព័ន្ធ ខ**

គឺជាសន្ទានុក្រមដែលពន្យល់ពីពាក្យបច្ចេកទេស ឬពាក្យគន្លឹះ ដើម្បីឱ្យអ្នកប្រើប្រាស់សៀវភៅងាយស្រួលយល់អំពីកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ។

## ☆ **ការប្រើប្រាស់រូបភាពអប់រំ**/Informaiton Education Communication (IEC) Materials

| **ជំពូកទី១** | | |
|---|---|---|
| ☆ ការណែនាំពីវគ្គបណ្តុះបណ្តាល | ប៉ុស្ទ័រ |  |
| មេរៀនទី១:ប្រវត្តិកំណែទម្រង់ វិមជ្ឈការ និង វិសហមជ្ឈការ | ប៉ុស្ទ័រ |  |
| | ប័ណ្ណផ្នត់ |  |
| មេរៀនទី២: អភិបាលកិច្ច និងទស្សនទានកំណែទម្រង់វិមជ្ឈការ | សម្ភារៈ ឧបទ្ទេស |  |

| | | |
|---|---|---|
| និងវិសហមជ្ឈការ | |  |
| | ប៉ុស្ទ័រ |    |

| | | |
|---|---|---|
| មេរៀនទី៣: តួនាទី និងការរួមចំណែករបស់សង្គមស៊ីវិល | ប៉ុស្ទ័រ |  |
| មេរៀនទី៤: ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ | ប៉ុស្ទ័រ |   |
| **ជំពូកទី២** | | |
| មេរៀនទី១: ការណែនាំពីកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ | ប៉ុស្ទ័រ |  |

| | | |
|---|---|---|
| | |  |
| | បណ្ណផ្ទត់ |  |
| | ប៉ុស្ទ័រ |  |

| ជំពូកទី៣ | | |
|---|---|---|
| មេរៀនទី២: ការចូលរួមរបស់អង្គការសង្គមស៊ីវិលក្នុងការភ្ជាប់ទំនាក់ទំនងជាមួយក្រុមប្រឹក្សាថ្នាក់ក្រោមជាតិ | ប៉ុស្ទ័រ |  |
| មេរៀនទី៣: ការលើកកម្ពស់ការប្រើប្រាស់បណ្ដាញសង្គមស៊ីវិល និង ព័ត៌មាននៅរដ្ឋបាល ថ្នាក់ក្រោមជាតិ | | សូមប្រើប្រាស់រូបភាពអប់រំទាំងយកបង្ហាញជាថ្មីម្តងទៀតថាតើរូបភាពណាប្រើប្រាស់នៅក្នុងមេរៀនណា |

# គោលបំណងរួមរបស់វគ្គ

នៅពេលដែលរចនាសម្ព័ន្ធថ្មីនៃរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានបង្កើតឡើង ការលើកកម្ពស់ការចូលរួមរបស់អង្គការស៊ីវិល ប្រព័ន្ធផ្សព្វផ្សាយ និងប្រជាពលរដ្ឋនៅក្នុងការអនុវត្តកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យគឺជាកត្តាដ៏សំខាន់ក្នុងកំឡុងអន្តរកាល និងអនាគត។

ដើម្បីចូលរួមគាំទ្រដល់កិច្ចខិតប្រឹងប្រែងរបស់ គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិនៅក្នុងកំណែទម្រង់រដ្ឋបាលនៅថ្នាក់ក្រោមជាតិ គោលបំណងសំខាន់នៃវគ្គបណ្តុះបណ្តាលគឺ:

- លើកកម្ពស់ការយល់ដឹងរបស់សង្គមស៊ីវិល ស្តីពីកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ទន្ទឹមនឹងនេះក៏ជាការរៀបចំឱ្យសង្គមស៊ីវិលបានចូលរួមសហការជាដៃគូធ្វើការងារជាមួយនឹងរដ្ឋបាលថ្នាក់ក្រោមជាតិ និងរដ្ឋបាលមូលដ្ឋាន។

- គាំទ្រ និងជម្រុញ ឱ្យមានការចូលរួមរបស់ប្រជាពលរដ្ឋនៅក្នុងមុខនាទីសំខាន់ៗ នៃអភិបាលកិច្ចរួមមាន តម្លាភាព និងគណនេយ្យភាព នៅរដ្ឋបាលថ្នាក់ក្រោមជាតិ និងរដ្ឋបាលមូលដ្ឋាន ក្នុងន័យលើកកម្ពស់ការផ្តល់សេវាសាធារណៈឆ្លើយតបតាមសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋ និង រួមចំណែកក្នុងការកាត់បន្ថយភាពក្រីក្រ។

### លទ្ធផលរំពឹងទុកនៃវគ្គបណ្តុះបណ្តាល:

- ពង្រឹងការយល់ដឹងរបស់សង្គមស៊ីវិលអំពីដំណើរការកំណែទម្រង់រដ្ឋបាលថ្នាក់ក្រោមជាតិ កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងជួយគាំទ្រដល់គោលនយោបាយ និងការតាក់តែងច្បាប់នានា។

- អង្គការសង្គមស៊ីវិលនឹងជួយជម្រុញការផ្សព្វផ្សាយព័ត៌មាន និងបង្កើនការយល់ដឹងអំពីវិមជ្ឈការនៅក្នុងស្ថាប័នរបស់ខ្លួន។

- ពង្រឹងសមត្ថភាព និងបង្ហាញពីឱកាសរបស់សង្គមស៊ីវិលក្នុងការភ្ជាប់ទំនាក់ទំនងទៅនឹងកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងការអភិវឌ្ឍមូលដ្ឋាន និងការជួយគាំទ្រដល់ការចូលរួមរបស់ប្រជាពលរដ្ឋ។

# កាលវិភាគវគ្គបណ្តុះបណ្តាល

## កាលវិភាគ

## វគ្គបណ្តុះបណ្តាលស្តីពី

## "លើកកម្ពស់ការយល់ដឹង និងភ្ជាប់ទំនាក់ទំនងសង្គមស៊ីវិលជាមួយកម្មវិធីជាតិ សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ"

| ជំពូកទី១/ថ្ងៃទី១ | |
|---|---|
| ០៨:០០ - ០៨:៤០ | **ការណែនាំអំពីវគ្គបណ្តុះបណ្តាល**<br>◆ ពិធីបើកវគ្គ<br>◆ ការណែនាំឱ្យស្គាល់គ្នា<br>◆ ការបង្ហាញអំពីគោលបំណង និងការរំពឹងទុក<br>◆ លំហូរនៃវគ្គបណ្តុះបណ្តាល<br>◆ វិន័យសម្រាប់វគ្គ |
| ០៨:៤០ - ១០:១០ | **មេរៀនទី១:** ប្រវត្តិដំណើរការវិមជ្ឈការ និងវិសហមជ្ឈការ |
| ១០:១០ - ១០:២៥ | សម្រាកអាហារសម្រន់ |
| ១០:២៥ - ១២:០០ | **មេរៀនទី២:** អភិបាលកិច្ច និងទស្សនទានកំណែទម្រង់វិមជ្ឈការ និង វិសហមជ្ឈការ |
| ១២:០០ - ១៤:០០ | សម្រាកអាហារថ្ងៃត្រង់ |
| ១៤:០០ - ១៤:៥០ | **មេរៀនទី៣:** តួនាទី និងការរួមចំណែករបស់សង្គមស៊ីវិលក្នុងដំណើរការកំណែទម្រង់ វិមជ្ឈការ និងវិសហមជ្ឈការ |
| ១៤:៥០ - ១៥:០០ | សម្រាកអាហារសម្រន់ |
| ១៥:០០ - ១៦:៤០ | **មេរៀនទី៤:** ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ |
| ១៦:៤០ - ១៧:០០ | **ការវាយតម្លៃប្រចាំថ្ងៃ និងការសង្ខេបមេរៀនបញ្ចប់ថ្ងៃទី១** |
| **ជំពូកទី២/ថ្ងៃទី២** | |
| ០៨:០០ - ០៨:២០ | **ការរំលឹកមេរៀនថ្ងៃទី១** |
| ០៨:២០ - ១០:១០ | **មេរៀនទី១:** ការណែនាំអំពីកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ នៅថ្នាក់ក្រោមជាតិ ២០១០-២០១៩ |
| ១០:១០ - ១០:២៥ | សម្រាកអាហារសម្រន់ |
| ១០:២៥ - ១២:០០ | **មេរៀនទី២:** ការគ្រប់គ្រងកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ |

| | |
|---|---|
| | នៅថ្នាក់ក្រោមជាតិ (២០១០-២០១៩) |
| ១២:០០ - ១៤:០០ | សម្រាកអាហារថ្ងៃត្រង់ |
| ១៤:០០ - ១៥:០០ | **មេរៀនទី២:** ការគ្រប់គ្រងកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (២០១០-២០១៩) (បន្ត) |
| ១៥:០០ - ១៥:១៥ | សម្រាកអាហារសម្រន់ |
| ១៥:១៥ - ១៦:៣០ | **មេរៀនទី៣:** លិខិតបទដ្ឋានគតិយុត្តនានាសម្រាប់គាំទ្រដល់ដំណើរកំណែទម្រង់រដ្ឋបាលថ្នាក់ក្រោមជាតិ (បន្ត) |
| ១៦:៣០ - ១៧:០០ | ការវាយតម្លៃប្រចាំថ្ងៃ និងការសង្ខេបមេរៀនបញ្ចប់ថ្ងៃទី២ |
| **ជំពូកទី៣/ថ្ងៃទី៣** | |
| ០៨:០០ - ០៨:២០ | ការរំលឹកមេរៀនថ្ងៃទី២ |
| ០៨:២០ - ០៩:១០ | **មេរៀនទី១:** ការយល់ឃើញរបស់អង្គការសង្គមស៊ីវិលក្នុងការភ្ជាប់ទំនាក់ទំនងជាមួយក្រុមប្រឹក្សាថ្នាក់ក្រោមជាតិ |
| ០៩:១០ - ១០:១០ | **មេរៀនទី២:** ការចូលរួមរបស់អង្គការសង្គមស៊ីវិលក្នុងការភ្ជាប់ទំនាក់ទំនងជាមួយក្រុមប្រឹក្សាថ្នាក់ក្រោមជាតិ |
| ១០:១០ - ១០:២៥ | សម្រាកអាហារសម្រន់ |
| ១០:២៥ - ១២:០០ | **មេរៀនទី២:** ការចូលរួមរបស់អង្គការសង្គមស៊ីវិលក្នុងការភ្ជាប់ទំនាក់ទំនងជាមួយក្រុមប្រឹក្សាថ្នាក់ក្រោមជាតិ (បន្ត) |
| ១២:០០ - ១៤:០០ | សម្រាកអាហារថ្ងៃត្រង់ |
| ១៤:០០ - ១៥:០០ | **មេរៀនទី៣:** ការលើកកម្ពស់ការប្រើប្រាស់បណ្ដាញសង្គមស៊ីវិល និងព័ត៌មាននៅរដ្ឋបាលថ្នាក់ក្រោមជាតិ |
| ១៥:០០ - ១៥:១៥ | សម្រាកអាហារសម្រន់ |
| ១៥:១៥ - ១៦:៣០ | **មេរៀនទី៤:** ការរំលឹកមេរៀន និងទស្សនៈវិស័យរបស់សិក្ខាកាមក្នុងការលើកកម្ពស់ការយល់ដឹងបន្តដល់សង្គមស៊ីវិលអំពីកម្មវិធីជាតិ |
| ១៦:៣០ - ១៧:០០ | **ការវាយតំលៃ និងការបិទវគ្គបណ្ដុះបណ្ដាល**<br>◆ ការវាយតម្លៃបញ្ចប់វគ្គ<br>◆ បិទវគ្គ |

# មាតិកា


សេចក្ដីថ្លែងអំណរគុណ........ i

សេចក្ដីផ្ដើម........ iii

របៀបប្រើប្រាស់សៀវភៅ........ v

គោលបំណងរួមរបស់វគ្គ........ xv

កាលវិភាគវគ្គបណ្ដុះបណ្ដាល........ xvii

មាតិកា........ xix

**ជំពូកទី១**_ប្រវត្តិដំណើរការវិមជ្ឈការ និងវិសហមជ្ឈការនៅកម្ពុជា........ ៣

មេរៀនទី១_ប្រវត្តិដំណើរការវិមជ្ឈការ និងវិសហមជ្ឈការ........ ៤

- គោលបំណង លទ្ធផលរំពឹងទុកនៃមេរៀន និងកំណត់ចំណាំរបស់អ្នកសម្របសម្រួល........ ៥
- ឯកសារសម្រាប់បង្ហាញ........ ៧
- ឯកសារសម្រាប់ចែក........ ១១
- ឯកសារផ្ទាំងរូបភាព........ ១៧
- ប្លង់មេរៀន........ ២១

មេរៀនទី២_អភិបាលកិច្ច និង ទស្សនទាននៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ........ ២៥

- គោលបំណង លទ្ធផលរំពឹងទុកនៃមេរៀន និងកំណត់ចំណាំរបស់អ្នកសម្របសម្រួល........ ២៧
- ឯកសារសម្រាបបង្ហាញ........ ២៩
- ឯកសារសម្រាប់ចែក........ ៣៩
- ឯកសារផ្ទាំងរូបភាព........ ៤៩
- ប្លង់មេរៀន........ ៥៥

មេរៀនទី៣_តួនាទី និងការរួមចំណែករបស់សង្គមស៊ីវិលក្នុងដំណើរការកំណែទម្រង់វិមជ្ឈការ និង
វិសហមជ្ឈការ........ ៦៣

- គោលបំណង លទ្ធផលរំពឹងទុកនៃមេរៀន និងកំណត់ចំណាំរបស់អ្នកសម្របសម្រួល........ ៦៥
- ឯកសារសម្រាប់បង្ហាញ........ ៦៧
- ឯកសារសម្រាប់ចែក........ ៧១
- ឯកសារផ្ទាំងរូបភាព........ ៧៣
- ប្លង់មេរៀន........ ៧៥




មេរៀនទី៤_ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ.............................. ៧៩

- គោលបំណង លទ្ធផលរំពឹងទុកនៃមេរៀន កំណត់ចំណាំរបស់អ្នកសម្របសម្រួល............ ៨១
- ឯកសារសម្រាបបង្ហាញ................................................................. ៨៣
- ឯកសារសម្រាប់ចែក...................................................................... ៩៣
- ឯកសារផ្ទាំងរូបភាព..................................................................... ១០៩
- ប្លង់មេរៀន.................................................................................. ១១១

**ជំពូកទី២**_ការណែនាំអំពីកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ នៅថ្នាក់ក្រោមជាតិ ២០១០_២០១៩.......................................................... ១១៧

មេរៀនទី១_ការណែនាំពីកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ នៅថ្នាក់ក្រោមជាតិ ២០១០_២០១៩.......................................................... ១១៩

- គោលបំណង លទ្ធផលរំពឹងទុកនៃមេរៀន កំណត់ចំណាំរបស់អ្នកសម្របសម្រួល............ ១២១
- ឯកសារសម្រាប់បង្ហាញ................................................................. ១២៣
- ឯកសារសម្រាប់ចែក...................................................................... ១៣៧
- ឯកសារផ្ទាំងរូបភាព..................................................................... ១៤៧
- ប្លង់មេរៀន.................................................................................. ១៥៥

មេរៀនទី២_ការគ្រប់គ្រងកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ នៅថ្នាក់ក្រោមជាតិ ២០១០_២០១៩.......................................................... ១៦៥

- គោលបំណង លទ្ធផលរំពឹងទុកនៃមេរៀន កំណត់ចំណាំរបស់អ្នកសម្របសម្រួល............ ១៦៧
- ឯកសារសម្រាប់បង្ហាញ................................................................. ១៦៩
- ឯកសារសម្រាប់ចែក...................................................................... ១៧៩
- ឯកសារផ្ទាំងរូបភាព..................................................................... ១៩១
- ប្លង់មេរៀន.................................................................................. ១៩៣

មេរៀនទី៣_លិខិតបទដ្ឋានគតិយុត្តនានាសម្រាប់គាំទ្រដល់ដំណើរការកំណែទម្រង់រដ្ឋបាលថ្នាក់ជាតិ... ២០៣

- គោលបំណង លទ្ធផលរំពឹងទុកនៃមេរៀន កំណត់ចំណាំរបស់អ្នកសម្របសម្រួល............ ២០៥
- ឯកសារសម្រាប់បង្ហាញ................................................................. ២០៧
- ឯកសារសម្រាប់ចែក...................................................................... ២១៥




- ប្លង់មេរៀន........................................................................ ២២៧

**ជំពូកទី៣**_ការភ្ជាប់ទំនាក់ទំនងសង្គមស៊ីវិលក្នុងការអនុវត្តកម្មវិធីជាតិ........................... ២៣៣

មេរៀនទី១_ការយល់ឃើញរបស់អង្គការសង្គមស៊ីវិលក្នុងការភ្ជាប់ទំនាក់ទំនងជាមួយក្រុមប្រឹក្សាថ្នាក់ក្រោមជាតិ........................................................................ ២៣៥

- គោលបំណង លទ្ធផលរំពឹងទុកនៃមេរៀន កំណត់ចំណាំរបស់អ្នកសម្របសម្រួល............ ២៣៧
- ឯកសារសម្រាប់បង្ហាញ........................................................................ ២៣៩
- ឯកសារសម្រាប់ចែក........................................................................ ២៤៥
- ប្លង់មេរៀន........................................................................ ២៥១

មេរៀនទី២_ការចូលរួមរបស់អង្គការសង្គមស៊ីវិលក្នុងការភ្ជាប់ទំនាក់ទំនងជាមួយក្រុមប្រឹក្សាថ្នាក់ក្រោមជាតិ........................................................................ ២៥៥

- គោលបំណង លទ្ធផលរំពឹងទុកនៃមេរៀន កំណត់ចំណាំរបស់អ្នកសម្របសម្រួល............ ២៥៧
- ឯកសារសម្រាប់បង្ហាញ........................................................................ ២៥៩
- ឯកសារសម្រាប់ចែក........................................................................ ២៧១
- ប្លង់មេរៀន........................................................................ ២៩១

មេរៀនទី៣_លើកកម្ពស់ការប្រើប្រាស់បណ្ដាញអង្គការសង្គមស៊ីវិល និងព័ត៌មាននៅរដ្ឋបាលថ្នាក់ក្រោមជាតិ........................................................................ ៣០១

- គោលបំណង លទ្ធផលរំពឹងទុកនៃមេរៀន កំណត់ចំណាំរបស់អ្នកសម្របសម្រួល............ ៣០៣
- ឯកសារសម្រាប់បង្ហាញ........................................................................ ៣០៥
- ឯកសារសម្រាប់ចែក........................................................................ ៣១៧
- ប្លង់មេរៀន........................................................................ ៣២៧

មេរៀនទី៤_ការរំលឹកមេរៀន និងទស្សនវិស័យរបស់សិក្ខាកាមក្នុងការលើកកម្ពស់ការយល់ដឹង និងបន្តដល់ស៊ីវិលអំពីកម្មវិធីជាតិ........................................................................ ៣៣១

- គោលបំណង លទ្ធផលរំពឹងទុកនៃមេរៀន កំណត់ចំណាំរបស់អ្នកសម្របសម្រួល............ ៣៣៣
- ឯកសារសម្រាប់បង្ហាញ........................................................................ ៣៣៥
- ឯកសារសម្រាប់ចែក........................................................................ ៣៤១




- ប្លង់មេរៀន..................................................... ៣៤៧

**ឧបសម្ព័ន្ធ_ក** ..................................................... ៣៥១

ការណែនាំពីការបើកវគ្គបណ្តុះបណ្តាល ..................................................... ៣៥៣

គំរូសម្រាប់ការរំលឹកមេរៀនប្រចាំថ្ងៃ (គំរូទី១)..................................................... ៣៥៩

គំរូសម្រាប់ការរំលឹកមេរៀនប្រចាំថ្ងៃ (គំរូទី២)..................................................... ៣៦៣

ការបិទវគ្គបណ្តុះបណ្តាល..................................................... ៣៦៧

គំរូសម្រាប់បិទវគ្គបណ្តុះបណ្តាល..................................................... ៣៦៩

ការវាយតម្លៃប្រចាំថ្ងៃ..................................................... ៣៧១

ការវាយតម្លៃបញ្ចប់វគ្គ..................................................... ៣៧៣

**ឧបសម្ព័ន្ធ_ខ_សន្ទានុក្រម**..................................................... ៣៧៥

# ជំពូកទី១

## ប្រវត្តិដំណើរការវិមជ្ឈការ និងវិសហមជ្ឈការនៅកម្ពុជា

# មេរៀនទី១

## ប្រវត្តិដំណើរការវិមជ្ឈការ
## និងវិសហមជ្ឈការ

# មេរៀនទី ១ ប្រវត្តិដំណើរការវិមជ្ឈការ និងវិសហមជ្ឈការ



**គោលបំណង** : នៅចុងបញ្ចប់មេរៀននេះ សិក្ខាកាមនឹងអាច

១.រំលឹកឡើងវិញនូវព្រឹត្តិការណ៍សំខាន់ៗនៃដំណើរការកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ និងការសិក្ខាកាមរបស់អង្គការសង្គមស៊ីវិល។

២.កំណត់ពីព្រឹត្តិការណ៍សំខាន់ៗ ទាក់ទងទៅនឹងការអនុម័តច្បាប់គោលនយោបាយ កំណែទម្រង់ការបោះឆ្នោត និងស្ថាប័នថ្នាក់ក្រោមជាតិ និងបទពិសោធន៍ ។

## លទ្ធផលរំពឹងទុកនៃមេរៀនៈ

ក. សិក្ខាកាម នឹងបានស្វែងយល់ពីទិដ្ឋភាពទូទៅស្តីពីប្រវត្តិកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការនៅក្នុងប្រទេសកម្ពុជា និងអាចចែករំលែកបទពិសោធន៍ពីគ្នាទៅវិញទៅមក ។

ខ. សិក្ខាកាមទទួលបាននូវចំណេះដឹងកាន់តែប្រសើរឡើង ស្តីពីដំណើរការកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការនៅក្នុងប្រទេសកម្ពុជា ។

គ. សិក្ខាកាម ក៏ទទួលបាននូវការយល់ដឹងពីការវិវឌ្ឍ តួនាទី និងភារកិច្ចរបស់សង្គមស៊ីវិល និងអង្គការសង្គមស៊ីវិលរួមទាំងអង្គការមិនមែនរដ្ឋាភិបាលផងដែរ ។

## កំណត់ចំណាំរបស់អ្នកសម្របសម្រួលៈ

នៅក្នុងមេរៀននេះ អ្នកសម្របសម្រួលមានគោលបំណងចំនួន ២

១. អធិប្បាយពីព្រឹត្តិការណ៍សំខាន់ៗនៃដំណើរការកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការក្នុងប្រទេសកម្ពុជា។ លើកឡើងនូវការយល់ដឹងដោយឆ្លុះបញ្ចាំងពីសមិទ្ធិផលជាច្រើន ដែលរដ្ឋាភិបាល និងសង្គមស៊ីវិលសម្រេចបានចាប់តាំងពីឆ្នាំ ១៩៩៣ ។

២.ទាញចំណាប់អារម្មណ៍របស់សិក្ខាកាម ឱ្យផ្តោតលើមេរៀនដែលនឹងត្រូវសម្របសម្រួលក្នុងរយៈពេល៣ថ្ងៃ។ ផ្តល់ជាឧទាហរណ៍ ពីការភ្ជាប់ការបណ្តុះបណ្តាលនៃថ្ងៃនីមួយៗ ទៅនឹងពេលវេលាដែលបានគ្រោងទុក ។

ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធដោយរដ្ឋបាលមូលដ្ឋាន និងការចូលរួមរបស់សហគមន៍



សហគមន៍ និងប្រជាពលរដ្ឋ ចូលរួមក្នុងដំណើរការវិមជ្ឈការ និងវិសហមជ្ឈការ



# មេរៀនទី ១ ឯកសារបង្ហាញ



ជំពូកទី១_មេរៀនទី១

## ប្រវត្តិដំណើរការវិមជ្ឈការ និងវិសហមជ្ឈការ

## គោលបំណងមេរៀនទី ១

១. រំលឹកឡើងវិញនូវព្រឹត្តិការណ៍សំខាន់ៗនៃដំណើរការកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ និងការចូលរួមរបស់អង្គការសង្គមស៊ីវិល

២. កំណត់ពីព្រឹត្តិការណ៍សំខាន់ៗ ទាក់ទងទៅនឹងការអនុម័តច្បាប់ គោលនយោបាយកំណែទម្រង់ ការបោះឆ្នោត និងស្ថាប័នថ្នាក់ក្រោមជាតិ និងបទពិសោធន៍ ។

## សំណួរបំផុសគំនិត

១. តើមានព្រឹត្តិការណ៍សំខាន់ៗអ្វីខ្លះ ទាក់ទងនឹងដំណើរការអភិវឌ្ឍលទ្ធិប្រជាធិបតេយ្យចាប់តាំងពីឆ្នាំ១៩៩៣មកដល់ពេលបច្ចុប្បន្ន?

២. តើមានព្រឹត្តិការណ៍សំខាន់ៗអ្វីខ្លះ ទាក់ទងនឹងការអភិវឌ្ឍន៍របស់សង្គមស៊ីវិល ឬអង្គការសង្គមស៊ីវិលចាប់តាំងពីឆ្នាំ១៩៩៣ មកដល់ពេលបច្ចុប្បន្ន ?






## ការពង្រឹងសមត្ថភាពអង្គការសហគមន៍មូលដ្ឋានរបស់អង្គការសង្គមស៊ីវិល



## ជំពូកទី១_មេរៀនទី១
## លំហូរពេលវេលានៃដំណើរការវិវឌ្ឍន៍វិមជ្ឈការ និងវិសហមជ្ឈការ

➢ **១៩៩៣ :** រដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា បានអនុម័តនៅ ថ្ងៃទី ២៤ កញ្ញា ១៩៩៣ ។

- **មាត្រា ៥១ (ប្រជាធិបតេយ្យសេរី អធិបតេយ្យភាព អំណាច)**

១. ព្រះរាជាណាចក្រកម្ពុជា អនុវត្តនយោបាយប្រជាធិបតេយ្យ សេរីពហុបក្ស ។ ប្រជាពលរដ្ឋខ្មែរជាម្ចាស់វាសនានៃប្រទេសជាតិរបស់ខ្លួន ។

២. អំណាចទាំងអស់ជារបស់ប្រជាពលរដ្ឋ ។ ប្រជាពលរដ្ឋប្រើអំណាចរបស់ខ្លួន តាមរយៈ រដ្ឋសភា ព្រឹទ្ធសភា រដ្ឋាភិបាល និងសាលាជំរះក្តី ។

៣. អំណាចបែងចែកដាច់ពីគ្នា រវាងអំណាចនីតិប្បញ្ញត្តិ អំណាចនីតិប្រតិបត្តិ និងអំណាចតុលាការ។

➢ **១៩៩៣ :** ការបោះឆ្នោតសភាជាតិ ត្រូវធ្វើឡើងរៀងរាល់៥ឆ្នាំម្តង ដូចដែលមានចែងនៅក្នុងរដ្ឋធម្មនុញ្ញ ។ ការបោះឆ្នោត ត្រូវបានប្រព្រឹត្តឡើង នៅក្នុងឆ្នាំ ១៩៩៨ ឆ្នាំ ២០០៣ និងពេលថ្មីៗបំផុតក្នុងឆ្នាំ ២០០៨។ ការបោះឆ្នោតសភាជាតិ លើកបន្ទាប់នឹងត្រូវប្រព្រឹត្តទៅ នៅក្នុងឆ្នាំ ២០១៣ ។

➢ **២០០១ :** រាជរដ្ឋាភិបាលកម្ពុជា បានចាប់ផ្តើមអនុវត្តគោលនយោបាយកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈ-ការលើកដំបូង នៅថ្នាក់ឃុំ សង្កាត់ ។

➢ **២០០១ :** ច្បាប់ស្តីពី ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និងច្បាប់ស្តីពីការបោះឆ្នោតឃុំ សង្កាត់ ត្រូវបានអនុម័ត ។

➢ **១៩ មីនា ២០០១ :** ច្បាប់ស្តីពី ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ។ រាជរដ្ឋាភិបាលកម្ពុជា បានចាប់ផ្តើមអនុវត្តគោលនយោបាយកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ របស់ខ្លួននៅថ្នាក់ឃុំ សង្កាត់ ។

➢ **២០០២ :** ប្រជាពលរដ្ឋបានបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាលើកដំបូងនៅក្នុងឃុំ សង្កាត់ចំនួន ១៦២១

នៅទូទាំងប្រទេស ។ ការបោះឆ្នោតឃុំ សង្កាត់ លើកទីពីរ ត្រូវបានធ្វើឡើងនៅក្នុងឆ្នាំ ២០០៧។ ការបោះឆ្នោតក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវធ្វើឡើងរៀងរាល់៥ឆ្នាំម្តង ។

➢ **២០០៤-២០០៨ :** យុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជា។ អភិបាលកិច្ចល្អ គឺជាសមាសធាតុស្នូល នៅក្នុងយុទ្ធសាស្ត្រចតុកោណ ។

- យុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជា ផ្តោតលើការប្រឆាំងអំពើពុករលួយ កំណែទម្រង់ច្បាប់ និងតុលាការ កំណែទម្រង់រដ្ឋបាលសាធារណៈ និងកំណែទម្រង់កងកំលាំងប្រដាប់អាវុធ ។
- នៅក្នុងកំណែទម្រង់រដ្ឋបាលសាធារណៈ រាជរដ្ឋាភិបាល ទទួលស្គាល់ថាវិមជ្ឈការ គឺជារឿងសំខាន់ដើម្បីពង្រឹងលទ្ធិប្រជាធិបតេយ្យ និងវិស័យទាំងអស់ សំដៅលើកកម្ពស់គុណភាពនៃការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋានដោយមានការចូលរួម។

➢ **១៧ មិថុនា ២០០៥ :** ក្របខ័ណ្ឌយុទ្ធសាស្ត្រ ស្តីពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ គឺជាឯកសារគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលណែនាំពីដំណើរការនៃកំណែទម្រង់អភិបាលកិច្ចនៅថ្នាក់ឃុំ សង្កាត់ ស្រុក ខណ្ឌ ខេត្ត ក្រុង ។

➢ **២០០៦-២០១០ :** ផែនការអភិវឌ្ឍន៍យុទ្ធសាស្ត្រជាតិ - ផែនការអភិវឌ្ឍន៍យុទ្ធសាស្ត្រជាតិ ក៏បានចាត់ទុកថាកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ គឺជាមធ្យោបាយមួយដើម្បីបង្កើន និងធ្វើឱ្យប្រសើរឡើងនូវការផ្តល់សេវាសាធារណៈ និងការពង្រឹងការអភិវឌ្ឍមូលដ្ឋាន (ទំព័រទី ៣៨) ។

➢ **២២ ឧសភា ២០០៨ :** ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ។

- **២៦ កញ្ញា ២០០៨ :** យុទ្ធសាស្ត្រចតុកោណដំណាក់កាលទីពីររបស់រាជរដ្ឋាភិបាលកម្ពុជា ។

- **២០០៨-២០១៣ :** យុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជាគឺ ដើម្បីសម្រេចឱ្យបាននូវអភិបាលកិច្ចល្អ យុទ្ធសាស្ត្រចតុកោណបានប្តេជ្ញាដើម្បីឱ្យរាជរដ្ឋាភិបាល ផ្តោតលើកំណែទម្រង់ចំនួនបួន គឺការប្រឆាំងអំពើពុករលួយ កំណែទម្រង់ច្បាប់ និងតុលាការ កំណែទម្រង់រដ្ឋបាលសាធារណៈ និងកំណែទម្រង់កងកំលាំងប្រដាប់អាវុធ ។ រាជរដ្ឋាភិបាលបានចាត់ទុក ការធ្វើវិមជ្ឈការគឺជាការសំខាន់ ដើម្បីពង្រឹងលទ្ធិប្រជាធិបតេយ្យ និងវិស័យទាំងអស់ សំដៅលើកកម្ពស់គុណភាពនៃការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋានដោយមានការចូលរួម ។

- **២៨ ឧសភា ២០១០ :** កម្មវិធីជាតិ សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិគឺជារបៀបវារៈរបស់រាជរដ្ឋាភិបាលកម្ពុជា សម្រាប់រយៈពេល១០ឆ្នាំខាងមុខ ។ កម្មវិធីនេះ ត្រូវបានបង្កើតឡើងដើម្បីសម្រេចឱ្យបាននូវការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ។

*** **លំហូរពេលវេលា :** ការចូលរួមចំណែករបស់អង្គការសង្គមស៊ីវិល ក្នុងដំណើរការកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ

បរិបទប្រទេសកម្ពុជា : ប្រវត្តិនៃសង្គមស៊ីវិល និងអង្គការមិនមែនរដ្ឋាភិបាលនៅក្នុងប្រទេសកម្ពុជា និងតួនាទីរបស់ខ្លួន ក្នុងដំណើរការអភិវឌ្ឍន៍ប្រទេសជាតិ ។

- **១៩៥៤-១៩៧០ :** បន្ទាប់ពីបានឯករាជ្យពីអាណានិគមបារាំង មិនមានភស្តុតាងបង្ហាញពីវត្តមានអង្គការមិនមែនរដ្ឋាភិបាលទេ តែសង្គមស៊ីវិលមានវត្តមានច្រើនទម្រង់។

- **១៩៧០-១៩៧៥ :** នៅក្នុងសង្គ្រាមសម័យលន់ណុលការផ្តល់ជំនួយរបស់អង្គការមិនមែរដ្ឋាបាលអន្តរជាតិដែលមាន រូបភាពជាការសង្គ្រោះជនដែលទទួលរងគ្រោះពីសង្គ្រាមត្រូវបានជំនួសមកវិញដោយការផ្តល់ជំនួយសម្រាប់ការអភិវឌ្ឍទ្វេភាគី ។

- **១៩៧៥-១៩៧៩ :** អំឡុងរបបខ្មែរក្រហម គេពុំឃើញមានវត្តមាននៃតំណាងអន្តរជាតិនៅក្នុងប្រទេសកម្ពុជាទេ លើកលែងតែតំណាងមកពីប្រទេសចិន និង ប្រទេសកូរ៉េខាងជើង ។

- **១៩៧៩-១៩៨២ :** បន្ទាប់ពីទទួលបានសេរីភាពពីរបបខ្មែរក្រហម មានបណ្តាអង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិជាច្រើន បានផ្តួចផ្តើមនូវកម្មវិធីសង្គ្រោះបន្ទាន់ ដោយប្រតិបត្តិការទាំងនៅក្នុងប្រទេសកម្ពុជា

និងនៅតាមបណ្ដោយព្រំដែនខ្មែរ_ថៃ ។

- មានការអនុវត្តន៍កម្មវិធីសង្គ្រោះបន្ទាន់ជាច្រើន ត្រូវបានគ្របដណ្តប់ស្ទើរតែគ្រប់វិស័យនៃសេដ្ឋកិច្ច និងសង្គមកិច្ច ដូចជាសុខាភិបាល ផលិតផលកសិកម្ម និងការដឹកជញ្ជូន ព្រមទាំងលើកទឹកចិត្តឱ្យមានកិច្ចសហការល្អ និងកិច្ចសហប្រតិបត្តិការ រវាងភ្នាក់ងារអង្គការសហប្រជាជាតិ កាកបាទក្រហមអន្តរជាតិ អង្គការមិនមែនរដ្ឋាបាល និងភ្នាក់ងាររដ្ឋាភិបាលនានា ។

➢ **ក្នុងឆ្នាំ១៩៨៦ :** អង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិនានា បានចាប់ផ្តើមយុទ្ធនាការតស៊ូមតិជាអន្តរជាតិសំដៅធ្វើ ឱ្យមានការផ្លាស់ប្តូរនៃការដាក់គំនាបនៃគោលនយោបាយបច្ចឹមប្រទេស ពីការបោះបង់ និងការហាមឃាត់ការផ្តល់ជំនួយដល់ប្រទេសកម្ពុជា។

➢ **១៩៨៧ :** ការផ្តល់ជំនួយទ្វេភាគី សម្រាប់ការសង្គ្រោះបន្ទាន់ ត្រូវបានផ្តល់តាមរយៈUNICEF, WFP, UNHCR, និង ICRC។ អង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិនានា ត្រូវបានបង្ខំចិត្តឱ្យផ្លាស់ប្តូរតួនាទីចំពោះការគាំទ្ររដ្ឋបាលថ្នាក់ ជាតិ ដែលធ្លាប់តែមានសមត្ថភាព ក្នុងការធ្វើការនៅថ្នាក់មូលដ្ឋាន។

➢ **១៩៨៨_១៩៩១ :** ការបង្កើនជំនួយទ្វេភាគី សម្រាប់សកម្មភាពមនុស្សធម៌ត្រូវបានធ្វើឡើងតាមរយៈអង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិ ដែលភាគច្រើនជាអង្គការដែលបានចេញពីព្រំដែនមកធ្វើការនៅក្នុងប្រទេសកម្ពុជា។ អង្គការទាំងនេះ បានពង្រីកវិសាលភាពគ្របដណ្តប់ការងាររបស់ខ្លួន និងការបោះទីតាំងដោយផ្អែកលើកត្តាភូមិសាស្ត្រក្នុងនោះរួមមានការផ្តល់វគ្គបណ្តុះបណ្តាលដល់ដៃគូអនុវត្តរបស់រដ្ឋាភិបាល ការធ្វើឱ្យមានការចូលរួមប្រកបដោយអត្ថន័យនៅក្នុងការកសាងផែនការ និងការអនុវត្តន៍កម្មវិធីហើយបានចាប់ផ្តើមងាកទៅរកតួនាទីដែលធ្លាប់ធ្វើកន្លងមកជាមួយសហគមន៍មូលដ្ឋានវិញ។ ម្ចាស់ជំនួយទ្វេភាគី និងពហុភាគីបានប្រើប្រាស់អង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិជំនួយឱ្យស្ថាប័នរបស់រដ្ឋាភិបាល។ ស្របពេលជាមួយគ្នានេះដែរ បណ្តាសហគមន៍អន្តរជាតិ និងអង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិនានាបានរួមចំណែកគាំទ្រដល់កិច្ចចរចារសន្តិភាពកម្ពុជា ដោយទទួលបានលទ្ធផលស្តីពីការចុះហត្ថលេខាស្តីពីកិច្ចព្រមព្រៀងទីក្រុងប៉ារីស ក្នុងខែ តុលា ឆ្នាំ ១៩៩១ ។

➢ **១៩៩២_១៩៩៧ :** អង្គការសហប្រជាជាតិ បានគ្រប់គ្រងការងារបោះឆ្នោតពហុបក្សដែលបានធ្វើឡើងក្នុងឆ្នាំ (១៩៩៣) ដោយទទួលបាននូវរដ្ឋាភិបាលចម្រុះ ការធ្វើសមាហរណកម្មប្រទេសកម្ពុជាឡើងវិញទៅ

ក្នុងសហគមន៍ពិភពលោក។ ប្រជាពលរដ្ឋខ្មែរជាច្រើន បានវិលត្រឡប់ពីជាយដែនខ្មែរ_ថៃមកកាន់មាតុភូមិរបស់ខ្លួន។ អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក បានលេចឡើង ហើយរីកសាយយ៉ាងលឿន ដោយមានការគាំទ្រពីម្ចាស់ជំនួយ និងតម្រូវការដើម្បីអនុវត្តនូវរបៀបវារៈនានារបស់ម្ចាស់ជំនួយនីមួយៗ។ ក្នុងអំឡុងពេលនោះ ការយល់ដឹងនៃសហគមន៍ ម្ចាស់ជំនួយ ស្តីពីសង្គមស៊ីវិល មានន័យថាជាអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ដែលទើបតែបង្កើតថ្មី ។

➢ **១៩៩៨_២០០៤ :** រាជរដ្ឋាភិបាលកម្ពុជា នីតិកាលទីពីរ ត្រូវបានបោះឆ្នោតជ្រើសរើស ហើយដោយមានការគាំទ្រពីសហគមន៍ម្ចាស់ជំនួយអន្តរជាតិផងនោះ បានធ្វើឱ្យរដ្ឋាភិបាលផ្តោតការយកចិត្តទុកដាក់យ៉ាងខ្លាំងលើរបៀបវារៈកំណែទម្រង់លើវិស័យជាច្រើន ដូចជា កំណែទម្រង់សេដ្ឋកិច្ច ការរំសាយកងទ័ព កំណែទម្រង់រដ្ឋបាល និង កំណែទម្រង់វិស័យសង្គមកិច្ច ។

# មេរៀនទី ១ ឯកសារផ្ទាំងរូបភាព





# សាវតាររដ្ឋបាលដែនដីនៅកម្ពុជា




ព្រះរាជាណាចក្រកម្ពុជាមានផ្ទៃដីសរុប១៨១.០៣៥គីឡូម៉ែត្រការ៉េ មានប្រជាជនសរុបចំនួន១៣.៣៩៥.៦៨២ នាក់( ស្រី៦.៨៧៩.៦២៨ នាក់ ស្មើនឹង៥១.៣៦%) និងមានដង់ស៊ីតេប្រជាជន៧៥នាក់ក្នុងមួយគីឡូម៉ែត្រការ៉េ ។ ប្រជាជនប្រមាណ៨៥%ជាកសិកររស់នៅពឹងផ្អែកលើវិស័យកសិកម្ម ដែលជាវិស័យមួយមានចំណែកប្រមាណ៣២.៤% នៃផលិតផលសរុបក្នុងស្រុកក្នុងឆ្នាំ២០០៨ និងជាមូលដ្ឋានបង្កើតការងារសម្រាប់ប្រជាជនជាង៧០% ។ ក្រៅពីវិស័យកសិកម្ម វិស័យផ្សេងៗទៀតជាពិសេសវិស័យកាត់ដេរ វិស័យទេសចរណ៍ និងសំណង់ បានជំរុញឱ្យសេដ្ឋកិច្ចកម្ពុជាមានការកើនឡើងក្នុងកម្រិតខ្ពស់ ក្នុងអត្រាមធ្យមប្រចាំឆ្នាំ ៩.៥%នៅក្នុងអំឡុងឆ្នាំ១៩៩៩-២០០៨។

រយៈពេល ១០ឆ្នាំនេះ ដោយផ្អែកលើសមិទ្ធផលដែលសម្រេចបានក្នុងរយៈពេល ១៥ឆ្នាំកន្លងមក។ ដោយប្រកាន់ខ្ជាប់នូវគោលការណ៍បោះជំហានទៅមុខជានិច្ច និងមានការគិតគូរច្បាស់លាស់ និងទទួលស្គាល់ថា ការអនុវត្តកម្មវិធីជាតិរយៈពេល១០ឆ្នាំអាចអនុវត្តជាក់ស្តែងបាន លុះត្រាតែមានការប្តេជ្ញាចិត្ត និងការគាំទ្រដ៏ទូលំទូលាយពីគ្រប់មជ្ឈដ្ឋាន និងពីគ្រប់ក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាល អាស្រ័យហេតុនេះ ការតាក់តែងកម្មវិធីជាតិនេះ បានជ្រើសរើសយកវិធីសាស្រ្តមួយ ដែលលើកទឹកចិត្តឱ្យមានការចូលរួមដ៏សកម្មពីតំណាងក្រសួង ស្ថាប័ន មន្ត្រីនៅថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិលនានា។

ក្នុងកិច្ចដំណើរការតាក់តែងកម្មវិធីជាតិក៏បានរៀបចំឱ្យមានកិច្ចពិភាក្សាដោយឡែកៗ ជាមួយក្រសួង ស្ថាប័នមួយចំនួនអំពីការផ្ទេរមុខងារ ធនធាន និងបុគ្គលិក។ កិច្ចប្រជុំជាមួយក្រសួងស្ថាប័នសំខាន់ៗ ត្រូវបានធ្វើឡើងទាំងមុន និងក្រោយកិច្ចពិភាក្សាក្នុងគោលបំណងកសាងនូវយុទ្ធសាស្រ្តដ៏សម្ថិតសម្រាប់កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការក្នុងវិស័យជាអាទិភាពបន្ថែមទៀត។

លទ្ធផលដែលទទួលបានពីការពិភាក្សាទាំងនេះ បានបង្កើតជាមូលដ្ឋានគ្រឹះមួយដ៏រឹងមាំសម្រាប់ការចាប់ផ្តើមអនុវត្តសកម្មភាពរៀបចំតាក់តែងកម្មវិធីជាតិនេះ។

***ប្រភពឯកសារ*** *: កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ២០១០-២០១៩ ( ទំព័រ ១-១២)*

**ផលិតដោយ** Pact Cambodia VBNK

**ឧបត្ថម្ភដោយ** THE WORLD BANK គជអប NCDD

រៀបចំអង្គការសម្រាប់រដ្ឋបាលឃុំ សង្កាត់។

ដូច្នេះចាប់ពីខែកុម្ភៈ ឆ្នាំ២០០២មក អភិបាលកិច្ចនៅថ្នាក់ឃុំ សង្កាត់ មានការកែសម្រួលជាច្រើន។ រដ្ឋបាល ដែលបានជ្រើសរើសឡើងតាមការបោះឆ្នោតនេះ គឺជាមធ្យោបាយសម្រាប់អនុវត្តការងារតាមរយៈការផ្ទេរភាពជាម្ចាស់ ពីរាជរដ្ឋាភិបាល ដើម្បីធានាឱ្យឃុំ សង្កាត់តំណាងឱ្យផលប្រយោជន៍សហគមន៍នៅមូលដ្ឋានរបស់ខ្លួនមានការឆ្លើយតប និង គណនេយ្យភាពចំពោះសហគមន៍នៅមូលដ្ឋាន។

ឯកសារគោលនយោបាយមួយចំនួនរបស់រាជរដ្ឋាភិបាលបានផ្តល់ជាមូលដ្ឋានដ៏សំខាន់ ក្នុងការកំណត់នូវចក្ខុវិស័យជាយុទ្ធសាស្រ្តសម្រាប់កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ។ រាជរដ្ឋាភិបាលបានប្តេជ្ញាចិត្តអនុវត្តគោលនយោបាយ អភិបាលកិច្ចល្អ ដោយបានដាក់ចេញនូវយុទ្ធសាស្រ្តចតុកោណដំណាក់កាលទី១ កាលពីឆ្នាំ ២០០៤ ក្នុងនោះរួមមាន កម្មវិធីកំណែទម្រង់សំខាន់ៗចំនួន៤ គឺ (១)ការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ (២)កំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ (៣)កំណែទម្រង់រដ្ឋបាលសាធារណៈ រួមទាំងវិមជ្ឈការ និងវិសហមជ្ឈការ និង (៤)កំណែទម្រង់កងកម្លាំងប្រដាប់អាវុធ ពិសេសកម្មវិធីកាត់បន្ថយទ័ព។

នៅខែមិថុនា ឆ្នាំ២០០៥ រាជរដ្ឋាភិបាលបានអនុម័តនូវក្របខ័ណ្ឌយុទ្ធសាស្រ្តស្តីពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ សំដៅបង្កើតឡើងនូវប្រព័ន្ធអភិបាលកិច្ចនៅថ្នាក់រដ្ឋបាលនានានៃរដ្ឋបាលថ្នាក់ក្រោមជាតិ ដោយឈរលើគោលការណ៍ពង្រឹង និងពង្រីកលទ្ធិប្រជាធិបតេយ្យនៅមូលដ្ឋាន ជំរុញកិច្ចអភិវឌ្ឍមូលដ្ឋាន និងកាត់បន្ថយភាពក្រីក្រ។

រាជរដ្ឋាភិបាលបានរៀបចំតាក់តែងកម្មវិធីជាតិសម្រាប់

យោងតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា កម្ពុជាជារដ្ឋទោលដែលមិនអាចបំបែកបាន។ មាត្រា១៤៥ថ្មី (មួយ) និងមាត្រា១៤៦ថ្មី (មួយ) នៃរដ្ឋធម្មនុញ្ញ បានកំណត់ពីការគ្រប់គ្រងរដ្ឋបាលដែនដីនៃព្រះរាជាណាចក្រកម្ពុជា ដោយចែកទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ជារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ និងសង្កាត់ ហើយរដ្ឋបាលដែនដីទាំងនេះ ត្រូវគ្រប់គ្រងតាមល័ក្ខខ័ណ្ឌដែលមានចែងក្នុងច្បាប់រៀបចំអង្គការមួយ។ មកដល់ចុងឆ្នាំ២០០៩ ព្រះរាជាណាចក្រកម្ពុជា រួមមានរាជធានីភ្នំពេញ និងខេត្តចំនួន២៣ ស្រុកចំនួន ១៥៩ ក្រុងចំនួន២៦ ខណ្ឌចំនួន៨ និងឃុំ សង្កាត់ចំនួន ១.៦២១។

មុនខែកុម្ភៈ ឆ្នាំ២០០២ រដ្ឋបាលនានានៃរដ្ឋបាលថ្នាក់ក្រោមជាតិ គឺជាអាជ្ញាធរដែលត្រូវបានតែងតាំងឡើង។ រដ្ឋបាលទាំងនេះបំពេញការងារក្នុងនាមរាជរដ្ឋាភិបាលក្នុងឋានៈជាទីភ្នាក់ងារ ដែលរាជរដ្ឋាភិបាលបានធ្វើប្រតិភូកម្មឱ្យ អនុវត្តសេចក្ដីសម្រេច សេចក្ដីណែនាំ និងគោលនយោបាយនានារបស់រាជរដ្ឋាភិបាល។ មន្ទីរខ្សែបណ្ដោយរបស់ក្រសួង ស្ថាប័ននានា ត្រូវបានដាក់ពង្រាយចាប់ពីរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដើម្បីអនុវត្តសេចក្ដីសម្រេច សេចក្ដីណែនាំ និង គោលនយោបាយរបស់ក្រសួង ស្ថាប័នសាមី។ ក្នុងប្រព័ន្ធនេះ រាជរដ្ឋាភិបាលបានរក្សាទុកភាពជាម្ចាស់ និងការទទួលខុសត្រូវចំពោះមុខងារដែលបានធ្វើប្រតិភូកម្មឱ្យរដ្ឋបាលនៅថ្នាក់ក្រោមជាតិ ឬមន្ទីរខ្សែបណ្ដោយ។ ប្រតិភូកម្មនេះ អមជាមួយទៅដោយសេចក្ដីណែនាំ និងការត្រួតពិនិត្យយ៉ាងល្អិតល្អន់។ ប្រព័ន្ធនេះ រដ្ឋបាលនៃរដ្ឋបាលថ្នាក់ក្រោមជាតិ មានការឆ្លើយតប និងគណនេយ្យភាពពីក្រោមឡើងលើមករាជរដ្ឋាភិបាលចំពោះអ្វីដែលរដ្ឋបាលថ្នាក់ក្រោមជាតិបានអនុវត្តអំណាច ដែលបានផ្ទេរ ប្រតិភូកម្ម។

ដូច្នេះ រហូតមកដល់មុនឆ្នាំ២០០២ រដ្ឋបាលថ្នាក់ក្រោមជាតិមានតែមួយប្រភេទនេះប៉ុណ្ណោះ។ កម្ពុជាចាត់ទុកអភិបាលកិច្ចនេះថាជា វិសហមជ្ឈការ។ វិសហមជ្ឈការនៅកម្ពុជាបានចាក់ឫសយ៉ាងជ្រៅ ព្រោះអភិបាលកិច្ចនេះ បានអនុវត្តនៅពេលមិនទាន់មានអាជ្ញាធរ ដែលត្រូវបានបោះឆ្នោតជ្រើសរើសឡើងនៅថ្នាក់ក្រោមជាតិ។

ខែមីនា ឆ្នាំ២០០១ ច្បាប់រៀបចំអង្គការ មានច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និងច្បាប់ស្ដីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវបានអនុម័ត។ តាមរយៈច្បាប់នេះ ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវបានធ្វើឡើងដោយជោគជ័យនាខែ កុម្ភៈ ឆ្នាំ២០០២ហើយបានបង្កើតជាអាជ្ញាធរមូលដ្ឋានយ៉ាងសំខាន់។ រាជរដ្ឋាភិបាលកម្ពុជាបានកំណត់គោលនយោបាយថ្មីនេះថាជា វិមជ្ឈការ និងវិសហមជ្ឈការ ដូចដែលបានកំណត់នៅក្នុងច្បាប់



# មេរៀនទី ១ ប្លង់មេរៀន



## ជំពូកទី១_មេរៀនទី១

## ចំណងជើងមេរៀនៈ ប្រវត្តិកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ

**ពេលវេលា : ៦០នាទី**

**របៀបសម្របសម្រួលមេរៀន**

| រយៈពេល | សកម្មភាព និង វិធីសាស្ត្រ | សម្ភារៈ/ឯកសារចែក |
|---|---|---|
| (១០នាទី) | **សកម្មភាពទី១ : សេចក្តីណែនាំ និងគោលបំណងរបស់មេរៀន**<br>• សិក្ខាកាមភាគច្រើន គឺយល់ច្បាស់ពីភាពរីកចំរើននៃអភិបាលកិច្ចល្អ និង វិមជ្ឈការនៅប្រទេសកម្ពុជា<br>• មេរៀនថ្ងៃនេះ នឹងរៀបរាប់នូវប្រវត្តិសង្ខេបអំពីការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ និងដំណើរការកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការនៅក្នុងប្រទេសកម្ពុជា<br>• **បង្ហាញពីគោលបំណងរបស់មេរៀន :**<br>១.រំលឹកឡើងវិញនូវព្រឹត្តិការណ៍សំខាន់ៗនៃដំណើរការកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ និងការចូលរួមរបស់អង្គការសង្គមស៊ីវិល។<br>២.កំណត់ពីព្រឹត្តិការណ៍សំខាន់ៗ ទាក់ទងទៅនឹងការអនុម័តច្បាប់ គោលនយោបាយកំណែទម្រង់ការបោះឆ្នោត និងស្ថាប័នថ្នាក់ក្រោមជាតិ និងបទពិសោធន៍។ | ឯកសារបញ្ចាំង ស្តីពីគោលបំណង និងប៉ុស្ទ័រផ្ទាំងធំទី២ ស្តីពីដំណើរការវិវឌ្ឍ នៃលទ្ធិប្រជាធិប្បតេយ្យ និងការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ |

| | | |
|---|---|---|
| | ការបោះឆ្នោត និងស្ថាប័នថ្នាក់ក្រោមជាតិ និងចំណេះដឹងបទពិសោធន៍នានា | |
| (២០ នាទី) | **<u>សកម្មភាពទី២:</u> ការបំផុសគំនិតអំពីប្រវត្តិ និងភាពរីកចំរើននៃលទ្ធិប្រជាធិបតេយ្យ**<br>• បែងចែកសិក្ខាកាម ៣នាក់ក្នុង១ក្រុមដើម្បីពិភាក្សាលើសំណួរ ចំនួន២ ដូចខាងក្រោម:<br>១,តើមានព្រឹត្តិការណ៍សំខាន់ៗអ្វីខ្លះដែលទាក់ទងនឹងដំណើរការវិវឌ្ឍន៍នៃលទ្ធិប្រជាធិបតេយ្យចាប់ពីឆ្នាំ ១៩៩៣ មកដល់ពេលបច្ចុប្បន្ន?<br>**<u>បញ្ជាក់:</u>** ស្នើឱ្យក្រុមនីមួយៗ កត់ត្រាទៅក្នុងសៀវភៅអំពីព្រឹត្តិការណ៍សំខាន់ៗ ទាក់ទងនឹងដំណើរការវិវឌ្ឍន៍នៃលទ្ធិប្រជាធិបតេយ្យចាប់ពីឆ្នាំ១៩៩៣ មកដល់ពេលបច្ចុប្បន្ន?។ ( ៣នាទី)<br>២, តើមានព្រឹត្តិការណ៍សំខាន់ៗអ្វីខ្លះជាប់ទាក់ទងទៅនឹងការវិវឌ្ឍ របស់អង្គការសង្គមស៊ីវិលចាប់ពីឆ្នាំ ១៩៩៣ មកដល់នឹងបច្ចុប្បន្ន។<br>**<u>បញ្ជាក់:</u>** សូមឱ្យក្រុមនីមួយៗ កត់ត្រានូវព្រឹត្តការណ៍សំខាន់ៗ ទាក់ទងនឹងការវិវឌ្ឍនៃអង្គការសង្គមស៊ីវិលចាប់ពីឆ្នាំ១៩៩៣ មកដល់ពេលបច្ចុប្បន្ន ។(៣ នាទី) | |

| | | |
|---|---|---|
| (២៥នាទី) | **សកម្មភាពទី៣: បទបង្ហាញ (មើលឯកសារចែកជូន) ប្រវត្តិកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ**<br>• បទបង្ហាញអំពីប្រវត្តិកំណែទម្រង់វិជ្ឈការ និង វិសហមជ្ឈការនៅប្រទេសកម្ពុជា<br>• បង្ហាញពីដំណើរការវិវឌ្ឍន៍នៃព្រឹត្តិការណ៍សំខាន់ៗ និង ការផ្លាស់ប្តូរពីឆ្នាំ១៩៩៣មកដល់បច្ចុប្បន្ន ដោយការឆ្លុះបញ្ចាំងតាមឆ្នាំ និងសួរសំណួរទៅអ្នកចូលរួមតើមានព្រឹត្តិការណ៍អ្វីខ្លះ? បញ្ជាក់ឱ្យច្បាស់ជាមួយនឹងសិក្ខាមផ្សេងទៀត - តើអ្នកដឹងច្បាប់ស្តីពីព្រឹត្តិការណ៍នេះដែរឬទេ? តើមានអ្វីកើតឡើងបន្ទាប់ទៀត?<br>• សួរសិក្ខាកាមបន្ទាប់ពីបង្ហាញចប់ស្វាយ ថាតើមានព្រឹត្តិការណ៍សំខាន់ៗអ្វីដែលមិនបានបង្ហាញ? | បទបង្ហាញពេលវេលានៃវិជ្ឈការ និងវិសហមជ្ឈការ និងប៉ុស្ទ័រផ្ទាំងធំទី២ ស្តីពីដំណើរការវិវឌ្ឍនៃលទ្ធិប្រជាធិបតេយ្យ និងការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅប្រទេសកម្ពុជា |
| (៥ នាទី) | **សកម្មភាពទី៤: សេចក្តីសន្និដ្ឋានមេរៀន**<br>១) សង្ខេបនូវព្រឹត្តិការណ៍សំខាន់ៗ នៃដំណើរការកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ។<br>២) សង្ខេបពីព្រឹត្តការណ៍សំខាន់ៗ នៃការចូលរួមរបស់អង្គការសង្គមស៊ីវិលក្នុងដំណើការកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ។<br>៣) ពន្យល់ថា ក្នុងរយៈពេលបណ្តុះបណ្តាលចំនួន ៣ថ្ងៃនេះ នឹងបន្តស្វែងយល់បន្ថែមទៀតពីការវិវឌ្ឍនៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ហើយយើងនឹងផ្តោតទៅលើកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែប | |

| | | |
|---|---|---|
| | ប្រជាធិបតេយ្យនៅថ្នាក់ ក្រោមជាតិ និងផែនការគាំទ្រការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ។ | |

**សម្ភារៈបង្រៀន ៖**

- ឯកសារចែកជូន ៖

  - លំហូរពេលវេលានៃដំណើរការកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ

  - សាវតាររដ្ឋបាលដែនដីនៅកម្ពុជា

- ហ្វីតសរសេរក្រដាស ក្រដាសផ្ទាំងធំ ស្កុតក្រដាស កាតពណ៌

- ស្លាយបទបង្ហាញ

- រូបភាពបង្ហាញពី ដំណើរការវិវឌ្ឍ នៃលទ្ធិប្រជាធិប្បតេយ្យ និងការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅប្រទេសកម្ពុជា

**ឯកសារយោង ៖**

- ឯកសារកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ជំពូកទី១ ទំព័រ ២_១៥

- ក្របខ័ណ្ឌយុទ្ធសាស្ត្រ សម្រាប់កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ២០០៥_២០០៩ របស់រាជរដ្ឋាភិបាល កម្ពុជា ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០០៥

# មេរៀនទី២

## អភិបាលកិច្ច និងទស្សនទានកំណែទម្រង់
## វិមជ្ឈការ និងវិសហមជ្ឈការ

# មេរៀនទី ២ អភិបាលកិច្ច និងទស្សនទានកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ



**គោលបំណង** : នៅចុងបញ្ចប់មេរៀននេះ អ្នកចូលរួមនឹងអាច :

១. កំណត់អត្ថន័យ អភិបាលកិច្ច អភិបាលកិច្ចល្អ វិមជ្ឈការ និងវិសហមជ្ឈការ

២. ពន្យល់ពីមូលហេតុនៃការធ្វើកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ

៣. ពិពណ៌នាអំពីគោលដៅ និងមូលដ្ឋានគ្រឹះនៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ

## លទ្ធផលរំពឹងទុកនៃមេរៀនៈ

ក. សិក្ខាកាមមានការយល់ដឹងពីអត្ថន័យអភិបាលកិច្ច អភិបាលកិច្ចល្អ វិមជ្ឈការ និងវិសហមជ្ឈការនិងភាពចាំបាច់នៃការភ្ជាប់ទំនាក់ទំនងជាមួយការអនុវត្តកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។

ខ. សិក្ខាកាមកាន់តែមានទំនុកចិត្ត លើដំណើរការនៃការអនុវត្តក្របខ័ណ្ឌយុទ្ធសាស្ត្រនៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ និងត្រៀមខ្លួនចូលរួមចំណែកអនុវត្តកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យថ្នាក់ក្រោមជាតិអោយបានល្អប្រសើរ។

## កំណត់ចំណាំរបស់អ្នកសម្របសម្រួលៈ

នៅក្នុងមេរៀននេះ អ្នកសម្របសម្រួលមានគោលបំណងចំនួន ៣

១. ជួយឱ្យសិក្ខាកាមមើលឃើញកាន់តែច្បាស់អំពីអភិបាលកិច្ច អភិបាលកិច្ចល្អ វិមជ្ឈការ និងវិសហមជ្ឈការ ។

២. ជួយឱ្យសិក្ខាកាមបានដឹងថារាជរដ្ឋាភិបាលបានធ្វើកំណែទម្រង់ វិមជ្ឈការ និង វិសហមជ្ឈការ ចាប់ពីឆ្នាំ ២០០២ និងបានបង្កើតក្របខ័ណ្ឌយុទ្ធសាស្ត្រកំណែទម្រង់ស្តីពីវិមជ្ឈការ និងវិសហមជ្ឈការនៅឆ្នាំ ២០០៥។

៣. ជួយឱ្យសិក្ខាកាមលើកឡើងនូវបទពិសោធន៍ជាក់ស្តែងដែលបានអនុវត្តកន្លងមក ។

# មេរៀនទី ២ ឯកសារបង្ហាញ

ជំពូកទី១_មេរៀនទី២

## អភិបាលកិច្ច និងទស្សនទានកំណែទម្រង់ វិមជ្ឈការ និងវិសហមជ្ឈការ

1

## គោលបំណងមេរៀន

១. កំណត់បានអត្ថន័យអភិបាលកិច្ច អភិបាលកិច្ចល្អ វិមជ្ឈការ និងវិសហមជ្ឈការ

២. ពន្យល់ពីមូលហេតុនៃការធ្វើកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ

៣. ពិពណ៌នាអំពីគោលដៅ និងមូលដ្ឋានគ្រឹះនៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ

2

## សំនួរសម្រាប់ក្រុមពិភាក្សា

១. តើអ្វីជាអភិបាលកិច្ច?

២. តើអ្វីជាអភិបាលកិច្ចល្អ? តើគោលការណ៍អភិបាលកិច្ចល្អមានអ្វីខ្លះ? ហើយធ្វើការរៀបរាប់ដោយសង្ខេបនូវសកម្មភាពដែលបានអនុវត្តទាក់ទងនឹងអភិបាលកិច្ចល្អ នៅក្នុងប្រទេសកម្ពុជា ។

3

## អភិបាលកិច្ច

អ្វីទៅជាអភិបាលកិច្ច?



**អភិបាលកិច្ច** គឺជាវិធីសាស្ត្រដែលរដ្ឋ ស្ថាប័ន អង្គភាព ប្រើប្រាស់ក្នុងការគ្រប់គ្រងសេដ្ឋកិច្ច សង្គមកិច្ច និង សន្តិសុខ ដើម្បីបំរើផលប្រយោជន៍រួមរបស់ ប្រជាពលរដ្ឋ។

4

# អ្វីជាអភិបាលកិច្ចល្អ?

**អភិបាលកិច្ចល្អ** ជាវិធីសាស្ត្រ ឬមធ្យោបាយដែលរដ្ឋ ស្ថាប័ន អង្គភាពប្រើប្រាស់ ក្នុងការគ្រប់គ្រងសេដ្ឋកិច្ច សង្គមកិច្ច និងសន្តិសុខ ដើម្បីបំរើផលប្រយោជន៍រួមរបស់ប្រជាពលរដ្ឋ ដោយបំពេញបាននូវ គោលការណ៍ចំនួន៨




5




6

## សំនួរសម្រាប់ពិភាក្សាជាក្រុម

១. តើវិមជ្ឈការមានន័យយ៉ាងដូចម្តេច?

២. តើវិសហមជ្ឈការមានន័យយ៉ាងដូចម្តេច?

7

## វិមជ្ឈការ

វិមជ្ឈការ មានន័យថា **រាជរដ្ឋាភិបាលប្រគល់នូវភាពជាម្ចាស់លើមុខងារ សិទ្ធិអំណាច ការទទួលខុសត្រូវ និងធនធាន** ***(ហិរញ្ញវត្ថុ ទ្រព្យសម្បត្តិ និង បុគ្គលិក)*** **ឱ្យទៅក្រុមប្រឹក្សាថ្នាក់ក្រោមជាតិ** ដូចជា ក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់ ត្រូវមាន គណនេយ្យភាពចំពោះប្រជាពលរដ្ឋ នៅ**មូលដ្ឋាន**។

8

# វិសហមជ្ឈការ

វិសហមជ្ឈការ មានន័យថា រាជរដ្ឋាភិបាល ឬក្រសួងស្ថាប័ន **ផ្ទេរប្រតិភូកម្មមុខងារ សិទ្ធិអំណាច និងធនធាន (ហិរញ្ញវត្ថុ ទ្រព្យសម្បត្តិ និងបុគ្គលិក) ទៅអង្គភាពក្រោមបង្គាប់** ឬទៅក្រុមប្រឹក្សាប្រភេទណាមួយ ដើម្បីអនុវត្តមុខងារ នោះក្នុងនាមរាជរដ្ឋាភិបាល ក្រសួង ឬស្ថាប័ននោះ។ ក្នុងន័យនេះ ភាពជាម្ចាស់មិនបានផ្តល់ជូនអង្គភាពក្រោមបង្គាប់ ឬ ក្រុមប្រឹក្សាឡើយ។ រាជរដ្ឋាភិបាល ឬ ក្រសួង ស្ថាប័ន នៃរាជរដ្ឋាភិបាលបានរក្សាទុកនូវភាពជាម្ចាស់នោះ។

9

# គោលការណ៍កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ

កំណែទម្រង់នឹងពង្រឹង តួនាទីរបស់ក្រុមប្រឹក្សាតាមថ្នាក់រដ្ឋបាលខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ ដែលបង្កើតឡើងតាមគោលការណ៍ នៃលទ្ធិប្រជាធិបតេយ្យសេរី ដោយពង្រីកអំណាច ភារកិច្ច ទទួលខុសត្រូវ និងធនធាន




10


គោលការណ៍កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ
ភាពជាតំណាង តាមលទ្ធិ ប្រជាធិបតេយ្យ
ការចូលរួម របស់ ប្រជាពលរដ្ឋ
គោលការណ៍ជាមូលដ្ឋានសម្រាប់កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ
ការផ្តោតទៅលើ ការកាត់បន្ថយ ភាពក្រីក្រ
គណនេយ្យភាព នៃវិស័យ សាធារណៈ
ប្រសិទ្ធភាព
កំណែទម្រង់ នឹងរៀបចំប្រព័ន្ធ និងទម្រង់ការនានាសម្រាប់ ប្រជាពលរដ្ឋ ពិសេសស្ត្រី និងក្រុមជនងាយរងគ្រោះ ក្រុមជនជាតិដើមភាគតិច អាចចូលក្នុងការធ្វើសេចក្តីសម្រេចចិត្ត នៅតាមបណ្តាថ្នាក់ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ ។
11


គោលការណ៍កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ
ភាពជាតំណាង តាមលទ្ធិ ប្រជាធិបតេយ្យ
ការចូលរួម របស់ ប្រជាពលរដ្ឋ
គោលការណ៍ជាមូលដ្ឋានសម្រាប់កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ
ការផ្តោតទៅលើ ការកាត់បន្ថយ ភាពក្រីក្រ
គណនេយ្យភាព នៃវិស័យ សាធារណៈ
ប្រសិទ្ធភាព
កំណែទម្រង់នឹងពង្រឹង គណនេយ្យភាព នៅគ្រប់លំដាប់ថ្នាក់រដ្ឋបាល និង សម្រួលការ ចូលរួមពិនិត្យមើលរបស់ប្រជាពលរដ្ឋក្នុង កិច្ចការរដ្ឋបាល និងហិរញ្ញវត្ថុ
12


គោលការណ៍កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ
ភាពជាតំណាង តាមលទ្ធិ ប្រជាធិបតេយ្យ
ការចូលរួម របស់ ប្រជាពលរដ្ឋ
គោលការណ៍ជាមូលដ្ឋានសម្រាប់កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ
ការផ្តោតទៅលើ ការកាត់បន្ថយ ភាពក្រីក្រ
គណនេយ្យភាព នៃវិស័យ សាធារណ :
ប្រសិទ្ធភាព
សេវាសាធារណៈបានឆ្លើយតបទៅនឹងតម្រូវការ និងអាទិភាពរបស់មូលដ្ឋាន។ ទន្ទឹមនេះកំណែទម្រង់នឹងកែលម្អប្រព័ន្ធរដ្ឋបាល និងការងារ សម្របសម្រួល និងពង្រឹងសមត្ថភាព គ្រប់គ្រងរបស់ថ្នាក់ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ ដើម្បីលើកកម្ពស់ គុណភាពសេវា ព្រមទាំងពង្រីកការងារ ផ្តល់សេវាសាធារណៈឱ្យបានទូលំទូលាយ ។
13


គោលការណ៍កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ
កំណែទម្រង់នេះនឹងពង្រឹងសមត្ថភាពរបស់មូលដ្ឋាន ក្នុងការប្រើប្រាស់ធនធានសម្រាប់ គាំទ្រដល់សកម្មភាពកាត់បន្ថយភាពក្រីក្រ ពិសេសក្រុមជនងាយរងគ្រោះ ក្រុមជនជាតិ ដើមភាគតិច ស្ត្រី និង កុមារ ដើម្បីឈានទៅសម្រេចគោលដៅអភិវឌ្ឍន៍សហសវត្សរ៍របស់កម្ពុជា។
ភាពជាតំណាង តាមលទ្ធិ ប្រជាធិបតេយ្យ
ការចូលរួម របស់ ប្រជាពលរដ្ឋ
គោលការណ៍ជាមូលដ្ឋានសម្រាប់កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ
ការផ្តោតទៅលើ ការកាត់បន្ថយ ភាពក្រីក្រ
គណនេយ្យភាព នៃវិស័យ សាធារណ :
ប្រសិទ្ធភាព
14

## សំនួរសម្រាប់ពិភាក្សាជាគូ

**តើហេតុអ្វីចាំបាច់ត្រូវធ្វើកំណែទម្រង់វិមជ្ឈការ និង វិសហមជ្ឈការ?**

15

## ភាពចាំបាច់ត្រូវធ្វើកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ

### មូលហេតុនៃការអនុវត្តកំណែទម្រង់

- បង្កើនការចូលរួមរបស់ប្រជាពលរដ្ឋក្នុងការធ្វើ សេចក្តីសម្រេចចិត្ត
- បង្កើនប្រសិទ្ធភាពនិងការផ្តល់សេវាកម្មសាធារណៈ ឱ្យកាន់តែជិតដល់ប្រជាពលរដ្ឋ
- បង្កើនលទ្ធភាពក្នុងការកៀរគរធនធានពីប្រជាពលរដ្ឋ សង្គមស៊ីវិល និងឯកជន

Reference - Key principles for management of Sub-National Administrations by MOI Jun09,p7

### គោលដៅនៃការអនុវត្តកំណែទម្រង់

- ពង្រឹង និងពង្រីកលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស នៅថ្នាក់មូលដ្ឋាន
- ការកាត់បន្ថយភាពក្រីក្រ
- ជំរុញកិច្ចអភិវឌ្ឍនៅមូលដ្ឋាន
- Reference - Key principles for management of Sub-National Administrations by MOI Jun09,p8

16

## សំនួរសម្រាប់បំផុសគំនិត

**តើមានក្របខ័ណ្ឌគោលនយោបាយ និងក្របខ័ណ្ឌច្បាប់អ្វីខ្លះ សម្រាប់គាំទ្រដល់ការអនុវត្ត កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ?**

17

## ក្របខណ្ឌគោលនយោបាយ និងក្របខណ្ឌច្បាប់សម្រាប់គាំទ្រ ដល់ការអនុវត្តកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ

### ក្របខ័ណ្ឌនយោបាយ

- យុទ្ធសាស្ត្រចតុកោណ
- ក្របខ័ណ្ឌយុទ្ធសាស្ត្រស្តីពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ

### ក្របខ័ណ្ឌច្បាប់

- ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

18

មេរៀនទី ២ ឯកសារសម្រាប់ចែក



# ជំពូកទី១_មេរៀនទី២
# អភិបាលកិច្ច និងទស្សនទាននៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ

**មាតិកា**


សេចក្តីផ្តើម
១. អ្វីជាអភិបាលកិច្ច?
២. អ្វីជាអភិបាលកិច្ចល្អ?
៣. តើវិមជ្ឈការមានន័យយ៉ាងដូចម្តេច?
៤. តើវិសហមជ្ឈការមានន័យយ៉ាងដូចម្តេច?
៥. គោលការណ៍ជាមូលដ្ឋានសម្រាប់កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ
៦. តើហេតុអ្វីចាំបាច់ត្រូវធ្វើកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ?
៧. តើមានក្របខ័ណ្ឌគោលនយោបាយ និងក្របខ័ណ្ឌច្បាប់អ្វីខ្លះសម្រាប់គាំទ្រដល់ការអនុវត្តកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ?

## សេចក្ដីផ្ដើម

អភិបាលកិច្ចល្អជាផ្នែកមួយយ៉ាងសំខាន់ក្នុងការជំរុញ និងគាំទ្រដំណើរការនៃការគ្រប់គ្រងធនធានរបស់ស្ថាប័ន អង្គភាព និងការអភិវឌ្ឍមួយប្រកបដោយនិរន្តរភាព។ ដោយមើលឃើញពីសារៈសំខាន់ នៃអភិបាលកិច្ចល្អ យើងបានរៀបចំ និងចងក្រងមេរៀននេះឡើង ដើម្បីស្វែងយល់ពីការអនុវត្តអភិបាលកិច្ចល្អនៅក្នុងក្របខ័ណ្ឌយុទ្ធសាស្ត្រ ស្ដីពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ និងកម្មវិធីជាតិសម្រាប់ ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ។

### ១. អ្វីជាអភិបាលកិច្ច?

អភិបាលកិច្ច គឺជាវិធីសាស្ត្រដែលរដ្ឋស្ថាប័នអង្គភាពប្រើប្រាស់ក្នុងការគ្រប់គ្រងសេដ្ឋកិច្ច សង្គមកិច្ច និងសន្តិសុខដើម្បីបំរើផលប្រយោជន៍រួមរបស់ប្រជាពលរដ្ឋ។

### ២. អ្វីជាអភិបាលកិច្ចល្អ?

អភិបាលកិច្ចល្អ ជាវិធីសាស្ត្រ ឬមធ្យោបាយដែលរដ្ឋ ស្ថាប័ន អង្គភាពប្រើប្រាស់ក្នុងការគ្រប់គ្រងសេដ្ឋកិច្ច សង្គមកិច្ច និងសន្តិសុខ ដើម្បីបំរើផលប្រយោជន៍រួមរបស់ប្រជាពលរដ្ឋ ដោយបំពេញបាននូវគោលការណ៍ចំនួន៨ រួមមាន (១)ការចូលរួម (២)នីតិរដ្ឋ (៣)តម្លាភាព (៤)ការព្រមព្រៀងឯកភាពគ្នា (៥)សមធម៌ (៦)ប្រសិទ្ធភាពខ្ពស់(៧) គណនេយ្យភាព និង (៨)ការឆ្លើយតប ។

អភិបាលកិច្ចល្អ គឺជាស្នូលនៃយុទ្ធសាស្ត្រចតុកោណ (ដំណាក់កាលទី១ និង ដំណាក់កាលទី២) របស់រាជរដ្ឋាភិបាល ដែលត្រូវបានទទួលស្គាល់ជាបុរេលក្ខណៈសំខាន់បំផុតសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាពមានសមធម៌ និងយុត្តិធម៌ ។ ដើម្បីសម្រេចបាននូវគោលបំណងនេះ រាជរដ្ឋាភិបាលបានផ្ដោតការយក ចិត្តទុកដាក់ទៅលើការអនុវត្តប្រកបដោយប្រសិទ្ធភាពនូវផែនការអភិបាលកិច្ចរបស់ខ្លួន ដែលគ្រប ដណ្ដប់ទៅលើកំណែទម្រង់លើវិស័យចំនួនបួនដែលមានការពាក់ព័ន្ធគ្នាទៅវិញទៅមករួមមាន

- ការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ
- កំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌
- កំណែទម្រង់រដ្ឋបាលសាធារណៈ (រួមមានវិមជ្ឈការ និងវិសហមជ្ឈការ ) និង
- កំណែទម្រង់កងកម្លាំងប្រដាប់អាវុធ

**ចំណាំ :** នៅក្នុងកំណែទម្រង់រដ្ឋបាលសាធារណៈ រាជរដ្ឋាភិបាលចាត់ទុកថាកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ មានសារៈសំខាន់ចំពោះការ កែលម្អគុណភាពនៃសេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋានដោយមានការចូលរួម។

## ៣. តើវិមជ្ឈការមានន័យយ៉ាងដូចម្ដេច?

វិមជ្ឈការ មានន័យថា រាជរដ្ឋាភិបាលប្រគល់នូវភាពជាម្ចាស់លើមុខងារ សិទ្ធិអំណាច ការទទួល ខុសត្រូវ និងធនធាន (ហិរញ្ញវត្ថុ ទ្រព្យសម្បត្តិ និងបុគ្គលិក) ឱ្យទៅក្រុមប្រឹក្សាថ្នាក់ក្រោមជាតិ ដូចជា ក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់ ដើម្បីឆ្លើយតបទៅនឹងតម្រូវការមូលដ្ឋាន។

## ៤. តើវិសហមជ្ឈការមានន័យយ៉ាងដូចម្ដេច?

វិសហមជ្ឈការមានន័យថា រាជរដ្ឋាភិបាល ឬក្រសួងស្ថាប័ន ធ្វើប្រតិភូកម្មមុខងារ សិទ្ធិអំណាច និងធនធាន (ហិរញ្ញវត្ថុ ទ្រព្យសម្បត្តិ និងបុគ្គលិក) ទៅអង្គភាពក្រោមបង្គាប់ ឬទៅក្រុមប្រឹក្សាប្រភេទណាមួយ ដើម្បីអនុវត្តមុខងារនោះ ក្នុងនាមរាជរដ្ឋាភិបាល ក្រសួង ឬស្ថាប័ននោះ។ ក្នុងន័យនេះ ភាពជាម្ចាស់មិនបានផ្ដល់ជូនអង្គភាពក្រោមបង្គាប់ ឬក្រុមប្រឹក្សាឡើយ។ រាជរដ្ឋាភិបាល ឬក្រសួង ស្ថាប័ននៃរាជរដ្ឋាភិបាលបានរក្សាទុកនូវភាពជាម្ចាស់នោះ។

**សម្រាប់អ្នកសម្របសម្រួល :** វិសហមជ្ឈការមានន័យថា :

- ថ្នាក់ជាតិប្រតិភូកម្មមុខងារទៅឱ្យថ្នាក់ក្រោមជាតិ
- ថ្នាក់ក្រោមជាតិអនុវត្តមុខងារក្នុងនាមថ្នាក់ជាតិ

• **ប្រតិភូកម្ម :** (គឺជាការផ្ទេរនូវមុខងារ ការទទួលខុសត្រូវអំណាច និងឆន្ទានុសិទ្ធិ ដើម្បីគ្រប់គ្រង និងអនុវត្តមុខងារក្នុងនាមអាជ្ញាធរដែលបានធ្វើប្រតិភូកម្មនៅតែរក្សាភាពជាម្ចាស់លើកិច្ចការដែលបានធ្វើប្រតិភូកម្ម។)

**ឧទាហរណ៍**

- ក្រុមប្រឹក្សាឃុំ សង្កាត់ចុះបញ្ជីអត្រានុកូលដ្ឋាន (ធ្វើក្នុងនាមក្រសួងមហាផ្ទៃ)
- ក្រុមប្រឹក្សាឃុំ សង្កាត់ធ្វើបច្ចុប្បន្នភាពបញ្ជីឈ្មោះអ្នកបោះឆ្នោត (ធ្វើក្នុងនាមគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត) ។

**៥. គោលការណ៍ជាមូលដ្ឋានសម្រាប់កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ**

កំណែទម្រង់ប្រព័ន្ធគ្រប់គ្រងនៅថ្នាក់រដ្ឋបាលខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ មានគោលដៅជាយុទ្ធសាស្ត្រពីរយ៉ាងគឺ (១)ការពង្រឹង និងពង្រីកលទ្ធិប្រជាធិបតេយ្យនៅមូលដ្ឋាន និង (២)ការជំរុញកិច្ចអភិវឌ្ឍន៍មូលដ្ឋាន និងការកាត់បន្ថយភាពក្រីក្រ ។

កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការត្រូវរៀបចំឡើងដោយផ្អែកតាមគោលការណ៍សំខាន់ៗ ចំនួន៥គឺ

- **ភាពជាតំណាងតាមលទ្ធិប្រជាធិបតេយ្យ** កំណែទម្រង់នឹងពង្រឹងតួនាទីរបស់ក្រុមប្រឹក្សាតាមថ្នាក់រដ្ឋបាលខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ ដែលបង្កើតឡើងតាមគោលការណ៍នៃលទ្ធិ ប្រជាធិបតេយ្យសេរីដោយពង្រីកអំណាចភារកិច្ចការទទួលខុសត្រូវ និងធនធាន។
- **ការចូលរួមរបស់ប្រជាពលរដ្ឋ** កំណែទម្រង់នឹងរៀបចំប្រព័ន្ធ និងទម្រង់ការនានាសម្រាប់ប្រជាពលរដ្ឋពិសេសស្ត្រី និងក្រុមជនងាយរងគ្រោះ ក្រុមជនជាតិដើមភាគតិចអាចចូលរួមក្នុងការធ្វើសេចក្តី សម្រេចចិត្តនៅតាមបណ្តាថ្នាក់ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់។
- **គណនេយ្យភាពនៃវិស័យសាធារណៈ** កំណែទម្រង់នឹងពង្រឹងគណនេយ្យភាពនៅគ្រប់លំដាប់ថ្នាក់រដ្ឋបាល និងសម្រួលការចូលរួមពិនិត្យមើលរបស់ប្រជាពលរដ្ឋក្នុងកិច្ចការរដ្ឋបាល និងហិរញ្ញវត្ថុ ។
- **ប្រសិទ្ធភាព** កំណែទម្រង់នឹងនាំសេវាសាធារណៈទាំងនោះ ដើម្បីឆ្លើយតបទៅនឹងតម្រូវការ និងអាទិភាពរបស់មូលដ្ឋាន។ ទន្ទឹមនេះកំណែទម្រង់នឹងកែលម្អប្រព័ន្ធរដ្ឋបាល និងការងារសម្របសម្រួល និងពង្រឹងសមត្ថភាពគ្រប់គ្រងរបស់ថ្នាក់ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ ដើម្បីលើកកម្ពស់ គុណភាពសេវាព្រមទាំងពង្រីកការងារផ្តល់សេវាសាធារណៈឱ្យបានទូលំទូលាយ។
- **ការផ្តោតទៅលើការកាត់បន្ថយភាពក្រីក្រ** : កំណែទម្រង់នេះនឹងពង្រឹងសមត្ថភាពរបស់មូលដ្ឋានក្នុងការ

ប្រើប្រាស់ធនធានសម្រាប់គាំទ្រដល់សកម្មភាពកាត់បន្ថយភាពក្រីក្រ ពិសេសក្រុមជនងាយរងគ្រោះក្រុមជន-ជាតិដើមភាគតិច ស្ត្រី និងកុមារ ដើម្បីឈានទៅសម្រេចគោលដៅអភិវឌ្ឍន៍ សហសវត្សរ៍របស់កម្ពុជា។

## ៦. តើហេតុអ្វីចាំបាច់ត្រូវធ្វើកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ?

### ក.មូលហេតុនៃការអនុវត្តកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ

១. ប្រជាពលរដ្ឋអាចមានលទ្ធភាពចូលរួមយ៉ាងសកម្មនៅក្នុងការធ្វើសេចក្តីសម្រេចចិត្តនៅមូលដ្ឋាន ដែលនេះគឺជាការពង្រឹង និងពង្រីកនូវការចូលរួមជាសាធារណៈនៅក្នុងការអភិវឌ្ឍប្រទេសជាតិ។ ផ្អែកលើលទ្ធផលនៃការចូលរួមនេះ តម្រូវការ និងអាទិភាពនានារបស់ប្រជាពលរដ្ឋនៅមូលដ្ឋាន ត្រូវបានគិតគូរយកចិត្តទុកដាក់ និងឆ្លើយតបកាន់តែប្រសើរឡើង។ ដូច្នេះតាមរយៈការអនុវត្តកំណែទម្រង់នេះ នឹងនាំឱ្យមានការធ្វើសេចក្តីសម្រេចចិត្តកាន់តែមានភាពល្អប្រសើរ និងការប្រើប្រាស់ធនធានកាន់តែមាន ប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិថែមទៀត។

២.ការផ្តល់សេវាសាធារណៈរបស់ក្រសួង ស្ថាប័ននៅថ្នាក់ជាតិកាន់តែរហ័ស និងមានប្រសិទ្ធភាពព្រោះអ្នកទទួលខុសត្រូវក្នុងការផ្តល់សេវាទាំងនោះត្រូវបានផ្ទេរ ឬបង្វិលឱ្យទៅជិតប្រជាពលរដ្ឋក្នុងគោលបំណងបម្រើផលប្រយោជន៍សាធារណៈ។

៣. ការបង្កើននូវលទ្ធភាពនៃការកៀរគរប្រភពធនធាននៅមូលដ្ឋានសម្រាប់ផ្តល់សេវា និងការអភិវឌ្ឍបន្ថែមទៀត ដោយផ្អែកលើធន្ធៈនៃការចូលរួមរបស់ប្រជាពលរដ្ឋ សង្គមស៊ីវិល ក៏ដូចជា ការកៀរគរ ធនធានរបស់វិស័យឯកជននានាឱ្យចូលរួមជាមួយធនធានរបស់អាជ្ញាធរមូលដ្ឋាន ក្នុងការវិនិយោគ លើការអភិវឌ្ឍមូលដ្ឋាន និងការកាត់បន្ថយភាពក្រីក្រ។

### ខ.គោលដៅនៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ

គោលការណ៍ជាមូលដ្ឋានសម្រាប់កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ គឺជាកំណែទម្រង់ប្រព័ន្ធគ្រប់គ្រងថ្នាក់រដ្ឋបាល ខេត្ត ក្រុង ស្រុក ខណ្ឌ និងមានគោលដៅជាយុទ្ធសាស្ត្រពីរយ៉ាង (១) ការពង្រឹង

និងពង្រីកលទ្ធិប្រជាធិបតេយ្យ និង (២)ការជំរុញកិច្ចអភិវឌ្ឍមូលដ្ឋាន និងការកាត់បន្ថយ ភាពក្រីក្រ និង មានគោលដៅនៃការអនុវត្តកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការចំនួន ៣ គឺ (១)ពង្រឹងលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស (២)លើកកម្ពស់ការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម និង (៣) ជំរុញកិច្ចអភិវឌ្ឍមូលដ្ឋាន។

ដូច្នេះដើម្បីឆ្លើយតបទៅនឹងគោលដៅជាយុទ្ធសាស្ត្រខាងលើ កំណែទម្រង់ចាំបាច់ត្រូវរៀបចំរចនាសម្ព័ន្ធ និងប្រព័ន្ធអភិបាលកិច្ចនៅថ្នាក់ក្រោមជាតិក្នុងគោលបំណងដើម្បី

- ធានាឱ្យមានការអភិវឌ្ឍប្រកបដោយនិរន្តរភាព ទូលំទូលាយ សំដៅពង្រឹងមូលដ្ឋានគ្រឹះសម្រាប់ខឿនសេដ្ឋកិច្ចនៅមូលដ្ឋាន
- ធានាឱ្យប្រជាពលរដ្ឋគ្រប់រូបមានឱកាសស្មើគ្នាក្នុងការចូលរួមរៀបចំ និងអនុវត្តផែនការអភិវឌ្ឍន៍មូលដ្ឋានរបស់ខ្លួន
- បង្កើតនូវបរិយាកាសប្រកបដោយប្រសិទ្ធភាពសម្រាប់គ្រប់គ្រងធនធានធម្មជាតិ និងសម្រាប់ការផ្តល់សេវាសាធារណៈប្រកបដោយគុណភាព ដើម្បីឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋ និងកាត់បន្ថយភាពក្រីក្រ ដោយផ្តោតការយកចិត្តទុកដាក់ទៅលើជនក្រីក្រក្រុមជនងាយរងគ្រោះជនជាតិដើមជនជាតិភាគតិច ស្ត្រី និងកុមារ យុវជន យុវនារី...។

## ៧. ក្របខណ្ឌគោលនយោបាយ និងក្របខណ្ឌច្បាប់សម្រាប់គាំទ្រដល់ការអនុវត្ត កំណែទម្រង់វិមជ្ឈការ និង វិសហមជ្ឈការ

រាជរដ្ឋាភិបាលមានក្របខ័ណ្ឌគោលនយោបាយចំនួន២ ដើម្បីត្រួសត្រាយផ្លូវសម្រាប់កំណែទម្រង់នេះរួមមាន(១) យុទ្ធសាស្ត្រចតុកោណ និង(២) ក្របខ័ណ្ឌយុទ្ធសាស្ត្រស្តីពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ និងមានក្របខ័ណ្ឌច្បាប់ចំនួន២ (១) ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និង (២) ច្បាប់ស្តីពីការគ្រប់គ្រងរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ។

## ក.ក្របខណ្ឌគោលនយោបាយ

### ១.យុទ្ធសាស្ត្រចតុកោណ

រាជរដ្ឋាភិបាលបានកំណត់នៅក្នុងអាទិភាពនៃគោលនយោបាយសេដ្ឋកិច្ចថា ស្នូលនៃនៃយុទ្ធសាស្ត្រចតុកោណ គឺអភិបាលកិច្ចល្អ។ អភិបាលកិច្ចល្អ គឺជាស្នូលនៃយុទ្ធសាស្ត្រចតុកោណ (ដំណាក់កាលទី១ និងដំណាក់កាលទី២) ដែលជាបុរេលក្ខណៈវិនិច្ឆ័យសំខាន់បំផុតមួយ ដើម្បីការអភិវឌ្ឍប្រកបដោយចីរភាព សមធម៌ និងយុត្តិធម៌។ ដើម្បីសម្រេចគោលបំណងនេះ រាជរដ្ឋាភិបាលបានផ្តោតការយកចិត្តទុកដាក់ទៅលើការអនុវត្តប្រកបដោយប្រសិទ្ធភាព នូវផែនការសកម្មភាពអភិបាលកិច្ចរបស់ខ្លួន ដោយគ្របដណ្តប់ ទៅលើកំណែទម្រង់លើវិស័យ ចំនួនបួនរួមមាន

- ការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ
- កំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌
- កំណែទម្រង់រដ្ឋបាលសាធារណៈ (រួមមានកម្មវិធីវិមជ្ឈការ និងវិសហមជ្ឈការ )និង
- កំណែទម្រង់កងកម្លាំងប្រដាប់អាវុធ។

**ចំណាំ:** នៅក្នុងកំណែទម្រង់រដ្ឋបាលសាធារណៈ រាជរដ្ឋាភិបាលចាត់ទុកថា កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ដែលកំណែទម្រង់នេះមានសារៈសំខាន់ចំពោះការកែលម្អគុណភាពនៃសេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋានដោយមានការចូលរួម។

### ២.ក្របខ័ណ្ឌយុទ្ធសាស្ត្រស្តីពីកំណែទម្រង់វិមជ្ឈការ និង វិសហមជ្ឈការ

ក្របខ័ណ្ឌយុទ្ធសាស្ត្រស្តីពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ គឺជាឯកសារគោលនយោបាយរបស់រាជរដ្ឋាភិបាលដែលបង្ហាញពីចក្ខុវិស័យ និងគោលការណ៍ជាមូលដ្ឋានរបស់រាជរដ្ឋាភិបាល សម្រាប់ដឹកនាំដំណើរការកំណែទម្រង់អភិបាលកិច្ច នៅថ្នាក់ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ ។ ក្របខ័ណ្ឌ យុទ្ធសាស្ត្រនេះត្រូវបានអនុម័ត ដោយរាជរដ្ឋាភិបាលកម្ពុជា ក្នុងសម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី នាថ្ងៃទី ១៧ ខែមិថុនា ឆ្នាំ២០០៥ ដោយបានកំណត់អំពី

- ប្រព័ន្ធគ្រប់គ្រងមុនពេលមានច្បាប់ស្តីពីការគ្រប់គ្រងរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- ចក្ខុវិស័យរបស់រដ្ឋាភិបាល
- យុទ្ធសាស្ត្រវិមជ្ឈការ និងវិសហមជ្ឈការរបស់រាជរដ្ឋាភិបាល

- កម្មវិធីជាតិសម្រាប់អនុវត្តយុទ្ធសាស្ត្រវិមជ្ឈការ និងវិសហមជ្ឈការ

## ខ.ក្របខ័ណ្ឌច្បាប់

ដោយផ្អែកតាមក្របខ័ណ្ឌគោលនយោបាយខាងលើ រាជរដ្ឋាភិបាលបានរៀបចំឱ្យមានច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដែលច្បាប់ទាំងពីរនេះត្រូវបានកំណត់ថាជា "ច្បាប់រៀបចំអង្គការ"។

### ១.ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់

ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ មានគោលដៅកំណត់ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ទាំងអស់ក្នុងព្រះរាជាណាចក្រកម្ពុជាតាមនយោបាយវិមជ្ឈការ ។ ច្បាប់នេះជាមូលដ្ឋានគ្រឹះសម្រាប់រាជរដ្ឋាភិបាលចាប់ផ្តើមអនុវត្តកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការនៅថ្នាក់ឃុំ សង្កាត់ ដែលបានអនុម័ត ក្នុងឆ្នាំ២០០១។

ច្បាប់នេះកំណត់ឱ្យក្រុមប្រឹក្សាឃុំ សង្កាត់មានតួនាទីពីរប្រភេទគឺ :

- តួនាទីបំរើកិច្ចការមូលដ្ឋានសំរាប់បំរើផលប្រយោជន៍ឃុំ សង្កាត់ និងប្រជាពលរដ្ឋក្នុងឃុំ សង្កាត់របស់ខ្លួន។
- តួនាទីជាភ្នាក់ងារតំណាងរដ្ឋ ក្រោមការចាត់តាំង ឬការប្រគល់អំណាចរបស់អាជ្ញាធររដ្ឋ ។

### ២.ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

ផ្អែកតាមកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល សម្រាប់នីតិកាលទី៣ រាជរដ្ឋាភិបាលបានអនុម័តក្របខ័ណ្ឌយុទ្ធសាស្ត្រស្តីពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ក្នុងគោលបំណងលើកកម្ពស់លទ្ធិប្រជាធិបតេយ្យអោយកាន់តែរីកចម្រើនឡើងនៅថ្នាក់ក្រោមជាតិ។

តាមរយៈក្របខ័ណ្ឌយុទ្ធសាស្ត្រនេះច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវបានប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥០៨ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៨ ។

ច្បាប់នេះមានគោលបំណងកំណត់ការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ។ រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវគ្រប់គ្រងតាមគោលការណ៍នៃរដ្ឋបាលឯកភាពដើម្បីបង្កើតជំរុញនិង ធ្វើអោយម

ានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យតាមរយៈនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ។ ដូចនេះ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ គឺជាមូលដ្ឋានគ្រឹះ សម្រាប់រាជរដ្ឋាភិបាលបន្តពង្រីកវិសាលភាពនៃការអនុវត្តកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ និង ជាមូលគ្រឹះនៃការអនុវត្តកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ។

# មេរៀនទី ២ ឯកសារផ្ទាំងរូបភាព







អភិបាលកិច្ចល្អ
តម្លាភាព
នីតិរដ្ឋ
ការព្រមព្រៀងឯកភាពគ្នា
សមធម៌
ប្រសិទ្ធភាពខ្ពស់
ការឆ្លើយតប
គណនេយ្យភាព
ការចូលរួម




៤
វប្បធម៌ប្រជាធិបតេយ្យ
កែលម្អការផ្តល់សេវាសាធារណៈ និង
ហេដ្ឋារចនាសម្ព័ន្ធ
ការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមកិច្ច
កាត់បន្ថយភាពក្រីក្រ
អភិបាលកិច្ច ល្អ
ផលិតដោយ
Pact Cambodia
VBNK
ឧបត្ថម្ភដោយ
THE WORLD BANK
គ.ជ.អ.ប
NCDD
ការចូលរួម
តម្លាភាព
ការឆ្លើយតប
សមធម៌
នីតិរដ្ឋ
ការឯកភាព
ប្រសិទ្ធភាព
និងប្រសិទ្ធផល
គណនេយ្យភាព


៣
ភាពជាតំណាង តាមលទ្ធិ ប្រជាធិបតេយ្យ ១
ការចូលរួម របស់ ប្រជាពលរដ្ឋ ២
គោលការណ៍ជា មូលដ្ឋានសម្រាប់កំណែទម្រង់វិមជ្ឈការ និង វិសហមជ្ឈការ
ការផ្តោតទៅលើ ការកាត់បន្ថយ ភាពក្រីក្រ ៥
គណនេយ្យភាព នៃវិស័យ សាធារណៈ ៣
ប្រសិទ្ធភាព ៤
១.ភាពជាតំណាងតាមលទ្ធិប្រជាធិបតេយ្យ : កំណែទម្រង់ នឹងពង្រឹងតួនាទី របស់ក្រុមប្រឹក្សា តាមថ្នាក់រដ្ឋបាលខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ ដែលបង្កើតឡើងតាមគោលការណ៍នៃលទ្ធិប្រជាធិបតេយ្យសេរីដោយពង្រីកអំណាច ភារកិច្ចទទួលខុសត្រូវ និងធនធាន។
២.ការចូលរួមរបស់ប្រជាពលរដ្ឋ : កំណែទម្រង់ នឹងរៀបចំប្រព័ន្ធ និងទម្រង់ការនានាសម្រាប់ប្រជាពលរដ្ឋ ពិសេសស្ត្រី និងក្រុមជនងាយរងគ្រោះ ក្រុម ជនជាតិដើមភាគតិច អាចចូលរួមក្នុងការធ្វើសេចក្តីសម្រេចចិត្តនៅតាមបណ្តា ថ្នាក់ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់។
៣.គណនេយ្យភាពនៃវិស័យសាធារណៈ : កំណែទម្រង់នឹងពង្រឹងគណនេយ្យភាពនៅគ្រប់លំដាប់ថ្នាក់រដ្ឋបាល និងសម្រួលការចូលរួមពិនិត្យមើលរបស់ប្រជាពលរដ្ឋក្នុងកិច្ចការរដ្ឋបាល និងហិរញ្ញវត្ថុ ។
៤.ប្រសិទ្ធភាព : កំណែទម្រង់នឹងនាំសេវាសាធារណៈទាំងនោះដើម្បីឆ្លើយតបទៅនឹងតម្រូវការ និងអាទិភាពរបស់មូលដ្ឋាន។ ទន្ទឹមនេះកំណែទម្រង់នឹងកែលម្អប្រព័ន្ធរដ្ឋបាល និងការងារសម្របសម្រួល និងពង្រឹងសមត្ថភាពគ្រប់គ្រងរបស់ថ្នាក់ខេត្ត ក្រុង ស្រុក ខណ្ឌ និង ឃុំ សង្កាត់ ដើម្បីលើកកម្ពស់គុណភាពសេវា ព្រមទាំងពង្រីកការងារផ្តល់សេវាសាធារណៈឱ្យបានទូលំទូលាយ។
៥.ការផ្តោតទៅលើការកាត់បន្ថយភាពក្រីក្រ : កំណែទម្រង់នេះនឹងពង្រឹងសមត្ថភាពរបស់មូលដ្ឋាន ក្នុងការប្រើប្រាស់ធនធានសម្រាប់គាំទ្រដល់សកម្មភាពកាត់បន្ថយភាពក្រីក្រ ពិសេសក្រុមជនងាយរងគ្រោះ ក្រុមជនជាតិដើមភាគតិច ស្ត្រី និងកុមារ ដើម្បីឈានទៅសម្រេចគោលដៅអភិវឌ្ឍន៍សហសវត្សរ៍របស់កម្ពុជា។
ប្រភពឯកសារ
ក្របខ័ណ្ឌយុទ្ធសាស្ត្រ ស្តីពី កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ (ទំព័រ ៨ - ៩)
ផលិតដោយ
Pact Cambodia
VBNK
ឧបត្ថម្ភដោយ
THE WORLD BANK
គជអប NCDD

## សេវាកម្មសាធារណៈរបស់រដ្ឋបាលថ្នាក់ឃុំ-សង្កាត់



មេរៀនទី ២ ប្លង់មេរៀន



## ជំពូកទី១_មេរៀនទី២

## ចំណងជើងមេរៀនៈ អភិបាលកិច្ច និងទស្សនទាននៃវិមជ្ឈការ និងវិសហមជ្ឈការ

**រយៈពេល ៖ ៩៥នាទី**

### របៀបសម្របសម្រួលមេរៀន

| រយៈពេល | សកម្មភាព និង វិធីសាស្ត្រ | សម្ភារ:/ឯកសារចែក |
|---|---|---|
| (២០ នាទី) | **សកម្មភាពទី១:** សេចក្តីណែនាំ និងគោលបំណងមេរៀន<br>អ្នកសម្រសម្រួលបញ្ជាក់ប្រាប់សិក្ខាកាមថាបទបង្ហាញស្តីពីប្រវត្តិនៃ កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ យើងបានសង្កេតឃើញមានព្រឹត្តិការណ៍សំខាន់ៗជាច្រើនកើតឡើងនៅប្រទេសកម្ពុជា និងមានព្រឹត្តិការណ៍មួយចំនួនរបស់អង្គការសង្គមស៊ីវិលបានចូលរួមចំណែកអនុវត្តជាមួយគ្នានេះដែរអ្នកសម្របសម្រួលបញ្ជាក់ថាអង្គការសង្គមស៊ីវិលនៅតែមានសារៈសំខាន់ក្នុងការចូលរួមចំណែក.អនុវត្តអភិបាលកិច្ចល្អ វិមជ្ឈការ និងវិសហមជ្ឈការ។ ដូចនេះដើម្បីយល់អោយកាន់តែស៊ីជម្រៅយើងនឹងសិក្សាមេរៀនថ្មីមួយទៀត ស្តីអំពី " អភិបាលកិច្ច និងទស្សនទានកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ " ។<br>អ្នកសម្របសម្រួលចាប់ផ្តើមដោយលើកឡើងថាអភិ-បាលកិច្ចល្អជាផ្នែកមួយយ៉ាងសំខាន់ក្នុងការជំរុញ និងគាំទ្រដំណើរការនៃការគ្រប់គ្រងធនធានរបស់ស្ថាប័នអង្គភាព និងការអភិវឌ្ឍមួយប្រកបដោយនិរន្តរភាព និងជាមូលដ្ឋានគ្រឹះនៃការអនុវត្តក្របខ័ណ្ឌយុទ្ធសាស្រស្តីពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ និងការអនុវត្តកម្មវិធីជាតិ | |

| | | |
|---|---|---|
| | សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។<br>**ក.** ពន្យល់សិក្ខាកាមឱ្យបានដឹងថា មេរៀននេះគឺជាការរំលឹកឡើងវិញនូវបទពិសោធន៍នៃការអនុវត្តអភិបាលកិច្ចល្អ វិមជ្ឈការ និងវិសហមជ្ឈការ និងស្វែងយល់ពីការ ភ្ជាប់ទំនាក់ទំនងរវាងអភិបាលកិច្ចល្អ វិមជ្ឈការ និងវិសហមជ្ឈការ ជាមួយនឹងការអនុវត្តកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។<br>**ខ.** បង្ហាញគោលបំណង: អ្នកសម្របសម្រួលបង្ហាញគោលបំណង ស្លាយទី២ | |
| (២៥ នាទី) | **សកម្មភាពទី២ :** និយមន័យនៃពាក្យអភិបាលកិច្ច អភិបាលកិច្ចល្អ និងគោលការណ៍អភិបាលកិច្ចល្អ ។<br>**ក.** ការបំផុសគំនិត : តើអ្វីជា អភិបាលកិច្ច? តើអ្វីជា អភិបា-លកិច្ចល្អ? តើគោលការណ៍ អភិបាលកិច្ចល្អ មានអ្វីខ្លះ? ហើយធ្វើការរៀបរាប់ដោយសង្ខេបនូវសកម្មភាពដែលបានអនុវត្តទាក់ទងនឹងអភិបាលកិច្ចល្អនៅក្នុងប្រទេសកម្ពុជា<br>**បញ្ជាក់:** អ្នកសម្រសម្រួលត្រូវចងចាំថាមុននឹងចែកក្រុម បង្ហាញបញ្ជីសំនួរ នៅស្លាយទី៣។ បន្ទាប់មកចែកអ្នកចូលរួមជា៤ក្រុមតូច ហើយប្រាប់ថា ក្រុមនីមួយៗមានរយៈពេល ២០នាទី សម្រាប់ពិភាក្សាលើសំណួរ : តើអ្វីជាអភិបាល-កិច្ច?<br>និងតើអ្វីជាអភិបាលកិច្ចល្អ? | ១. រូបភាពគោលការណ៍ជាមូលដ្ឋានម្រាប់កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ<br>២. ចែកឯកសារ<br>- ហ្វីតសរសេរក្រដាស |

| | | |
|---|---|---|
| | តើគោលការណ៍អភិបាលកិច្ចល្អមានអ្វីខ្លះ? ហើយធ្វើការរៀបរាប់ដោយសង្ខេបនូវសកម្មភាពដែលបានអនុវត្តទាក់ទងនឹងអភិបាលកិច្ចល្អនៅក្នុងប្រទេសកម្ពុជា។<br>**ខ.** អ្នកសម្របសម្រួលបង្ហាញ និងពន្យល់អំពី<br>- និយមន័យនៃពាក្យអភិបាលកិច្ច អភិបាលកិច្ចល្អ និងគោលការណ៍អភិបាលកិច្ចល្អ នៅស្លាយទី ៤ ទី៥ និង ស្លាយទី ៦<br>- ណែនាំអោយមើលប៉ុស្ត័រនៅក្នុងបន្ទប់រៀន ។<br>- សួរសិក្ខាកាមប្រសិនបើចង់លើកជាសំណួរ (មានរយៈពេល ០៥ នាទី) | |
| (១០ នាទី) | **សកម្មភាពទី៣ :** និយមន័យនៃពាក្យ វិមជ្ឈការ និងវិសហមជ្ឈការ<br>អ្នកសម្របសម្រួលប្រាប់អោយសិក្ខាកាមជ្រើសរើសដៃគូអង្គុយជិតគ្នាពិភាក្សាហើយឱ្យកត់ត្រាចម្លើយនៅក្នុងសៀវភៅផ្ទាល់ខ្លួន។ បន្ទាប់មកអ្នកសម្របសម្រួលបង្ហាញសំនួរនៅ ស្លាយទី៧ ដែលមានខ្លឹមសារដូចខាងក្រោម ដោយបញ្ជាក់ថាការពិភាក្សាមាន រយៈពេល ០៥ នាទី ។<br>- តើវិមជ្ឈការមានន័យយ៉ាងដូចម្តេច?<br>- តើវិសហមជ្ឈការមានន័យយ៉ាងដូចម្តេច?<br>**ក.** អ្នកសម្របសម្រួល បង្ហាញអត្ថន័យនៃពាក្យ វិមជ្ឈការ និងវិសហមជ្ឈការ នៅស្លាយទី៨ និង ទី៩ ដោយមានលើកឧទាហរណ៍២ ឬ៣ ស្តីពីរឿងរ៉ាវដែលបានកើតឡើងនៅក្នុងប្រទេសកម្ពុជា និងបន្ទាប់មកបង្ហាញពីគោលការណ៍នៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ស្លាយទី១០ | ១. អ្នកសម្របសម្រួលចង្អុលប៉ុស្ត័ររូបភាពដើមឈើស្តីពីអភិបាលកិច្ចល្អ។<br>- ក្រដាសផ្ទាំងធំ<br>- ឯកសារចែក |

| | | |
|---|---|---|
| | និងទី១៤ | |
| (១៥ នាទី) | **សកម្មភាពទី៤:** សំណួរបំផុសបង្ហាញ និងពន្យល់ខ្លឹមសារមេរៀនអំពី ភាពចាំបាច់ ត្រូវធ្វើកំណែទម្រង់វិមជ្ឈការ និង វិសហមជ្ឈការ :<br>- អ្នកសម្របសម្រួលស្នើឱ្យសិក្ខាកាមអង្គុយក្បែរៗគ្នាចាប់ដៃគូដើម្បី ពិភាក្សាសំណួរ នៅស្លាយទី១១ ដែលមាន-ន័យថា : ហេតុអ្វីចាំបាច់ត្រូវធ្វើកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ?" ដោយប្រាប់ថាដៃគូនីមួយៗមានរយៈពេល ៥ នាទី សម្រាប់គិត និង សរសេរចម្លើយនៅក្នុងសៀវភៅផ្ទាល់ខ្លួន។<br>- អ្នកសម្របសម្រួលអោយសិក្ខាកាមចំនួន ៣ គូ អានចម្លើយរបស់ខ្លួននៅនឹងកន្លែង។<br>អ្នកសម្របសម្រួលបង្ហាញ និងពន្យល់អំពីមូលហេតុនៃការអនុវត្តកំណែទម្រង់ និងគោលដៅនៃការអនុវត្តកំណែទម្រង់ នៅស្លាយទី ១៦ ដែលមានខ្លឹមសារសង្ខេបដូចជា:<br>**មូលហេតុ :**<br>- បង្កើនការចូលរួមរបស់ប្រជាពលរដ្ឋ ក្នុងការធ្វើសេចក្តីសម្រេចចិត្ត<br>- បង្កើនប្រសិទ្ធភាពនិងការផ្តល់សេវាកម្ម សាធារណៈឱ្យកាន់តែជិតដល់ប្រជាពលរដ្ឋ<br>- បង្កើនលទ្ធភាពក្នុងការកៀរគរធនធានពី ប្រជាពលរដ្ឋ សង្គមស៊ីវិល និងឯកជន | - ក្រដាសផ្ទាំងធំ<br>- ឯកសារចែក |

| | | |
|---|---|---|
| | **គោលដៅ:**<br>- ពង្រឹង និងពង្រីកលទ្ធិប្រជាធិបតេយ្យ<br>- លើកកម្ពស់ការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមសេរីពហុបក្ស នៅថ្នាក់មូលដ្ឋាន<br>- ការកាត់បន្ថយភាពក្រីក្រ<br>- ជំរុញកិច្ចអភិវឌ្ឍនៅមូលដ្ឋាន | |
| (២០ នាទី) | **៦.សកម្មភាពទី៥** សំណួរបំផុស,បង្ហាញ និងពន្យល់ខ្លឹមសារមេរៀនអំពីក្របខ័ណ្ឌ គោលយោបាយ និងក្របខ័ណ្ឌច្បាប់ សម្រាប់គាំទ្រដល់ការអនុវត្តកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ<br>- អ្នកសម្របសម្រួលចាប់ផ្តើមបង្ហាញសំនួរនៅស្លាយទី១៧ ដោយសួរបំផុសថា "តើមានក្របខ័ណ្ឌគោលយោបាយ និងក្របខ័ណ្ឌច្បាប់អ្វីខ្លះសម្រាប់គាំទ្រដល់ការអនុវត្តកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ? "<br>- អ្នកសម្របសម្រួលផ្តល់ឱកាសដល់សិក្ខាកាមចំនួន ៥ នាក់ ផ្តល់ចម្លើយក្នុងក្រុមធំ ។ បន្ទាប់មកអ្នកសម្របសម្រួលកត់ត្រាចម្លើយលើក្រដាសផ្ទាំងធំ។<br>- អ្នកសម្របសម្រួលបង្ហាញ និងពន្យល់ខ្លឹមសារមេរៀនក្របខ័ណ្ឌគោលនយោបាយ និងក្របខ័ណ្ឌច្បាប់សម្រាប់គាំទ្រកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការនៅស្លាយទី១៨ ដែលមានខ្លឹមសារសង្ខេបដូចជា : | |

| | | |
|---|---|---|
| | **ក្របខ័ណ្ឌគោលនយោបាយ:**<br>- យុទ្ធសាស្ត្រចតុកោណ<br>- ក្របខ័ណ្ឌយុទ្ធសាស្ត្រស្តីពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ<br>**ក្របខ័ណ្ឌច្បាប់:**<br>- ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់<br>- ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ<br>**ចំណាំ :** អ្នកសម្របសម្រួលជម្រាបជូនសិក្ខាកាមថា ដោយមានច្បាប់ស្តីពីការ គ្រប់គ្រងរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ទើបមានកម្មវិធីជាតិសំរាប់ការអភិវឌ្ឍ តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ។ | - ក្រដាសផ្ទាំងធំ<br>- ឯកសារចែកជូន |
| (៥ នាទី) | **៧. សេចក្តីសន្និដ្ឋាន :**<br>ក. សិក្ខាកាមបានរំលឹកឡើងវិញនូវបទពិសោធន៍នៃការអនុវត្តអភិបាលកិច្ច អភិបាលកិច្ចល្អ វិមជ្ឈការ និងវិសហមជ្ឈការនៅកម្ពុជា ។<br>ខ. សិក្ខាកាមបានយល់ឃើញអំពីសារៈប្រយោជន៍នៃអភិបាលកិច្ចល្អ វិមជ្ឈការ និងវិសហមជ្ឈការ ក្នុងការចូលរួមចំណែកអនុវត្តកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ នៅថ្នាក់ក្រោមជាតិ។<br>គ. សិក្ខាកាមមានការប្តេជ្ញាចិត្តចូលរួមចំណែកអនុវត្តកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ។ | |

**សម្ភារៈបង្រៀន :**

- ឯកសារចែក
- ហ្វឺតសរសេរក្រដាស ក្រដាសផ្ទាំងធំ ស្កុតក្រដាស និងកាតពណ៌
- ផ្ទាំងប៉ាណូ
- ប៉ុស្ទ័រ
  - ☆ រូបភាពដើមឈើស្តីពីអភិបាលកិច្ចល្អ,
  - ☆ រូបភាពគោលការណ៍ជាមូលដ្ឋានសម្រាប់កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ
- ម៉ាស៊ីនបញ្ចាំង (LCD)
- កុំព្យូទ័រយួរដៃ (Laptop)

**ឯកសារយោង :**

- អភិបាលកិច្ចល្អសំរាប់ក្រុមប្រឹក្សាឃុំ សង្កាត់រៀបចំដោយនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន ក្រសួងមហាផ្ទៃ ខែវិច្ឆិកា ឆ្នាំ២០០៥ ។
- ក្របខ័ណ្ឌយុទ្ធសាស្ត្រស្តីពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ចេញផ្សាយដោយ រាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ១៧ មិថុនា ២០០៥។
- ច្បាប់ស្តីពីការគ្រប់គ្រងរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- ប្លង់មេរៀនគោលការណ៍សំខាន់ៗជាមូលដ្ឋានសម្រាប់ការគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិខែមិថុនា ឆ្នាំ២០០៩

# មេរៀនទី៣

## តួនាទី និងការរួមចំណែករបស់ សង្គមស៊ីវិលក្នុងដំណើរការកំណែទម្រង់ វិមជ្ឈការ និងវិសហមជ្ឈការ

# មេរៀនទី ៣ តួនាទី និងការរួមចំណែករបស់សង្គមស៊ីវិលក្នុងដំណើរការកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ

**គោលបំណង** : នៅចុងបញ្ចប់មេរៀននេះ អ្នកចូលរួមនឹងអាច

១. ពន្យល់ពីអត្ថន័យជាក់លាក់នៃសង្គមស៊ីវិល អង្គការសង្គមស៊ីវិល និងផ្តល់ឧទាហរណ៍មួយចំនួននៃអង្គការសង្គមស៊ីវិល ។

២. រៀបរាប់នូវបទពិសោធន៍ចូលរួមក្នុងដំណើរការកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការរបស់អង្គការសង្គមស៊ីវិល ។

## លទ្ធផលរំពឹងទុកនៃមេរៀនៈ

ក. សិក្ខាកាមយល់ស្របថា កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ផ្តល់ឱកាសដល់សង្គមស៊ីវិលរួមចំណែកយ៉ាងសកម្មក្នុងកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ។

ខ. សិក្ខាកាមទទួលស្គាល់ថា រដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាល បានផ្តល់នូវអត្ថន័យពិតប្រាកដដល់កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ព្រោះថាប្រជាពលរដ្ឋបានរួមចំណែក ប្រកបដោយការស្លាបទាក្នុងដំណើរនេះ ។

## កំណត់ចំណាំរបស់អ្នកសម្របសម្រួលៈ

នៅក្នុងមេរៀននេះ អ្នកសម្របសម្រួលមានគោលបំណងចំនួន ២

១. ជួយឱ្យសិក្ខាកាមយល់ថាសង្គមស៊ីវិលមានអត្ថន័យលើសពីអង្គការមិនមែនរដ្ឋាភិបាល។ នៅក្នុងថ្ងៃដំបូងអ្នកសម្របសម្រួលត្រូវធ្វើឱ្យអ្នកចូលរួម ចាប់ផ្តើមស្វែងយល់ពីការរួមចំណែករបស់អង្គការមិនមែនរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិល នៅក្នុងប្រទេសកម្ពុជា ក្នុងអំឡុងពី ១៥-២០ឆ្នាំកន្លងមក ។

២. លើកកម្ពស់ការយល់ដឹងពីតួនាទី និងការទទួលខុសត្រូវរបស់សង្គមស៊ីវិលក្នុងកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ដែលបានរួមវិភាគទាន ជាផ្នែកមួយនៅក្នុងដំណើរការវិមជ្ឈការចាប់តាំងពីឆ្នាំ២០០២ មកទល់ពេលបច្ចុប្បន្ន។ មានការលើកឡើងពីបទពិសោធន៍ជោគជ័យជាច្រើនដូចជា យន្តការលើកកម្ពស់ការចូលរួមរបស់អង្គការសង្គមស៊ីវិលជាមួយក្រុមប្រឹក្សាឃុំសង្កាត់ការរួមចំណែកក្នុងការរៀបចំផែនការអភិវឌ្ឍន៍ឃុំសង្កាត់ កម្មវិធីវិនិយោគឃុំសង្កាត់ ការទំនាក់ទំនងប្រកបដោយការទទួលខុសត្រូវខ្ពស់ ការសម្របសម្រួលជាមួយជនបង្គោលទទួលបន្ទុកយេនឌ័រ និងទំនាក់ទំនងជាមួយគណៈកម្មការឃុំទទួលបន្ទុកស្ត្រី និងកុមារ ។

លើកកម្ពស់ការចូលរួមរបស់មូលដ្ឋាន-ប្រជាពលរដ្ឋទាំងស្រី ប្រុស ចូលរួម
ក្នុងដំណើរការអភិវឌ្ឍមូលដ្ឋាន



ការគាំទ្រ និងការចូលរួមចំណែករបស់ជនជាតិភាគតិច



# មេរៀនទី ៣ ឯកសារបង្ហាញ



## ជំពូកទី១_មេរៀនទី៣
## តួនាទី និងការរួមចំណែករបស់សង្គមស៊ីវិល ក្នុងដំណើរការកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ

## គោលបំណង

- ពន្យល់ពីអត្ថន័យជាក់លាក់នៃសង្គមស៊ីវិល និងអង្គការសង្គមស៊ីវិល និងផ្តល់ឧទាហរណ៍មួយចំនួននៃអង្គការសង្គមស៊ីវិល ។
- រៀបរាប់នូវបទពិសោធន៍ចូលរួមក្នុងការដំណើរការកំណែទម្រង់ វិមជ្ឈការ និងវិសហមជ្ឈការ នៃអង្គការសង្គមស៊ីវិល។

## តួអង្គអភិវឌ្ឍ ៣ សំខាន់ៗ

- **រដ្ឋាភិបាល** រាជរដ្ឋាភិបាលកម្ពុជាបង្កើតឡើងដោយការបោះឆ្នោត ដើម្បីបម្រើ និងលើកកម្ពស់ផលប្រយោជន៍ប្រជាពលរដ្ឋ
- **វិស័យឯកជន** ជាផ្នែកនៃសេដ្ឋកិច្ច ដែលបង្កើតឡើងដោយបុគ្គល ឬជាក្រុមតាមទម្រង់ជាសហគ្រិនដើម្បីរកផលចំណេញ

(http://en.wiklpedia.org/wiki/Private_sector)

- **សង្គមស៊ីវិល** រួមមានអង្គការមិនមែនរដ្ឋាភិបាលសហគមន៍មូលដ្ឋាននានាដែលមិនរកប្រាក់ចំណេញ បម្រើផលប្រយោជន៍សាធារណៈ និងគុណតម្លៃនៃសមាជិករបស់ខ្លួន

( WoldBank.http.//search.worldbank.org/all?qterm=civil%20society )

## តើអង្គការសង្គមស៊ីវិលជាអ្វី?

- **អង្គការសង្គមស៊ីវិល** ត្រូវបានបកស្រាយថាជា សមាគមដែលបានបង្កើតឡើងដោយមិនស្ថិតនៅក្នុងរដ្ឋ ឬទីផ្សារ ហើយជាស្ថាប័នដែលរក្សាជំហរស្វ័យភាព ឯករាជ្យភាព និងមានសក្តានុពលក្នុងការផ្តល់នូវទស្សនៈ គោលនយោបាយ និងសកម្មភាពនានា ដល់ស្ថាប័នរដ្ឋ ឬទីផ្សារ ។
- **អង្គការមិនមែនរដ្ឋាភិបាល** គឺជាសមាសធាតុមួយនៃអង្គការសង្គមស៊ីវិល ហើយដែលគេសង្កេត ឃើញថានៅក្នុងវេទិកាជាច្រើន ពេលខ្លះអត្ថន័យនៃពាក្យពីរនេះ ត្រូវបានប្រើដោយអាចផ្លាស់ប្តូរគ្នាបាន ។

(Defined by the NGOs Sector Report in 2010 by CCC/NGO Training and Research Center (INTRAC), P2)

## តើអង្គការសង្គមស៊ីវិល ជាអ្វី? ត...

អង្គការសង្គមស៊ីវិលរួមមាន

- អង្គការមិនមែនរដ្ឋាភិបាល (AMARA, AK, PK, BFD, CFD, COWS, ODOV etc.)
- អង្គការអន្តរជាតិ (Pact, NDI, GTZ, CDRI, NPA, PATH, CARE etc...)
- អង្គការសហគមន៍មូលដ្ឋាន ( Community Mobilizing Committee, Community forestry, Saving group, Self Help Group, Rice Bank, Cow bank, etc...)
- បណ្តាញការងារ ( CCC, Open Forum, WGPD, NLO, HACC ,etc... )
- គណៈកម្មការ សមាគម (National Leagues of Communes and Sangkats, Khmer Youth Association etc...)

## តើតួនាទីអង្គការសង្គមស៊ីវិល អាចធ្វើអ្វីខ្លះ នៅក្នុងកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ? (ដកស្រង់ពី ម៉ឺលការ)

- តស៊ូមតិ នៅក្នុងដំណើរការរៀបចំមាតិការ និងគោលនយោបាយ
- ប្រភពព័ត៌មានៈ ផ្តល់មតិត្រឡប់ និងសេចក្តីជារម្ភ លើបញ្ហាសំខាន់ៗ និងផ្តល់អនុសាសន៍លើផ្នែក ជាក់លាក់នានា
- ជាអ្នកមានសមត្ថភាពៈ បង្កើនសមត្ថភាពដល់តួអង្គសំខាន់ៗនៅគ្រប់កម្រិត (ក្រុមប្រឹក្សាមូលដ្ឋាន ប្រជាពលរដ្ឋ អង្គការមូលដ្ឋាន)

⇩ **ការបង្កើនសមត្ថភាព**

ការកៀរគរសហគមន៍ឱ្យចូលរួមក្នុងដំណើរការ

- ○ តំណាងប្រជាពលរដ្ឋនៅពេលប្រជុំក្រុមប្រឹក្សាឃុំ
- ○ ពិភាក្សាជាមួយក្រុមប្រឹក្សាពីតំរូវការរបស់សមាជិកខ្លួន និងអ្នកភូមិ
- ○ ចូលរួមតាមដាន និងផ្តល់យោបល់ត្រឡប់
- ○ ដល់ក្រុមប្រឹក្សា

⇩ **ចូលរួមបង្កើតគោលនយោបាយ**

## សំណួរពិភាក្សាក្រុមតូច

តើសកម្មភាពចំបងៗ ឬសំខាន់ៗ អ្វីខ្លះដែលអង្គការ សង្គមស៊ីវិលបានអនុវត្ត កន្លងមកនៅក្នុងដំណើរការ កំណែទម្រង់ វិមជ្ឈការ និងវិសហមជ្ឈការ? សូមសរសេរតែ៣ចំនុចដែលលោកអ្នក គិតថាមានសារៈ សំខាន់នៅលើក្រដាស ផ្ទាំងធំ។

មេរៀនទី ៣ ឯកសារចែក



# ជំពូកទី១_មេរៀនទី៣
## ចំណងជើងមេរៀន : តួនាទី និងការរួមចំណែករបស់សង្គមស៊ីវិល ក្នុងដំណើរការកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ

**អង្គការសង្គមស៊ីវិល**

ត្រូវបានបកស្រាយថាជា សមាគមដែលបានបង្កើតឡើង ដោយមិនស្ថិតនៅក្នុងរដ្ឋ ឬទីផ្សារ ហើយជាស្ថាប័នដែលរក្សាជំហរស្វ័យភាព ឯករាជ្យភាព និងមានសក្តានុពលក្នុងការផ្តល់នូវទស្សនៈ គោលនយោបាយ និងសកម្មភាពនានាដល់ស្ថាប័នរដ្ឋ ឬទីផ្សារ ។

អង្គការមិនមែនរដ្ឋាភិបាល : គឺជាសមាសធាតុមួយនៃអង្គការសង្គមស៊ីវិល គឺជាសមាសធាតុមួយនៃអង្គការសង្គមស៊ីវិល ហើយដែលគេសង្កេតឃើញថានៅក្នុងវេទិកាជាច្រើន ពេលខ្លះអត្ថន័យនៃពាក្យពីរនេះត្រូវបានប្រើដោយអាចផ្លាស់ប្តូរគ្នាបាន ។

និយមន័យនេះបកស្រាយនៅក្នុងរបាយការណ៍ឆ្នាំ២០១០ស្តីពីការវាយតំលៃអង្គការមិនមែនរដ្ឋាភិបាលតាមវិស័យនៅក្នុងប្រទេសកម្ពុជាដោយ CCC/INGOs (INTRACT), Page 2 ។

មានតួអង្គជាអ្នកអភិវឌ្ឍចំនួនបី :

- **រដ្ឋាភិបាល** រាជរដ្ឋាភិបាលកម្ពុជាបង្កើតឡើងដោយការបោះឆ្នោត ដើម្បីបម្រើ និងលើកកម្ពស់ផលប្រយោជន៍ប្រជាពលរដ្ឋ
- **វិស័យឯកជន** ជាផ្នែកនៃសេដ្ឋកិច្ច ដែលបង្កើតឡើងដោយបុគ្គល ឬជាក្រុមតាមទម្រង់ជាសហគ្រិនដើម្បីរកផលចំណេញ (http://en.wiklpedia.org/wiki/Private_sector)
- **សង្គមស៊ីវិល** រួមមានអង្គការមិនមែនរដ្ឋាភិបាលសហគមន៍មូលដ្ឋាននានាដែលមិនរកប្រាក់ចំណេញ បម្រើផលប្រយោជន៍សាធារណៈ និងគុណតម្លៃនៃសមាជិករបស់ខ្លួន
  WoldBank: http.//search.worldbank.org/civilsociety

ឧទាហរណ៍អង្គការសង្គមស៊ីវិល មាន:

- អង្គការមិនមែនរដ្ឋាភិបាល (Amara, AK, PK, BFD, CFD, COWS, ODOV, etc...)
- អង្គការអន្តរជាតិ (Pact, NDI, GTZ, CDRI, NPA, PATH, CARE etc...)
- អង្គការសហគមន៍មូលដ្ឋាន ( Community Mobilizing Committee, Community Forestry, Saving Group, Self Help Group, Rice Bank etc...)
- បណ្តាញការងារ ( CCC, Open Forum, WGPD, NLO, HACC ,etc...

- គណៈកម្មការ សមាគម ( National League of communes and Sangkat, Khmer Youth Association etc...)

អង្គការសង្គមស៊ីវិលធ្លាប់បានបំពេញតួនាទី ក្នុងកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ តាមរយៈសកម្មភាព ដូចជា

- ស្វែងរកការគាំទ្រមតិ នៅក្នុងដំណើរការរៀបចំ គោលនយោបាយនៅគ្រប់កំរិត
- ប្រភពព័ត៌មានៈ ផ្តល់មតិត្រឡប់ និងសេចក្តីបារម្ភ លើបញ្ហាសំខាន់ៗ ដល់ក្រុមប្រឹក្សាមូលដ្ឋាន លើការលើកឡើងនូវតម្រូវការនិងការចាត់អាទិភាព
- ជាអ្នកមានសមត្ថភាព បង្កើនសមត្ថភាពដល់តួអង្គ សំខាន់ៗនៅគ្រប់កម្រិត ក្រុមប្រឹក្សាមូលដ្ឋាន ប្រជាពលរដ្ឋ និងអង្គការនានាដែលពាក់ព័ន្ធ
- កៀរគរសហគមន៍ឱ្យចូលរួមក្នុងដំណើរការអភិវឌ្ឍ
- រៀបចំឱ្យមានតំណាងប្រជាពលរដ្ឋចូលរួមក្នុងកិច្ច ប្រជុំរបស់ក្រុមប្រឹក្សាមូលដ្ឋាន
- ជួយឱ្យមានការសន្ទនាជាមួយក្រុមប្រឹក្សាក្នុងការលើកឡើងពីតម្រូវការរបស់សមាជិក និងប្រជាពលរដ្ឋ
- រៀបចំឱ្យមានការភ្ជាប់ទំនាក់ទំនងក្នុងត្រួតពិនិត្យនិងផ្តល់ត្រឡប់ទៅក្រុមប្រឹក្សាមូលដ្ឋានពីការធ្វើសេចក្តី សម្រេចចិត្ត ។

សំនួរសួរថាតើសង្គមស៊ីវិលមានតួនាទីអ្វីខ្លះទៀត?
ចម្លើយអាចជា សង្គមស៊ីវិលមានតួនាទី
១,ស្វែងរកសេវាកម្ម ជួយដល់ប្រជាពលរដ្ឋ
២,ផ្តល់ចំណេះដឹងបន្តដល់ប្រជាពលរដ្ឋ
៣,ត្រួតពិនិត្យការអនុវត្តរបស់អ្នកពាក់ព័ន្ធនូវកម្មវិធីជាតិ១០ឆ្នាំ
៤,តស៊ូមតិបញ្ចុះបញ្ចូល ដើម្បីប្រជាពលរដ្ឋទទួលបានសេវាកម្មប្រកបដោយ ប្រសិទ្ធិភាព
៥,ជួយផ្សព្វផ្សាយច្បាប់បទដ្ឋានគតិយុត្ត
៦,ផ្សព្វផ្សាយពីសិទ្ធិមនុស្ស និងរចនាសម្ព័ន្ធផ្សេងៗ
៧,ជាស្ពានផ្តល់ព័ត៌មានដល់រដ្ឋាភិបាលដើម្បីលើកកម្ពស់អភិបាលកិច្ចល្អក្នុងការអភិវឌ្ឍតាមបែប ប្រជាធិបតេយ្យ ។

# មេរៀនទី ៣ ឯកសារផ្ទាំងរូបភាព





## ៣ មេរៀនទី គំរូប្លង់មេរៀន



## ជំពូកទី១ - ប្លង់មេរៀនទី ៣

## ចំណងជើងមេរៀន: តួនាទី និងការរួមចំណែករបស់សង្គមស៊ីវិល ក្នុងដំណើរការកំណែទម្រង់ វិមជ្ឈការ និងវិសហមជ្ឈការ

**រយៈពេល** : ៥០ នាទី

**របៀបសម្របសម្រួលមេរៀន**

| រយៈពេល | សកម្មភាព និង វិធីសាស្រ្ត | សម្ភារៈ/ ឯកសារចែកជូន |
|---|---|---|
| (៥នាទី) | **សកម្មភាពទី ១:** លំហាត់ប្រាណបង្កើនថាមពល<br>☆ អ្នកសម្របសម្រួលអញ្ជើញអោយសិក្ខាកាមក្រោកឈរឡើង ដោយរក្សានៅទីកន្លែងដដែល ហើយលើកដៃឡើងលើរួចដកដង្ហើមវែងៗចំនួន៣ដង បន្ទាប់ មកដាក់ដៃចុះវិញ ដោយដកដង្ហើមវែងៗចំនួន៣ដងដែរ បន្ទាប់មកទៀត អោយសិក្ខាកាមអង្គុយចុះ ដោយបិទភ្នែកសមាធិចំនួន ២ នាទីមុននឹងចាប់ផ្តើមមេរៀន។<br>**បញ្ជាក់** សម្រាប់ល្បែងថាមពលនេះអ្នកសម្របសម្រួលអាចបត់បែនបានទៅតាមជំនាញ របស់អ្នកសម្របសម្រួលម្នាក់ៗ។ | |
| (១៥ នាទី) | **សកម្មភាពទី ២:** សេចក្តីណែនាំ<br>▪ ដូចបានពិភាក្សានៅក្នុងមេរៀនទី១_ប្រវត្តិកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ រួចហើយថាសង្គមស៊ីវិលចូលរួមយ៉ាងសកម្មក្នុងដំណើរការលទ្ធិប្រជាធិបតេយ្យនៅកម្ពុជា ។ ដូចនេះមេរៀនទី៣នេះនឹងបន្តពិភាក្សាពីតួនាទី និងការទទួលខុសត្រូវនៅក្នុងដំណើរការកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ។ ស្នើអោយអ្នកចូលរួម២នាក់ អានគោលបំណងមេរៀនទីមួយៗ | |

| | | |
|---|---|---|
| (១៥ នាទី) | ហើយអ្នកសម្របសម្រួលពន្យល់ពីគោលបំណងទាំងនោះដោយប្រើបទបង្ហាញទី ២ ។<br>**គោលបំណងរបស់មេរៀនមានចំនួន២ គឺ**<br>១. ពន្យល់ពីអត្ថន័យជាក់លាក់នៃសង្គមស៊ីវិល និងអង្គការសង្គមស៊ីវិល និងផ្តល់ឧទាហរណ៍មួយចំនួននៃអង្គការសង្គមស៊ីវិល។<br>២. រៀបរាប់នូវបទពិសោធន៍ចូលរួមក្នុងដំណើរការកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការរបស់អង្គការសង្គមស៊ីវិល ។ | ☆ បទបង្ហាញទី ២ |
| (១៥ នាទី) | **សកម្មភាពទី ៣:** ការពិភាក្សាក្រុមធំ<br>▪ អ្នកសម្របសម្រួលសួរសិក្ខាកាម ថាតើមានតួអង្គសំខាន់ៗអ្វីខ្លះក្នុងការអភិវឌ្ឍ?<br>▪ កត់ត្រាចំលើយសិក្ខាកាមនៅលើក្រដាសផ្ទាំងធំ រួចពន្យល់ពីតួអង្គសំខាន់ៗទាំង៣ ដោយប្រើ បទបង្ហាញទី៣ ។<br>▪ សួរសិក្ខាកាម តើអ្វីជាអង្គការសង្គមស៊ីវិល? បន្ទាប់មកស្នើអោយសិក្ខាកាមអោយនិយមន័យ និងឧទាហរណ៍មួយចំនួន ។<br>▪ អ្នកសម្របសម្រួលសរសេរចំលើយទាំងនោះ នៅលើក្រដាសផ្ទាំងធំ រួចបង្ហាញ និងពន្យល់ដោយប្រើបទបង្ហាញទី ៤-៥ ដើម្បីអោយសិក្ខាកាមយល់ដឹងបន្ថែមលើអង្គការសង្គមស៊ីវិល ។<br>▪ អ្នកសម្របសម្រួលបន្តបង្ហាញបទបង្ហាញទី៦ និងពន្យល់ដល់សិក្ខាកាមអំពី តើតួនាទីអង្គការសង្គមស៊ីវិលបានធ្វើអ្វីខ្លះនៅក្នុងដំណើរការកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ?<br>ផ្តល់ឱកាសអោយអ្នកចូលចែករំលែកបទពិសោធន៍មួយចំនួនព្រមទាំងសំនួរ និងចំលើយ ។ | ☆ ក្រដាសផ្ទាំងធំ |

| | | |
|---|---|---|
| (៤០ នាទី) | **សកម្មភាពទី៤ ក្រុមពិភាក្សា**<br>**ក.** អ្នកសម្របសម្រួលចែកអ្នកចូលរួមជា ៦ក្រុម ។<br>**ខ.** ក្រុមនីមួយៗមាន២០នាទី ដើម្បីពិភាក្សា និង១៥នាទីសម្រាប់អ្នកសម្របសម្រួលបូក សរុបលទ្ធផល។<br>**គ.** ក្រុមនីមួយៗពិភាក្សាដោយផ្តោតទៅលើសំណួរ តើសកម្មភាពចំបងៗ ឬសំខាន់ៗ អ្វីខ្លះដែលអង្គការសង្គមស៊ីវិលបានអនុវត្តកន្លងមកនៅក្នុងដំណើរការកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ? សកម្មភាពចំបងៗ ឬសំខាន់ៗដែលលើកឡើងគួរខុសពីអ្វីដែលអ្នកសម្របសម្រួលបានបង្ហាញ និងលើកឡើង។ ក្រុមនីមួយៗគួរតែលើកឡើងពី សកម្មភាពចំបងៗ ឬសំខាន់ៗដែលបានអនុវត្តចំនួន៣<br>**ឃ,** អ្នកសម្របសម្រួលសង្ខេបលទ្ធផលក្រុមពិភាក្សា ហើយធានាថាអ្នកចូលរួមយល់ ។ | |
| (៥ នាទី) | **សកម្មភាព៥** - សេចក្តីសន្និដ្ឋាន<br>**ក,** លើកសរសើរនូវគំនិតដែលបានលើកឡើងដោយក្រុមពិភាក្សានីមួយៗ ។<br>▪ អ្នកសម្របសម្រួល ត្រូវសង្ខេបនូវឧទាហរណ៍ស្តីពីសកម្មភាពនានាដែលបានលើកឡើងញឹកញាប់បំផុតក្នុងបទបង្ហាញរបស់ក្រុមនីមួយៗ ។<br>▪ គូសបញ្ជាក់ឱ្យអ្នកចូលរួមបានដឹងថា រាល់គំនិតយោបល់ដែលបានពិភាក្សានៅក្នុងមេរៀននេះនឹងមានសារៈប្រយោជន៍សម្រាប់មេរៀនបន្តបន្ទាប់ទៀត។ | |

| | | |
|---|---|---|
| | ខ. អ្នកសម្របសម្រួល ពន្យល់អ្នកចូលរួមឱ្យបានយល់ថា សង្គមស៊ីវិល និងអង្គការសង្គមស៊ីវិលមានតួនាទីយ៉ាងសំខាន់នៅក្នុងដំណើរការ អនុវត្តកម្មវិធីជាតិសម្រាប់ ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ១០ ឆ្នាំ ២០១០-២០១៩។ មេរៀននេះភ្ជាប់ទៅនឹងមេរៀនផ្សេងៗទៀតនៅជំពូកទី២។ | |

## សម្ភារៈបង្រៀន

- ឯកសារចែកជូនអ្នកចូលរួម មានបទបង្ហាញថតចម្លងស្តីពីតួនាទី និងការទទួលខុសត្រូវរបស់សង្គមស៊ីវិលក្នុងដំណើរការ កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ។
- រូបភាពផ្ទាំងធំទី៦ តួអង្គចូលរួមអនុវត្តកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- ហ្វឺតសរសេរក្រដាស ក្រដាសផ្ទាំងធំ ស្កុតក្រដាស និងកាតពណ៌

## ឯកសារយោង

- ឯកសារបញ្ជាំង ស្តីពីតួនាទីសង្គមស៊ីវិលនៅក្នុងដំណើរការកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ដែលបានបណ្តុះបណ្តាល ដោយអង្គការសីលការ ដែលមានភ្ជាប់ជូននៅក្នុងបទបង្ហាញ ។

# មេរៀនទី៤

## ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

# ៤ មេរៀនទី ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

**គោលបំណង** : នៅចុងបញ្ចប់មេរៀននេះ អ្នកចូលរួមនឹងអាច :

១. ពន្យល់គោលបំណង និងរៀបរាប់ទិដ្ឋភាពសំខាន់ៗនៃច្បាប់ ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

២. រៀបរាប់ពីការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

## លទ្ធផលរំពឹងទុកនៃមេរៀន

ក. សិក្ខាកាមមានទំនុកចិត្តក្នុងការពន្យល់បញ្ហានានាដែលជាឥទ្ធិពលនៃច្បាប់ស្តីពីការគ្រប់គ្រង រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

ខ. សិក្ខាកាមកំណត់បានពីការប្រែប្រួលនៃរដ្ឋាបាលថ្នាក់ក្រោមជាតិតាមរយៈច្បាប់នេះ

គ. សិក្ខាកាមដឹងពីទំនាក់ទំនងនៃច្បាប់នេះជាមួយនឹងការរៀបចំកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍបែបប្រជាធិប-តេយ្យនៅថ្នាក់ក្រោមជាតិ ។

## កំណត់ចំណាំរបស់អ្នកសម្របសម្រួលៈ

នៅក្នុងមេរៀននេះ អ្នកសម្របសម្រួលមានគោលបំណងចំនួន ២

១. នៅមេរៀនមុនបានគូសបញ្ជាក់ឱ្យឃើញអំពីទស្សនៈវិស័យសម្រាប់កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ។ ដើម្បីសម្រេចបាននូវទស្សនៈវិស័យនេះ រាជរដ្ឋាភិបាលបានអនុម័តច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ក្នុងគោលបំណងតម្រង់ទិសសម្រាប់បន្តការអនុវត្តកំណែទម្រង់នេះ។ មេរៀននេះមានបំណងជួយឱ្យសិក្ខាកាមដឹងពីការផ្លាស់ប្តូរ នៃរចនាសម្ព័ន្ធរដ្ឋបាលថ្នាក់ក្រោមជាតិតាមរយៈច្បាប់នេះ។

២.មេរៀននេះ ដឹកនាំសិក្ខាកាមឱ្យយល់ពីការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅក្រោមថ្នាក់ជាតិ ដែលបានលើឡើងនៅក្នុងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

## មេរៀនទី ៤ ឯកសារបង្ហាញ

ជំពូកទី១_មេរៀនទី៤

# ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

1

## គោលបំណងមេរៀន

១. ពន្យល់គោលបំណង និងរៀបរាប់ទិដ្ឋភាពសំខាន់ៗនៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

២. រៀបរាប់ពីការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

2

## ការរៀបចំដែនដីនៃព្រះរាជាណាចក្រកម្ពុជា

☆ មាត្រា១៤៥ថ្មីនៃរដ្ឋធម្មនុញ្ញបានចែងថា ទឹកដីព្រះរាជាណាចក្រ កម្ពុជា ត្រូវចែកជា រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ។

☆ មាត្រា១៤៦ថ្មីនៃរដ្ឋធម្មនុញ្ញចែងថា រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ត្រូវគ្រប់គ្រងតាមលក្ខខណ្ឌដែលមានក្នុងច្បាប់រៀបចំអង្គការ។

3

## ច្បាប់ស្តីពីការគ្រប់គ្រង រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

- **មាត្រា៤ បានចែងថា:**
  - ភ្នំពេញ ជារាជធានីនៃព្រះរាជាណាចក្រកម្ពុជា។
  - រាជធានីភ្នំពេញចែកជា ខណ្ឌ។
  - ខណ្ឌ ចែកជាសង្កាត់។
- **មាត្រា៥ បានចែងថា:**
  - ខេត្ត ចែកជាក្រុង និងស្រុក។
  - ក្រុង ចែកជាសង្កាត់។
  - ស្រុក ចែកជាឃុំ និងជាសង្កាត់

4


រចនាសម្ព័ន្ធរដ្ឋបាលកន្លងមក និងបច្ចុប្បន្ន
កន្លងមក
បច្ចុប្បន្ន
ព្រះរាជាណាចក្រកម្ពុជា
ខេត្ត
ក្រុង
ស្រុក
ខណ្ឌ
ឃុំ
សង្កាត់
ព្រះរាជាណាចក្រកម្ពុជា
រាជធានីភ្នំពេញ
ខេត្ត
ខណ្ឌ
ក្រុង
ស្រុក
សង្កាត់
សង្កាត់
សង្កាត់
ឃុំ
( ស្រង់ពីសៀវភៅណែនាំគោលការណ៍សំខាន់ៗ ជាមូលដ្ឋានសម្រាប់ការគ្រប់គ្រងថ្នាក់ក្រោមជាតិ ទំព័ ១៥ )
5


និន្នាការសំខាន់ៗនៃច្បាប់គ្រប់គ្រង
ការអភិវឌ្ឍបែបប្រជាធិបតេយ្យ
វិមជ្ឈការសារពើពន្ធ
ក្រុមប្រឹក្សាជាប់ឆ្នោត
រដ្ឋបាលឯកភាព
មុខងាររដ្ឋបាល និង តាមវិស័យ
អភិបាលកិច្ចជនបទ និងទីប្រជុំជន
អំណាចបញ្ញត្តិ និង ប្រតិបត្តិ
6

## ក្រុមប្រឹក្សាជាប់ឆ្នោត

- យោងមាត្រា ១៤. ១១៤. ១១៥. ១៣៨. ១៨៣. ១៨៩

រចនាសម្ព័ន្ធទូទៅ នៃរដ្ឋបាលរាជធានី រដ្ឋបាលខេត្ត រដ្ឋបាលក្រុង រដ្ឋបាលស្រុក និងរដ្ឋបាលខណ្ឌ មានដូចរូបខាងឆ្វេង:

- រចនាសម្ព័ន្ធជាក់ស្តែងនៃរដ្ឋបាលរាជធានី រដ្ឋបាល ខេត្ត រដ្ឋបាលក្រុង រដ្ឋបាលស្រុក និង រដ្ឋបាលខណ្ឌ នឹងកំណត់ដោយបទដ្ឋានដោយឡែក។

*(ស្រង់ពីសៀវភៅណែនាំគោលការណ៍សំខាន់ៗ ជាមូលដ្ឋានសម្រាប់ការគ្រប់គ្រងថ្នាក់ក្រោមជាតិ ទំព័ ២០)*




## រដ្ឋបាលឯកភាព

មាត្រា២នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ បានចែងថា **រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវគ្រប់គ្រងតាមគោលការណ៍ នៃរដ្ឋបាលឯកភាពដើម្បីបង្កើត ជម្រុញ និងធ្វើឱ្យមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យតាមនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ**។

9

## រដ្ឋបាលឯកភាព

**ដើម្បីធានានូវគោលការណ៍ឯកភាព ក្រុមប្រឹក្សាត្រូវមានលទ្ធភាព:**

- **ម្ចាស់ការក្នុងការគ្រប់គ្រង ចាត់ចែងមុខងារ និងធនធានរាប់ទាំងហិរញ្ញវត្ថុ បុគ្គលិក ទ្រព្យសម្បត្តិរបស់ខ្លួន និង**
- **សមត្ថភាពសម្របសម្រួលប្រកបដោយប្រសិទ្ធភាពនូវសកម្មភាពនៃការផ្តល់សេវាកម្ម និងការអភិវឌ្ឍផ្សេងៗទៀត រួមទាំងការផ្តល់សេវា និងការអភិវឌ្ឍដែលធ្វើឡើងដោយក្រសួង ស្ថាប័ននានារបស់រាជរដ្ឋាភិបាល សំដៅឆ្លើយតមសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋនៅមូលដ្ឋានរបស់ខ្លួន។**

*(ស្រង់ពីសៀវភៅណែនាំគោលការណ៍សំខាន់ៗ ជាមូលដ្ឋានសម្រាប់ការគ្រប់គ្រងថ្នាក់ក្រោមជាតិ ទំព័ ១៦-១៧)*

10

## គោលបំណងរៀបចំរដ្ឋបាលឯកភាព




11

## អំណាចបញ្ញត្តិ និងប្រតិបត្តិរបស់ក្រុមប្រឹក្សា

យោងមាត្រា៣០_៣២ ក្រុមប្រឹក្សាសិទ្ធអំណាចពីរគឺ:

- សិទ្ធិអំណាចធ្វើសេចក្តីសម្រេចខាងបញ្ញត្តិ (ដីកា)
- សិទ្ធិអំណាចធ្វើសេចក្តីសម្រេចខាងប្រតិបត្តិ (តាមដាន និងផ្តល់ការណែនាំដែលធានាថាការសម្រេចចិត្តត្រូវបានអនុវត្ត យ៉ាងត្រឹមត្រូវ)

12

## មុខងារជាជម្រើស និងតាមវិស័យរបស់ក្រុមប្រឹក្សា

មាត្រា៣៦: ក្រុមប្រឹក្សាមុខងារពីរគឺ:

-មុខងារជា ជម្រើស (រដ្ឋបាល) និង

-មុខងារជា កាតព្វកិច្ច (វិស័យ)

**កំណត់សម្គាល់:**

ការពន្យល់លម្អិតមាននៅក្នុងសន្ទានុក្រមដែលបានចែកនៅថ្ងៃទី១ 14

# វិមជ្ឈការសារពើពន្ធ

មាត្រាទី ៤៤: (រាជធានី ខេត្ត ក្រុង ស្រុក មានថវិកាផ្ទាល់របស់ខ្លួន ដែលហៅកាត់ថាថវិការដ្ឋបាលថ្នាក់ ក្រោមជាតិ។ ....)

ប្រភពចំណូលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ: ក្រុមប្រឹក្សា រាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សា ក្រុង ក្រុមប្រឹក្សាស្រុក មានសិទ្ធិទទួលបានចំណូលពី:

- ប្រភពនៅមូលដ្ឋាន (មាត្រា២៤៦)
- ប្រភពពីថ្នាក់ជាតិ (មាត្រា២៤៧)
- ប្រភពផ្សេងៗទៀត (មាត្រា២៤៨)
- ការផ្ទេរមូលនិធិពីថ្នាក់ជាតិ (មាត្រា២៤៩)

15



## អភិបាលកិច្ចនៅជនបទ និង នៅទីប្រជុំជន

មានការលូតលាស់មិនដូចគ្នាទាំងចំនួនប្រជាជន និងសេដ្ឋកិច្ច ។ ជាឧទាហរណ៍

| តំបន់ប្រជុំជន | តំបន់ជនបទ |
|---|---|
| ▪ ពឹងផ្អែកលើរបរមិនមែនកសិកម្មភាគច្រើន | ▪ ពឹងផ្អែកលើសកម្មភាពកសិកម្ម |
| ▪ តម្រូវឱ្យមានយន្តការស្របទៅតាមរបរដែលប្រជាពលរដ្ឋនៅទីនេះមាន | ▪ តម្រូវឱ្យមានយន្តការធ្វើស្រែចំការ |
| ▪ ...... | ▪ ...... |

13

## ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ

មាត្រា ១២ នៃច្បាប់គ្រប់គ្រងរដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ បានចែង ថា:ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យរួមមាន:

(១)ភាពជាតំណាងសាធារណៈ
(២)ស្វ័យភាពរបស់មូលដ្ឋាន
(៣)ការពិគ្រោះ យោបល់និងការចូលរួម
(៤)ការឆ្លើយតបនិងគណនេយ្យភាព
(៥)ការលើកកម្ពស់គុណភាពជីវិតរបស់ប្រជាពលរដ្ឋក្នុងមូលដ្ឋាន
(៦)ការលើកស្ទួយសមធម៌
(៧)តម្លាភាពនិងសុចរិតភាព និង
(៨)វិធានការប្រឆាំងអំពើ ពុករលួយនិងការរំលោភអំណាច

## ការពិភាក្សាក្រុមតូច

- មាន ៥ក្រុម (មួយក្រុមមាន២នាក់/៣នាក់) និង មាន **២៥នាទី** សម្រាប់ការ ពិភាក្សា និងត្រៀមបង្ហាញទៅក្រុមធំ
- ក្រុមនីមួយៗមាន**៥នាទី**សំរាប់ការបង្ហាញលទ្ធផលទៅក្រុមធំ
- ក្រុមនីមួយៗនឹងពិភាក្សា ទាក់ទងនឹងប្រធានបទតាមក្រុម
- ក្រុមនីមួយៗនឹងបង្ហាញជាឧទាហរណ៍(១) និង សំណួរ ការយល់ឃើញរបស់ក្រុម

17

## សំណួរពិភាក្សាក្រុម

**១. តើគណៈកម្មាធិការរបស់ក្រុមប្រឹក្សាដែលបានកំណត់ក្នុងច្បាប់មានប៉ុន្មាន និងមានឈ្មោះអ្វីខ្លះ?**

**២. តើវដ្តបាលឯកភាព មានន័យយ៉ាងដូចម្តេច? តើអ្វីជាគោលបំណងក្នុងការ បង្កើតវដ្តបាលឯកភាព?**

**៣. តើក្រុមប្រឹក្សានីមួយៗមានអំណាច និងមុខងារអ្វីខ្លះ?**

**៤. តើក្រុមប្រឹក្សាមានចំណូលពីប្រភពណាខ្លះ? ចូររៀបរាប់**

**៥.ហេតុអ្វីចាំបាច់ឱ្យមានអភិបាលកិច្ចនៅតំបន់ជនបទ និងតំបន់ប្រជុំជន?**[18]

## ជំពូកទី១_មេរៀនទី៤

## ចំណងជើងមេរៀនៈ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

- ឯកសារទី១ : ការរៀបចំដែនដីនៃព្រះរាជាណាចក្រកម្ពុជាផ្អែកលើរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- ឯកសារទី២ : អ្វីជាច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- ឯកសារទី៣ : ក្រុមប្រឹក្សាជាប់ឆ្នោត
- ឯកសារទី៤ : រដ្ឋបាលឯកភាព
- ឯកសារទី៥ : សិទ្ធិអំណាចបញ្ញត្តិ និងនិតិប្រតិបត្តរបស់ក្រុមប្រឹក្សា
- ឯកសារទី៦ : មុខងារតាមវិស័យ និងរដ្ឋបាល
- ឯកសារទី៧ : វិមជ្ឈការសារពើពន្ធ
- ឯកសារទី៨ : អភិបាលកិច្ចនៅជនបទ និងនៅទីប្រជុំជន
- ឯកសារទី៩ : ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ

## ឯកសារទី១

## អភិបាលកិច្ចកម្ពុជាអាស្រ័យរដ្ឋធម្មនុញ្ញ

ជំហានដំបូងនៅប្រទេសកម្ពុជា ដំណើរការនៃវិមជ្ឈការបែបប្រជាធិបតេយ្យទទួលបានជោគជ័យយ៉ាងទូលំទូលាយ។ យើងបានផ្តួចផ្តើមគំនិតថ្មី ដែលជាដំណើរការរយៈពេលវែង នៃការអភិវឌ្ឍន៍លទ្ធិប្រជាធិបតេយ្យស៊ីជំរៅ ដើម្បីធ្វើអោយរដ្ឋបាលមូលដ្ឋានប្រសើរឡើង។

បង្កើនលើការផ្តួចផ្តើមរបស់សហគមន៍នៅក្នុងឆ្នាំ២០០៥ រាជរដ្ឋាភិបាលបានមើលទៅមុខ នូវចក្ខុវិស័យសំរាប់វិមជ្ឈការ និងវិសហមជ្ឈការជាមួយនឹងក្របខណ្ឌយុទ្ធសាស្ត្រវិមជ្ឈការ និងវិសហមជ្ឈការ។ ជាមួយនឹងដំណើរផ្តើមអនុម័តច្បាប់គ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌនេះនៅខែ ឧសភា ឆ្នាំ២០០៨។ កម្ពុជាសព្វថ្ងៃនេះកំពុងចាប់ផ្តើមដំណើរការជំហានទីពីរនៃកំណែទម្រង់។ យើងរំពឹងថានឹងចូលរួមពាក់ព័ន្ធជាមួយសកម្មភាពចែករំលែកអំណាចពីថ្នាក់កណ្តាលទៅឱ្យថ្នាក់ខេត្ត និងស្រុក ដើម្បីជួយជ្រោមជ្រែងធ្វើឱ្យប្រសើរឡើង នូវការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ការធ្វើឱ្យសេវាកម្មមូលដ្ឋានប្រសើរឡើង (សេវាសុខភាព ការអប់រំ ផ្លូវថ្នល់ ទឹក និងអនាម័យ ។ល។) និងពង្រឹងការអនុវត្តមុខងារទៀងទាត់របស់រដ្ឋ (ដូចជាផ្នែកសុរិយោដី និងរុក្ខាប្រមាញ់និងនេសាទ) ។ យោងតាមសំដីរបស់ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ស ខេង ថ្លែងថា ដំណាក់ការចែករំលែកអំណាចពីថ្នាក់កណ្តាលទៅថ្នាក់ក្រោមជាតិនេះនឹងសន្យាថា ការអភិវឌ្ឍដ៏ស៊ីជំរៅ មានសារៈសំខាន់ និងស្របតាមរដ្ឋធម្មនុញ្ញ នៅក្នុងប្រទេកម្ពុជាតាំងពីបានទទួលយកច្បាប់រដ្ឋធម្មនុញ្ញមកអនុវត្តនៅឆ្នាំ១៩៩៣មក។

### <u>ការផ្សាភ្ជាប់ទំនាក់ទំនងរវាងច្បាប់រៀបចំអង្គការ និងរដ្ឋធម្មនុញ្ញ</u>

នៅឆ្នាំ១៩៩៣ កម្ពុជាបានប្រើគោលការណ៍បែងចែកអំណាចដាច់ពីគ្នារវាងអង្គនិតិបញ្ញត្តិ អង្គនិតិប្រតិបត្តិ និងអំណាចតុលាការ។ របនាសម្ព័ន្ធ និងអំណាច អភិបាលកិច្ចនៅព្រះរាជាណាចក្រកម្ពុជាដែលមានព្រះមហាក្សត្រជាអ្នកគ្រងរាជ្យអាស្រ័យរដ្ឋធម្មនុញ្ញ។

## ឯកសារទី២
## តើអ្វីជាច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

- ✓ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ គឺជាក្របខ័ណ្ឌច្បាប់ដែលមានលក្ខណៈចាំបាច់ដើម្បីអនុវត្ត ចក្ខុវិស័យដែលបានគូសបញ្ជាក់នៅក្នុងក្របខ័ណ្ឌយុទ្ធសាស្ត្រស្តីពី**កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ** ។ ច្បាប់នេះប្រកាសឱ្យប្រើប្រាស់ដោយព្រះរាជក្រមលេខ នស/រកម/០៥០៨/ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ ២០០៨។
- ✓ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ គឺជាមូលដ្ឋានគ្រឹះសម្រាប់រាជរដ្ឋាភិបាល បន្តពង្រីកវិសាលភាពនៃការអនុវត្តកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការនៅថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ។

### គោលបំណង

ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌមានគោលបំណងកំណត់ការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ តាមគោលការណ៍នៃរដ្ឋបាលឯកភាពដើម្បីបង្កើត ជំរុញ និងធ្វើឱ្យមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យតាមរយៈនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ។ ដើម្បីអនុវត្តក្របខ័ណ្ឌច្បាប់ទាំងនេះ រាជរដ្ឋាភិបាលចាំបាច់ត្រូវរៀបចំលិខិតបទដ្ឋាននានាជាច្រើនទៀត ហើយទាមទារឱ្យមានការត្រួតពិនិត្យ និងកែសម្រួលលិខិតបទដ្ឋានទាំងនោះជាបន្តបន្ទាប់ផងដែរ ។

(ស្រង់ពីសៀវភៅណែនាំស្តីពីគោលការណ៍សំខាន់ៗជាមូលដ្ឋានសម្រាប់ការគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ ទំព័រ១២-១៣)




ស្រង់ពីសៀវភៅណែនាំគោលការណ៍សំខាន់ៗ ជាមូលដ្ឋានសម្រាប់ការគ្រប់គ្រងថ្នាក់ក្រោមជាតិ ទំព័ ១៥ )

**គណនេយ្យភាពតាមបែបប្រជាធិបតេយ្យសំដៅលើ**

តំណាងជាប់ឆ្នោតដែលមានគណនេយ្យភាពតាមបែបប្រជាធិបតេយ្យ ប្រកាន់យកជម្រើសផ្អែកលើព័ត៌មានបែងចែកធនធានដ៏មានកម្រិត និងអនុវត្តភារកិច្ច និងមុខងាររបស់ខ្លួន ដើម្បីជាប្រយោជន៍សាធារណៈ និងឆ្លើយតបចំពោះតម្រូវការដែលបានលើកឡើងនៅមូលដ្ឋាន។

មានគណនេយ្យភាពតាមបែបប្រជាធិបតេយ្យ នៅពេលប្រជាពលរដ្ឋអាចកំណត់ផលវិបាកតាមរយៈការបោះឆ្នោតទៅលើតំណាងជាប់ឆ្នោត របស់ខ្លួនចំពោះជម្រើស ដែលតំណាងជាប់ឆ្នោតបានប្រកាន់យក ចំពោះរបៀបដែលតំណាងជាប់ឆ្នោតបែងចែកធនធានដ៏មានកម្រិត និងចំពោះការអនុវត្តភារកិច្ច និងមុខងាររបស់ខ្លួន។

(ដកស្រង់ពីមេរៀនសម្រាប់ការយល់ដឹង និងបណ្តុះបណ្តាលអំពីច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ នៅខែ ឧសភា ឆ្នាំ ២០១០ របស់អង្គការ GTZ)

## ក្រុមប្រឹក្សាដែលជាប់ឆ្នោត

**១.** ច្បាប់ស្តីពីវិសោធនកម្មរដ្ឋធម្មនុញ្ញលើមាត្រា១៤៥ថ្មី និងមាត្រា១៤៦ថ្មី ដែលបានដាក់ឱ្យប្រើប្រាស់កាលពីខែកុម្ភៈ ឆ្នាំ២០០៨ បានបើកផ្លូវសម្រាប់កែសម្រួលការរៀបចំទឹកដីនៃព្រះរាជាណាចក្រកម្ពុជាឱ្យកាន់តែសមស្របនឹងស្ថានភាពជាក់ស្តែង។

**២.** មាត្រា១៤៥ថ្មីនៃរដ្ឋធម្មនុញ្ញចែងថា ទឹកដីព្រះរាជាណាចក្រកម្ពុជាចែកជារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់។ មាត្រា ១៤៦ថ្មីចែងផងដែរថា រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ត្រូវគ្រប់គ្រងតាម លក្ខខណ្ឌដែលមានក្នុងច្បាប់រៀបចំអង្គការ។

**៣.** ផ្អែកតាមស្មារតីនៃវិសោធនកម្មរដ្ឋធម្មនុញ្ញខាងលើមាត្រា៤ និងមាត្រា៥នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ បានកំណត់អំពីការរៀបចំទឹកដីនៃព្រះរាជាណាចក្រកម្ពុជាដូចខាងក្រោម :

- ភ្នំពេញជារាជធានីនៃព្រះរាជាណាចក្រកម្ពុជា
- រាជធានីភ្នំពេញចែកជាខណ្ឌ ហើយខណ្ឌចែកជាសង្កាត់
- ខេត្តចែកជា
  - ក្រុង ហើយ ក្រុងចែកជា សង្កាត់
  - ស្រុក ចែកជា ឃុំ និងជា សង្កាត់។

ខាងឆ្វេងនេះជារចនាសម្ព័ន្ធទូទៅរបស់ក្រុមប្រឹក្សាថ្នាក់ក្រោមជាតិ។ រចនាសម្ព័ន្ធជាក់ស្តែងនៃរដ្ឋបាលរាជធានី រដ្ឋបាលខេត្ត រដ្ឋបាលក្រុង រដ្ឋបាលស្រុក និងរដ្ឋបាលខណ្ឌ នឹងកំណត់ដោយ**បទដ្ឋានដោយឡែក**។



(ចំណុចទី ១ និង ២ស្រង់ពីសៀវភៅណែនាំគោលការណ៍សំខាន់ៗ ជាមូលដ្ឋានសម្រាប់ការគ្រប់គ្រងថ្នាក់ក្រោមជាតិ ទំព័ ១៤_១៥)

## ឯកសារទី ៣

- ✓ ទិដ្ឋភាពសំខាន់ៗ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ រួមមាន
  - ក្រុមប្រឹក្សាជាប់ឆ្នោត
  - ការអភិវឌ្ឍបែបប្រជាធិបតេយ្យ
  - អភិបាលកិច្ចនៅជនបទ និងនៅទីប្រជុំជន
  - រដ្ឋបាលឯកភាព
  - អំណាចបញ្ញត្តិ និងអំណាចប្រតិបត្តិរបស់ក្រុមប្រឹក្សា
  - មុខងាររដ្ឋបាល និងមុខងារតាមវិស័យ
  - វិមជ្ឈការសារពើពន្ធ



## ឯកសារទី៤

## រដ្ឋបាលឯកភាព

(ច្បាប់រៀបចំអង្គការ មាត្រា២, ៨, ២៩-៣៤, ៣៦, ១១៤, ១២៣, ១២៤, ១៥៤-១៧០, ១៦៦, ១៧៣, ១៧៩, ១៨៣)

✓ ភ្នំពេញ និង គ្រប់ខេត្ត ក្រុង ស្រុក និង ខណ្ឌ មានរដ្ឋបាលឯកភាព ( មាត្រា ២ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ)។

ច្បាប់រៀបចំអង្គការបានតម្រូវឱ្យរៀបចំរចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងរដ្ឋបាលរាជធានី រដ្ឋបាលខេត្ត រដ្ឋបាលក្រុង រដ្ឋបាលស្រុក និងរដ្ឋបាលខណ្ឌ តាមគោលការណ៍នៃរដ្ឋបាលឯកភាព ។

ដើម្បីធានានូវគោលការណ៍នៃរដ្ឋបាលឯកភាព ក្រុមប្រឹក្សាត្រូវមានលទ្ធភាព

☆ ម្ចាស់ការក្នុងការគ្រប់គ្រង ចាត់ចែងមុខងារ និងធនធានរាប់ទាំងហិរញ្ញវត្ថុ បុគ្គលិក ទ្រព្យសម្បត្តិរបស់ខ្លួន និងសមត្ថភាពសម្របសម្រួលប្រកបដោយប្រសិទ្ធភាពនៃការផ្តល់សេវាកម្ម និងការអភិវឌ្ឍផ្សេងៗទៀត រួមទាំងការផ្តល់សេវា និងការអភិវឌ្ឍដែលធ្វើដោយក្រសួង ស្ថាប័ននានារបស់រាជរដ្ឋាភិបាល សំដៅឆ្លើយតបសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋនៅមូលដ្ឋានរបស់ខ្លួន ។

☆ ឧទាហរណ៍: ដើម្បីធានានូវគោលការណ៍នៃរដ្ឋបាលឯកភាពក្នុងខេត្តមួយ មានន័យថា ក្រុមប្រឹក្សាខេត្តនោះមានសមត្ថភាពពេញលេញក្នុងការគ្រប់គ្រង ចាត់ចែងមុខងារ និងធនធានរាប់ទាំងហិរញ្ញវត្ថុ បុគ្គលិក ទ្រព្យសម្បត្តិដែលខ្លួនមាន និងធ្វើការសម្របសម្រួលសកម្មភាពនៃការផ្តល់សេវា និងការអភិវឌ្ឍផ្សេងៗរបស់មន្ទីរជំនាញជុំវិញខេត្តនោះ ដើម្បីឆ្លើយតបតម្រូវការរបស់ប្រជាពលរដ្ឋក្នុងខេត្តរបស់ខ្លួន ។

(ស្រង់ពីសៀវភៅណែនាំស្តីពីគោលការណ៍សំខាន់ៗជាមូលដ្ឋានសម្រាប់ការគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ ទំព័រ ១៦-១៧)

✓ រដ្ឋបាលឯកភាព មានគោលបំណងជាគន្លឹះចំនួនពីរ គឺ :

- ដើម្បីរួមចំណែកចំពោះការសំរេចបានការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ
- ដើម្បីពង្រឹងអង្គឯកភាពរបស់រដ្ឋ ដើម្បីសម្របសម្រួលនូវរាល់សកម្មភាពរដ្ឋបាលសាធារណៈ នៅក្នុងដែនដីរបស់ខ្លួន (មាត្រា ២ និង ៨ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ)។




## ឯកសារទី៥

### អំណាចបញ្ញត្តិ និងអំណាចប្រតិបត្តិ

អំណាចបញ្ញត្តិមានន័យថា សមត្ថភាពចេញច្បាប់។ ឧ. ក្រុមប្រឹក្សាខេត្តមានសិទ្ធចេញដីកា។

អំណាចប្រតិបត្តិមានសិទ្ធសម្រេចចិត្តធ្វើដើម្បីកិច្ចការរដ្ឋបាលនិងការគ្រប់គ្រង។ឧ. ក្រុមប្រឹក្សាមានសិទ្ធសម្រេចលើគម្រោងមួយដើម្បីអនុវត្តន៍ក្នុងមូលដ្ឋានខ្លួន។

**១.** ក្រុមប្រឹក្សា មានអំណាចបញ្ញត្តិ និងអំណាចប្រតិបត្តិ (មាត្រា ៣០ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ) ។

**២.** ក្រុមប្រឹក្សា ប្រើប្រាស់អំណាចបញ្ញត្តិរបស់ខ្លួន ដោយការធ្វើដីកា ។ ដីកា គឺជាវិធានខាងផ្លូវច្បាប់ដែលបានអនុម័ត ដោយក្រុមប្រឹក្សា ហើយដែលត្រូវអនុវត្ត (មាត្រា ៣១ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ )។

**៣.** ក្រុមប្រឹក្សា ប្រើប្រាស់សិទ្ធិអំណាចបញ្ញត្តិរបស់ខ្លួនដោយការធ្វើដីកាស្របតាមបទបញ្ញត្តិមានចែងក្នុងផ្នែកទី ៣ នៃជំពូកទី ២នៃច្បាប់នេះ។ (មាត្រា ៣២ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ )។

**៤.** ក្រុមប្រឹក្សា ប្រើប្រាស់សិទ្ធិអំណាចប្រតិបត្តិរបស់ខ្លួនដោយ ធ្វើសេចក្តីសំរេច នៅក្នុងអង្គប្រជុំរបស់ក្រុមប្រឹក្សា ហើយ ត្រូវធានាថាសេចក្តីសំរេចរបស់ខ្លួន ត្រូវបានអនុវត្ត (មាត្រា ៣៣ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ) ។

**៥.** នៅពេលក្រុមប្រឹក្សាអនុវត្តអំណាចបញ្ញត្តិ និងអំណាចប្រតិបត្តិរបស់ខ្លួន ក្រុមប្រឹក្សាប្រកាន់យកជម្រើសផ្នែកនយោបាយក្នុងនាមប្រជាពលរដ្ឋរបស់ខ្លួន។ ក្រុមប្រឹក្សា គួរអនុវត្តអំណាចទាំងនេះ បន្ទាប់ពីបានផ្តល់ឱកាសដល់ប្រជាពលរដ្ឋឱ្យសំដែងទស្សនៈរបស់ខ្លួន និងបន្ទាប់ពីក្រុមប្រឹក្សាបានពិចារណាទស្សនៈទាំងនេះ។ ក្រុមប្រឹក្សាគួរធ្វើសេចក្តីសម្រេចរបស់ខ្លួន ដោយពិចារណាទៅលើសម្លេងរបស់ប្រជាពលរដ្ឋ និងភស្តុតាងពីទិន្នន័យការសិក្សា និងព័ត៌មានអំពីជោគជ័យនិងបរាជ័យពីមុន។ គណៈអភិបាល និងបុគ្គលិករបស់ក្រុមប្រឹក្សាមានតួនាទីផ្តល់ភស្តុតាងនោះដល់ក្រុមប្រឹក្សា (មាត្រា ២៩, ៨៦, ១៤៧ នៃអនុក្រឹត្យស្តីពីតួនាទី-ខេត្ត)។

## ឯកសារទី ៦

### មុខងាររដ្ឋបាល និងមុខងារតាមវិស័យ

- ✓ នៅពេលក្រុមប្រឹក្សាថ្មី បន្ទាប់ពីការបោះឆ្នោតលើកទីមួយ ជំនួសរដ្ឋបាលដែលត្រូវតែងតាំងនៅក្នុងដែនដីរបស់ខ្លួន ក្រុមប្រឹក្សា និង គណៈអភិបាល នឹងជំនួសមុខងាររបស់អភិបាល ដែលត្រូវតែងតាំងនៅមុនពេលបោះឆ្នោតលើក ទីមួយរបស់ក្រុមប្រឹក្សា ។ ក្រៅពីនេះ បុគ្គលិកដែលកំពុងបំពេញការងារនៅក្នុងអង្គភាពរដ្ឋបាលរាជធានីភ្នំពេញ ខេត្ត ក្រុង ស្រុក និងខណ្ឌ នឹងត្រូវរៀបចំជាថ្មីដល់ក្រុមប្រឹក្សាដែលជាប់ឆ្នោតថ្មី (មាត្រា ២៧៧, ២៧៨, ២៨១ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មាត្រា ៦, ៧ នៃប្រកាសលេខ ១២៤៩ ស្តីពីកិច្ច ប្រជុំចូលកាន់តំណែង មាត្រា ២០៦ នៃអនុក្រឹត្យស្តីពីតួនាទី-ខេត្ត)។
- ✓ នៅពេលខាងមុខ ក្រុមប្រឹក្សារាជធានីភ្នំពេញ ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក និងក្រុមប្រឹក្សាឃុំ នឹងទទួលបានមុខងារតាមវិស័យជាក់លាក់ដើម្បីអនុវត្ត ។ នៅពេលក្រុមប្រឹក្សាទទួលមុខងារ ក្រុមប្រឹក្សាទាំងនេះ ក៏នឹងទទួលបានហិរញ្ញវត្ថុ បុគ្គលិក និងទ្រព្យសម្បត្តិ ចាំបាច់ផងដែរដើម្បីអនុវត្តមុខងារនោះ (មាត្រា ២៩, ២១៣, ២១៤, ២១៧, ២២០, ២២២ ដល់ ២៧៣ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ )។

  ឧទាហរណ៍ -មុខងារវិស័យអប់រំស្រមៃមើលថា ក្រុមប្រឹក្សានឹងទទួលបានមុខងារឱ្យបង្កើត

និងប្រតិបត្តិសាលាមត្តេយ្យ។ ប្រសិនបើមុខងារនោះត្រូវបានផ្ទេរឱ្យក្រុមប្រឹក្សាស្រុក។ ក៏ទទួលបានផងដែរនូវ

- ☆ ហិរញ្ញវត្ថុ ដើម្បីបង្កើត និងដំណើរការសាលាមត្តេយ្យជាប្រចាំ
- ☆ បុគ្គលិក ដូចជា គ្រូសាលាមត្តេយ្យដែលមានស្រាប់
- ☆ ទ្រព្យសម្បត្តិ ដែលពាក់ព័ន្ធនឹងសាលាមត្តេយ្យ ដូចជា ឧបករណ៍បង្រៀន របស់ក្មេងលេង និងប្រហែលជាអគារសាលាមតេយ្យដែលមានស្រាប់ផងដែរ ។

## ឯកសារ ទី ៧

## វិមជ្ឈការសារពើពន្ធ

**១.** ភ្នំពេញ និងគ្រប់ខេត្ត ក្រុង និងស្រុក មានថវិកាប្រចាំឆ្នាំរបស់ខ្លួនផ្ទាល់។ (មាត្រា ៤៤ នៃច្បាប់ស្តីពីការគ្រប់គ្រង រដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ)។

**២.** ឃុំ និងសង្កាត់ទាំងអស់នៅក្នុងស្រុក មានថវិការបស់ខ្លួនផ្ទាល់ ដូចមានចែងនៅក្នុងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ (មាត្រា ៧៣ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់)។

**៣.** ក្រុមប្រឹក្សា ត្រូវមានហិរញ្ញវត្ថុគ្រប់គ្រាន់ ពីការផ្ទេរថ្នាក់ជាតិ និងពីចំណូលរបស់ខ្លួនផ្ទាល់ដើម្បី

- ☆ គ្រប់គ្រងចាត់ចែង និងអនុវត្តមុខងារជាកាតព្វកិច្ចរបស់ខ្លួន
- ☆ ជ្រើសរើស គ្រប់គ្រង ចាត់ចែង និងអនុវត្តមុខងារជាជម្រើសរបស់ខ្លួន
- ☆ អនុវត្តតួនាទី ភារកិច្ចតាមច្បាប់កំណត់
- ☆ ចំណាយផ្នែករដ្ឋបាលរបស់ខ្លួន និង
- ☆ អនុវត្តមុខងារភាគិច្ចសម្រាប់ជំរុញដល់ការអភិវឌ្ឍតាមបែបប្រជាធិប្បតេយ្យក្នុងដែនសមត្ថកិច្ចរបស់ខ្លួន

(ស្រង់ពីសៀវភៅណែនាំគោលការណ៍សំខាន់ៗ ជាមូលដ្ឋានសម្រាប់ការគ្រប់គ្រងថ្នាក់ក្រោមជាតិ ទំព័ ៧២)

ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ផ្តល់ការចង្អុលបង្ហាញយ៉ាងទូលំទូលាយអំពីហិរញ្ញវត្ថុ និងការគ្រប់គ្រងហិរញ្ញវត្ថុរបស់ក្រុមប្រឹក្សា។ ទោះបីជាយ៉ាងណាក៏ដោយ ត្រូវមានការបកស្រាយលើខ្លឹមសារលំអិតជាច្រើនទៀតទាក់ទងនឹងហិរញ្ញវត្ថុ និងការគ្រប់គ្រងហិរញ្ញវត្ថុរបស់ក្រុមប្រឹក្សានៅក្នុងច្បាប់ និងលិខិតបទដ្ឋានរួមមានច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលនៅថ្នាក់ក្រោមជាតិ (មាត្រា ៤៤-៤៦, ១៣៧, ២៤៤, ២៤៥, ២៤៨, ២៥៣, ២៥៥ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី



## ឯកសារទី៨

### អភិបាលនៅទីប្រជុំជន និងនៅទីជនបទ

ហេតុអ្វី អភិបាលនៅទីជនបទ និងនៅទីប្រជុំជនមានលក្ខណៈខុសគ្នា?

១. នៅកម្ពុជាទីប្រជុំជនកំពុងមានលូតលាស់ឆាប់រហ័ស។ តំបន់ប្រជុំជនកំពុងរីករាលដាលយ៉ាងលឿន ដូចជាកំណើនប្រជាពលរដ្ឋ និងចំណាកស្រុករបស់ពលរដ្ឋពីជនបទទៅទីប្រជុំជន។ គេរំពឹងថា ដំណើការនេះនឹងកើនឡើងនៅពេលអនាគត។

២. ទីប្រជុំជននីមួយៗផ្នែកមួយមានលក្ខណៈភូមិសាស្ត្រសង្គម សេដ្ឋកិច្ច និងនយោបាយ និងដង់ស៊ីតេប្រជាពលរដ្ឋខ្ពស់ និងការពឹងពាក់អាស្រ័យគ្នាទៅវិញទៅមក និងការប្រាស្រ័យទាក់ទងគ្នាមានកំរិតខ្ពស់។ ផ្នែកសេដ្ឋកិច្ច ទីប្រជុំជនផ្តែកលើសកម្មភាពមិនមែនកសិកម្មទេ គឺអាចរួមបញ្ចូលសកម្មភាពរោងចក្រឧស្សាហកម្ម និងសេវានានា។ តំបន់ជនបទមានលក្ខណៈខុសគ្នាជាមួយនឹងទុនផ្នែកសង្គម ការប្រាស្រ័យទាក់ទង ច្រើនតែភ្ជាប់ជាមួយអ្នកភូមិ និងសេដ្ឋកិច្ចអាស្រ័យលើកសិកម្មជាចំបង។

៣. តំបន់ប្រជុំជន និងជនបទមានលក្ខណៈខុសគ្នា និងតម្រូវការ និងអាទិភាពខុសគ្នា។ ទោះបីមានពេលខ្លះតម្រូវការ និងអាទិភាពប្រហែលគ្នា ជានិច្ចជាកាលគេត្រូវមានយន្តការខុសគ្នាដើម្បីឆ្លើយតបឱ្យបានសមស្រប ។

៤. ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ កំណត់រចនាសម្ព័ន្ធ និងប្រព័ន្ធអភិបាលកិច្ចខុសៗ គ្នាសម្រាប់តំបន់ទីប្រជុំជន និងតំបន់ជនបទ។ វិសោធនកម្មរដ្ឋធម្មនុញ្ញត្រូវបានអនុម័តលើមាត្រា ១៤៥ និង ១៤៦ នៃរដ្ឋធម្មនុញ្ញដែលកំណត់ភាពខុសគ្នារវាងទីប្រជុំជន និងជនបទ។

៥. នៅរាជធានីភ្នំពេញ មានអភិបាលកិច្ចបីថ្នាក់គឺ រាជធានីភ្នំពេញ ខណ្ឌ និង សង្កាត់ ។ ដើម្បីឱ្យមានការអភិវឌ្ឍដែលមានលក្ខណៈស៊ីសង្វាក់គ្នា និងមានលក្ខណៈឯកភាពគ្នានៅតំបន់ប្រជុំជននៃរាជធានីភ្នំពេញ ខណ្ឌ និង សង្កាត់ ត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យ និងការគ្រប់គ្រងរបស់ក្រុមប្រឹក្សារាជធានីភ្នំពេញ (មាត្រា ៤, ១០៦,១០៧នៃ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ) ។

៦. ខេត្តត្រូវចែកចេញជាក្រុងទីប្រជុំជន និងស្រុកជនបទ។ ក្រុង ចែកចេញជាសង្កាត់ ។ ដើម្បីធានាឱ្យមានការអភិវឌ្ឍដែលមានលក្ខណៈស៊ីសង្វាក់គ្នា និងមានលក្ខណៈឯកភាពគ្នានៅក្នុងក្រុង សង្កាត់ត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យ និងការគ្រប់គ្រងរបស់ក្រុមប្រឹក្សាក្រុង (មាត្រា ៥, ១១០, ១១១ នៃច្បាប់ស្តីពី

ការគ្រប់គ្រងរដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ) ។

៧. ស្រុក ទោះបីជាភាគច្រើន មានលក្ខណៈជាជនបទក្តី ស្រុកអាចមានសង្កាត់មួយ ឬច្រើន បន្ថែមពីលើឃុំ។ ដូច្នេះ ស្រុកត្រូវចែកចេញជាឃុំ និងសង្កាត់ (មាត្រា ៥ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ)។

៨. តំបន់ទីប្រជុំជន និងតំបន់ជនបទ ត្រូវតែកំណត់ និងបោះព្រំប្រទល់ដែលជាជំហានទីមួយនៅក្នុងការអនុវត្តបទបញ្ញត្តិនៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ទាក់ទងនឹងអភិបាលកិច្ចនៅជនបទ និងនៅទីប្រជុំជន ។ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ប្រមើលមើលថា ព្រំប្រទល់ អាចត្រូវបង្កើតឡើង លុបចេញ ឬ កែសំរួលនៅរាជធានីភ្នំពេញ ខេត្ត ក្រុង ស្រុក ឬ ខណ្ឌ (មាត្រា ៦ និង ៧នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ)។

៩. ក្រោមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ទីរួមខេត្តទាំងអស់ ត្រូវបានកំណត់រួចហើយ ថាជាក្រុង។ ដូចគ្នានេះដែរ តំបន់ប្រជុំជនបន្ថែមមួយចំនួន ត្រូវបានកំណត់ថាជាក្រុង រួមមានក្រុងសួងនៅខេត្ត កំពង់ចាម និងក្រុងបាវិតនៅខេត្តស្វាយរៀង។

នៅពេលបច្ចុប្បន្ន កម្ពុជាមាន

- រាជធានីភ្នំពេញ
- ២៣ ខេត្ត
- ២៦ ក្រុង
- ១៥៩ ស្រុក
- ៨ ខណ្ឌ
- ១៤១៤ ឃុំ និង
- ២០៤ សង្កាត់

(អនុក្រឹត្យលេខ ១៨ ស្តីពីចំនួនសមាជិកក្រុមប្រឹក្សា)

បច្ចុប្បន្ន មិនមានសង្កាត់នៅក្នុងស្រុកទេ។ នៅពេលសង្កាត់នៅក្នុងស្រុក ត្រូវបង្កើតឡើង សង្កាត់ ទាំងនេះនឹងរក្សាថានៈរបស់ខ្លួនក្រោមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ដូច្នេះ មិនស្ថិតនៅក្រោមការត្រួតពិនិត្យ និងការគ្រប់គ្រងរបស់ក្រុមប្រឹក្សា ស្រុកឡើយ (មាត្រា ២៨៣នៃច្បាប់ស្តីពីការគ្រប់គ្រង រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ)។ ដ្យាក្រាមខាងក្រោម បង្ហាញពីតំបន់ប្រជុំជន និង តំបន់ជនបទក្រោមច្បាប់អង្គការ ។ តំបន់ប្រជុំជន ត្រូវបាន បង្ហាញជាពណ៌ក្រហម ។ ខេត្ត ទោះបីជាមានពណ៌ខ្មៅក្តី ក៏មានផ្នែកទីប្រជុំជន និង ជនបទ ។



**ឯកសារទី៩**

**ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ**

- ✓ គោលបំណងរបស់ក្រុមប្រឹក្សា គឺដើម្បីបង្កើតជម្រុញ និងធ្វើឱ្យមានចីរភាពការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ (មាត្រា ២, ១១, ២០ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ) ។
- ✓ ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ និងអភិបាលកិច្ចល្អ សំដៅលើស្ថាប័ននយោបាយដែលមានប្រសិទ្ធិភាព និងការប្រើប្រាស់ដោយមានការទទួលខុសត្រូវលើអំណាចនយោបាយ និងការគ្រប់គ្រងធនធានសាធារណៈដោយរដ្ឋ ដើម្បីជាប្រយោជន៍ដល់ និងក្នុងនាមប្រជាពលរដ្ឋរបស់ខ្លួន ។
- ✓ តាមគោលការណ៍ច្បាប់ ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យរួមមាន
  - ភាពតំណាងជាសាធារណៈ
  - ស្វ័យភាពរបស់មូលដ្ឋាន
  - ការពិគ្រោះយោបល់ និងការចូលរួម
  - ការឆ្លើយតប និងគណនេយ្យភាព
  - ការលើកកំពស់គុណភាពនៃជីវភាពរស់នៅរបស់ប្រជាពលរដ្ឋនៅមូលដ្ឋាន
  - ការលើកស្ទួយសមធម៌
  - តម្លាភាព និងសុចរិតភាព
  - វិធានការប្រឆាំងអំពើពុករលួយ និងការរំលោភអំណាច

(មាត្រា ១២ ៤៧ ដល់៤៩ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ) និងមាននៅក្នុងសៀវភៅណែនាំស្តីពីគោលការណ៍សំខាន់ៗជាមូលដ្ឋានសម្រាប់ការគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ ទំព័រ ១៧_១៩)

# មេរៀនទី ៤ ឯកសារជំនួយរូបភាព




៧
# រចនាសម្ព័ន្ធរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ



**យោងមាត្រា៣០ ក្រុមប្រឹក្សាមានសិទ្ធិអំណាចពីរគឺ :**

- សិទ្ធិអំណាចធ្វើសេចក្តីសម្រេចខាងបញ្ញត្តិ និង
- សិទ្ធិអំណាចធ្វើសេចក្តីសម្រេចខាងប្រតិបត្តិ

| តួនាទី និងភារកិច្ចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ | រាជធានី | ខេត្ត | ក្រុង | ស្រុក | ខណ្ឌ |
|---|---|---|---|---|---|
| **គសាងផែនការ** : ក្រុមប្រឹក្សាត្រូវរៀបចំ និងអនុម័តផែនការអភិវឌ្ឍន៍រយៈពេល ០៥ឆ្នាំ និងកម្មវិធីវិនិយោគ ៣ឆ្នាំរំកិលប្រចាំឆ្នាំ។ | ✓ | ✓ | ✓ | ✓ | ✓ |
| **គ្រប់គ្រងហិរញ្ញវត្ថុ** : ក្រុមប្រឹក្សារៀបចំ និងអនុម័តគម្រោង ថវិកាប្រចាំឆ្នាំ និងក្របខ័ណ្ឌចំណាយរយៈពេលមធ្យម។ | ✓ | ✓ | ✓ | ✓ | ✓ |
| **តាមដានត្រួតពិនិត្យ និងវាយតម្លៃ** : ក្រុមប្រឹក្សាត្រូវតាមដាន និងវាយតម្លៃជារៀងរាល់ឆ្នាំ ទៅលើការអនុវត្តផែនការអភិវឌ្ឍន៍របស់ខ្លួន ដោយរាប់បញ្ចូលទាំងផ្នែកនៃផែនការអភិវឌ្ឍន៍... | ✓ | ✓ | ✓ | ✓ | ✓ |
| **គ្រប់គ្រងបុគ្គលិក** : ក្រុមប្រឹក្សាត្រូវពិនិត្យ និងសម្រេចអំពីការតែងតាំង ការបណ្តេញចោល ការកម្រិតប្រាក់បៀវត្ស និងផលប្រយោជន៍ផ្សេងទៀតរបស់បុគ្គលិក។ | ✓ | ✓ | ✓ | ✓ | ✓ |
| **រៀបចំរបាយការណ៍** : ក្រុមប្រឹក្សាត្រូវរៀបចំ និងអនុម័តមិនឱ្យលើសពីសែសិបប្រាំ(៤៥)ថ្ងៃបន្ទាប់ពីដំណាច់ឆ្នាំនីមួយៗ... | ✓ | ✓ | ✓ | ✓ | ✓ |
| **ផ្សព្វផ្សាយព័ត៌មាន** : ក្រុមប្រឹក្សាត្រូវបង្កលក្ខណៈងាយស្រួលឱ្យ សាធារណជនទទួលព័ត៌មានអំពីរបាយការណ៍ របៀបវារៈប្រជុំ កំណត់ហេតុប្រជុំ ដីកា ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ និងប្រកាស ទាំងអស់... | ✓ | ✓ | ✓ | ✓ | ✓ |
| **រាយការណ៍អំពីសកម្មភាពរំលោភអំណាច** : ក្នុងករណីដែល មានការរំលោភអំណាចកើតមានឡើង នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ក្រុមប្រឹក្សាត្រូវមានភារកិច្ចរាយការណ៍ជាលាយល័ក្ខណ៍អក្សរជាបន្ទាន់ជូនរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។ | ✓ | ✓ | ✓ | ✓ | ✓ |
| **ដោះស្រាយវិវាទ** : ក្រុមប្រឹក្សាត្រូវចាត់វិធានការសមស្រប ដើម្បីដោះស្រាយវិវាទនៅមូលដ្ឋាន ដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួន... | ✓ | ✓ | ✓ | ✓ | ✓ |

ច្បាប់រៀបចំអង្គការបានតម្រូវឱ្យរៀបចំរចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងរដ្ឋបាលរាជធានី រដ្ឋបាលខេត្ត រដ្ឋបាលក្រុង រដ្ឋបាលស្រុក និងរដ្ឋបាលខណ្ឌតាមគោលការណ៍នៃរដ្ឋបាលឯកភាព។
ដើម្បីធានានូវគោលការណ៍នៃរដ្ឋបាលឯកភាព ក្រុមប្រឹក្សាត្រូវមានលទ្ធភាព :

- ម្ចាស់ការក្នុងការគ្រប់គ្រង ចាត់ចែងមុខងារ និងធនធានរាប់ទាំងហិរញ្ញវត្ថុ បុគ្គលិក ទ្រព្យសម្បត្តិរបស់ខ្លួន និង
- សមត្ថភាពសម្របសម្រួលប្រកបដោយប្រសិទ្ធភាពនូវសកម្មភាពនៃការផ្តល់សេវាកម្ម និងការអភិវឌ្ឍផ្សេងៗទៀត រួមទាំងការផ្តល់សេវា និងការអភិវឌ្ឍដែលធ្វើឡើងដោយក្រសួង ស្ថាប័ននានារបស់រាជរដ្ឋាភិបាល សំដៅឆ្លើយតបសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋនៅក្នុងមូលដ្ឋានរបស់ខ្លួន។

ការបង្កើតរដ្ឋបាលឯកភាពនៅរដ្ឋបាលទាំងនេះ គឺសំដៅដល់ការពង្រឹងអង្គឯកភាពរបស់រដ្ឋដើម្បីសម្របសម្រួលនូវរាល់សកម្មភាពរដ្ឋបាលសាធារណៈនៅក្នុងដែនដីរបស់ខ្លួន។

**ប្រភពឯកសារ** សៀវភៅណែនាំស្តីពី "គោលការណ៍សំខាន់ៗជាមូលដ្ឋានសម្រាប់ការគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ" (ទំព័រ ១៦ និង ២២-២៥)

ផលិតដោយ Pact Cambodia VBNK
ឧបត្ថម្ភដោយ THE WORLD BANK គជអប NCDD

## ជំពូកទី១_មេរៀនទី៤

## ចំណងជើងមេរៀនៈ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

**រយៈពេល ៖** ២ ម៉ោង

### របៀបសម្របសម្រួលមេរៀន

| ពេលវេលា | សកម្មភាព និងវិធីសាស្រ្ត | សម្ភារៈ/ឯកសារ |
|---|---|---|
| ១៥នាទី | **១. សេចក្តីផ្តើម**<br>ក. រំលើកអ្នកចូលរួមពី ការវិវឌ្ឍន៍នៃកំណែទម្រង់ វិមជ្ឈការ និង វិសហមជ្ឈការនៅកម្ពុជា។<br>ឧទាហរណ៍<br>– រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា មាត្រា ១៤៥ និង១៤៦ ថ្មី ។<br>– សភាជាតិ និងព្រឹទ្ធសភាអនុម័តច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និងច្បាប់ស្តីពីការបោះឆ្នោត ។<br>– នៅដើមឆ្នាំ២០០២ប្រជាពលរដ្ឋបោះឆ្នោតក្រុមប្រឹក្សាឃុំ សង្កាត់ និង នៅឆ្នាំ ២០០៧ និងលើកទី៣ នឹងធ្វើនៅឆ្នាំ ២០១២។<br>– នៅឆ្នាំ២០០៥រាជរដ្ឋាភិបាលអនុម័តគោលនយោបាយស្តីពីក្របខ័ណ្ឌយុទ្ធសាស្រ្តសម្រាប់កំណែទម្រង់ វិមជ្ឈការ និងវិសហមជ្ឈការ។<br>– នៅឆ្នាំ២០០៨ សភាជាតិបង្កើតច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ។<br>– នៅឆ្នាំ២០០៩ ក្រុមប្រឹក្សាត្រូវបានបោះឆ្នោតអសកល | – រូបភាព_ផ្ទាំងធំទី២ ស្តីពីដំណើរការវិវឌ្ឍន៍នៃលទ្ធិប្រជាធិបតេយ្យ និងការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅកម្ពុជា<br>- ឯកសារទី១ |

| | | |
|---|---|---|
| | នៅថ្នាក់ក្រោមជាតិ ។<br>ខ. ពន្យល់គោលបំណងមេរៀន<br>បង្ហាញពីចំណងជើង និង គោលបំណងមេរៀនទី៤ (បទបង្ហាញទី១ និងទី២) ។ | ☆ បទបង្ហាញ |
| ៤៥នាទី | **២. <u>ការបង្ហាញក្នុងក្រុមធំ - ទិដ្ឋភាពទូទៅនៃច្បាប់ស្តីពី ការគ្រប់ គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ</u>**<br>ក. រៀបរាប់ពីការរៀបចំដែនដី នៃព្រះរាជាណាចក្រកម្ពុជា (ស្លាយទី ៣ និង៤) ។<br>ខ. បង្ហាញពីរចនាសម្ព័ន្ធរដ្ឋបាលកន្លងមក និង បច្ចុប្បន្ន យោងតាមច្បាប់ស្តីពី ការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ (បទបង្ហាញទី៥) ។<br>គ. បង្ហាញពី ទិដ្ឋភាពសំខាន់ៗនៃច្បាប់នេះ (បទបង្ហាញទី៦) និង ពន្យល់ពីអត្ថន័យនៃក្រុមប្រឹក្សាជាប់ឆ្នោត និងរចនាសម្ព័ន្ធរដ្ឋបាលថ្នាក់ក្រោមជាតិ (បទបង្ហាញទី៧) ។<br>ឃ. ពន្យល់ពី ការអភិវឌ្ឍបែបប្រជាធិបតេយ្យ ក្នុងបទបង្ហាញទី៨ ។ អ្នកសម្របសម្រួលធ្វើការបកស្រាយពីគោលការណ៍នៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យទាក់ទងនឹងការអនុវត្តកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ និង គោលដៅនៃកំណែទម្រង់ដែលជាមូលដ្ឋានសម្រាប់ការរៀបចំកម្មវិធីជាតិ ។ | |

| | | |
|---|---|---|
| | ង. ពន្យល់ពីអត្ថន័យនៃពាក្យរដ្ឋបាលឯកភាពនៅក្នុង (ស្លាយទី៩-១១)។ អ្នកសម្របសម្រួលអានឯកសារទី៤ ដើម្បីការពន្យល់បានលម្អិតអំពីគោលការណ៍នៃរដ្ឋបាលឯកភាពតាមការចាំបាច់។<br><br>ច. ពន្យល់ពីអំណាចរបស់ក្រុមប្រឹក្សា នៅក្នុង (ស្លាយទី១២) និងលើកឧទាហរណ៍ ដូចមានក្នុងឯកសារទី៥។<br><br>ឆ. ពន្យល់ពីអភិបាលកិច្ចនៅជនបទនិងទីប្រជុំជន ស្លាយទី១៣។ អ្នកសម្របសម្រួលបង្ហាញពីភាពខុសគ្នានៃតម្រូវ ការនិងអាទិភាពនៅតាមតំបន់នានា ដើម្បីឆ្លើយតប សមស្រប (ឯកសារទី៨)។<br><br>ជ. ពន្យល់អត្ថន័យពីមុខងារជាជម្រើស និង មុខងារតាមវិស័យបទបង្ហាញទី ១៤ និងពន្យល់នៅក្នុងឯកសារទី៦ ។<br><br>ឈ. ពន្យល់អត្ថន័យនៃវិមជ្ឈការសារពើពន្ធបទបង្ហាញទី១៥-១៦ និង បង្ហាញរូបនៃឯកសារទី៧ អំពីការសង្ខេបពីប្រភពចំណូលរបស់ក្រុមប្រឹក្សា ។ | ☆ បទបង្ហាញទី៣ និង៤<br><br>☆ បទបង្ហាញទី៥<br>- ឯកសារទី២<br>- ឯកសារទី៣<br><br>☆ បទបង្ហាញទី៨<br>- ឯកសារទី៩<br><br>☆ បទបង្ហាញទី ៩-១១<br>- ឯកសារទី៤ |

| | | |
|---|---|---|
| (៥០ នាទី) | **១. ការពិភាក្សាក្រុមតូច**<br>ក. ចែកសិក្ខាកាមជា ៥ក្រុម ហើយក្រុមនីមួយៗមាន ២៥នាទី សម្រាប់ពិភាក្សា និង៥នាទីសម្រាប់ការបង្ហាញ លទ្ធផលពិភាក្សាតាមក្រុមនីមួយៗ ។<br>ខ. រកកន្លែងឱ្យក្រុមនីមួយៗជួបពិភាក្សា។ សំណួរជាក់លាក់ ក្នុងប្រធានបទតាមក្រុមមាន ។<br>**ក្រុម១** តើគណៈកម្មាធិការរបស់ក្រុមប្រឹក្សាដែលបានចែងក្នុងច្បាប់ មានប៉ុន្មាន និងមានឈ្មោះអ្វីខ្លះ ?<br>**ក្រុម២** តើរដ្ឋបាលឯកភាពមានន័យយ៉ាងដូចម្តេច? តើអ្វីជាគោលបំណងក្នុងការបង្កើតរដ្ឋបាលឯកភាព ?<br>**ក្រុម៣** តើក្រុមប្រឹក្សានីមួយៗមានអំណាច និងមុខងារអ្វីខ្លះ ?<br>**ក្រុម៤** តើក្រុមប្រឹក្សាមានចំណូលពីប្រភពណាខ្លះ? ចូររៀបរាប់<br>**ក្រុម៥** ហេតុអ្វីចាំបាច់ឱ្យមានអភិបាលកិច្ចនៅតំបន់ជនបទ និង តំបន់ប្រជុំជន?<br>គ. អ្នកសម្របសម្រួលប្រាប់សិក្ខាកាមឱ្យកម្រិតចំលើយមិន អោយលើសពី ៣-៤ (អាចជាឧទាហរណ៍) និងដើរពិនិត្យពីការពិភាក្សាតាមក្រុម។<br>**២. ការសន្និដ្ឋានមេរៀន**<br>ក. អ្នកសម្របសម្រួលសង្ខេបចំណុចដែលសិក្ខាកាមបានដឹង អំពីរចនាសម្ព័ន្ធរដ្ឋបាលនៅថ្នាក់ក្រោមជាតិ។ | ឯកសារទី១-៩ |

| | | |
|---|---|---|
| ១០ នាទី | ខ. សួរសិក្ខាកាមប្រសិនបើពួកគាត់មានការបារម្ភពេល មាន ការប្តូរ ពីរចនាសម្ព័ន្ធរដ្ឋបាលសព្វថ្ងៃ ទៅរចនាសម្ព័ន្ធថ្មីរបស់រដ្ឋបាលក្រោមថ្នាក់ជាតិ។<br>គ. អ្នកសម្របសម្រួលលើកទឹកចិត្តអោយសិក្ខាកាមសួរសំណួរ ដើម្បីឱ្យរដ្ឋាភិបាលដឹងអំពីការបារម្ភរបស់សង្គមស៊ីវិល ។<br>អ្នកសម្របសម្រួលនឹងរក្សាទុកនូវសំណួរទាំងឡាយណាដែលមិនអាចឆ្លើយបានដើម្បីបន្តស្វែងយល់បន្តទៀត។ | ឯកសារទី១_៩ |

## សម្ភារៈបង្រៀន

- ឯកសារទី១ : ការរៀបចំដែនដីនៃព្រះរាជាណាចក្រកម្ពុជា
- ឯកសារទី២ : អ្វីជាច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- ឯកសារទី៣ : ក្រុមប្រឹក្សាជាប់ឆ្នោត
- ឯកសារទី៤ : រដ្ឋបាលឯកភាព
- ឯកសារទី៥ : សិទ្ធិអំណាចបញ្ញត្តិ និងប្រតិបត្តរបស់ក្រុមប្រឹក្សា
- ឯកសារទី៦ : មុខងារតាមវិស័យ និងរដ្ឋបាល
- ឯកសារទី៧ : វិមជ្ឈការសារពើពន្ធ
- ឯកសារទី៨ : អភិបាលកិច្ចនៅជនបទ និង នៅទីប្រជុំជន
- ឯកសារទី៩ : ការអភិវឌ្ឍបែបប្រជាធិបតេយ្យ
- រូបភាពផ្ទាំងធំទី៧ស្តីពីរចនាសម្ព័ន្ធរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

- ហ្វីត ផ្ទាំង ក្រដាស បង់ស្អិត និងក្រដាសពណ៌

**ឯកសារយោង**


- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ជំពូកទី១៣ថ្មី អំពីការគ្រប់គ្រងរដ្ឋបាល ត្រង់មាត្រាទី ១៤៥ និង១៤៦ ថ្មី។
- ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ នៅឆ្នាំ២០០៨

  www.ncdd.gov.kh
- មេរៀនសម្រាប់ការយល់ដឹង និងបណ្តុះបណ្តាលអំពីច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ នៅខែ ឧសភា ឆ្នាំ ២០១០ របស់អង្គការ GTZ
- សៀវភៅណែនាំ ស្តីពីគោលការណ៍សំខាន់ៗជាមូលដ្ឋានសម្រាប់ការគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោម ជាតិ របស់គ.ជ.អ.ប ខែមិថុនា ឆ្នាំ ២០០៩។

# ជំពូកទី២

## ការណែនាំអំពីកម្មវិធីជាតិ
## សម្រាប់ការអភិវឌ្ឍតាមបែប
## ប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
## ២០១០_២០១៩

# មេរៀនទី១

## ការណែនាំអំពីកម្មវិធីជាតិ សម្រាប់ការអភិវឌ្ឍតាមបែប ប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ២០១០-២០១៩



# មេរៀនទី ១

# ការណែនាំអំពីកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ២០១០-២០១៩

**គោលបំណង** : នៅចុងបញ្ចប់មេរៀននេះ អ្នកចូលរួមនឹងអាច :

១. បកស្រាយពីរូបភាពទំនាក់ទំនងរវាងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ។

២. រៀបរាប់ពីគោលដៅ និងគោលបំណងកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ។

៣. រៀបរាប់ពីរចនាសម្ព័ន្ធរបស់កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ រួមជាមួយនឹងសមាសធាតុកម្មវិធីទាំង ៥ កម្មវិធីអន្តរវិស័យទាំង៣ និងលទ្ធផលរំពឹងទុកដែលពាក់ព័ន្ធសង្គមស៊ីវិល ។

## លទ្ធផលរំពឹងទុកនៃមេរៀន:

ក. សិក្ខាកាមយល់ដឹងពីកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។ សិក្ខាកាមមានឯកសារយោង ដើម្បីជួយសម្រួលដល់ការផ្សព្វផ្សាយចំណេះដឹងដល់អ្នកផ្សេងទៀត ដែលមិនបានចូលរួមនៅក្នុងវគ្គបណ្តុះបណ្តាលនេះ។

ខ. សិក្ខាកាមទទួលបានឧទាហរណ៍ បង្ហាញពីទំនាក់ទំនងរវាងកម្មវិធីជាតិ និងច្បាប់អង្គការ និង

គ. សិក្ខាកាមកំណត់បាននូវគោលបំណងចេញពីកម្មវិធីទាំង៥ ពាក់ព័ន្ធជាមួយនឹងការចូលរួមជាសាធារណៈ និងការតាមដានត្រួតពិនិត្យការអនុវត្តការងារដោយសង្គមស៊ីវិល ។

## កំណត់ចំណាំរបស់អ្នកសម្របសម្រួល:

នៅក្នុងមេរៀននេះ អ្នកសម្របសម្រួលមានគោលបំណងចំនួន ២

១. សិក្ខាកាម ត្រូវកំណត់ឱ្យបានច្បាស់ជាស្រេច នូវទិដ្ឋភាពសំខាន់ៗរបស់ច្បាប់គ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ (មើលមេរៀន ទី ៤ ក្នុងជំពូកទី ១) ។ អ្នកសម្របសម្រួលគួរតែជួយពន្យល់ដល់សិក្ខាកាមថាកម្មវិធីជាតិ គឺជាកម្មវិធីដែលរាជរដ្ឋាភិបាលកម្ពុជាបានរៀបចំឡើង ដើម្បីបន្តអនុវត្តកំណែទម្រង់នៅថ្នាក់ក្រោមជាតិ និងចូលរួមការអនុវត្តច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ។

២. អ្នកសម្របសម្រួលត្រូវតែធ្វើយ៉ាងណាឱ្យការពន្យល់ស្តីពីកម្មវិធីជាតិមានលក្ខណៈសាមញ្ញ។ មានន័យថា ជួយឱ្យសិក្ខាកាមយល់ថា កម្មវិធីទាំង ៥ នឹងបន្តសម្រាប់រយៈពេលរបស់កម្មវិធី ពីឆ្នាំ២០១០-២០១៩ និងឱ្យសិក្ខាកាមដឹងពីកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជា ។

៣. អ្នកសម្របសម្រួល គួរតែយល់ដឹងពីគោលបំណងនីមួយៗ មាតិការបស់មេរៀន នេះនិងរំលឹកឡើងវិញពីប្រវត្តិកំណែ ទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ និងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។ អ្នកសម្របសម្រួលគួរតែរក្សានូវវិសាលភាព មាតិកាដែលបានរៀបរាប់នៅក្នុងប្លង់មេរៀននេះ។ អ្នកសម្របសម្រួលគួរតែជូនព័ត៌មានដល់សិក្ខាកាមឱ្យបានដឹងថា គាត់នឹងមានឱកាសដើម្បីសិក្សាស្វែងយល់នូវប្រធានបទផ្សេងៗទៀតដែលពាក់ព័ន្ធនឹងមេរៀននេះនៅក្នុងមេរៀនបន្ទាប់។



មេរៀនទី ១ ឯកសារបង្ហាញ

ជំពូកទី២ មេរៀនទី១

# ការណែនាំអំពីកម្មវិធីជាតិ សម្រាប់ការអភិវឌ្ឍតាមបែប ប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ២០១០-២០១៩

1

## គោលបំណងមេរៀនទី១

១. រៀបរាប់ពីទំនាក់ទំនងរវាងច្បាប់គ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងកម្មវិធីជាតិ

២. រៀបរាប់ពីគោលដៅ និងទិសដៅរបស់កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

៣. រៀបរាប់ពីរចនាសម្ព័ន្ធរបស់កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ រួមជាមួយសមាសធាតុកម្មវិធីទាំង៥ និងកម្មវិធីអន្តរវិស័យទាំង៣

2

ជំពូកទី២

## ទំនាក់ទំនងច្បាប់រៀបចំអង្គការ និងកម្មវិធីជាតិ

តើរូបភាព
មនុស្សនេះ
មានន័យ
ដូចម្តេច
ចំពោះអ្នក?




3

## តើអ្វីទៅជា កម្មវិធីជាតិ?

- របៀបវារៈរបស់រាជរដ្ឋាភិបាលសម្រាប់រយៈពេល១០ឆ្នាំក្នុងការបន្តកំណែទម្រង់អភិបាលកិច្ច និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- ឆ្លុះបញ្ចាំងពីការប្តេជ្ញាចិត្តខាងគោលនយោបាយរបស់រាជរដ្ឋាភិបាល ចំពោះចក្ខុវិស័យ គោលនយោបាយ និងយុទ្ធសាស្ត្រដែលមានក្នុងក្របខ័ណ្ឌយុទ្ធសាស្ត្រវិមជ្ឈការ និង វិសហមជ្ឈការ
- ឆ្លុះបញ្ចាំងពីការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាល ក្នុងការអនុវត្តច្បាប់អង្គការ

4

## ហេតុអ្វីបានជាមានកម្មវិធីជាតិ?

- ពង្រឹង និងពង្រីកលទ្ធិប្រជាធិបតេយ្យនៅថ្នាក់មូលដ្ឋាន
- ជម្រុញការអភិវឌ្ឍថ្នាក់មូលដ្ឋាន និងកាត់បន្ថយភាពក្រីក្រ
- បង្ហាញពីការប្តេជ្ញាចិត្តខាងគោលនយោបាយរបស់រាជរដ្ឋាភិបាល
- បន្តគាំទ្រការអនុវត្តគោលនយោបាយវិមជ្ឈការ
- បន្តគាំទ្រគោលនយោបាយកំណែទម្រង់
- គាំទ្រការអនុវត្តច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

5




មេរៀនទី១

# តើគោលដៅ និងគោលបំណង ក្នុងកម្មវិធីជាតិមានន័យដូចម្តេច?

7

# គោលដៅ

- អភិវឌ្ឍតាមបែបប្រជាធិបតេយ្យដោយមានការចូលរួម និងមានសមធម៌
- លើកកម្ពស់បរិមាណ គុណភាព និងការទទួលបានសេវាសាធារណៈឱ្យមានភាពប្រសើរឡើង
- រួមចំណែកដល់ការកាត់បន្ថយភាពក្រីក្រ ។

8

## គោលបំណង

បង្កើតប្រព័ន្ធគ្រប់គ្រងនៅថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ ផ្អែកតាមគោលការណ៍នៃការចូលរួមតាមបែបប្រជាធិបតេយ្យ ដែលធានាដល់ការអនុវត្តប្រកបដោយតម្លាភាព និងគណនេយ្យភាពសំដៅលើកកម្ពស់ការអភិវឌ្ឍមូលដ្ឋាន និងការផ្តល់សេវាសាធារណៈ ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋ ព្រមទាំងរួមចំណែកក្នុងការកាត់បន្ថយភាពក្រីក្រនៅតាមមូលដ្ឋាននីមួយៗ។

9

## តើសមាសធាតុកម្មវិធីនីមួយៗមានន័យដូចម្តេច?

10

ឧបសម្ព័ន្ធ

ថ្ងៃទី២

## សមាសធាតុកម្មវិធី និងគោលបំណង

| សមាសធាតុកម្មវិធី | អត្ថាធិប្បាយគោលបំណងកម្មវិធី |
|---|---|
| **សមាសធាតុកម្មវិធីទី១** ការរៀបចំស្ថាប័នរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ | បង្កើតតួនាទីស្ថាប័នរដ្ឋបាលថ្នាក់ក្រោមជាតិ តាមរយៈការរៀបចំរចនាសម្ព័ន្ធ ប្រព័ន្ធគ្រប់គ្រងមួយផ្អែកតាមគោលការណ៍នៃការចូលរួម តាមបែបប្រជាធិបតេយ្យ |
| **សមាសធាតុកម្មវិធីទី២** ប្រព័ន្ធគ្រប់គ្រង និងអភិវឌ្ឍធនធានមនុស្ស | រៀបចំឱ្យមានមន្ត្រីរាជការស៊ីវិលប្រកបដោយវិជ្ជាជីវៈ និងមានឆន្ទៈមោះមុតក្នុងការ បំពេញការងារនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលមានគណនេយ្យភាពចំពោះក្រុមប្រឹក្សា និងគ្រប់គ្រងដោយក្រុមប្រឹក្សា។ |

11

## សមាសធាតុកម្មវិធី និងគោលបំណង

| សមាសធាតុកម្មវិធី | អត្ថាធិប្បាយគោលបំណងកម្មវិធី |
|---|---|
| **សមាសធាតុកម្មវិធីទី៣** ការផ្ទេរមុខងារ | លើកកម្ពស់បរិមាណ និងគុណភាពសេវាសាធារណៈ តាមរយៈការផ្ទេរមុខងារឱ្យទៅ រដ្ឋបាលថ្នាក់ក្រោមជាតិ ដោយភ្ជាប់ជាមួយនូវការទទួលខុសត្រូវ សិទ្ធិអំណាច និងធនធានដែលពាក់ព័ន្ធនឹងការអនុវត្តមុខងារទាំងនោះ |

12

## សមាសធាតុកម្មវិធី និងគោលបំណង

| សមាសធាតុកម្មវិធី | អត្ថាធិប្បាយគោលបំណងកម្មវិធី |
|---|---|
| **សមាសធាតុកម្មវិធីទី៤** ប្រព័ន្ធគ្រប់គ្រងថវិកា ហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិ របស់រដ្ឋបាលថ្នាក់ក្រោមជាតិ | បង្កើតប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុមួយរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ មានលទ្ធភាពកៀរគរ និងទទួលបានធនធានគ្រប់គ្រាន់ ព្រមទាំងមានសិទ្ធិអំណាចក្នុងការគ្រប់គ្រង និងបែងចែកធនធានទាំងនោះប្រកបដោយតម្លាភាព និងគណនេយ្យភាព។ |
| **សមាសធាតុកម្មវិធីទី៥** ស្ថាប័នគាំទ្រកំណែទម្រង់ វិមជ្ឈការ និងវិសហមជ្ឈការ | ពង្រឹងស្ថាប័នថ្នាក់ជាតិនានាសម្រាប់ដឹកនាំការអនុវត្ត កម្មវិធីជាតិ រយៈពេល១០ឆ្នាំ និងគាំទ្រដល់រដ្ឋបាល ថ្នាក់ក្រោមជាតិ។ |

13

## សំណួរ

១.តើលទ្ធផលរំពឹងទុករបស់កម្មវិធីមានអ្វីខ្លះ?

២.តើលទ្ធផលរំពឹងទុកនីមួយៗ ពាក់ព័ន្ធសង្គមស៊ីវិល ឬទេ? ហេតុអ្វី?

14

## គោលបំណង និងលទ្ធផលរំពឹងទុកកម្មវិធីទី១

**សមាសធាតុកម្មវិធីទី១: ការរៀបចំស្ថាប័នរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ**

| គោលបំណង | លទ្ធផលរំពឹងទុកពាក់ព័ន្ធសង្គមស៊ីវិល |
|---|---|
| បង្កើតតួនាទីស្ថាប័នរដ្ឋបាលថ្នាក់ក្រោមជាតិ | ១.៣. រៀបចំនិងដាក់ឱ្យអនុវត្តនូវកម្មវិធីនានាដើម្បីលើកកម្ពស់ការចូលរួមរបស់ប្រជាពលរដ្ឋ និងការការពារសិទ្ធិរបស់ប្រជាពលរដ្ឋ។<br>១.៥. ដាក់បញ្ចូលស្តង់ដារសមភាព និងសមធម៌យេនឌ័រទៅក្នុងប្រព័ន្ធគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ។<br>១.៧ រៀបចំ និងអនុវត្តនូវកម្មវិធីសម្រាប់ដាក់បញ្ចូលបញ្ហាប្រែប្រួលអាកាសធាតុទៅក្នុងដំណើរការកសាងផែនការ ការគ្រប់គ្រង និងការផ្តល់សេវាសាធារណៈរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ |

## គោលបំណង និងលទ្ធផលរំពឹងទុកកម្មវិធីទី២

**សមាសធាតុកម្មវិធីទី២— ប្រព័ន្ធគ្រប់គ្រង និងអភិវឌ្ឍន៍ធនធានមនុស្ស**

| គោលបំណង | លទ្ធផលរំពឹងទុក |
|---|---|
| រៀបចំឱ្យមានមន្ត្រីរាជការស៊ីវិលប្រកបដោយវិជ្ជាជីវៈ និងមានឆន្ទៈមោះមុតក្នុងការបំពេញការងារនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលមានគណនេយ្យភាពចំពោះក្រុមប្រឹក្សា និងគ្រប់គ្រងដោយក្រុមប្រឹក្សា។ | ២.៤ បញ្ជ្រាបយេនឌ័រក្នុងកម្មវិធីគ្រប់គ្រងធនធានមនុស្ស និងកម្មវិធីអភិវឌ្ឍន៍សមត្ថភាព |

16

## គោលបំណង និងលទ្ធផលរំពឹងទុកកម្មវិធីទី៣

| សមាសធាតុកម្មវិធីទី៣ - ការផ្ទេរមុខងារ | |
|---|---|
| **គោលបំណង** | **លទ្ធផលរំពឹងទុកពាក់ព័ន្ធសង្គមស៊ីវិល** |
| ផ្ទេរមុខងារឱ្យទៅរដ្ឋបាលថ្នាក់ក្រោមជាតិ ដោយភ្ជាប់ជាមួយនូវការទទួលខុសត្រូវ សិទ្ធិអំណាច និងធនធាន | ៣.៤ យកចិត្តទុកដាក់ដល់ការលើកកម្ពស់សមត្ថភាពយេនឌ័រ និងការឆ្លើយតបចំពោះក្រុមជនងាយរងគ្រោះនានានៅក្នុងការផ្ទេរមុខងារ<br>៣.៥ លើកកម្ពស់ការទទួលបាន និងការប្រើប្រាស់សេវាសាធារណៈ នៅរដ្ឋបាលថ្នាក់ក្រោមជាតិ ស្របតាមតម្រូវការរបស់ប្រជាពលរដ្ឋ និងមានគណនេយ្យភាពចំពោះប្រជាពលរដ្ឋ |

17

## គោលបំណង និងលទ្ធផលរំពឹងទុកកម្មវិធីទី៤

| សមាសធាតុកម្មវិធី ទី៤ - ប្រព័ន្ធ គ្រប់គ្រងថវិកា ហិរញ្ញវត្ថុ និង ទ្រព្យសម្បត្តិ | |
|---|---|
| **គោលបំណង** | **លទ្ធផលរំពឹងទុកពាក់ព័ន្ធសង្គមស៊ីវិល** |
| បង្កើតប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ លទ្ធភាពគៀរគរ ទទួលធនធានគ្រប់គ្រាន់ មានសិទ្ធិគ្រប់គ្រងបែងចែកធនធាន ដោយតម្លាភាព និងគណនេយ្យភាព | ៤.២ ប្រព័ន្ធកសាងផែនការ និងថវិកាបានលើកកម្ពស់សមត្ថភាពយេនឌ័រ និងឆ្លើយតបចំពោះក្រុមជនងាយរងគ្រោះ<br>៤.១៣. រដ្ឋបាលថ្នាក់ក្រោមជាតិមានលទ្ធភាពរៀបចំផែនការប្រកបដោយតម្លាភាព ដោយយកចិត្តទុកដាក់លើការចំណាយពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុ។ |

18

ជំពូក២

## គោលបំណង និងលទ្ធផលរំពឹងទុកកម្មវិធីទី៥

| សមាសធាតុកម្មវិធីទី៥ - ស្ថាប័នគាំទ្រកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ | |
|---|---|
| **គោលបំណង** | **លទ្ធផលរំពឹងទុកពាក់ព័ន្ធសង្គមស៊ីវិល** |
| ពង្រឹងស្ថាប័នថ្នាក់ជាតិនានា សម្រាប់ដឹកនាំការអនុវត្តកម្មវិធីជាតិ | ៥.៧ ស្ថាប័ននានាសម្រាប់គាំទ្រកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការបង្កើន និងជំរុញការយកចិត្តទុកដាក់ក្នុងការលើកកម្ពស់សមភាព និងសមធម៌យេនឌ័រ និងការឆ្លើយតបចំពោះក្រុមជនងាយរងគ្រោះ |

19

## សំណួរ

១. តើអ្វីជាកម្មវិធីអន្តរវិស័យ? តើកម្មវិធីអន្តរវិស័យ មានន័យដូចម្តេចចំពោះអ្នក?

២. តើការពាក់ព័ន្ធជាមួយសមាសធាតុកម្មវិធីទាំង៥ យ៉ាងដូចម្តេច?

20

## កម្មវិធីអន្តរវិស័យ

| កម្មវិធីអន្តរវិស័យ | អត្ថាធិប្បាយ |
|---|---|
| ការបញ្ជ្រាបយេនឌ័រ | • ការលើកកម្ពស់សមភាពយេនឌ័រ និងការបង្កើនភាពអង់អាចដល់ស្ត្រី<br>• តួនាទីស្ត្រីក្នុងការធ្វើសេចក្តីសម្រេច នៅក្នុងគ្រប់ផ្នែកនៃអភិបាលកិច្ច<br>• ការធ្វើឱ្យស្ត្រីទទួលបានសេវាសាធារណៈផ្សេងៗកាន់តែប្រសើរឡើង<br>• ធានាសេវាសាធារណៈទាំងអស់ដែលជាតម្រូវការរបស់ស្ត្រីត្រូវបានឆ្លើយតប ។ |

21

## កម្មវិធីអន្តរវិស័យ (ត)

| កម្មវិធីអន្តរវិស័យ | អត្ថាធិប្បាយ |
|---|---|
| ការប្រែប្រួលអាកាសធាតុ | • ការឆ្លើយតបចំពោះការគំរាមកំហែងដែលមាន លក្ខណៈជាសាកល ចំពោះអាយុ ជីវិត ជីវភាពរស់នៅ និងប្រព័ន្ធគាំទ្រជីវិតនានា<br>• ទាមទារឱ្យមានការអនុម័ត ជាបន្ទាន់នូវរបៀបវារៈនានាដែលពាក់ព័ន្ធ នឹងការប្រើប្រាស់ជាតិកាបូនកម្រិតទាប<br>• រៀបចំដើម្បីការពារចំពោះហានិភ័យថ្មីៗផ្នែកអាកាសធាតុដែលគំរាមកំហែងដល់ ប្រទេសកម្ពុជា<br>• បង្កើតប្រព័ន្ធសម្របសម្រួល ថ្នាក់ជាតិមួយ ដែលគាំទ្រដល់សង្គមក្នុងរយៈពេលវែងនិងដំណើរការសម្របសម្រួលជាមួយនឹងការប្រែប្រួលអាកាសធាតុ |

## កម្មវិធីអន្តរវិស័យ (ត)

| កម្មវិធីអន្តរវិស័យ | អត្ថាធិប្បាយ |
|---|---|
| គណនេយ្យភាព និងការការពារក្រុមជនក្រីក្រ និងក្រុមជនងាយរងគ្រោះ | បង្កើតនូវខ្សែគណនេយ្យភាពថ្មី ប្រព័ន្ធ នីតិវិធី យន្តការ និងវិធីសាស្ត្រដើម្បីធានាថា:<br>• (១) សិទ្ធិរបស់ប្រជាពលរដ្ឋត្រូវបានការពារ, (២) សំឡេងរបស់ប្រជាពលរដ្ឋត្រូវបានដឹងឮ, (៣) ធនធាននានាត្រូវបានប្រើប្រាស់ស្របតាមច្បាប់, (៤) ប្រជាពលរដ្ឋមានសិទ្ធិស្របច្បាប់ក្នុងការទទួលបាននូវព័ត៌មានអំពីការធ្វើសេចក្តីសម្រេច និងការចាត់វិធានការនានារបស់ក្រុមប្រឹក្សា, (៥) ផ្តល់នូវមធ្យោបាយសមស្រប ដល់ប្រជាពលរដ្ឋក្នុងការវាយតម្លៃសកម្មភាពនានារបស់ក្រុមប្រឹក្សា និងដើម្បីឱ្យក្រុមប្រឹក្សាមានគណនេយ្យភាពចំពោះទង្វើរបស់ខ្លួន ដែលអនុវត្តមិនបានសមស្រប<br>• ខ្សែគណនេយ្យភាពថ្មី ប្រព័ន្ធ នីតិវិធី យន្តការ និងវិធីសាស្ត្រទាំងនេះ ត្រូវបានបញ្ចូលទៅក្នុងគ្រប់ផ្នែកទាំងអស់នៃកំណែទម្រង់របស់រាជរដ្ឋាភិបាល ព្រមទាំងទៅក្នុងដំណើរការខាងបញ្ញត្តិ និងក្នុងដំណើរការរដ្ឋបាល |

## ហេតុផលដែលមានកម្មវិធីអន្តរវិស័យនាំ៣

—គាំទ្រគោលនយោបាយដែលមានស្រាប់ និងយុទ្ធសាស្ត្រកំពុងអនុវត្តរបស់រាជរដ្ឋាភិបាលកម្ពុជា

—ធានាឱ្យមានការទទួលខុសត្រូវនៅគ្រប់កម្រិតរដ្ឋបាលថ្នាក់ក្រោមជាតិ

24

## ហេតុផលដែលអង្គការសង្គមស៊ីវិលត្រូវដឹងពីអន្តរកម្មវិស័យកម្មវិធីជាតិ១០ឆ្នាំ

១. ជាដៃគូអនុវត្តកម្មវិធីជាមួយរដ្ឋបាលនៅថ្នាក់មូលដ្ឋាន

២. ស្វែងយល់ពីសមាសធាតុកម្មវិធី ដើម្បីតម្រង់ទិសការអនុវត្តការងារ

៣. ធានាពីការយល់ដឹង និងសមត្ថភាព គ្រប់ដណ្តប់លើកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ ។

25

## រចនាសម្ព័ន្ធកម្មវិធីជាតិ

| | | | | |
|---|---|---|---|---|
| ***គោលដៅ*** | ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ | | • មានការចូលរួម និងសមធម៌<br>• លើកកម្ពស់គុណភាពសេវា | ដើម្បីចូលរួមចំណែកកាត់បន្ថយភាពក្រីក្រ |
| **គោលបំណង** | ប្រព័ន្ធគ្រប់គ្រងថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និង ឃុំ សង្កាត់ | | • មានការចូលរួម តម្លាភាព និងគណនេយ្យភាព<br>• លើកម្ពស់ការអភិវឌ្ឍមូលដ្ឋាន<br>• ផ្តល់សេវាសាធារណៈឆ្លើយតបតម្រូវការ | |
| សមាសធាតតុកម្មវិធីទី១:ការរៀបចំស្ថាប័ន រដ្ឋបាលថ្នាក់ក្រោម ជាតិ | សមាសធាតុកម្មវិធីទី២: ប្រព័ន្ធ គ្រប់គ្រង និងអភិវឌ្ឍធនធានមនុស្ស | សមាសធាតុកម្មវិធីទី៣:ការផ្ទេរមុខងារ | សមាសធាតុកម្មវិធីទី៤:ប្រព័ន្ធ គ្រប់គ្រងថវិកា ហិរញ្ញវត្ថុ | សមាសធាតុកម្មវិធីទី៥: ស្ថាប័នគាំទ្រកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ |
| ប្រព័ន្ធគ្រប់គ្រងរចនាសម្ព័ន្ធថ្នាក់ក្រោមជាតិកើតឡើង<br>• មានការចូលរួម<br>• ឆ្លើយតបខ្សែគណនេយ្យភាពថ្មី<br>• មានតម្លភាព<br>• គណនេយ្យភាព<br>• សេវាសាធារណៈ ប្រកបដោយប្រសិទ្ធភាព និងនិរន្តរភាព | មន្ត្រីរាជការស៊ីវិល<br>• ប្រកបដោយវិជ្ជាជីវៈ<br>• មានឆន្ទៈមោះមុត<br>• គណនេយ្យភាព | • លើកកម្ពស់គុណភាពសេវាសាធារណៈ<br>• ភ្ជាប់ទំនាក់ទំនងការទទួល ខុសត្រូវ សិទ្ធិអំណាច និង ធនធាន | • មានលទ្ធភាពកៀរគរ<br>• ទទួលបានធនធានគ្រប់គ្រាន់<br>• មានសិទ្ធិអំណាចគ្រប់គ្រង និងចែកចាយធនធន<br>• មានតម្លាភាព<br>• មានគណនេយ្យភាព | • ពង្រឹងស្ថាប័នថ្នាក់ជាតិ<br>• គាំទ្រដល់រដ្ឋ-បាលថ្នាក់ក្រោមជាតិ |
| កម្មវិធីអន្តរវិស័យ: (១) ការបញ្ជ្រាបយេនឌ័រ (២) ការប្រែប្រួលអាកាសធាតុ (៣)គណនេយ្យភាព និងការការពារក្រុមជនក្រីក្រ និងក្រុមជនងាយរងគ្រោះ | | | | |

# មេរៀនទី១
# ស្ដីពីការណែនាំពីកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ (២០១០_២០១៩)

## ១. គោលដៅ និងគោលបំណង

គោលដៅកម្មវិធីជាតិ គឺដើម្បីអភិវឌ្ឍតាមបែបប្រជាធិបតេយ្យដោយមានការចូលរួមនិងមានសមធម៌ លើកកម្ពស់បរិមាណ គុណភាព និងការទទួលបានសេវាសាធារណៈឱ្យមានភាពប្រសើរឡើង និងរួមចំណែកកាត់បន្ថយភាពក្រីក្រ។

គោលបំណងកម្មវិធីជាតិ គឺដើម្បីបង្កើតប្រព័ន្ធគ្រប់គ្រងនៅថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ ផ្អែកតាមគោលការណ៍នៃការចូលរួមតាមបែបប្រជាធិបតេយ្យដែលធានាដល់ការអនុវត្តប្រកបដោយតម្លាភាព និង គណនេយ្យភាព សំដៅលើកកម្ពស់ការអភិវឌ្ឍមូលដ្ឋាន និងការផ្ដល់សេវាសាធារណៈដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋ ព្រមទាំងរួមចំណែកក្នុងការកាត់បន្ថយភាពក្រីក្រនៅតាមមូលដ្ឋាននីមួយៗ។

## ២. វិសាលភាពនៃក្របខ័ណ្ឌអនុវត្តកម្មវិធីជាតិ

ក្របខ័ណ្ឌអនុវត្តកម្មវិធីជាតិបានផ្ដោតទៅលើគ្រប់ទិដ្ឋភាពនៃរចនាសម្ព័ន្ធ ប្រព័ន្ធ និងកិច្ចប្រតិបត្តិការនានារបស់រាជរដ្ឋាភិបាល ដែលនឹងរួមចំណែកដល់ការបង្កើតរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលមានការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាព និងប្រជាធិបតេយ្យ។ កម្មវិធីជាតិរយៈពេល១០ឆ្នាំបានកំណត់នូវសកម្មភាពសំខាន់ៗដែលត្រូវអនុវត្ត ដូចជាការរៀបចំសេចក្ដីព្រាង និងការអនុម័តលិខិតបទដ្ឋានគតិយុត្តនានា ត្រូវស្របនឹងការប្ដេជ្ញាចិត្តខាងគោលនយោបាយក្នុងការអនុវត្តកម្មវិធី ដើម្បីធានាថា ការប្ដេជ្ញាចិត្តខាងគោលនយោបាយទទួលបានលទ្ធផលជោគជ័យតាមការរំពឹងទុក។

### ក). ទំនាក់ទំនងទៅវិញទៅមកក្នុងកម្មវិធី

កម្មវិធីជាតិបានរៀបចំឱ្យមានសមាសធាតុកម្មវិធីចំនួន៥ ដែលមានទំនាក់ទំនងទៅវិញទៅមកក្នុងការកសាងសមត្ថភាពស្ថាប័នដែលគាំទ្រ និងបង្កលក្ខណៈឱ្យសម្រេចបាននូវគោលដៅនៃកំណែទម្រង់វិមជ្ឈការ និងវិសហ_មជ្ឈការ។ សកម្មភាពនានាដែលបានលើកឡើងនៅក្នុងសមាសធាតុកម្មវិធីទាំងប្រាំនេះ គឺគួសបញ្ជាក់ពីលក្ខណៈដែលត្រូវអនុវត្ត ព្រមៗគ្នា និងមានភាពប្រទាក់ក្រឡាគ្នានៃប្រព័ន្ធ និងកិច្ចប្រតិបត្តិការរបស់រាជរដ្ឋាភិបាល ពោលគឺមិនមែនមានគោលបំណងបញ្ជាក់អំពីភាពជាលំដាប់លំដោយនៃសកម្មភាពនានាក្នុងការគាំទ្រកំណែទម្រង់

វិមជ្ឈការ និងវិសហមជ្ឈការនោះទេ។ សកម្មភាពនានាដែលបានលើកឡើងនៅក្នុងសមាសធាតុកម្មវិធីទាំងប្រាំនៃកម្មវិធីជាតិ មានដូចខាងក្រោម :

- **សមាសធាតុកម្មវិធីទី១ :** ការរៀបចំស្ថាប័នរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីធានាថា ហេដ្ឋារចនាសម្ព័ន្ធស្ថាប័នជាមូលដ្ឋានត្រូវបានបង្កើតឡើងដើម្បីសម្របសម្រួលដល់ការធ្វើសេចក្តីសម្រេច និងការបែងចែក សិទ្ធិអំណាចនៅក្នុងចំណោមថ្នាក់រដ្ឋបាលនានានៃរដ្ឋបាលថ្នាក់ក្រោមជាតិ និងរវាងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ព្រមទាំងដើម្បីសម្របសម្រួលការធ្វើស្ថាប័នភាវូបនីយកម្មយន្តការនានាសំដៅធានាឱ្យដំណើរការអនុវត្តស្របតាមគោលការណ៍ប្រជាធិបតេយ្យ នីតិរដ្ឋ និងធានាការពារបាននូវសិទ្ធិរបស់ប្រជាពលរដ្ឋ។ (សមាសធាតុកម្មវិធីទី១ បង្ហាញអំពីសកម្មភាព ចាំបាច់នានាក្នុងការរៀបចំស្ថាប័ននៅរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីធានាថា រដ្ឋបាលថ្នាក់ក្រោមជាតិអាចគ្រប់គ្រងចាត់ចែងការងារប្រកបដោយ ប្រសិទ្ធភាព និងមានលក្ខណៈប្រជាធិបតេយ្យ។
- **សមាសធាតុកម្មវិធីទី២ :** ប្រព័ន្ធគ្រប់គ្រង និងអភិវឌ្ឍធនធានមនុស្ស នឹងធ្វើឱ្យមានការកែសម្រួលការគ្រប់គ្រងមន្ត្រីរាជការស៊ីវិល និងបុគ្គលិកនៅថ្នាក់ក្រោមជាតិ។ ការសម្រេចបាននូវលទ្ធផលនានាដែល បានកំណត់នៅក្នុងសមាសធាតុកម្មវិធីនេះ ធ្វើឱ្យមានការផ្លាស់ប្តូរប្រព័ន្ធលើកទឹកចិត្តក្នុងការបំពេញការងាររបស់មន្ត្រីរាជការស៊ីវិល ពីអ្នកដែលបំពេញការងារឱ្យគ្រាន់តែបានចប់តាមការកំណត់ទៅជាអ្នកដែលបម្រើសេវាជូនប្រជាពលរដ្ឋយ៉ាងពិតប្រាកដ។ ការគ្រប់គ្រងបុគ្គលិកតាមទស្សនទាននេះនឹងជួយដល់ការលើកកម្ពស់គណនេយ្យភាពក្នុងការផ្តល់សេវាសាធារណៈនានា។ (សមាសធាតុកម្មវិធីទី២ បង្ហាញអំពីបញ្ហាដែលពាក់ព័ន្ធនឹងការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្សរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ)។
- **សមាសធាតុកម្មវិធីទី៣ :** ការផ្ទេរមុខងារ គឺជាស្នូលនៃកំណែទម្រង់ទាំងមូល ពីព្រោះសមាសធាតុកម្មវិធីនេះបានកំណត់អំពី (ក)ការទទួលខុសត្រូវ និងសិទ្ធិអំណាចដែលត្រូវអនុវត្តតាមរយៈរចនាសម្ព័ន្ធ ស្ថាប័នដែលបានបង្កើតឡើងក្នុងសមាសធាតុកម្មវិធីទី១ និង(ខ)ធនធាននានាដែលត្រូវគ្រប់គ្រងចាត់ចែងផ្អែកតាមប្រព័ន្ធ និងនីតិវិធីប្រតិបត្តិការនានាដែលបានកំណត់នៅក្នុងសមាសធាតុកម្មវិធីទី១ ទី២ និងទី៤។ (សមាសធាតុកម្មវិធីទី៣ បង្ហាញអំពីជំហានចាំបាច់នានាក្នុងការផ្ទេរមុខងារ និងធនធានព្រមទាំងការលើកកម្ពស់ការផ្តល់សេវាសាធារណៈតាមរយៈរដ្ឋបាលថ្នាក់ក្រោមជាតិ។ ទំព័រ ១៤)
- **សមាសធាតុកម្មវិធីទី៤ :** ប្រព័ន្ធគ្រប់គ្រងថវិកា ហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិនានា នឹងចូលរួមចំណែកក្នុងការរៀបចំកម្មវិធីជាតិលើទិដ្ឋភាពពីរ : ទីមួយ គឺការបង្កើតប្រព័ន្ធហិរញ្ញវត្ថុ និងក្របខ័ណ្ឌ

ប្រតិបត្តិការដែលចាំបាច់សម្រាប់ការគ្រប់គ្រងធនធានហិរញ្ញវត្ថុទាំងឡាយ (ឧទាហរណ៍ : ចំណូល និងទ្រព្យសម្បត្តិ) និងទីពីរ គឺការកំណត់យន្តការនានាក្នុងការផ្តល់ហិរញ្ញប្បទានសម្រាប់សកម្មភាពនានារបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ សមាសធាតុកម្មវិធីទី៤បង្ហាញអំពីប្រព័ន្ធហិរញ្ញវត្ថុ និងថវិកាដ៏ច្បាស់លាស់មួយរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

- **សមាសធាតុកម្មវិធីទី៥ :** ស្ថាប័នគាំទ្រកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការគឺដើម្បីធានាឱ្យមានការរៀបចំស្ថាប័នដែលចាំបាច់ និងបេសកកម្មនានារបស់ស្ថាប័ន ដើម្បីជំរុញកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ព្រមទាំងបង្កលទ្ធភាពឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិអាចគ្រប់គ្រង និងចាត់ចែងការងារប្រកបដោយប្រសិទ្ធភាព និងមាននិរន្តរភាព។ សមាសធាតុកម្មវិធីទី៥បង្ហាញអំពីការបង្កើតស្ថាប័នដែលចាំបាច់សម្រាប់សម្របសម្រួលការគាំទ្រដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ព្រមទាំងការកែសម្រួលនូវស្ថាប័នដែលកំពុងមាននាពេលបច្ចុប្បន្ន ដើម្បីធានាថា ស្ថាប័នទាំងនោះ ត្រូវមានលក្ខណៈស៊ីសង្វាក់គ្នាជាមួយរចនាសម្ព័ន្ធរដ្ឋបាល ដែលត្រូវបានរៀបចំឡើងវិញតាមរយៈ កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ។



## ខ). កម្មវិធីអន្តរវិស័យ

ប្រធានបទចំនួនបីដែលមានលក្ខណៈអន្តរវិស័យ គឺការបញ្ជ្រាបយេនឌ័រ ការប្រែប្រួលអាកាសធាតុ និងគណនេយ្យភាព ត្រូវបានដាក់បញ្ចូលទៅក្នុងសមាសធាតុកម្មវិធីទាំង៥។

### ខ.១). ការបញ្ជ្រាបយេនឌ័រ

ការបញ្ជ្រាបយេនឌ័រនៅក្នុងកម្មវិធីជាតិ គឺជាការខិតខំប្រឹងប្រែងក្នុងការលើកកម្ពស់សមភាពយេនឌ័រ និងការបង្កើនភាពអង់អាចដល់ស្ត្រី ជាពិសេសតួនាទីក្នុងការធ្វើសេចក្តីសម្រេចនៅក្នុងគ្រប់ផ្នែកនៃអភិបាលកិច្ច និងការធ្វើឱ្យស្ត្រីទទួលបានសេវាសាធារណៈផ្សេងៗកាន់តែប្រសើរឡើង។ កម្មវិធីជាតិបានផ្តល់នូវចំណុចចាប់ផ្តើម និងកាលានុវត្តភាព ដែលបានកំណត់នៅក្នុងសមាសធាតុកម្មវិធីទាំងប្រាំ សំដៅបង្កើនកាលានុវត្តភាព និងភាពអង់អាចដល់ស្ត្រី និងធានាថា សេវាសាធារណៈទាំងអស់ដែលជាតម្រូវការរបស់ស្ត្រីត្រូវបានឆ្លើយតប។

សកម្មភាពនានាដែលបានលើកឡើងនៅក្នុងសមាសធាតុកម្មវិធីនៃកម្មវិធីជាតិ នឹងបង្កើនលទ្ធភាពដល់ស្ត្រីនិងក្រុមជនងាយរងគ្រោះផ្សេងៗទៀត ក្នុងការទទួលបាននូវសេវាសាធារណៈ ព្រមទាំងបង្កើនការគ្រប់គ្រងធនធានអភិវឌ្ឍន៍សម្រាប់លើកកម្ពស់ជីវភាពរស់នៅ។

### ១.២). ការប្រែប្រួលអាកាសធាតុ

ផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុនៅក្នុងប្រទេសកម្ពុជា មិនអាចប៉ាន់ស្មានបាននោះឡើយ ហេតុនេះ ទាមទារឱ្យរដ្ឋបាលនៅគ្រប់លំដាប់ថ្នាក់ទាំងអស់ ត្រូវយកចិត្តទុកដាក់ក្នុងការឆ្លើយតបចំពោះការគំរាមកំហែងដែលមានលក្ខណៈជាសាកលនេះចំពោះអាយុជីវិត ជីវភាពរស់នៅ និងប្រព័ន្ធគាំទ្រជីវិតនានា។ ដូច្នេះ ទាមទារឱ្យមានការអនុម័ត ជាបន្ទាន់នូវរបៀបវារៈនានាដែលពាក់ព័ន្ធនឹងការប្រើប្រាស់ជាតិកាបូនកម្រិតទាប ហើយក្នុងពេលជាមួយគ្នានេះដែរ ត្រូវរៀបចំដើម្បីការពារចំពោះហានិភ័យថ្មីៗផ្នែកអាកាសធាតុដែលគំរាមកំហែងដល់ប្រទេសកម្ពុជា។ កម្មវិធីជាតិ ផ្តល់នូវចំណុចចាប់ផ្តើមមួយដ៏សំខាន់ក្នុងការបង្កើត "ប្រព័ន្ធសម្របសម្រួល"ថ្នាក់ជាតិមួយ ដែលគាំទ្រដល់សង្គមក្នុងរយៈពេលវែង និងដំណើរការសម្របសម្រួលជាមួយនឹងការប្រែប្រួលអាកាសធាតុ។

**១.៣).** គណនេយ្យភាព និងការការពារក្រុមជនក្រីក្រ និងក្រុមជនងាយរងគ្រោះកម្មវិធីជាតិនឹងធ្វើឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិកាន់តែមានតម្លាភាព ដែលអាចឱ្យសាធារណជនអាចសង្កេត និង ចូលរួមក្នុងសកម្មភាពនានា។ ក្នុងការអនុវត្តច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងកម្មវិធីជាតិ ទាមទារឱ្យមានការបង្កើតនូវខ្សែគណនេយ្យភាពថ្មីនានា ការលើកកម្ពស់ការយល់ដឹង និងការបង្កើតប្រព័ន្ធ នីតិវិធី និង យន្តការទាំងឡាយ ដើម្បីធានាថា សិទ្ធិរបស់ប្រជាពលរដ្ឋត្រូវបានការពារ សំឡេងរបស់ប្រជាពលរដ្ឋត្រូវបានដឹងឮ និងធនធាននានាត្រូវបានប្រើប្រាស់ស្របតាមច្បាប់។

ប្រជាពលរដ្ឋមានសិទ្ធិស្របច្បាប់ក្នុងការទទួលបាននូវព័ត៌មានអំពីការធ្វើសេចក្តីសម្រេច និងការចាត់វិធានការ នានារបស់ក្រុមប្រឹក្សា។ ជាមួយគ្នានេះដែរ ត្រូវរៀបចំនូវយន្តការនានាដើម្បីផ្តល់នូវមធ្យោបាយសមស្របដល់ប្រជាពលរដ្ឋ ក្នុងការវាយតម្លៃសកម្មភាពនានារបស់ក្រុមប្រឹក្សា និងដើម្បីឱ្យក្រុមប្រឹក្សាមានគណនេយ្យភាពចំពោះទង្វើរបស់ខ្លួន ដែលអនុវត្តមិនបានសមស្រប។ ដូច្នេះវិធីសាស្ត្រដែលធ្វើឱ្យសម្រេចនូវគណនេយ្យភាពត្រូវតែដាក់បញ្ចូលទៅក្នុងគ្រប់ផ្នែកទាំងអស់នៃកំណែទម្រង់របស់រាជរដ្ឋាភិបាលព្រមទាំងទៅក្នុងដំណើរការខាងបញ្ញត្តិ និងក្នុងដំណើរការរដ្ឋបាល។

ដើម្បីធានាសម្រេចឱ្យបាននូវគណនេយ្យភាពដោយរដ្ឋបាលថ្នាក់ក្រោមជាតិ គឺត្រូវអនុវត្តតាមវិធានការ

មួយចំនួននៅតាមសមាសធាតុកម្មវិធីនីមួយៗនៃកម្មវិធីជាតិ ដូចខាងក្រោម ៖

- បញ្ជាក់ឱ្យបានច្បាស់ពីគោលដៅ និងគោលបំណងនានានៃគណនេយ្យភាព
- ពិនិត្យឡើងវិញនូវយន្តការគណនេយ្យភាពដែលមានស្រាប់ និងអនុវត្តសាកល្បងនូវយន្តការថ្មីនានា ដើម្បីពិនិត្យមើលលទ្ធភាពក្នុងការសម្រេចនូវគោលដៅ និងគោលបំណងនានានៃគណនេយ្យភាពរបស់រដ្ឋបាលនានា ដើម្បីជាមូលដ្ឋានសម្រាប់បង្កើតនូវសេចក្តីណែនាំ និងនីតិវិធីប្រតិបត្តិការនានា
- ត្រូវរៀបចំឱ្យមានលិខិតបទដ្ឋានគតិយុត្តនានាស្តីពីការដាក់ពិន័យ ដូចមានចែងក្នុងមាត្រានានានៃច្បាប់ស្តីពី ការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ដែលពាក់ព័ន្ធនឹងការពង្រឹងគណនេយ្យភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- ធ្វើឱ្យប្រជាពលរដ្ឋមានសិទ្ធិស្របច្បាប់ពិតប្រាកដក្នុងការទទួលបានព័ត៌មាន
- ចាត់វិធានការសមស្របនានា ក្នុងការលើកកម្ពស់ការយល់ដឹងរបស់សង្គមស៊ីវិលអំពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ
- ពង្រឹងយន្តការនានាសម្រាប់ការតវ៉ារបស់ប្រជាពលរដ្ឋនៅពេលដែលរដ្ឋបាលថ្នាក់ក្រោមជាតិបានរំលោភសិទ្ធិរបស់ពួកគាត់។

(ឯកសារយោង ដកស្រង់ចេញពីកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ២៨ ឧសភា ២០១០ ‑ ជំពូកទី២ ទំព័រ១៩‑២៣)

**លទ្ធផលរំពឹងទុកនៅតាមសមាសធាតុកម្មវិធីនិមួយៗ**

| **គោលបំណងសមាសធាតុ** | **លទ្ធផលរំពឹងទុក** |
|---|---|
| **សមាសធាតុកម្មវិធីទី១ ៖** ការរៀបចំស្ថាប័នថ្នាក់ក្រោមជាតិ | |
| បង្កើតស្ថាប័នរដ្ឋបាលថ្នាក់ក្រោមជាតិ តាមរយៈការរៀបចំនូវរចនាសម្ព័ន្ធ ប្រព័ន្ធគ្រប់គ្រងមួយផ្អែកតាមគោលការណ៍នៃការចូលរួមតាមបែបប្រជាធិបតេយ្យ។ | ១.១. បង្កើតរចនាសម្ព័ន្ធជាមូលដ្ឋានរបស់រដ្ឋបាលថ្នាក់ក្រោមជាតិឱ្យបានសមស្របតាមកម្រិតថ្នាក់រដ្ឋបាលនីមួយៗ<br>១.២. រៀបចំប្រព័ន្ធគ្រប់គ្រង និងនីតិវិធីប្រតិបត្តិស្តង់ដារ ដើម្បីគាំទ្រខ្សែគណនេយ្យភាពថ្មី និងការទទួលខុសត្រូវផ្នែកគ្រប់គ្រង |

| | |
|---|---|
| ប្រព័ន្ធគ្រប់គ្រងមួយ ផ្អែកតាម គោលការណ៍នៃការចូលរួមតាមបែបប្រជាធិបតេយ្យ។ | ១.៣. រៀបចំ និងដាក់ឱ្យអនុវត្តនូវកម្មវិធីនានាដើម្បី លើកកម្ពស់ការចូលរួមរបស់ប្រជាពលរដ្ឋ និងការការពារសិទ្ធិរបស់ប្រជាពលរដ្ឋ<br>១.៤. រៀបចំ និងដាក់ឱ្យអនុវត្តនូវប្រព័ន្ធគ្រប់គ្រង អន្តររដ្ឋបាលថ្នាក់ក្រោមជាតិ និងប្រព័ន្ធទំនាក់ទំនងអន្តររដ្ឋបាល<br>១.៥. ដាក់បញ្ចូលស្តង់ដារសមភាព និងសមធម៌យេនឌ័រ ទៅក្នុងប្រព័ន្ធគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ<br>១.៦. ដាក់ឱ្យអនុវត្តនូវកម្មវិធីព័ត៌មានវិទ្យា និងទំនាក់ទំនងតាមប្រព័ន្ធព័ត៌មានវិទ្យានៅរដ្ឋបាលថ្នាក់ក្រោមជាតិ<br>១.៧. រៀបចំ និងអនុវត្តនូវកម្មវិធីសម្រាប់ដាក់បញ្ចូលបញ្ហាប្រែប្រួលអាកាសធាតុទៅក្នុងដំណើរការកសាងផែនការ ការគ្រប់គ្រង និងការផ្តល់សេវាសាធារណៈរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ |
| **សមាសធាតុកម្មវិធីទី២ :** ប្រព័ន្ធគ្រប់គ្រង និងអភិវឌ្ឍន៍ធនធានមនុស្ស | |
| រៀបចំឱ្យមានមន្ត្រីរាជការស៊ីវិលប្រកបដោយវិជ្ជាជីវៈ និងមានឆន្ទៈមោះមុតក្នុងការបំពេញការងារនៅរដ្ឋបាលថ្នាក់ក្រោមជាតិដែលមានគណនេយ្យភាពចំពោះក្រុមប្រឹក្សា និងគ្រប់គ្រងដោយក្រុមប្រឹក្សា។ | ២.១. រៀបចំលិខិតបទដ្ឋានគតិយុត្តសម្រាប់ការគ្រប់គ្រងធនធានមនុស្ស តាមបែបវិមជ្ឈការ ដើម្បីផ្តល់លទ្ធភាពដល់ក្រុមប្រឹក្សានានា នៃរដ្ឋបាលថ្នាក់ក្រោមជាតិអាចគ្រប់គ្រង និងចាត់ចែងមន្ត្រី បុគ្គលិករបស់ខ្លួន តាមរយៈការបង្កើតនូវរចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងធនធានមនុស្ស<br>២.២. បុគ្គលិករបស់ក្រសួង ស្ថាប័ននានាត្រូវបានរៀបចំឡើងវិញដោយផ្អែកលើមុខងារដែលបានផ្ទេរ តាមរយៈដំណើរការមួយប្រកបដោយតម្លាភាព<br>២.៣. បង្កើតឱ្យមានកម្មវិធីសម្រាប់ការអភិវឌ្ឍធនធានមនុស្ស<br>២.៤. បញ្ជ្រាបយេនឌ័រក្នុងកម្មវិធីគ្រប់គ្រងធនធានមនុស្សនិងកម្មវិធីអភិវឌ្ឍន៍សមត្ថភាព |

| | |
|---|---|
| | ២.៥. បុគ្គលិករបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ទទួលបាននូវការលើកកម្ពស់ ឱ្យក្លាយជាបុគ្គលិកប្រកប ដោយវិជ្ជាជីវៈ |
| **សមាសធាតុកម្មវិធីទី៣ :** ការផ្ទេរមុខងារ | |
| លើកកម្ពស់បរិមាណនិងគុណភាពសេវាសាធារណៈតាមរយៈការផ្ទេរមុខងារឱ្យទៅរដ្ឋបាលថ្នាក់ក្រោមជាតិដោយភ្ជាប់ជាមួយនូវការទទួលខុសត្រូវ សិទ្ធិអំណាច និងធនធានដែលពាក់ព័ន្ធនឹងការអនុវត្តមុខងារទាំងនោះ។ | ៣.១. ពិនិត្យមើលមុខងារឡើងវិញ និងផ្ទេរមុខងារ ស្របតាមវិធីសាស្ត្រ និងដំណើរការដែលមានការពិគ្រោះយោបល់ មានការគ្រោងទុក មានសនិទានភាព និងមានលក្ខណៈជាប្រព័ន្ធ<br>៣.២. ការទទួលខុសត្រូវ និងសិទ្ធិអំណាចសម្រាប់អនុវត្ត មុខងារដែលបានផ្ទេរ ត្រូវបានអនុវត្តដោយពុំមានការរំខានដល់ការផ្តល់សេវាសាធារណៈនានា<br>៣.៣. រៀបចំ និងអនុវត្តផែនការស្តីពីការផ្ទេរមុខងាររបស់ក្រសួងស្ថាប័នឱ្យបានច្បាស់លាស់<br>៣.៤. យកចិត្តទុកដាក់ដល់ការលើកកម្ពស់សមភាពយេនឌ័រ និងការឆ្លើយតបចំពោះក្រុមជនងាយរងគ្រោះនានានៅក្នុងការផ្ទេរមុខងារ<br>៣.៥. លើកកម្ពស់ការទទួលបាន និងការប្រើប្រាស់សេវាសាធារណៈនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ស្របតាមតម្រូវការរបស់ប្រជាពលរដ្ឋ និងមានគណនេយ្យភាពចំពោះប្រជាពលរដ្ឋ |
| **សមាសធាតុកម្មវិធីទី៤ :** ប្រព័ន្ធគ្រប់គ្រងថវិកា ហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ | |
| បង្កើតប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុមួយរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិមានលទ្ធភាពកៀរគរនិងទទួលបានធនធានគ្រប់គ្រាន់ ព្រមទាំង មានសិទ្ធិអំណាចក្នុងការគ្រប់គ្រង និងបែងចែកធនធានទាំងនោះ | ៤.១. បង្កើតប្រព័ន្ធកសាងផែនការអភិវឌ្ឍន៍និងថវិកានិងប្រព័ន្ធគណនេយ្យសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិដែលលើកកម្ពស់គណនេយ្យភាព តម្លាភាព និងដែលមានសង្គតិភាពជាមួយនឹងគោលការណ៍នៃកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ |

| | |
|---|---|
| ប្រកបដោយតម្លាភាព និង គណនេយ្យភាព។ | ៤.២. ប្រព័ន្ធកសាងផែនការ និងថវិកាបានលើកកម្ពស់សមភាពយេនឌ័រ និងឆ្លើយតបចំពោះក្រុមជនងាយរងគ្រោះ<br>៤.៣. ដាក់ឱ្យប្រើប្រាស់នូវប្រព័ន្ធគ្រប់គ្រងសាច់ប្រាក់ដែលមានលក្ខណៈឆ្លើយតប និងមានប្រសិទ្ធភាព នៅរដ្ឋបាលថ្នាក់ក្រោមជាតិ<br>៤.៤. ផ្ទេរមូលនិធិមានភ្ជាប់ល័ក្ខខ័ណ្ឌ និងមូលនិធិគ្មានភ្ជាប់ល័ក្ខខ័ណ្ឌទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ បានទាន់ពេលវេលាដោយមានការផ្តល់នូវសិទ្ធិអំណាចគ្រប់គ្រាន់ក្នុងការប្រើប្រាស់ និងការបែងចែកដោយផ្អែកលើលក្ខណៈវិនិច្ឆ័យច្បាស់លាស់ និងមានតម្លាភាព<br>៤.៥. ប្រគល់ប្រភេទចំណូលពន្ធមូលដ្ឋានដ៏ច្បាស់លាស់ (១00% ឬចែករំលែកជាមួយថ្នាក់រដ្ឋបាលផ្សេងទៀត)ឱ្យទៅប្រភេទរដ្ឋបាលនីមួយៗ នៃរដ្ឋបាលថ្នាក់ក្រោមជាតិ<br>៤.៦. ប្រគល់ប្រភេទចំណូលមិនមែនសារពើពន្ធមួយចំនួន និងសិទ្ធិចាត់ចែងចំណូលមិនមែនសារពើពន្ធទាំងនេះទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ<br>៤.៧. ឃុំ សង្កាត់ក្នុងស្រុកទទួលបានចំណូលចែករំលែក ដែលត្រូវបានផ្តល់ឱ្យតាមមធ្យោបាយមួយប្រកបដោយតម្លាភាព និងសមធម៌<br>៤.៨. ផ្ទេរ និងផ្តល់ទ្រព្យសម្បត្តិចាំបាច់ឱ្យបានទាន់ពេលវេលាសម្រាប់អនុវត្តមុខងារនានា និងបង្កើតប្រព័ន្ធគ្រប់គ្រងទ្រព្យសម្បត្តិនៅរដ្ឋបាលថ្នាក់ក្រោមជាតិ<br>៤.៩. រៀបចំ និងដាក់ឱ្យប្រើប្រាស់នូវប្រព័ន្ធ និងនីតិវិធីលទ្ធកម្មសាធារណៈរបស់រដ្ឋបាលថ្នាក់ក្រោមជាតិដោយឈរលើគោលការណ៍តម្លាភាព និងប្រសិទ្ធភាព<br>៤.១០.រៀបចំ និងដាក់ឱ្យប្រើប្រាស់នូវប្រព័ន្ធសវនកម្មផ្ទៃក្នុងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ<br>៤.១១. ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុធ្វើអធិការកិច្ចហិរញ្ញវត្ថុទៅលើរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីធានាដល់ការអនុវត្តតាម |

| | |
|---|---|
| | ច្បាប់ និងនីតិវិធីនានា<br>៤.១២. គាំទ្រផ្នែកស្ថាប័ន និងការកសាងសមត្ថភាពដល់អាជ្ញាធរសវនកម្មជាតិក្នុងការធ្វើសវនកម្ម ទៅលើរដ្ឋបាលថ្នាក់ក្រោមជាតិ<br>៤.១៣. រដ្ឋបាលថ្នាក់ក្រោមជាតិមានលទ្ធភាពរៀបចំផែនការប្រកបដោយតម្លាភាពដោយយកចិត្តទុកដាក់លើការចំណាយពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុ |
| **សមាសធាតុកម្មវិធីទី៥ :** ស្ថាប័នគាំទ្រកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ | |
| ពង្រឹងស្ថាប័នថ្នាក់ជាតិនានាសម្រាប់ដឹកនាំការអនុវត្ត កម្មវិធីជាតិរយៈពេល១០ឆ្នាំ និងគាំទ្រដល់រដ្ឋបាលថ្នាក់ក្រោមជាតិ។ | ៥.១. គ.ជ.អ.ប រៀបចំ និងអនុម័តលិខិតបទដ្ឋានគតិយុត្ត និងនីតិវិធី ប្រតិបត្តិការសមស្រប សម្រាប់ការអនុវត្តកម្មវិធីជាតិ<br>៥.២. ជួយគាំទ្រក្រសួង ស្ថាប័នក្នុងការពិនិត្យមើល និង រៀបចំឡើងវិញនូវរចនាសម្ព័ន្ធ និងដំណើរការដែលឆ្លុះបញ្ចាំងពីតួនាទី និងការទទួលខុសត្រូវថ្មីរបស់ខ្លួនចំពោះរដ្ឋបាលនានានៃរដ្ឋបាលថ្នាក់ក្រោមជាតិ<br>៥.៣. បង្កើតឱ្យមានយន្តការសម្របសម្រួលកិច្ចការរដ្ឋបាល និងសម្រុះសម្រួលវិវាទរដ្ឋបាល<br>៥.៤. គ.ជ.អ.ប ត្រូវរៀបចំឡើងវិញនូវអង្គភាពតាមដាន និងវាយតម្លៃរបស់ខ្លួន ដើម្បីអនុវត្តកម្មវិធីតាមដាន និងវាយតម្លៃរបស់កម្មវិធីជាតិ<br>៥.៥. រៀបចំបង្កើតស្ថាប័នបណ្តុះបណ្តាល ដើម្បីឆ្លើយតបនឹងតម្រូវការអភិវឌ្ឍន៍សមត្ថភាពហិរញ្ញវត្ថុទៅលើរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីធានាដល់ការអនុវត្តច្បាប់ និងនីតិវិធីនានា |

| | |
|---|---|
| | បុគ្គលិក និងស្ថាប័នដែលទទួលខុសត្រូវចំពោះការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យទាំងនៅ ថ្នាក់ជាតិ និងនៅថ្នាក់ក្រោមជាតិ<br>៥.១. ស្ថាប័ននានាសម្រាប់គាំទ្រកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ បង្កើន និងជំរុញការយកចិត្តទុកដាក់ក្នុងការលើកកម្ពស់សមភាព និងសមធម៌ យេនឌ័រ និងការឆ្លើយតបចំពោះក្រុមជនងាយរងគ្រោះ<br>៥.២. សម្ព័ន្ធភាពជាតិ និងសមាគមនីមួយៗនៃរដ្ឋបាល ថ្នាក់ក្រោមជាតិ មានសមត្ថភាព និងថវិកា សមស្របសម្រាប់រៀបចំកម្មវិធី ដើម្បីឆ្លើយតប នឹងតម្រូវការនានា |



# មេរៀនទី ១ ឯកសារផ្ទាំងរូបភាព






ជំពូកទី២


១១
ខ្សែគណនេយ្យភាព
ប្រជាពលរដ្ឋ
បោះឆ្នោត
គណនេយ្យភាពចំពោះប្រជាពលរដ្ឋ
ក្រុមប្រឹក្សាឃុំ សង្កាត់
បោះឆ្នោត
គណនេយ្យភាពអន្តររដ្ឋបាលថ្នាក់ក្រោមជាតិ
គណនេយ្យភាពចំពោះប្រជាពលរដ្ឋ
ក្រុមប្រឹក្សា
គណនេយ្យភាពទៅរាជរដ្ឋាភិបាល
រាជរដ្ឋាភិបាល
គ.ជ.អ.ប
ក្រសួងស្ថាប័ននានា
ក្រសួងស្ថាប័ននានា
គណនេយ្យភាពទៅក្រសួង
មន្ទីរ
គណនេយ្យភាពអន្តររដ្ឋបាល
គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស
គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រីនិងកុមារ
គណៈកម្មាធិការលទ្ធកម្ម
គណៈកម្មាធិការនានា
គណៈអភិបាល
នាយករដ្ឋបាល
អង្គភាព...
អង្គភាព...
អង្គភាព...
អង្គភាព...
រដ្ឋបាលថ្នាក់ក្រោមជាតិ
កំណត់សំគាល់ខ្សែគណនេយ្យភាព
គណនេយ្យភាពចំពោះប្រជាពលរដ្ឋ
គណនេយ្យភាពអន្តររដ្ឋបាល
គណនេយ្យភាពផ្ទៃក្នុង
គណនេយ្យភាពអន្តររដ្ឋបាលថ្នាក់ក្រោមជាតិ

## ឧបសម្ព័ន្ធទី២

របស់ស្ត្រី កុមារ និងក្រុមជនងាយរងគ្រោះនានា ទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ។

- ពង្រឹងទំនាក់ទំនងនិងការសម្របសម្រួល ខ្សែទទឹងនៃអន្តររដ្ឋបាល និងលើកកម្ពស់គណនេយ្យភាពចំពោះ ប្រជាពលរដ្ឋ ។
- តាមដានការអនុវត្តគោលនយោបាយ និងគោលការណ៍សមភាព និងសមធម៌យេនឌ័រ ក្នុងការផ្ទេរមន្ត្រី បុគ្គលិកទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ។

**ការបញ្ជ្រាបយេនឌ័រក្នុងសមាសធាតុកម្មវិធីទី ៤**

- រៀបចំនីតិវិធីសម្រាប់ការរៀបចំថវិកា និងការផ្តល់សេវាសមស្រប
- បង្កើត និងអនុវត្តគោលនយោបាយសារពើពន្ធ នីតិវិធី និងសេចក្តីណែនាំស្តីពីការរៀបចំថវិកានៅរដ្ឋបាល ថ្នាក់ក្រោមជាតិ ដែលឆ្លើយតបនឹងយេនឌ័រ ផ្អែកតាមមេរៀនបទពិសោធន៍ក្នុងការរៀបចំថវិកាដែលឆ្លើយតបនឹងយេនឌ័រនៅក្នុងកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។
- ផ្សារភ្ជាប់ការផ្ទេរសារពើពន្ធ និងការវិភាជន៍ថវិកាជាមួយនឹងសូចនាករសមភាពយេនឌ័រ ការកាត់បន្ថយ ភាពក្រីក្រ និងសូចនាករផ្សេងៗទៀត ។
- ផ្តល់ធនធានដល់យន្តការ និងបណ្តាញការងារលើកកម្ពស់សមភាពយេនឌ័រ ។
- ផ្តល់ថវិកាដល់កម្មវិធីដែលផ្តោតការយកចិត្តទុកដាក់លើបញ្ហាជាក់លាក់របស់ស្ត្រី និងការបញ្ជ្រាបយេនឌ័រ ។

**ការបញ្ជ្រាបយេនឌ័រក្នុងសមាសធាតុកម្មវិធីទី ៥**

រដ្ឋបាលថ្នាក់ក្រោមជាតិនឹង :

- រៀបចំកម្មវិធីបណ្តុះបណ្តាលអំពីសមភាពយេនឌ័រ សម្រាប់បុគ្គលិករបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដោយប្រើប្រាស់ឯកសារបណ្តុះបណ្តាលរបស់ក្រសួងកិច្ចការនារីដែលមានបច្ចុប្បន្ន ។
- រៀបចំកម្មវិធីដើម្បីបង្កើតបរិយាកាសក្នុងការលើកកម្ពស់សមភាពយេនឌ័រ នៅរដ្ឋបាលថ្នាក់ក្រោមជាតិ តាម រយៈការអភិវឌ្ឍចំណេះដឹងជំនាញ និងអាកប្បកិរិយា ។
- ធ្វើការងារជាមួយសហគមន៍ និងអង្គការសង្គមស៊ីវិល ដើម្បីបង្កើនការយល់ដឹងអំពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ និងការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យសម្រាប់ប្រជាពលរដ្ឋទូទៅ ទាំងស្ត្រី និងបុរស ដោយបង្កលក្ខណៈឱ្យប្រជាពលរដ្ឋទាំងពីរភេទមានលទ្ធភាពចូលរួមក្នុងដំណើរការអភិបាលកិច្ចនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ។
- រៀបចំយុទ្ធនាការ និងធ្វើការងារយ៉ាងសកម្មជាមួយសហគមន៍ ដើម្បីឈានទៅដល់ការសម្រេចឱ្យបាន នូវការលុបបំបាត់រាល់ទម្រង់នៃការរើសអើង ដែលមាននៅក្នុងតួនាទី និងទម្លាប់នៃការគ្រប់គ្រង ។
- លើកកម្ពស់តំណាងរបស់ស្ត្រីនៅក្នុងសកម្មភាពអភិបាលកិច្ចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីផ្លាស់ប្តូរផ្នត់គំនិត និងការប្រព្រឹត្តជាអវិជ្ជមានមកលើស្ត្រី ។
- លើកទឹកចិត្តដល់អ្នកមានស្នាដៃក្នុងការលើកកម្ពស់សមភាពយេនឌ័រ នៅក្នុងរដ្ឋបាលថ្នាក់ក្រោមជាតិ ។
- បង្កើតសមាគម ឬបណ្តាញមន្ត្រី បុគ្គលិករបស់រដ្ឋបាលថ្នាក់ក្រោមជាតិជាស្ត្រី ដើម្បីជួយគាំទ្រគ្នាទៅវិញទៅមក និងជួយអភិវឌ្ឍសមត្ថភាពដល់សមាគម ឬបណ្តាញទាំងនេះក្នុងការតាមដាន និងចូលរួមរៀបចំគោលនយោបាយដែលយកចិត្តទុកដាក់យេនឌ័រ ។
- កំណត់អំពីធនធានហិរញ្ញវត្ថុ និងធនធានមនុស្ស ដើម្បីបង្កើត និងអនុវត្ត គោលនយោបាយនានាដែលយក ចិត្តទុកដាក់យេនឌ័រ ។



**ប្រភពឯកសារ :** កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ២០១០-២០១៩ (ទំព័រ ១៤៣-១៤៨)

**ផលិតដោយ** Pact Cambodia, VBNK **ឧបត្ថម្ភដោយ** THE WORLD BANK, គ.ជ.អ.ប NCDD

# ការបញ្ជ្រាបយេនឌ័រក្នុង កម្មវិធីជាតិ សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ នៅថ្នាក់ក្រោមជាតិ

**សមាសធាតុកម្មវិធីទី ១**
ការរៀបចំស្ថាប័នរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

**សមាសធាតុកម្មវិធីទី ២**
ប្រព័ន្ធគ្រប់គ្រង និងអភិវឌ្ឍធនធានមនុស្ស

**សមាសធាតុកម្មវិធីទី ៣**
ការផ្ទេរមុខងារ

**សមាសធាតុកម្មវិធីទី ៤**
ប្រព័ន្ធគ្រប់គ្រងថវិកា ហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិនានា

**សមាសធាតុកម្មវិធីទី ៥**
ស្ថាប័នគាំទ្រកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ

ឧបសម្ព័ន្ធ២

### ការបញ្រ្ជាបយេនឌ័រក្នុងសមាសធាតុកម្មវិធីទី ១

**ក-ក្របខ័ណ្ឌគោលនយោបាយ**

- បង្កើត និងបញ្ចូលបញ្ញត្តិនានាដែលបានមកពីបទដ្ឋានគតិយុត្តជាតិ និងអន្តរជាតិពាក់ព័ន្ធបញ្ហាយេនឌ័រ
- បញ្ចូលគោលការណ៍នៃការលើកកម្ពស់សិទ្ធិស្ត្រីជាចំណុចសំខាន់នៃការតាក់តែងគោលនយោបាយ និងការផ្តល់សេវាសាធារណៈ
- បង្កើតនីតិវិធី និងគោលនយោបាយសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការដោះស្រាយនូវរាល់ទម្រង់នៃ ការរើសអើងនានានៅក្នុងកិច្ចដំណើរការប្រតិបត្តិការ និងស្ថាប័ននៃរដ្ឋបាលថ្នាក់ក្រោមជាតិ ដោយយកចិត្តទុកដាក់ជាពិសេសចំពោះសិទ្ធិរបស់ស្ត្រី និងក្រុមជនងាយរងគ្រោះ ។
- បង្កើតកម្មវិធី និងគោលនយោបាយដោយផ្អែកលើព័ត៌មាន និងទិន្នន័យដែលឆ្លើយតបទៅនឹងបញ្ហាយេនឌ័រ ព្រមទាំងធានាឱ្យមានធនធានសម្រាប់អនុវត្តកម្មវិធី និងគោលនយោបាយទាំងនោះ ។
- បង្កើតឱ្យមានដំណើរការ និងនីតិវិធីនៃការតាក់តែងគោលនយោបាយដែលធានាឱ្យមានការចូលរួមដោយស្មើភាពពីអ្នកពាក់ព័ន្ធ( ស្ត្រី-បុរស) ។
- អនុវត្តផែនការយុទ្ធសាស្ត្របញ្រ្ជាបយេនឌ័រតាមវិស័យ ដោយមានការចូលរួម និងកិច្ចសហការពីក្រុម ការងារបញ្រ្ជាបយេនឌ័រ

**ខ-ការធានាឱ្យមានតំណាងរបស់ស្ត្រី និងក្រុមតំណាងផលប្រយោជន៍ប្រជាពលរដ្ឋនៅក្នុងដំណើរការកសាងផែនការអភិវឌ្ឍន៍រយៈពេល ៥ឆ្នាំ និងកម្មវិធីវិនិយោគពាឆ្នាំរំកិលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ**

- រៀបចំដំណើរការនៃការតាក់តែងគោលនយោបាយឆ្លើយតបនឹងបញ្ហាយេនឌ័រនៅថ្នាក់ក្រោមជាតិ តាម រយៈការធានា និងផ្តល់លទ្ធភាពក្នុងការចូលរួមរបស់បុរស និងស្ត្រីនៅក្នុងដំណើរការកសាងផែនការអភិវឌ្ឍន៍ រយៈពេល៥ឆ្នាំ និងកម្មវិធីវិនិយោគពាឆ្នាំរំកិលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ។
- បញ្ចូលគោលការណ៍សម្រាប់ការកសាងផែនការ និងការរៀបចំថវិកាឆ្លើយតបនឹងយេនឌ័រ នៅរាល់លិខិត បទដ្ឋាន និងសេចក្តីណែនាំទាំងអស់ សម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ ដោយមានការគាំទ្រផ្នែកការអភិវឌ្ឍសមត្ថភាព និងបច្ចេកទេស ។

**គ-កិច្ចដំណើរការពិនិត្យមើលឡើងវិញ**

- បង្កើតសេចក្តីណែនាំសម្រាប់ធ្វើសវនកម្មយេនឌ័រនៅ រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីកំណត់អំពីការបំពេញ ការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធនឹងការរៀបចំគោលនយោបាយ ការអនុវត្ត និងការផ្តល់សេវា សាធារណៈនានាក្នុងការលើកកម្ពស់សមភាព និងសមធម៌យេនឌ័រ ។
- ធ្វើសវនកម្មយេនឌ័រជាទៀងទាត់នៅរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីកំណត់អំពីវឌ្ឍនភាព និងបញ្ហានានា ព្រមទាំងធ្វើការកែលម្អស្ថានភាពសមភាពយេនឌ័ររបស់ស្ថាប័ននៃរដ្ឋបាលថ្នាក់ក្រោមជាតិ ទាំងនៅក្នុងការផ្តល់សេវាសាធារណៈ និងនៅក្នុងអង្គការចាត់តាំងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ។

### ការបញ្រ្ជាបយេនឌ័រក្នុងសមាសធាតុកម្មវិធីទី ២

**ក-គោលនយោបាយស្តីពីឱកាសស្មើភាព**

- បង្កើតគោលនយោបាយនិងនីតិវិធីស្តីពីការគ្រប់គ្រងធនធានមនុស្សដែលមានបញ្ចូលនូវបញ្ញត្តិនានា ទាក់ ទងនឹងសមភាព និងសមធម៌យេនឌ័រ ដើម្បីធានា និងផ្តល់ឱកាសស្មើភាពដល់ស្ត្រីក្នុងការទទួលបានការងារ និងមុខតំណែងដែលមានសិទ្ធិអំណាចនៅក្នុងស្ថាប័ន ។ល ។
- បង្កើតគោលនយោបាយ និងប្រព័ន្ធលើកទឹកចិត្តសម្រាប់ការគ្រប់គ្រងធនធានមនុស្ស ដែលធានាថា បុគ្គលិក រដ្ឋបាលថ្នាក់ក្រោមជាតិគោរពតាមគោលការណ៍សមភាព និងសមធម៌យេនឌ័រ ។
- បង្កើតគោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្តសំខាន់ៗ ដែលបង្កឱ្យមានសមភាព និងសមធម៌យេនឌ័រ នៅក្នុងរដ្ឋបាលថ្នាក់ក្រោមជាតិរួមទាំងគោលនយោបាយស្តីពីឱកាសស្មើគ្នានៅគ្រប់អង្គការចាត់តាំងទាំងអស់នៃរដ្ឋបាលថ្នាក់ក្រោមជាតិ ។

**ខ-គោលនយោបាយស្តីពីធនធានមនុស្ស**

- បង្កើតគោលនយោបាយដែលកំណត់អំពីមុខងារ ការទទួលខុសត្រូវ និងគណនេយ្យភាពសម្រាប់សកម្មភាពបញ្រ្ជាបយេនឌ័រនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ។
- សិក្សាវាយតម្លៃ និងរៀបចំទិន្នន័យគោលអំពីយេនឌ័រនៃរដ្ឋបាលថ្នាក់ក្រោមជាតិ ដោយបែងចែកទិន្នន័យ ទៅតាមភេទនៃបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិនៅគ្រប់កម្រិត ។
- រៀបចំវិធានការចាំបាច់នានា ដើម្បីជំរុញការចូលរួមរបស់ស្ត្រីនៅក្នុងអភិបាលកិច្ចនៃរដ្ឋបាលថ្នាក់ក្រោមជាតិ នៅគ្រប់កម្រិត ។

**គ-ប្រព័ន្ធលើកទឹកចិត្តដើម្បីលើកកម្ពស់សមភាពយេនឌ័រ**

- ពង្រឹងយន្តការ និងបណ្តាញសម្រាប់គាំទ្រការបញ្រ្ជាបយេនឌ័រនៅរដ្ឋបាលថ្នាក់ក្រោមជាតិតាមរយៈការបណ្តុះបណ្តាល និងការផ្តល់ធនធានសមស្របសម្រាប់បំពេញតួនាទី ក្នុងការជំរុញការអនុវត្ត និងតាមដានការបញ្រ្ជាបយេនឌ័ររបស់ស្ថាប័ន ។
- កំណត់អំពីការលើកទឹកចិត្តដល់បុគ្គលដែលបានបំពេញការងារទាក់ទងនឹងសមភាពយេនឌ័រ ។
- បង្កើតបរិយាកាសការងារដែលអំណោយផលដល់ស្ត្រី និងបុរសក្នុងការបំពេញភារកិច្ច ( ពេលវេលាធ្វើ ការងារដែលអាចបត់បែនបាន និងការឧបត្ថម្ភសម្រាប់ការថែទាំកូនជាដើម) ដើម្បីផ្តល់លទ្ធភាពដល់ស្ត្រីក្នុងការបំពេញតួនាទី និងកាត់បន្ថយកម្រិតអវត្តមានពីការងារ ។

**ឃ-ការអភិវឌ្ឍសមត្ថភាព**

- រៀបចំកម្មវិធី និងឯកសារបណ្តុះបណ្តាលរដ្ឋបាលថ្នាក់ក្រោមជាតិដែលបញ្ចូលគោលយោបាយសមភាព និងសមធម៌យេនឌ័រ ។
- បណ្តុះបណ្តាលដល់យន្តការ និងបណ្តាញការងារលើកកម្ពស់សមភាពយេនឌ័រ ដើម្បីបំពេញតួនាទីប្រកបដោយប្រសិទ្ធភាព ។
- បណ្តុះបណ្តាលបុគ្គលិករបស់រដ្ឋបាលថ្នាក់ក្រោមជាតិអំពីគោលនយោបាយ និងគោលការណ៍សមភាពនិង សមធម៌យេនឌ័រ និងការបង្កើនភាពអង់អាចដល់ស្ត្រី ។

### ការបញ្រ្ជាបយេនឌ័រក្នុងសមាសធាតុកម្មវិធីទី ៣

ការបញ្រ្ជាបយេនឌ័រនៅក្នុងសមាសធាតុកម្មវិធីនេះនឹងកំណត់អំពីមុខងារ និងការទទួលខុសត្រូវដែលពាក់ព័ន្ធ ដើម្បីសម្របសម្រួល និងធ្វើឱ្យមានសង្គតិភាពនូវសកម្មភាពបញ្រ្ជាបយេនឌ័រនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ។

- រៀបចំលិខិតបទដ្ឋានចាំបាច់នានាសម្រាប់គាំទ្រ គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ ដូចជា ប្រកាសស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ ។
- បង្កើតនីតិវិធីសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការ រៀបចំគោលនយោបាយ ដែលគិតគូរ និងឆ្លើយតប នឹងបញ្ហាយេនឌ័រដោយធានាបាននូវតុល្យភាពរវាងស្ត្រីនិងបុរសនៅក្នុងដំណើរការពិភាក្សា ។
- កំណត់ និងផ្ទេរមុខងារដែលឆ្លើយតបទៅនឹងតម្រូវការជាអាទិភាព

# ឧបសម្ព័ន្ធ២



**ការលើកកម្ពស់គណនេយ្យភាពក្នុងកម្មវិធីជាតិ សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ នៅថ្នាក់ក្រោមជាតិ**

**សមាសធាតុកម្មវិធីទី ១**
ការរៀបចំស្ថាប័នរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

**សមាសធាតុកម្មវិធីទី ២**
ប្រព័ន្ធគ្រប់គ្រង និងអភិវឌ្ឍធនធានមនុស្ស

**សមាសធាតុកម្មវិធីទី ៣**
ការផ្ទេរមុខងារ

**សមាសធាតុកម្មវិធីទី ៤**
ប្រព័ន្ធគ្រប់គ្រងថវិកា ហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិនានា

**សមាសធាតុកម្មវិធីទី ៥**
ស្ថាប័នគាំទ្រកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ

ក្នុងការចាត់ចែងធនធានសម្រាប់ ការអនុវត្តមុខងារដែលបានផ្ទេរ ទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ព្រមទាំងការទទួលខុសត្រូវ និងសិទ្ធិអំណាចដែលរក្សាទុកនៅថ្នាក់ជាតិ ។

- ការធ្វើវេទិកាសាធារណៈ ដោយផ្ទាល់ជាមួយប្រជាពលរដ្ឋស្តីពីសេវាសាធារណៈដែលផ្តល់ដោយរដ្ឋបាល ថ្នាក់ក្រោមជាតិ ។
- ការរៀបចំឱ្យមានសន្លឹកប័ណ្ណរបាយការណ៍របស់ប្រជាពលរដ្ឋអំពីសេវាសាធារណៈដែលផ្តល់ដោយ រដ្ឋបាលថ្នាក់ក្រោមជាតិ ។
- ការរៀបចំឱ្យមានក្រុមគណនេយ្យភាព ឬការិយាល័យប្រជាពលរដ្ឋការចូលរួមផ្តល់យោបល់ ឬរិះគន់ តាមរយៈប្រអប់សំបុត្រ និងប្រព័ន្ធផ្សេងៗទៀត ។ល។

**ការលើកកម្ពស់គណនេយ្យភាពក្នុង សមាសធាតុកម្មវិធីទី ៤**

ការពង្រឹងខ្សែគណនេយ្យភាពនៅក្នុងដំណើរការអនុវត្តសមាសធាតុកម្មវិធីទី៤នេះ នឹងត្រូវធ្វើឡើងតាមរយៈយន្តការខាងក្រោម :

- គណនេយ្យភាពផ្ទៃក្នុង នឹងស្តែងឡើងតាមរយៈការធ្វើសវនកម្មផ្ទៃក្នុង ទំនាក់ទំនង និងរបៀបរបបធ្វើ ការងាររវាងក្រុមប្រឹក្សា គណៈអភិបាល និងអង្គភាពនានារបស់ក្រុមប្រឹក្សាពាក់ព័ន្ធនឹងការអនុវត្តថវិកា ។
- គណនេយ្យភាពអន្តររដ្ឋបាលថ្នាក់ក្រោមជាតិ នឹងស្តែងឡើងច្បាស់លាស់ តាមរយៈការចែករំលែក ចំណូលរវាងស្រុក និងឃុំ សង្កាត់នៅក្នុងស្រុក ។
- គណនេយ្យភាពអន្តររដ្ឋបាល នឹងស្តែងឡើងតាមរយៈការធ្វើអធិការកិច្ចហិរញ្ញវត្ថុរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងការធ្វើសវនកម្មរបស់អាជ្ញាធរសវនកម្មជាតិ ទៅលើការអនុវត្តកិច្ចការហិរញ្ញវត្ថុរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ។
- គណនេយ្យភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិចំពោះប្រជាពលរដ្ឋ នឹងស្តែងឡើងតាមរយៈការរៀបចំ ការសម្រេច និងការអនុវត្តថវិកា និងតាមរយៈវេទិកាពិគ្រោះយោបល់ និងផ្សព្វផ្សាយជាសាធារណៈ ពាក់ព័ន្ធនឹងកិច្ចការថវិកា ការវិនិយោគ និងការអភិវឌ្ឍនានា ព្រមទាំងតាមរយៈការអនុវត្តសាកល្បង នូវយន្តការនានាដែលពាក់ព័ន្ធនឹងសវនកម្មផ្នែកសង្គមកិច្ច និងការផ្តល់លទ្ធភាពឱ្យប្រជាពលរដ្ឋ ឬក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងការចូលរួមផ្តល់យោបល់ លើគម្រោងថវិកានានារបស់រដ្ឋបាលថ្នាក់ក្រោមជាតិប្រភេទ ផ្សេងៗទៀត ។

**ការលើកកម្ពស់គណនេយ្យភាពក្នុង សមាសធាតុកម្មវិធីទី ៥**

គ.ជ.អ.ប ក៏នឹងត្រូវរៀបចំបង្កើត និងពង្រឹងនូវយន្តការសម្របសម្រួលកិច្ចការ និង ដោះស្រាយវិវាទរដ្ឋបាលនានា ដើម្បីពង្រឹងខ្សែគណនេយ្យភាពផ្ទៃក្នុង និងខ្សែគណនេយ្យភាពអន្តររដ្ឋបាលថ្នាក់ក្រោមជាតិផងដែរ ។ អាស្រ័យហេតុនេះ គ.ជ.អ.ប ត្រូវធានាឱ្យមានការរៀបចំ និងដាក់ចេញនូវលិខិតបទដ្ឋានគតិយុត្ត នីតិវិធី និង យន្តការសំខាន់ៗមួយចំនួនដូចខាងក្រោម :

- កំណត់នីតិវិធី និងយន្តការត្រួតពិនិត្យនីត្យានុកូលភាពទៅលើការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដោយ ផ្តល់សិទ្ធិអំណាចដល់ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការទាមទារ សាកសួរលើករណីមានការធ្វើមោឃភាពសេចក្តីសម្រេចរបស់ក្រុមប្រឹក្សា ឬក្នុងករណីមានការរំលាយក្រុមប្រឹក្សាណាមួយនៃរដ្ឋបាលថ្នាក់ក្រោមជាតិ ។
- រៀបចំគោលនយោបាយដែលបង្កបរិយាកាសអំណោយផល និងជំរុញឱ្យមានការបង្កើតសមាគម និង សម្ព័ន្ធភាពនៃក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីលើកកម្ពស់ឋានៈ សមត្ថភាព និងជាពិសេសការពារសិទ្ធិ និងផលប្រយោជន៍របស់រដ្ឋបាលថ្នាក់ក្រោមជាតិ ។
- ធានា និងផ្តល់ធនធានសម្រាប់ការរៀបចំនីតិវិធី និងយន្តការសំខាន់ៗក្នុងការលើកកម្ពស់សិទ្ធិទទួលបាន ព័ត៌មាន ការប្រឹក្សាយោបល់ជាសាធារណៈ និងការចូលរួមផ្តល់យោបល់របស់ប្រជាពលរដ្ឋលើដំណើរការ អភិបាលកិច្ចមូលដ្ឋាន ព្រមទាំងការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើការងារអនុវត្តរបស់រដ្ឋបាល ថ្នាក់ក្រោមជាតិ ។ល។

គ.ជ.អ.ប នឹងរៀបចំក្របខ័ណ្ឌការងារគណនេយ្យភាពដ៏លម្អិត និងច្បាស់លាស់សម្រាប់អ្នកពាក់ព័ន្ធសំខាន់ៗ ទាំងអស់នៅក្នុងអភិបាលកិច្ចថ្នាក់ក្រោមជាតិ ។

***ប្រភពឯកសារ :*** *កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ នៅថ្នាក់ក្រោមជាតិ ២០១០-២០១៩ (ទំព័រ ១៥៤-១៥៥)*

ផលិតដោយ: Pact Cambodia, VBNK
ឧបត្ថម្ភដោយ: THE WORLD BANK, គ.ជ.អ.ប NCDD

**ការលើកកម្ពស់គណនេយ្យភាពនៅក្នុងការអនុវត្តកម្មវិធីជាតិ**

ក្នុងការពង្រឹងបញ្ហាគណនេយ្យភាព កម្មវិធីជាតិបានកំណត់ឱ្យមានខ្សែគណនេយ្យភាពសំខាន់ៗចំនួនបួន ដូចខាងក្រោម :

១. **គណនេយ្យភាពផ្ទៃក្នុង** សំដៅទៅលើគណនេយ្យភាពនៅក្នុងអង្គការចាត់តាំងមួយរបស់រដ្ឋបាលថ្នាក់ ក្រោមជាតិ ឬនៅក្នុងរង្វង់រដ្ឋបាលមួយនៃរដ្ឋបាលថ្នាក់ក្រោមជាតិ។ ក្នុងបរិបទនៃការអភិវឌ្ឍតាមបែបប្រជា ធិបតេយ្យនៅថ្នាក់ក្រោមជាតិ ការពង្រឹងខ្សែគណនេយ្យភាពផ្ទៃក្នុង សំដៅទៅលើការរៀបចំវិធានការ យន្តការ និងនីតិវិធីនានាសម្រាប់រដ្ឋបាលនីមួយៗនៃថ្នាក់ក្រោមជាតិ ដើម្បីធានាថាក្រុមប្រឹក្សា (ជាអង្គជាប់ឆ្នោត) គឺជាអង្គទទួលខុសត្រូវកំពូល ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន អាចធ្វើសេចក្តីសម្រេចផ្អែកតាម តម្រូវការរបស់ប្រជាពលរដ្ឋ មានលទ្ធភាពត្រួតពិនិត្យ និងណែនាំដល់គណៈអភិបាល និងអង្គភាពនានា ដែលអនុវត្តសេចក្តីសម្រេចរបស់ខ្លួន។

២. **គណនេយ្យភាពអន្តររដ្ឋបាលថ្នាក់ក្រោមជាតិ** សំដៅទៅលើគណនេយ្យភាពរវាងរដ្ឋបាលថ្នាក់ក្រោមជាតិ ឬរវាងអង្គការចាត់តាំងនានានៃរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលមានប្រភេទដូចគ្នា ឬប្រភេទផ្សេងគ្នា។ ការងារជំរុញក្នុងការពង្រឹងគណនេយ្យភាពអន្តររដ្ឋបាលថ្នាក់ក្រោមជាតិ គឺការលើកស្ទួយការឆ្លើយតប ការគាំទ្រ និងគណនេយ្យភាពរបស់ក្រុមប្រឹក្សាស្រុកចំពោះក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងដែនសមត្ថកិច្ច របស់ខ្លួន ស្របតាមមាត្រា៩៧ មាត្រា៩៨ និងមាត្រា១០០នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

៣. **គណនេយ្យភាពអន្តររដ្ឋបាល** សំដៅទៅលើគណនេយ្យភាពរវាងក្រសួង ស្ថាប័ន មន្ទីរ ទីភ្នាក់ងារនានា របស់ក្រសួង ស្ថាប័នជាមួយនឹងរដ្ឋបាលនានានៃរដ្ឋបាលថ្នាក់ក្រោមជាតិ។ លើសពីនេះទៀត គណនេយ្យ ភាពអន្តររដ្ឋបាលនឹងស្តែងចេញតាមរយៈការត្រួតពិនិត្យនីត្យានុកូលភាព (គណនេយ្យភាពផ្នែកច្បាប់) ការត្រួតពិនិត្យដើម្បីធានាបាននូវស្តង់ដារបច្ចេកទេសតាមវិស័យ និងការធ្វើសវនកម្មរដ្ឋបាល និងហិរញ្ញវត្ថុ នៅរដ្ឋបាលថ្នាក់ក្រោមជាតិ។

៤. **គណនេយ្យភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិចំពោះ ប្រជាពលរដ្ឋ ឬគណនេយ្យភាពពីលើទៅក្រោម** សំដៅទៅលើខ្សែគណនេយ្យភាពផ្ទៃកនយោបាយរវាងរដ្ឋបាលថ្នាក់ក្រោមជាតិជាមួយប្រជាពលរដ្ឋ ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន តាមរយៈការរៀបចំឱ្យមានវិធានការ យន្តការ និងនីតិវិធីនានាសម្រាប់ធានា ឱ្យមានការចូលរួមរបស់ប្រជាពលរដ្ឋនៅក្នុងដំណើរការអភិបាលកិច្ចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

**ការលើកកម្ពស់គណនេយ្យភាពក្នុង**
**សមាសធាតុកម្មវិធីទី ១**

ការរៀបចំស្ថាប័នថ្នាក់ក្រោមជាតិ ទាមទារឱ្យមានការយកចិត្តទុកដាក់ទៅលើការពង្រឹងដល់ខ្សែគណនេយ្យភាពទាំងបួនប្រភេទ ដូចខាងក្រោម :

- គណនេយ្យភាពផ្ទៃក្នុង នឹងបង្ហាញឱ្យឃើញតាមរយៈការបង្កើតនូវប្រព័ន្ធរដ្ឋបាលដោយផ្អែកលើវិធាន នៃច្បាប់ និងតម្រូវការរបាយការណ៍នានា។
- គណនេយ្យភាពអន្តររដ្ឋបាលថ្នាក់ក្រោមជាតិ នឹងបង្ហាញឱ្យឃើញតាមរយៈការបង្កើតអង្គភាពគាំទ្រ ឃុំ សង្កាត់របស់ថ្នាក់ស្រុក និងប្រព័ន្ធរបាយការណ៍រវាងរដ្ឋបាលនានានៃរដ្ឋបាលថ្នាក់ក្រោមជាតិ។
- គណនេយ្យភាពអន្តររដ្ឋបាល នឹងបង្ហាញឱ្យឃើញតាមរយៈការសម្របសម្រួលខ្សែទំនងរវាងមន្ទីរ ការិយាល័យ ទីភ្នាក់ងារនានារបស់ក្រសួង ស្ថាប័នជាមួយនឹងរដ្ឋបាលនានានៃរដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងក្របខ័ណ្ឌនៃរដ្ឋបាលឯកភាព។
- គណនេយ្យភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិចំពោះប្រជាពលរដ្ឋនឹងបង្ហាញឱ្យឃើញតាមរយៈ (១) ការអង្កេតពីការពេញចិត្តរបស់ប្រជាពលរដ្ឋចំពោះសេវាសាធារណៈនានា (២) ការប្រើប្រាស់ព័ត៌មានវិទ្យា ដើម្បីជួយឱ្យប្រជាពលរដ្ឋអាចទទួលបាននូវព័ត៌មាន និងសេវាសាធារណៈនានា (៣) គោលការណ៍ ណែនាំ សេចក្តីណែនាំ និងឧបករណ៍នានាសម្រាប់ការចូលរួម ការទទួលបាននូវព័ត៌មាន និងការពិគ្រោះយោបល់របស់ប្រជាពលរដ្ឋ (៤) ការបង្កើតនូវកម្មវិធី និងយន្តការនានាសម្រាប់លើកកម្ពស់ការចូលរួមរបស់ប្រជាពលរដ្ឋ។ល។

**ការលើកកម្ពស់គណនេយ្យភាពក្នុង**
**សមាសធាតុកម្មវិធីទី ២**

កិច្ចការសំខាន់ៗ និងបន្ទាន់ក្នុងការពង្រឹង ខ្សែគណនេយ្យភាពក្នុងប្រព័ន្ធគ្រប់គ្រង និងអភិវឌ្ឍន៍ធនធានមនុស្សនៅថ្នាក់ក្រោមជាតិរួមមាន :

- ការកំណត់តួនាទី ភារកិច្ច និងរបៀបរបបធ្វើការងាររបស់អង្គការចាត់តាំង និងអង្គភាពនានា និង ល័ក្ខខ័ណ្ឌការងាររបស់មន្ត្រី បុគ្គលិករបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។
- ការរៀបចំលក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ ដោយផ្តោតលើការប្រគល់ការ គ្រប់គ្រងមន្ត្រី បុគ្គលិកនៅសាលារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ទៅឱ្យក្រុមប្រឹក្សានានានៃរដ្ឋបាលថ្នាក់ក្រោមជាតិ។
- ការបង្កើតឱ្យមានការប្រាស្រ័យទាក់ទងជាទៀងទាត់រវាងមន្ត្រីបុគ្គលិកនៃរដ្ឋបាលថ្នាក់ក្រោមជាតិ ជាមួយ សហគមន៍ដើម្បីបង្កើនការយល់ដឹងអំពីតួនាទី និងការទទួលខុសត្រូវរបស់មន្ត្រី បុគ្គលិកនៃរដ្ឋបាលថ្នាក់ក្រោមជាតិ និងអំពីតួនាទី និងការទទួលខុសត្រូវរបស់ប្រជាពលរដ្ឋក្នុងការចូលរួម និងជំរុញការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ។
- ការរៀបចំឱ្យមានកម្មវិធី និងសកម្មភាពបណ្តុះបណ្តាល និងអភិវឌ្ឍធនធានមនុស្សនានា ដែលផ្តោតការ យកចិត្តទុកដាក់លើការពង្រឹងខ្សែគណនេយ្យភាពចំពោះប្រជាពលរដ្ឋ (អ្នកទទួលសេវា)។

**ការលើកកម្ពស់គណនេយ្យភាពក្នុង**
**សមាសធាតុកម្មវិធីទី ៣**

ដើម្បីពង្រឹងគណនេយ្យភាពអន្តររដ្ឋបាល និងគណនេយ្យភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិចំពោះប្រជាពលរដ្ឋ កិច្ចការសំខាន់ៗដែលត្រូវអនុវត្តក្នុងសមាធាតុកម្មវិធីនេះរួមមាន :

- ការកំណត់អំពីមុខងារ ការទទួលខុសត្រូវ និងសិទ្ធិអំណាចក្នុងការចាត់ចែងធនធានសម្រាប់អនុវត្តមុខងារ នោះឱ្យបានច្បាស់លាស់តាមប្រភេទរដ្ឋបាលនីមួយៗនៃរដ្ឋបាលថ្នាក់ក្រោមជាតិ។
- ការកំណត់អំពីតួនាទី ការទទួលខុសត្រូវ និងសិទ្ធិអំណាចដែលត្រូវរក្សាទុកនៅថ្នាក់ជាតិ។
- ការកំណត់អំពីស្តង់ដារបច្ចេកទេសជាអប្បរមា និងតម្រូវការក្នុងការផ្តល់សមត្ថភាពចំពោះមុខងារជាក់ លាក់។
- ការកំណត់អំពីនីតិវិធីច្បាស់លាស់ក្នុងការតាមដាន និងត្រួតពិនិត្យរបស់ក្រសួង ស្ថាប័នថ្នាក់ជាតិ។
- ការផ្សព្វផ្សាយជាសាធារណៈអំពីការទទួលខុសត្រូវ និងសិទ្ធិអំណាច


ភ្នែក :
មើលឃើញពីអ្វីដែល
តម្រូវឱ្យផ្លាស់ប្តូរ
ក្បាល :
គិតពិចារណា និង
រៀបចំបង្កើតច្បាប់
បេះដូង :
អារម្មណ៍ចង់ឱ្យផ្លាស់ប្តូរ
សម្រាប់មនុស្សគ្រប់រូប
+ ភ្នែក
+ ក្បាល
+ បេះដូង
ច្បាប់រៀបចំ
អង្គភាព
កម្មវិធីជាតិ :
អនុវត្តច្បាប់រៀបចំ
អង្គការ
កម្មវិធីជាតិ
ផលិតដោយ
ឧបត្ថម្ភដោយ
Pact Cambodia
VBNK
THE WORLD BANK
គជអប
NCDD

# មេរៀនទី ១ ប្លង់មេរៀន

## មេរៀនទី១

## ចំណងជើងមេរៀន ការណែនាំស្ដីពីកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ នៅថ្នាក់ក្រោមជាតិ ២០១០-២០១៩

**ពេលវេលា :** ១១០ នាទី

**របៀបសម្របសម្រួលមេរៀន**

| រយៈពេល | សកម្មភាព និងវិធីសាស្ត្រ | ឯកសារចែកជូន |
|---|---|---|
| ២០ នាទី | <u>១-សេចក្ដីណែនាំ និងគោលបំណងមេរៀន</u><br>ក. សង្ខេបមេរៀនទី១ មេរៀនទី២ និងមេរៀនទី៤ នៅក្នុងជំពូក១<br>▪ ពន្យល់ប្រាប់សិក្ខាកាម ដើម្បីរំលឹកការយល់ដឹងឡើងវិញនូវប្រវត្តិនៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ និងអភិបាលកិច្ច ។ ពន្យល់ថា កម្មវិធីជាតិ គឺបន្តអនុវត្តកំណែទម្រង់ដែលមានកន្លងមក ។<br>▪ រំលឹកឡើងវិញពីទិដ្ឋភាពសំខាន់ៗ របស់ច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ។ ពន្យល់ថា កម្មវិធីជាតិនឹងគាំទ្រដល់ការអនុវត្តច្បាប់ការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ។<br>▪ ប្រាប់ថា រដ្ឋាភិបាលកម្ពុជាបានផ្សព្វផ្សាយអំពីកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ នៅខែសីហា ឆ្នាំ២០១០ ។<br>▪ មេរៀននេះ នឹងរៀបរាប់ពីកម្មវិធីជាតិគោលដៅគោលបំណងរួមទាំងកម្មវិធីអន្តរវិស័យ និងលទ្ធផលរំពឹងទុកដែលពាក់ព័ន្ធនឹងសង្គមស៊ីវិល ។ | ▪ ផ្ទាំងរូបភាពទី ២ និង បទបង្ហាញអំពីដំណើរការវិវឌ្ឍនៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ មេរៀនទី១ ជំពូកទី១<br>▪ ផ្ទាំងរូបភាពទី ៧ និង បទបង្ហាញអំពីទិដ្ឋភាពសំខាន់ៗ ។ នៃច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មេរៀនទី ៤ ជំពូកទី១ ។<br>▪ បទបង្ហាញទី២ |

ជំពូកទី២

| | |
|---|---|
| **ខ. បង្ហាញ និងពន្យល់ពីគោលបំណងមេរៀន**<br>១. បកស្រាយពីរូបភាពទំនាក់ទំនងរវាងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ។<br>២. រៀបរាប់ពីគោលដៅ និងគោលបំណងកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ។<br>៣. រៀបរាប់ពីរចនាសម្ព័ន្ធរបស់កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិរួមជាមួយនឹងសមាសធាតុកម្មវិធីទាំង៥កម្មវិធី អន្តរវិស័យទាំង៣និងលទ្ធផលរំពឹងទុកដែលពាក់ព័ន្ធសង្គមស៊ីវិល។<br>- ជូនព័ត៌មានដល់សិក្ខាកាមថាពួកគេនឹងទទួលបានរាល់ឯកសារចែកជូន ដើម្បីជួយឱ្យពួកគេចងចាំមាតិកាដែលបានបង្ហាញជូន។ ពន្យល់ថារាល់ឯកសារចែកជូននឹងជួយពន្យល់ពីកម្មវិធីជាតិនឹងផ្នែកពាក់ព័ន្ធដទៃទៀត ។ | ▪ ផ្ទាំងរូបភាពទី ១ និង បទបង្ហាញទី ២ |
| **គ. ការពិភាក្សាក្រុមធំ:** ពីទំនាក់ទំនងរវាងច្បាប់ស្តីពី ការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និង កម្មវិធីជាតិ<br>▪ បង្ហាញរូបភាពមនុស្ស : ច្បាប់ស្តីពី ការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ តំណាងឱ្យភ្នែក (មើលឃើញអ្វីដែលតម្រូវឱ្យផ្លាស់ប្តូរ) បេះដូង (អារម្មណ៍ចង់ឱ្យផ្លាស់ប្តូរសម្រាប់មនុស្សគ្រប់រូប) និង ក្បាល (គិតពិចារណា និងរៀបចំបង្កើតច្បាប់) ។ | ▪ រូបភាពមនុស្ស_ភ្នែក ក្បាល និងបេះដូង ជា ច្បាប់តម្រង់ទិស និងកម្មវិធីជាតិគឺជា ដៃ និងជើងទាំងគូរ ម្រាប់ការអនុវត្ត<br>▪ បង្ហាញទី៣ |

| | | |
|---|---|---|
| | បើទោះជាកម្មវិធីជាតិគឺជាដៃ និងជើងទាំងគូរដែលគាំទ្រសកម្មភាពការអនុវត្តច្បាប់អង្គការ ។<br>▪ លើកបង្ហាញពីរូបភាព ហើយសួរថា តើរូបភាពមនុស្សនេះមានន័យដូចម្តេចចំពោះអ្នក ?<br>▪ លើកទឹកចិត្តដល់អ្នកចូលរួម ពីរ ឬ បីនាក់បញ្ចេញមតិយោបល់ ។<br>▪ ពន្យល់លំអិតអំពី រូបភាពដែលបង្ហាញពីទំនាក់ទំនងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ តម្រង់ទិសដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ ។ | ▪ ផ្ទាំងរូបភាពទី ៨ |
| ២០ នាទី | **៤. បង្ហាញក្រុមធំ:** គោលដៅ និងគោលបំណង និងរចនាសម្ព័ន្ធ<br>**ក, ពិភាក្សាក្រុមធំអំពី**<br>– តើអ្វីជាកម្មវិធីជាតិ ? ហេតុអ្វីបានជាមានកម្មវិធីជាតិកើតឡើង ? តើកម្មវិធីជាតិបង្កើតឡើងដើម្បីអ្វី ?<br>– លើកទឹកចិត្តឱ្យសិក្ខាកាម ២-៣នាក់ បញ្ចេញយោបល់ចំពោះសំណួរនីមួយៗ ។<br>– បង្ហាញបទបង្ហាញ និងបកស្រាយពីកម្មវិធីជាតិ និងមូលហេតុ ។<br>**ហេតុផលរបស់កម្មវិធីជាតិ**<br>▪ ពង្រឹង និងពង្រីកលទ្ធិប្រជាធិបតេយ្យថ្នាក់មូលដ្ឋាន ។<br>▪ លើកកម្ពស់ការអភិវឌ្ឍ និងកាត់បន្ថយភាពក្រីក្រថ្នាក់មូលដ្ឋាន ។ | |

| | | |
|---|---|---|
| | ▪ បង្ហាញនូវកិច្ចខិតខំប្រឹងប្រែងគោលនយោបាយរបស់រដ្ឋាភិបាល ។<br>▪ គាំទ្របន្តនូវគោលនយោបាយវិមជ្ឈការ ។<br>▪ គាំទ្របន្តការចូលរួមកំណែទម្រង់ ។<br>▪ គាំទ្រការអនុវត្តច្បាប់ស្តីពីការគ្រប់គ្រងរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ។<br>**ខ, ពិភាក្សាក្រុមធំ - រចនាសម្ព័ន្ធ គោលដៅនៃកម្មវិធីជាតិ**<br>– គោលដៅ គោលបំណង សកម្មភាពចំបងៗ (សមាសធាតុកម្មវិធី) ។<br>– លើកទឹកចិត្តអោយអ្នកចូលរួម ២ ឬ ៣នាក់បញ្ចេញមតិយោបល់តាមការយល់ឃើញ ។<br>**គ, គោលដៅ និងគោលបំណងរបស់កម្មវិធីជាតិ**<br>– បង្ហាញរចនាសម្ព័ន្ធកម្មវិធី គោលដៅ និងគោលបំណងរបស់កម្មវិធីជាតិ (អានគោលដៅ និងគោលបំណងនៅលើរូបភាពផ្ទាំងធំដោយមិនចាំបាច់ពន្យល់)។<br>– ចែកសិក្ខាមពាក់/ក្រុមដែលអង្គុយជិតគ្នា ដើម្បីពិភាក្សាអំពីគោលដៅ និងគោលបំណងរបស់កម្មវិធីជាតិ — តើគោលដៅ និង ទិសដៅកម្មវិធីជាតិមានន័យដូចម្តេច? (៤នាទី)។<br>– លើកទឹកចិត្តឱ្យសិក្ខាកាមបញ្ចេញយោបល់ទៅតាមការយល់ឃើញ ។<br>– បង្ហាញ និងបញ្ជាក់ឱ្យបានច្បាស់លាស់ពីគោលដៅ និងគោលបំណងរបស់កម្មវិធីជាតិ ។ | ▪ បទបង្ហាញទី៤-៥<br>▪ ផ្ទាំងរូបភាពទី ៩- ១០<br>▪ បទបង្ហាញទី ៦-៧<br>▪ រូបភាពផ្ទាំងធំពីរចនាសម្ព័ន្ធកម្មវិធីជាតិ<br>▪ បទបង្ហាញទី ៨-១០ |

**គោលដៅកម្មវិធីជាតិ**

- អភិវឌ្ឍតាមបែបប្រជាធិបតេយ្យដោយមានការចូលរួម និងមានសមធម៌ ។
- លើកកម្ពស់បរិមាណ គុណភាព និងការទទួលបានសេវាសាធារណៈ ឱ្យមានភាពប្រសើរឡើង ។
- រួមចំណែកដល់ការកាត់បន្ថយភាពក្រីក្រ ។

**គោលបំណងកម្មវិធីជាតិ**

- បង្កើតប្រព័ន្ធគ្រប់គ្រងនៅថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និង ឃុំ សង្កាត់ ។ ដោយផ្តោតលើគោលការណ៍នៃការចូលរួមតាមបែបប្រជាធិបតេយ្យ ។
- ប្រតិបត្តិ ឬ ការអនុវត្ត ប្រកបដោយតម្លាភាព និងគណនេយ្យភាព ។
- លើកកម្ពស់ការអភិវឌ្ឍមូលដ្ឋាន និង ការផ្តល់សេវាសាធារណៈ ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋ ។
- រួមចំណែកកាត់បន្ថយភាពក្រីក្រនៅតាមមូលដ្ឋាន ។

២៥ នាទី

| **កម្មវិធី** | **ការពណ៌នាពីគោលដៅ (សង្ខេប)** |
|---|---|
| កម្មវិធីទី ១ | • តួនាទីភារកិច្ចស្ថាប័នរដ្ឋបាលថ្នាក់ក្រោមជាតិ<br>• គោលការណ៍ចូលរួមតាមបែបប្រជាធិបតេយ្យ |
| កម្មវិធីទី ២ | • លើកទឹកចិត្ត និងជំរុញឱ្យមានការផ្តល់សេវារដ្ឋប្រកបដោយវិជ្ជាជីវៈ ។ |
| កម្មវិធីទី ៣ | • កម្រិតនិងគុណភាពនៃការផ្តល់សេវាសា ធារណៈ |

| | |
|---|---|
| | • ប្រតិភូកម្មមុខងារដល់រដ្ឋបាលថ្នាក់ក្រោមជាតិ។ |
| កម្មវិធីទី ៤ | • រដ្ឋបាលថ្នាក់ក្រោមជាតិអាចរក និង ទទួលបាននូវធនធានគ្រប់គ្រាន់ ។<br>• បែងចែកមូលនិធិប្រកបដោយតម្លាភាព និង គណនេយ្យភាព ។ |
| កម្មវិធីទី ៥ | • ពង្រឹងស្ថាប័នជាតិ ដែលដឹកនាំការអនុវត្តកម្មវិធីជាតិ ។ |

**<u>អត្ថន័យរបស់សមាសធាតុកម្មវិធីទាំង៥</u>**

**<u>សមាសធាតុកម្មវិធីទី១</u>** បង្ហាញអំពីសកម្មភាពចាំបាច់នានាក្នុងការរៀបចំស្ថាប័ននៅរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីធានាថារដ្ឋបាលថ្នាក់ក្រោមជាតិអាចគ្រប់គ្រងចាត់ចែងការងារប្រកបដោយប្រសិទ្ធភាព និងមានលក្ខណៈប្រជាធិបតេយ្យ ។

**<u>សមាសធាតុកម្មវិធីទី២</u>** បង្ហាញអំពីបញ្ហាដែលពាក់ព័ន្ធនឹងការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្សរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

**<u>សមាសធាតុកម្មវិធីទី៣</u>** បង្ហាញអំពីជំហានចាំបាច់នានាក្នុងការផ្ទេរមុខងារ និងធនធាន ព្រមទាំងការលើកកម្ពស់ការផ្តល់សេវាសាធារណៈតាមរយៈ រដ្ឋបាលថ្នាក់ក្រោមជាតិ ។

**<u>សមាសធាតុកម្មវិធីទី៤</u>** បង្ហាញអំពីប្រព័ន្ធហិរញ្ញវត្ថុ និង ថវិកាដ៏ច្បាស់លាស់មួយរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ។

**<u>សមាសធាតុកម្មវិធីទី៥</u>** បង្ហាញអំពីការបង្កើតស្ថាប័នដែលចាំបាច់សម្រាប់សម្របសម្រួលការគាំទ្រដល់រដ្ឋបាលថ្នាក់ក្រោមជាតិព្រមទាំងការកែសម្រួលនូវស្ថាប័នដែលកំពុងមាននាពេលបច្ចុប្បន្ន ដើម្បីធានាថាស្ថាប័នទាំងនោះត្រូវមានលក្ខណៈស៊ីសង្វាក់គ្នាជា

▪ បទបង្ហាញទី ១១-១៤

| | | |
|---|---|---|
| | មួយរចនាសម្ព័ន្ធរដ្ឋបាល ដែលត្រូវបានរៀបចំឡើងវិញតាមរយៈកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ។<br>ខ, លទ្ធផលរំពឹងទុករបស់សមាសធាតុកម្មវិធីដែលពាក់ព័ន្ធសង្គមស៊ីវិល ។<br>- បង្ហាញ និងការពិភាក្សាក្រុមធំ — សួរអ្នកចូលរួម តើអ្វីជាលទ្ធផល រំពឹងទុករបស់កម្មវិធី? តើលទ្ធផលរំពឹងទុកនិមួយៗពាក់ព័ន្ធសង្គមស៊ីវិល ឬទេ? ហេតុអ្វី ? | ▪ បទបង្ហាញទី ១៥-២០ |
| ២៥ នាទី | **៥. បំផុសគំនិត:** បង្ហាញ និងពិភាក្សាពីកម្មវិធីអន្តរវិស័យទាំង៣ នៃកម្មវិធីជាតិ<br>▪ តើអ្វីជាកម្មវិធីអន្តរវិស័យ? តើកម្មវិធីអន្តរវិស័យមានន័យដូចម្តេចចំពោះអ្នក ?<br>▪ បង្ហាញកម្មវិធីអន្តរវិស័យទាំងបី ហើយសួរថា ហេតុអ្វីមានកម្មវិធី អន្តរវិស័យចំនួន៣ គឺការបញ្ជ្រាបយេនឌ័រ ការប្រែប្រួលអាកាសធាតុ និង គណនេយ្យភាព ? តើវាពាក់ព័ន្ធជាមួយសមាសធាតុកម្មវិធីទាំង៥ដូចម្តេច? គ្រប់ផែនការ និង ការអនុវត្តសមាសធាតុកម្មវិធីទាំង៥ ត្រូវតែគិតពិចារណា និងដាក់បញ្ចូលកម្មវិធីអន្តរវិស័យ ។<br>▪ <u>ពន្យល់ពីហេតុផលដែលមានកម្មវិធីអន្តរវិស័យទាំង៣</u><br>○ គាំទ្រគោលនយោបាយដែលមានស្រាប់ និងយុទ្ធសាស្ត្រកំពុងអនុវត្តរបស់រាជរដ្ឋាភិបាលកម្ពុជា ។<br>○ ធានាឱ្យមានការទទួលខុសត្រូវនៅគ្រប់កម្រិតរដ្ឋបាលថ្នាក់ក្រោមជាតិ ។<br>▪ បង្ហាញ និងបកស្រាយពីវិសាលភាពរបស់កម្មវិធី | ▪ បទបង្ហាញទី ២១-២៤ |

អន្តរវិស័យទាំង៣ ។

| **កម្មវិធីអន្តរវិស័យ** | **ពណ៌នា** |
|---|---|
| ការបញ្ច្រៀបយេនឌ័រ | |
| បម្រែបម្រួលអាកាសធាតុ | |
| គណនេយ្យភាព | |

▪ បទបង្ហាញទី២៦

**៦. ពិភាក្សាក្រុមធំ:** សង្គមស៊ីវិល និង កម្មវិធីជាតិ

គ. ហេតុអ្វីអង្គការសង្គមស៊ីវិលត្រូវយល់ដឹងពីកម្មវិធីជាតិ

- សង្គមស៊ីវិល គួរតែលើកកម្ពស់ការយល់ដឹងអំពី លទ្ធភាពសម្រាប់ការចូលរួមជាសាធារណៈ ។
- សង្គមស៊ីវិលគួរតែយល់ដឹង អំពីការផ្លាស់ប្តូរចេញពីរចនាសម្ព័ន្ធរដ្ឋបាលដែលមានស្រាប់ ។

**៧. ពិភាក្សាក្រុមធំ:** សង្ខេប និងបញ្ជាក់ឱ្យបានច្បាស់លាស់ពីចំណុចសិក្សាជាគន្លឹះ អំពីកម្មវិធីជាតិ

<u>ក. រំលឹកការយល់ដឹងឡើងវិញ ពីរចនាសម្ព័ន្ធរបស់កម្មវិធីជាតិ</u>

គោលដៅ
កាត់បន្ថយភាពក្រីក្រ ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ និងការផ្តល់សេវា



| | | |
|---|---|---|
| ១០ នាទី | **៣១. សេចក្តីសន្និដ្ឋាន**<br>**៨.**<br>១) រូបភាពទំនាក់ទំនងរបស់ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងកម្មវិធីជាតិ ។<br>▪ ច្បាប់ស្តីពី ការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ជាការតម្រង់ទិសដៅសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ និងការរៀបចំកម្មវិធីជាតិ ។<br>២) កម្មវិធីជាតិ មានគោលដៅ គោលបំណង សមាសធាតុកម្មវិធីទាំង៥ និងកម្មវិធីអន្តរវិស័យទាំង ៣ ។<br>▪ កម្មវិធីជាតិ គឺគាំទ្រនូវគោលនយោបាយដែលមានស្រាប់ និងយុទ្ធសាស្ត្រដែលកំពុងបន្តអនុវត្តរបស់រាជរដ្ឋាភិបាលកម្ពុជា ។<br>៣) នៅមេរៀនបន្ទាប់(ការគ្រប់គ្រងការអនុវត្តកម្មវិធីជាតិ) នឹងពិភាក្សាអំពីយុទ្ធសាស្ត្រគ្រប់គ្រងកម្មវិធីខ្សែគណនេយ្យ-ភាព និងការទទួលខុសត្រូវរបស់ភាគីពាក់ព័ន្ធ ក្នុងការអនុវត្តកម្មវិធីព្រមទាំង — លិខិតបទដ្ឋានគតិយុត្តគាំទ្រការអនុវត្តកម្មវិធីជាតិនឹងសិក្សាអំពី ក្របខ័ណ្ឌច្បាប់លិខិតបទដ្ឋានគតិយុត្តគាំទ្រការអនុវត្តកម្មវិធីជាតិ ។ | ផ្ទាំងរូបភាព ទី ១១:<br>ខ្សែគណនេយ្យភាព |

**សម្ភារៈបង្រៀន :**

- បទបង្ហាញ : ការណែនាំពីកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ២០១០-២០១៩
- ហ្វឺតសរសេរក្រដាស ក្រដាសផ្ទាំងធំ ស្កុតក្រដាស កាតពណ៌
- ប្រើផ្ទាំងរូបភាពទី ៨: រូបមនុស្សឈរជួយឱ្យអ្នកសម្របសម្រួលក្នុងការពន្យល់ទំនាក់ទំនងពីច្បាប់រដ្ឋបាលថ្នាក់ក្រោមជាតិ និងកម្មវិធីជាតិ

- ប្រើផ្ទាំងរូបភាពទី ៩: គោលដៅ_គោលបំណងរបស់កម្មវិធីជាតិ
- ប្រើផ្ទាំងរូបភាពទី ១០: គោលដៅ_គោលបំណងរបស់កម្មវិធីជាតិ សមាសធាតុកម្មវិធីទាំងប្រាំ និងអន្តរកម្មវិធី

## ប្រភពឯកសារយោង

- កម្មវិធីជាតិ សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (អនុម័ត នៅថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១០) អាចយកបានពី គេហទំព័រ www.ncdd.gov.kh
- ច្បាប់ស្តីពី ការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ (អនុម័តឆ្នាំ២០០៨) អាចយកបានពី គេហទំព័រ www.ncdd.gov.kh ដោយដាក់ពាក្យ “organic law” នៅក្នុងប្រអប់ស្វែងរក

# មេរៀនទី២

## ការគ្រប់គ្រងកម្មវិធីជាតិ
## សម្រាប់ការអភិវឌ្ឍតាមបែប
## ប្រជាធិបតេយ្យនៅថ្នាក់
## ក្រោមជាតិ ២០១០_២០១៩

មេរៀនទី ២

# ការគ្រប់គ្រងកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ២០១០-២០១៩

**គោលបំណង** : នៅចុងបញ្ចប់មេរៀននេះ អ្នកចូលរួមនឹងអាច :

១. ពន្យល់អំពីដំណាក់កាលសម្រាប់អនុវត្តកម្មវិធីជាតិ និងលទ្ធផលរំពឹងទុកក្នុងដំណាក់កាលទី១។

២. បរិយាយពីទិដ្ឋភាពទូទៅនៃក្របខ័ណ្ឌការងារតាមដាននិងវាយតម្លៃសម្រាប់កត់ត្រាលទ្ធផលរីកចម្រើនរបស់កម្មវិធីជាតិ។

៣. បរិយាយពីទិដ្ឋភាពទូទៅនៃខ្សែគណនេយ្យភាពទាំង៤សម្រាប់អនុវត្តក្នុងសមាសធាតុកម្មវិធី នៅក្នុងកម្មវិធីជាតិ។

៤. បរិយាយពីទិដ្ឋភាពទូទៅនៃកត្តាសំខាន់ៗមួយចំនួន ដែលមានឥទ្ធិពលលើលទ្ធផលរបស់កម្មវិធី។

៥. គូសបញ្ជាក់ស្ថាប័នពាក់ព័ន្ធ និងតួនាទីសំខាន់ៗរបស់អ្នកពាក់ព័ន្ធ។

## លទ្ធផលរំពឹងទុកនៃមេរៀន:

ក. សិក្ខាកាមនឹងចែករំលែកចំណេះដឹងដែលទទួលបានពីមេរៀននេះជាមួយសមាជិកក្រុមរបស់ខ្លួន។

ខ. សិក្ខាកាមមានជម្រើសដែលជាចំណុចចាប់ផ្តើមរបស់ខ្លួនសម្រាប់ចូលរួមក្នុងដំណើរការអនុវត្តកម្មវិធីជាតិ។

គ. សិក្ខាកាមស្វែងរកព័ត៌មានបន្ថែមអំពីកម្មវិធីជាតិ និងឯកសារពាក់ព័ន្ធដទៃទៀតដោយខ្លួនឯង។

## កំណត់ចំណាំរបស់អ្នកសម្របសម្រួល:

នៅក្នុងមេរៀននេះ អ្នកសម្របសម្រួលមានគោលបំណងចំនួន ២

១. អ្នកសម្របសម្រួលចាំបាច់ត្រូវយល់ពីប្រធានបទដែលបានបង្ហាញនៅក្នុងមេរៀនទី១ ក្នុងជំពូកទី២ មុននឹងចាប់ផ្តើមមេរៀននេះ។ អ្នកសម្របសម្រួលចាំបាច់ត្រូវជួយដល់សិក្ខាកាមឱ្យទទួលស្គាល់ថា នៅក្នុងមេរៀននេះនឹងបន្តបរិយាយអំពីប្រធានបទទាក់ទងទៅនឹងកម្មវិធីជាតិ១០ឆ្នាំ (២០១០-២០១៩)។ ប៉ុន្តែ នៅក្នុងមេរៀននេះនឹងបរិយាយពីទិដ្ឋភាពទូទៅ ថាតើកម្មវិធីជាតិនឹងត្រូវរៀបចំអនុវត្តយ៉ាងដូចម្តេច?

២. អ្នកសម្របសម្រួលចាំបាច់ត្រូវពិនិត្យ និងត្រូវធានាថា ខ្លួនអាចផ្តល់សារបានយ៉ាងច្បាស់លាស់ដែលបានរៀបចំនៅក្នុងបទបង្ហាញរបស់ខ្លួន។ ចំណុចដែលត្រូវផ្តោតការយកចិត្តទុកដាក់នៅក្នុងមេរៀននេះគឺ ១)លទ្ធផលរំពឹងទុកនៅក្នុងដំណាក់កាលទី១, (២) តើក្របខ័ណ្ឌការងារតាមដាននិងវាយតម្លៃអាចជួយដល់ការកត់ត្រាលទ្ធផលរីកចម្រើនរបស់កម្មវិធីជាតិយ៉ាងដូចម្តេច? (៣) ថាតើខ្សែគណនេយ្យភាពទាំង៤ ត្រូវបានបញ្ជ្រាបទៅក្នុងសមាសធាតុកម្មវិធីនៃកម្មវិធីជាតិយ៉ាងដូចម្តេច?។

៣. អ្នកសម្របសម្រួលត្រូវរំលឹកដល់សិក្ខាកាមថា អ្វីដែលបានផ្តល់នៅក្នុងមេរៀននេះ គ្រាន់តែជាទិដ្ឋភាពរួម

និងជាចំណេះដឹងមូលដ្ឋានតែប៉ុណ្ណោះ។

៤. អ្នកសម្របសម្រួលត្រូវរំលឹកដល់សិក្ខាកាមថា ពាក់ព័ន្ធទៅនឹងការចូលរួមរបស់សង្គមស៊ីវិលនៅក្នុងការអនុវត្តកម្មវិធីជាតិ នឹងត្រូវពិភាក្សាលម្អិតនៅជំពូកបន្ទាប់។

៥. អ្នកសម្របសម្រួលត្រូវកត់ត្រារាល់សំណួរដែលមិនអាចឆ្លើយបាន ដើម្បីធ្វើការបូកសរុបដើម្បីឆ្លើយបំភ្លឺក្នុងមេរៀនបន្ទាប់ ឬផ្ញើទៅក្រុមការងាររបស់គ.អ.ជ.ប។



មេរៀនទី ៣ ឯកសារបង្ហាញ

ជំពូកទី២ មេរៀនទី២:

# ការគ្រប់គ្រងកម្មវិធីជាតិ សម្រាប់ការអភិវឌ្ឍតាមបែប ប្រជាធិបតេយ្យនៅថ្នាក់ ក្រោមជាតិ ២០១០-២០១៩

1

## គោលបំណងនៃមេរៀន

- ពិពណ៌នាអំពីដំណាក់កាលនៃអនុវត្តកម្មវិធីជាតិ និងលទ្ធផលរំពឹងទុកក្នុងដំណាក់កាលទី១ នៃការផ្លាស់ប្តូរស្ថាប័ន។
- បរិយាយពីទិដ្ឋភាពទូទៅនៃក្របខ័ណ្ឌការងារតាមដាន និងវាយតម្លៃ សម្រាប់កត់ត្រាលទ្ធផលចម្រើនរបស់កម្មវិធីជាតិ។
- បរិយាយពីទិដ្ឋភាពទូទៅនៃខ្សែគណនេយ្យភាពទាំង៤សម្រាប់អនុវត្តក្នុងសមាសធាតុកម្មវិធី នៅក្នុងកម្មវិធីជាតិ។
- បរិយាយពីទិដ្ឋភាពទូទៅនៃកត្តាសំខាន់ៗដែលមានឥទ្ធិពលលើលទ្ធផលរបស់កម្មវិធី។
- អាចបញ្ជាក់ពីស្ថាប័នពាក់ព័ន្ធ និងតួនាទីសំខាន់ៗរបស់ស្ថាប័នទាំងនោះ

2


រយៈពេលនិងដំណាក់កាលនីមួយៗនៃការអនុវត្តកម្មវិធីជាតិ
មុខងារ
ធនធានហិរញ្ញវត្ថុ
ធនធានមនុស្ស
ការរៀបចំស្ថាប័នថ្នាក់ក្រោមជាតិ
ស្ថាប័នគាំទ្រកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ
ដំណាក់កាលទី១
(២០១១_២០១៣)
ដំណាក់កាលទី២
(២០១៤_២០១៦)
ដំណាក់កាលទី៣
(២០១៧_២០១៩)
3


សកម្មភាពជាអាទិភាពនៅក្នុងសមាសធាតុទាំង៥
ដែលត្រូវអនុវត្តតាមដំណាក់កាលនីមួយៗ
គោលដៅ និងគោលបំណង
(លទ្ធផលរំពឹងទុក)
សមាសធាតុកម្មវិធីទាំង ៥ និង
កម្មវិធីអន្តរវិស័យ
១. ការរៀបចំស្ថាប័នរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
២. ប្រព័ន្ធគ្រប់គ្រង និងអភិវឌ្ឍធនធានមនុស្ស
៣. ការផ្ទេរមុខងារ
៤. ប្រព័ន្ធគ្រប់គ្រងថវិកា ហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិនានា
៥. ស្ថាប័នគាំទ្រកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ
កម្មវិធីអន្តរវិស័យ
ដំណាក់កាលទី១
(២០១១_២០១៣)
ដំណាក់កាលទី២
(២០១៤_២០១៦)
ដំណាក់កាលទី៣
(២០១៧_២០១៩)
4

## លទ្ធផលរំពឹងទុកតាមដំណាក់កាលនីមួយៗ នៃកម្មវិធីជាតិ

នៅពេលដែលគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ និងលិខិតបទដ្ឋានគតិយុត្តនានាត្រូវបានអនុម័ត និងកម្មវិធីនានា នៃកម្មវិធីជាតិត្រូវបានអនុវត្តនោះការផ្លាស់ប្តូរស្ថាប័ននឹងកើតមានតាមដំណាក់កាលនីមួយៗដូចខាងក្រោមៈ

| ការពិពណ៌នា | លទ្ធផលរំពឹងទុកតាមដំណាក់កាលនីមួយៗ | | |
|---|---|---|---|
| | ដំណាក់កាលទី១ (២០១១_២០១៣) | ដំណាក់កាលទី២ (២០១៤_២០១៦) | ដំណាក់កាលទី៣ (២០១៧_២០១៩) |
| គោលដៅ | | | |
| ការផ្លាស់ប្តូរផ្នែកស្ថាប័ន | ក្រុមប្រឹក្សាទាំងអស់នៃរដ្ឋបាលថ្នាក់ក្រោមជាតិនឹងក្លាយជាអ្នកធ្វើសេចក្តីសម្រេចនៅរដ្ឋបាលថ្នាក់ក្រោមជាតិ | | |
| លទ្ធផលរំពឹងទុកផ្នែកស្ថាប័ន | | | 5 |

## លទ្ធផលរំពឹងទុកតាមដំណាក់កាលទី១ (២០១១_២០១៣)

| ការពិពណ៌នា | លទ្ធផលរំពឹងទុកក្នុងដំណាក់កាលទី១ (២០១១_២០១៣) |
|---|---|
| លទ្ធផលរំពឹងទុកផ្នែកស្ថាប័ន | • មន្ត្រីរដ្ឋបាលថ្នាក់ក្រោមជាតិនឹងមានសមត្ថភាពចាំបាច់ជាមូលដ្ឋានដើម្បីអនុវត្តកំណែទម្រង់ វិមជ្ឈការ និងវិសហមជ្ឈការ។<br>• លិខិតបទដ្ឋានគតិយុត្តចាំបាច់នានាសម្រាប់អនុវត្តច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវបានរៀបចំ និងដាក់ឱ្យប្រើប្រាស់។<br>• កិច្ចដំណើរការដែលមាន លក្ខណៈជាប្រព័ន្ធមួយអំពីការពិនិត្យមុខងារឡើងវិញ ដោយរួមទាំងការពិនិត្យមើលមុខងារជាជម្រើសជាដំបូង ដែលនឹងត្រូវផ្ទេរជាបន្តបន្ទាប់ទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបានអនុម័តដោយ គ.ជ.អ.ប។<br>• ប្រព័ន្ធដែលចាំបាច់សម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិទទួលយកមុខងារ និងធនធានដែលនឹងត្រូវផ្ទេរជាបន្តបន្ទាប់ ត្រូវបានបង្កើតឡើង។<br>• មុខងារជាបឋមនានាដែលបានផ្ទេរដោយថ្នាក់ជាតិ ត្រូវបានអនុវត្តដោយរដ្ឋបាលថ្នាក់ក្រោមជាតិ។<br>6 |

## សារៈសំខាន់នៃការបែងចែកជាដំណាក់កាល

ដំណាក់កាលនីមួយៗនឹងកំណត់នូវមូលដ្ឋានគ្រឹះសម្រាប់ការអនុវត្តសកម្មភាពនានាដើម្បីរួមចំណែកសម្រេច បាននូវលទ្ធផលរំពឹងទុក។ ដូច្នេះការបែងចែកជាដំណាក់កាលនិងផ្តល់ៈ

(១) ផ្ទុះបញ្ចាំងពីទិដ្ឋភាពនៃការអនុវត្តជាក់ស្តែងនៃកម្មវិធី។

(២) ផ្តល់នូវភាពច្បាស់លាស់ និងគ្រប់ជ្រុងជ្រោយ ដោយពិចារណាលើរយៈពេលដែលត្រូវប្រើប្រាស់សម្រាប់ការកែតម្រូវ និងការសម្របសម្រួលនានាពាក់ព័ន្ធនឹងការផ្លាស់ប្តូរបុគ្គលិក និងស្ថាប័ន។

(៣) នឹងផ្តល់ពេលវេលាគ្រប់គ្រាន់សម្រាប់អនុញ្ញាតឱ្យមានការសិក្សាវាយតម្លៃច្បាស់លាស់ទៅលើកិច្ចខិតខំប្រឹងប្រែងនៃកំណែទម្រង់ និងការកែតម្រូវតាមការចាំបាច់នានា។

7

## តើធ្វើយ៉ាងដូចម្តេចដើម្បីដឹងពីលទ្ធផលរំពឹងទុកច្រើនដែលសម្រេចបាននៅក្នុងដំណាក់កាលនីមួយៗ?

- ក្របខ័ណ្ឌការងារតាមដាននិងវាយតម្លៃ នឹងត្រូវបានរៀបចំឡើងដែលទាក់ទងទៅនឹងសមាសធាតុកម្មវិធីនានា និងគោលបំណងនានានៃវិមជ្ឈការ និងវិសហមជ្ឈការ
- គ.ជ.អ.ប នឹងបង្កើតនូវអនុគណៈកម្មាធិការតាមដាននិងវាយតម្លៃដែលមានក្រុមផ្តល់យោបល់មួយដែលមានសមាសភាពមកពីរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ ដើម្បីជួយគាំទ្រដល់អនុគណៈកម្មាធិការនេះអាចពិនិត្យមើលការអនុវត្តការងារតាមដាន និងវាយតម្លៃរបស់កម្មវិធីជាតិ។
- រៀបចំឱ្យមានសង្គតភាពការតម្រឹមដៃគូអភិវឌ្ឍន៍ជាមួយក្របខ័ណ្ឌការងារតាមដាននិងវាយតម្លៃនៃកម្មវិធី ជាតិ។

8

## យុទ្ធសាស្ត្រតាមដានត្រួតពិនិត្យនិងវាយតម្លៃ នៅក្នុងដំណាក់កាលទី១(២០១១-២០១៣)

១- ការវាយតម្លៃកម្មវិធី: ការវាយតម្លៃរួមបញ្ចូលនូវការសិក្សា និងវាយតម្លៃលើ:

ក). លទ្ធផលកម្មវិធី

ខ). ផលប៉ះពាល់ពីការអនុវត្តកម្មវិធី

គ). ជម្រើសនៃការរៀបចំគោលនយោបាយ

២-ការតាមដានលើការអនុវត្តកម្មវិធី ដែលរួមមាន:

ក). តាមដានត្រួតពិនិត្យលើការអភិវឌ្ឍសមត្ថភាព រួមមាន: ធាតុចូល សកម្មភាព លទ្ធផល ដោយផ្អែកលើកម្មវិធីដែលបានកំណត់នៅក្នុងផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ។

9

## យុទ្ធសាស្ត្រតាមដានត្រួតពិនិត្យនិងវាយតម្លៃ នៅក្នុងដំណាក់កាលទី១(២០១១-២០១៣) (ត)

ខ).តាមដានលើសកម្មភាពអនុវត្ត និងសមត្ថភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ (សកម្មភាព របស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងលទ្ធផល)។

គ). គាំទ្រដល់រដ្ឋបាលថ្នាក់ជាតិ លើការរៀបចំ និងប្រមូលព័ត៌មានសម្រាប់ត្រួតពិនិត្យមើលលើការអនុវត្តរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ការតាមដានលើការចំណាយសាធារណៈ ការគ្រប់គ្រងធនធានមនុស្ស និងការគ្រប់គ្រងទ្រព្យសម្បត្តិសាធារណៈ។

**កំណត់សម្គាល់:** ការងារតាមដានត្រួតពិនិត្យ និងវាយតម្លៃ មិនគ្រាន់តែសម្រាប់ការវាស់វែងលទ្ធផលប៉ុណ្ណោះទេ ថែមទាំងសម្រាប់ការគ្រប់គ្រង និងលើកកម្ពស់សេវាសាធារណៈផងដែរ។ ដូច្នេះ ការតាមដានត្រួតពិនិត្យមានគោលបំណងចម្បងពីរគឺ: (១) ការពង្រឹងគណនេយ្យភាព និង(២)ការលើកកម្ពស់សេវាសាធារណៈឱ្យកាន់តែមានប្រសិទ្ធភាព។

10

## តើមានខ្សែគណនេយ្យភាពអ្វីខ្លះដែលនឹងអនុវត្តនៅក្នុងកម្មវិធីជាតិ?

| ខ្សែគណនេយ្យភាព | ការពិពណ៌នា |
|---|---|
| ១. គណនេយ្យភាពផ្ទៃក្នុង | សំដៅទៅលើគណនេយ្យភាពនៅក្នុងអង្គភាពចាត់តាំងមួយរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ឬនៅក្នុងរង្វង់រដ្ឋបាលមួយនៃរដ្ឋបាលថ្នាក់ក្រោមជាតិ។ |
| ២.គណនេយ្យភាពអន្តររដ្ឋបាលថ្នាក់ក្រោមជាតិ | សំដៅទៅលើគណនេយ្យភាពរវាងរដ្ឋបាលថ្នាក់ក្រោមជាតិឬរវាងអង្គភាពចាត់តាំងនានានៃរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលមានប្រភេទដូចគ្នា ឬប្រភេទផ្សេងគ្នា។ |
| ៣. គណនេយ្យភាពអន្តររដ្ឋបាល | សំដៅទៅលើគណនេយ្យភាពរវាងក្រសួង ស្ថាប័ន មន្ទីរ ទីភ្នាក់ងារនានារបស់ក្រសួង ស្ថាប័ន ជាមួយនឹងរដ្ឋបាលនានានៃរដ្ឋបាលថ្នាក់ក្រោមជាតិ។ |
| ៤.គណនេយ្យភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិចំពោះប្រជាពលរដ្ឋ | សំដៅទៅលើខ្សែគណនេយ្យភាព ផ្នែកនយោបាយរវាងរដ្ឋបាលថ្នាក់ក្រោមជាតិជាមួយ ប្រជាពលរដ្ឋក្នុង ដែនសមត្ថកិច្ចរបស់ខ្លួន។ 11 |

## ឧទាហរណ៍ៈខ្សែគណនេយ្យភាពអ្វីខ្លះដែលនឹងអនុវត្តនៅក្នុងកម្មវិធីជាតិ




ខ្សែគុណនេយ្យភាពមួយឬច្រើន អាចមានការពាក់ព័ន្ធនឹងសមាសធាតុកម្មវិធីនីមួយៗ
គោលដៅ និង គោលបំណង
(លទ្ធផលរំពឹងទុក)
សមាសធាតុកម្មវិធីទាំង ៥
១. ការរៀបចំការរៀបចំស្ថាប័នរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
២. ប្រព័ន្ធគ្រប់គ្រង និងអភិវឌ្ឍធនធានមនុស្ស
៣. ការផ្ទេរមុខងារ
៤. ប្រព័ន្ធគ្រប់គ្រងថវិកា ហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិនានា
៥. ស្ថាប័នគាំទ្រកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ
ដំណាក់កាលទី១
(២០១១-២០១៣)
ដំណាក់កាលទី២
(២០១៤-២០១៦)
ដំណាក់កាលទី៣
(២០១៧-២០១៩)
ខ្សែគុណនេយ្យភាពទាំងបួនដែលត្រូវអនុវត្ត
ដំណាក់កាលនៃកម្មវិធីជាតិ
13


ខ្សែគុណនេយ្យភាពដែលអាចពាក់ព័ន្ធនឹងសមាសធាតុនីមួយៗ
ខ្សែគុណនេយ្យភាព
ខ្សែគុណនេយ្យភាពដែលនឹងអនុវត្តក្នុងសមាសធាតុកម្មវិធទាំង៥
ស.ធ១
ស.ធ២
ស.ធ ៣
ស.ធ ៤
ស.ធ ៥
១. គណនេយ្យភាពផ្ទៃក្នុង
២. គណនេយ្យភាពអន្តររដ្ឋបាលថ្នាក់ក្រោមជាតិ
៣. គណនេយ្យភាពអន្តររដ្ឋបាល
៤. គណនេយ្យភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិចំពោះប្រជាពលរដ្ឋ
14

## ខ្សែគណនេយ្យភាពដែលអាចពាក់ព័ន្ធនឹងសមាសធាតុនីមួយៗ (ត)

**កំណត់ចំណាំ :** គ.ជ.អ.ប នឹងស្នើឱ្យមាន :

(១)- យន្តការ និងនីតិវិធីច្បាស់លាស់ដើម្បីធ្វើឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិមានគណនេយ្យភាពដោយផ្ទាល់ចំពោះប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន និងរៀបចំយន្តការ និងនីតិវិធីច្បាស់លាស់ក្នុងការកំហិតការត្រួតពិនិត្យរបស់ក្រសួង ស្ថាប័នថ្នាក់ជាតិ ទៅលើការអនុវត្តរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ,

(២)- គ.ជ.អ.ប នឹងរៀបចំបង្កើត និងពង្រឹងនូវយន្តការសម្របសម្រួលកិច្ចការ និងដោះស្រាយវិវាទរដ្ឋបាលនានា ដើម្បីពង្រឹងខ្សែគណនេយ្យភាពផ្ទៃក្នុង និងខ្សែគណនេយ្យភាពអន្តររដ្ឋបាលថ្នាក់ក្រោមជាតិផងដែរ។

15

## កត្តាជាសំខាន់ៗចំនួនដែលមានឥទ្ធិពលលើលទ្ធផលរបស់កម្មវិធីជាតិ

១. ការទទួលខុសត្រូវក្នុងការធានាឱ្យមានភាពត្រឹមត្រូវនៃការប្រើប្រាស់ហិរញ្ញប្បទានរបស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវមាន សង្គតិភាព ជាមួយនឹងការគ្រប់គ្រងចំណូលនិងហិរញ្ញវត្ថុ។

២. ក្រុមប្រឹក្សាត្រូវមានលទ្ធភាពក្នុងការធ្វើសេចក្តីសម្រេចលើការវិភាជន៍ធនធានដែលមានលក្ខណៈឆ្លើយតបនឹងតម្រូវការរបស់មូលដ្ឋាន។

៣. ត្រូវមានប្រព័ន្ធគ្រប់គ្រងបុគ្គលិក និងតារាងប្រាក់បៀវត្សរ៍ច្បាស់លាស់។

៤. ត្រូវការសិក្សាវាយតម្លៃអំពីសមត្ថភាពដើម្បីរៀបចំទិន្នន័យគោលសម្រាប់ការកសាងសមត្ថភាព។

៥. បង្កើននូវការផ្ទេរមុខងារនិងធនធាន។

16

## តើមានស្ថាប័នណាខ្លះនឹងចូលរួមដើម្បី ធ្វើឱ្យសម្រេចបានលទ្ធផលកម្មវិធីជាតិ?

១- **ប្រជាពលរដ្ឋទូទៅ:** ប្រជាពលរដ្ឋទូទៅដែលរស់នៅក្នុងដែនសមត្ថកិច្ចនៃថ្នាក់រដ្ឋបាលនីមួយៗ

២-**ស្ថាប័នជាតិ:** ក្រសួង, អាជ្ញាធរជាតិ,ក្រុមប្រឹក្សាជាតិ,គ្រឹះស្ថានសិក្សា,វិទ្យាស្ថានស្រាវជ្រាវ ..

៣- **គ.ជ.អ.ប:** លេខាធិការដ្ឋាន គ.ជ.អ.ប, អនុគណៈកម្មការនានា, អង្គភាពគាំទ្រ.....។ល។

៤-**ដៃគូអភិវឌ្ឍ:** UNDP, UNCDF, WB, UNICEF, UNFPA, USAID,.......

៥-**រដ្ឋបាលថ្នាក់ក្រោមជាតិ:** រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ និងមន្ទីរីស័យ

៦-**វិស័យឯកជន:** គ្រឹះស្ថានសិក្សាឯកជន,ក្រុមហ៊ុនឯកជន, អ្នកផ្តល់សេវាប្រឹក្សាឯកជន រោងចក្រ, សហគ្រាស..

៧-**អង្គការសង្គមស៊ីវិល:** អង្គការជាតិ និងអន្តរជាតិ, អង្គការសហគមន៍មូលដ្ឋាន និងសមាគម

17

## តើស្ថាប័នទាំងនោះមានតួនាទីសំខាន់ៗអ្វីខ្លះ ដើម្បីធ្វើឱ្យសម្រេចបានលទ្ធផលកម្មវិធីជាតិ?

១- **ប្រជាពលរដ្ឋទូទៅ:** ចូលរួមអនុវត្ត, តាមដានការផ្តល់សេវា, ផ្តល់ព័ត៌មានត្រលប់, ចែករំលែកព័ត៌មាន, ជ្រើសរើសតំណាងរបស់ខ្លួន,..។ល។

២-**ស្ថាប័នជាតិ:** រៀបចំគោលនយោបាយ, យុទ្ធសាស្ត្រ, យន្តការអនុវត្ត, គោលការណ៍ណែនាំ, តាមដានការអនុវត្តគោលនយោបាយ, ផ្តល់ព័ត៌មានត្រលប់,..។ល។

៣- **គ.ជ.អ.ប:** សេនាធិការឱ្យរាជរដ្ឋាភិបាល, សម្របសម្រួល, គាំទ្រ និងការពិនិត្យមើលលើការអនុវត្តកម្មវិធី កំណត់តម្រូវការបុគ្គលិក សមត្ថភាព និងធនធានហិរញ្ញវត្ថុសម្រាប់ការអនុវត្ត កម្មវិធី..។ល។

18

## តើស្ថាប័នទាំងនោះមានតួនាទីសំខាន់ៗអ្វីខ្លះ ដើម្បីធ្វើឱ្យសម្រេចបានលទ្ធផលកម្មវិធីជាតិ?

**៤_ដៃគូអភិវឌ្ឍ:** សហការ, ផ្តល់ប្រឹក្សាយោបល់, គាំទ្រផ្នែកហិរញ្ញវត្ថុ..។ល។

**៥_រដ្ឋបាលថ្នាក់ក្រោមជាតិ:** ចូលរួមអនុវត្តកម្មវិធីជាតិ, ផ្តល់យោបល់ត្រលប់សម្រាប់ការកែសម្រួលគោលនយោបាយ និងតាមដាន ការអនុវត្តកម្មវិធីជាតិ...។ល។

**៦_វិស័យឯកជន:** កសាងដៃគូជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិ, ចូលរួមផ្តល់សេវាកម្ម (រូបវន្ត និង អរូបវន្ត), បណ្តុះបណ្តាល និងកសាងសមត្ថភាពផ្នែកតាមតម្រូវការ, តាមដានការអនុវត្ត និងពង្រឹកគណនេយ្យភាព, ផ្តល់ព័តមាន ត្រលប់សម្រាប់,..។ល។

19

## តើស្ថាប័នទាំងនោះមានតួនាទីសំខាន់ៗអ្វីខ្លះ ដើម្បីធ្វើឱ្យសម្រេចបានលទ្ធផលកម្មវិធីជាតិ?

**៧_អង្គការសង្គមស៊ីវិល:** (១) កសាងដៃគូជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិ, (២) ចូលរួមផ្តល់ សេវាកម្ម (រូបវន្ត និងអរូបវន្ត), (៣) បណ្តុះបណ្តាល និងកសាងសមត្ថភាពផ្នែក តាមតម្រូវការ,(៤)តាមដានការអនុវត្ត និងពង្រឹកគណនេយ្យភាព, (៥)ផ្តល់ព័តមានត្រលប់ និងចូលរួមក្នុងការៀបចំគោលនយោបាយ, (៦)ចូលរួមការពង្រឹកការ ពិគ្រោះយោបល់រវាងប្រជាពលរដ្ឋ និងក្រុមប្រឹក្សាថ្នាក់ក្រោមជាតិ, (៧) ចូលរួម ពង្រឹងការផ្សារភ្ជាប់ទំនាក់ទមនងរវាង ប្រជាពលរដ្ឋនិងថ្នាក់រដ្ឋបាលនីមួយៗនៅថ្នាក់ ក្រោមជាតិ. (៨)ចែករំលែកព័ត៏មានដែល ទទួលបានពីប្រជាពលរដ្ឋទៅក្រុមប្រឹក្សា និងពីក្រុមប្រឹក្សាទៅប្រជាពលរដ្ឋ, ស្វែងរកការគាំទ្រមតិ...។ល។

20

ឧបករណ៍២

មេរៀនទី ៣ ឯកសារចែក

## ជំពូកទី២_មេរៀនទី២

## ចំណងជើងមេរៀន : ការគ្រប់គ្រងកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ២០១០_២០១៩

### ឯកសារចែកទី១:

ការផ្លាស់ប្តូរស្ថាប័ននឹងកើតមានឡើងនៅពេលដែលគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ និងលិខិតបទដ្ឋានគតិយុត្តនានាត្រូវបានអនុម័ត និងកម្មវិធីនានានៃកម្មវិធីជាតិដែលពាក់ព័ន្ធនឹងគោលនយោបាយទាំងនេះត្រូវបានអនុវត្ត។តារាងបង្ហាញពីគោលដៅការផ្លាស់ប្តូរផ្នែកស្ថាប័ន និងលទ្ធផលផ្នែក ស្ថាប័នដែលរំពឹងទុកតាមដំណាក់កាលនីមួយៗ។

តារាង២.១ : រយៈពេល និងលទ្ធផលរំពឹងទុកតាមដំណាក់កាលនីមួយៗនៃកម្មវិធីជាតិ

| ការពិពណ៌នា | លទ្ធផលរំពឹងទុកតាមដំណាក់កាលនីមួយៗ | | |
|---|---|---|---|
| | ដំណាក់កាលទី១ (២០១០_២០១២) | ដំណាក់កាលទី២ (២០១៣_២០១៥) | ដំណាក់កាលទី៣ (២០១៦_២០១៩) |
| **គោលដៅ** | បង្កើតរចនាសម្ព័ន្ធ និងប្រព័ន្ធអភិបាលកិច្ចទាំងនៅថ្នាក់ក្រោមជាតិ និងថ្នាក់ជាតិ ដើម្បីធានាដល់ការអនុវត្តគោលនយោបាយ និងប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិសេវាសាធារណៈដែលផ្តល់ដោយរដ្ឋបាលថ្នាក់ក្រោមជាតិ | ពង្រឹង និងពង្រីករចនាសម្ព័ន្ធ និង ប្រព័ន្ធដើម្បីធានាឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិមានលទ្ធភាពដាក់ចេញនិងអនុវត្តនូវគោលនយោបាយសម្រាប់មូលដ្ឋានខ្លួនសំដៅលើកកម្ពស់ការផ្តល់សេវាសាធារណៈ និងបង្កើនលទ្ធភាពទទួលយកសេវាសាធារណៈរបស់ស្ត្រី និងអ្នកដែលបានទទួលសេវាសាធារណៈជាមូលដ្ឋានតិចតួច | កែតម្រូវកម្មវិធីនានា និងធ្វើឱ្យមានឥទ្ធិពលកាន់តែស៊ីជម្រៅតាមរយៈការអនុវត្តមេរៀន និងបទពិសោធន៍ដែលទទួលបាន និងធានាថាកម្មវិធីនានាស្តីពីការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិឆ្លើយតប និងឆ្លុះបញ្ចាំងពីគោលនយោបាយ និងយុទ្ធសាស្ត្រថ្មីៗ របស់រាជរដ្ឋាភិបាល |

| ការពិពណ៌នា | លទ្ធផលរំពឹងទុកតាមដំណាក់កាលនីមួយៗ | | |
|---|---|---|---|
| | ដំណាក់កាលទី១ (២០១០_២០១២) | ដំណាក់កាលទី២ (២០១៣_២០១៥) | ដំណាក់កាលទី៣ (២០១៦_២០១៩) |
| | | | ឆ្លើយតប និងឆ្លុះបញ្ចាំងពីគោល នយោបាយនិងយុទ្ធសាស្ត្រថ្មីៗរបស់រាជរដ្ឋាភិបាល |
| ការផ្លាស់ប្តូរផ្នែកស្ថាប័ន | ក្រុមប្រឹក្សាទាំងអស់នៃរដ្ឋបាលថ្នាក់ក្រោមជាតិនឹងក្លាយជាអ្នកធ្វើសេចក្តីសម្រេចនៅរដ្ឋបាលថ្នាក់ក្រោមជាតិ | នៅពេលមុខងារត្រូវបានផ្ទេរកាន់តែច្រើនឡើង ខ្សែគណនេយ្យភាពរវាងក្រសួង ស្ថាប័នជាមួយរដ្ឋបាលនានាថ្នាក់ក្រោមជាតិនឹងត្រូវបានពង្រឹងឡើងចំពោះក្រុមប្រឹក្សា | ក្រសួង ស្ថាប័ននានា ទទួលខុសត្រូវកាន់តែច្រើនឡើងក្នុងការបង្កលទ្ធភាពឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ជាអ្នកអនុវត្តយុទ្ធសាស្ត្រនានារបស់វិស័យ |
| | • មន្ត្រីរដ្ឋបាលថ្នាក់ក្រោមជាតិនឹងមានសមត្ថភាពចាំបាច់ជាមូលដ្ឋានដើម្បីអនុវត្តកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ<br>• លិខិតបទដ្ឋានគតិយុត្តចាំបាច់នានាសម្រាប់អនុវត្តច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវបានរៀបចំនិងដាក់ឱ្យប្រើប្រាស់<br>• កិច្ចដំណើរការដែលមានលក្ខណៈជាប្រព័ន្ធមួយអំពីការពិនិត្យមុខងារឡើងវិញ | • មុខងារដែលបានផ្ទេរក្នុងដំណាក់កាលទី១ ត្រូវពិនិត្យឡើងវិញដើម្បីបន្តពង្រីកការផ្ទេរមុខងារជាបន្ថែមទៀតទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ<br>• រដ្ឋបាលថ្នាក់ក្រោមជាតិមានស្វ័យភាពផ្នែករដ្ឋបាលច្រើនជាង<br>• មុននៅពេលដែលសមត្ថភាពរបស់ខ្លួនមានការកើនឡើង | |

| ការពិពណ៌នា | លទ្ធផលរំពឹងទុកតាមដំណាក់កាលនីមួយៗ | | |
|---|---|---|---|
| | ដំណាក់កាលទី១ (២០១០_២០១២) | ដំណាក់កាលទី២ (២០១៣_២០១៥) | ដំណាក់កាលទី៣ (២០១៦_២០១៩) |
| លទ្ធផលរំពឹងទុកផ្នែកស្ថាប័ន | ស្រុក ខណ្ឌ ត្រូវបានរៀបចំ និងដាក់ឱ្យប្រើប្រាស់<br>• កិច្ចដំណើរការដែលមានលក្ខណៈជាប្រព័ន្ធមួយអំពីការពិនិត្យមុខងារឡើងវិញ មុខងារជាជម្រើសជាដំបូង ដែលនឹងត្រូវផ្ទេរជាបន្តបន្ទាប់ទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបានអនុម័តដោយ គ.ជ.អ.ប<br>• ប្រព័ន្ធដែលចាំបាច់សម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ ទទួលយកមុខងារ និងធនធានដែល នឹងត្រូវផ្ទេរជាបន្តបន្ទាប់ ត្រូវ បានបង្កើតឡើង<br>• មុខងារជាបឋមនានាដែលបានផ្ទេរដោយថ្នាក់ជាតិត្រូវបានអនុវត្តដោយរដ្ឋបាលថ្នាក់ក្រោមជាតិ | • រដ្ឋបាលថ្នាក់ក្រោមជាតិមានស្វ័យភាពផ្នែករដ្ឋបាលច្រើនជាងមុននៅពេលដែលសមត្ថភាពរបស់ខ្លួនមានការកើនឡើង<br>• មុខងារដែលបានផ្ទេរក្នុងដំណាក់កាលទី១ ត្រូវពិនិត្យឡើងវិញដើម្បីបន្តពង្រីកការផ្ទេរមុខងារជាបន្ថែមទៀតទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ<br>• គណនេយ្យភាពខ្សែទទឹង និងខ្សែបណ្ដោយមានតុល្យភាពដើម្បីធានាឱ្យក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិឆ្លើយតបតម្រូវការ និងគោរពសិទ្ធិរបស់ប្រជាពលរដ្ឋ | • រដ្ឋបាលថ្នាក់ក្រោមជាតិមានការទទួលខុសត្រូវកាន់តែច្រើនចំពោះគុណភាព និងការទទួលបាននូវសេវាសាធារណៈនានារបស់ប្រជាពលរដ្ឋ<br>• ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិធ្វើការរួមគ្នាជាមួយប្រជាពលរដ្ឋដើម្បីសម្រេចគោលដៅអភិវឌ្ឍន៍ជាតិ<br>• រដ្ឋបាលថ្នាក់ក្រោមជាតិមានលទ្ធភាពក្នុងការធ្វើសេចក្តីសម្រេចបែងចែកធនធានសម្រាប់កិច្ចការតាមវិស័យ |

**កំណត់សម្គាល់:** អាស្រ័យដោយកម្មវិធីជាតិមានរយៈពេលវែង ដូចនេះ ការបែងចែកជាដំណាក់កាលនីមួយៗនឹងកំណត់នូវមូលដ្ឋានគ្រឹះសម្រាប់ការអនុវត្តសកម្មភាពនានា ដើម្បីរួមចំណែកសម្រេចបាននូវលទ្ធផលរំពឹងទុក។ ដូច្នេះការបែងចែកជាដំណាក់កាលនិងផ្តល់: (១) ឆ្លុះបញ្ចាំងពីទិដ្ឋភាពនៃការអនុវត្តជាក់ស្តែងនៃកម្មវិធី។ (២)ផ្តល់នូវភាពច្បាស់លាស់និងគ្រប់ជ្រុងជ្រោយ ដោយពិចារណាលើរយៈពេលដែលត្រូវប្រើប្រាស់សម្រាប់ការកែតម្រូវ និង ការសម្របសម្រួលនានាពាក់ព័ន្ធនឹងការផ្លាស់ប្តូរបុគ្គលិក និងស្ថាប័ន។ (៣)នឹងផ្តល់ពេលវេលាគ្រប់គ្រាន់សម្រាប់អនុញ្ញាតឱ្យមានការសិក្សាវាយតម្លៃច្បាស់លាស់ទៅលើកិច្ចខិតខំប្រឹងប្រែងនៃកំណែទម្រង់ និងការកែតម្រូវតាមការចាំបាច់នានា។ ឯកសារយោង: កម្មវិធីជាតិ (២០១០-២០១៩): ជំពូកទី២ ទំព័រ ២៩-៣១។

## ឯកសារចែកទី២:

### ១– សង្ខេបការងារតាមដាន និងវាយតម្លៃ

គ.ជ.អ.ប ត្រូវធ្វើជាសេនាធិការជូនរាជរដ្ឋាភិបាលក្នុងការវិភាគ និងការពិនិត្យឡើងវិញឱ្យបានច្បាស់លាស់លើ ការអនុវត្តកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។ អាស្រ័យហេតុនេះ គ.ជ.អ.ប ត្រូវរៀបចំប្រព័ន្ធមួយដែលមិនគ្រាន់តែជាយន្តការសម្រាប់ធ្វើរបាយការណ៍ប៉ុណ្ណោះទេ ប៉ុន្តែជាប្រព័ន្ធដែលអាចប្រើប្រាស់សម្រាប់ការគ្រប់គ្រង និងការធ្វើសេចក្តីសម្រេច។ ដើម្បីអនុវត្តការងារនេះ ចាំបាច់ត្រូវបង្កើតប្រព័ន្ធតាមដាន និងវាយតម្លៃមួយដែលមានលក្ខណៈឌីណាមិច និងដោយមានធនធានគ្រប់គ្រាន់សម្រាប់ប្រតិបត្តិការ។ តាមមធ្យោបាយនេះ គ.ជ.អ.ប នឹងមានលទ្ធភាពតាមដានលើរាល់ការអនុវត្តសកម្មភាពរបស់កម្មវិធីជាតិ និងកែតម្រូវកម្មវិធីជាតិប្រកបដោយតម្លាភាព និងការឆ្លើយតប ព្រមទាំងអាចរាយការណ៍ជូនរាជរដ្ឋាភិបាលអំពីការជះឥទ្ធិពលជាទូទៅនៃកំណែទម្រង់ វិមជ្ឈការ និងវិសហមជ្ឈការទៅលើជីវភាពរស់នៅរស់ប្រជាពលរដ្ឋ។ គ.ជ.អ.ប នឹងប្រើប្រាស់ក្របខ័ណ្ឌតាមដាន និងវាយតម្លៃនេះសម្រាប់ការវាស់វែងលទ្ធផល និងសម្រាប់ការគ្រប់គ្រងនិងលើកកម្ពស់សេវាសាធារណៈផងដែរ។ ដូច្នេះក្របខ័ណ្ឌនេះត្រូវបាន ប្រើប្រាស់សម្រាប់គោលបំណងចម្បងពីរពោលគឺការពង្រឹងគណនេយ្យភាព និងការលើកកម្ពស់សេវាសាធារណៈឱ្យកាន់តែមានប្រសិទ្ធភាព។

## ២-ទំនាក់ទំនងរវាងក្របខ័ណ្ឌការងារតាមដាននិងវាយតម្លៃជាមួយនឹងសមាសធាតុកម្មវិធីនានានិងគោលបំណងនានានៃវិមជ្ឈការ និងវិសហមជ្ឈការ

ក្របខ័ណ្ឌការងារតាមដាន និងវាយតម្លៃនឹងគាំទ្រដល់ដំណើរការបង្កើតបន្ថែមនូវសូចនាករចាំបាច់នានានៅក្នុងអំឡុងពេល នៃការអនុវត្តកម្មវិធីជាតិរយៈពេល១០ឆ្នាំនេះ។ ផ្អែកតាមក្របខ័ណ្ឌការងារតាមដាន និងវាយតម្លៃនេះ គ.ជ.អ.ប ក្រសួង ស្ថាប័នពាក់ព័ន្ធ និងដៃគូអភិវឌ្ឍន៍ នឹងអាចតាមដានលើការអនុវត្តសមាសធាតុកម្មវិធីនីមួយៗ អាចវាយតម្លៃទៅលើការសម្រេចបាននូវលទ្ធផលរំពឹងទុកនានា និងអាចជួយរៀបចំបង្កើតឡើងនូវគោលនយោបាយ និងកម្មវិធីសម្រាប់អន្តរាគមន៍ទៅលើបញ្ហានានា ដែលបានកើតឡើង។

ក្របខ័ណ្ឌតក្កភាពនៃកម្មវិធីជាតិ បានកំណត់នូវលទ្ធផលរំពឹងទុកនានា ដែលលទ្ធផលរំពឹងទុកទាំងនោះបង្កើតបានជាមូលដ្ឋាននៃក្របខ័ណ្ឌការងារតាមដាន និងវាយតម្លៃ។ សូចនាករនៃលទ្ធផលដែលបានកំណត់នៅក្នុងក្របខ័ណ្ឌតក្កភាព គឺជាសូចនាករគន្លឹះ៧សម្រាប់ការតាមដាន និងការរៀបចំរបាយការណ៍ជាទៀងទាត់របស់ គ.ជ.អ.ប ដោយសារសូចនាករទាំងនេះជួយតាមដានលើដំណើរការអនុវត្ត និងផលប៉ះពាល់នៃការអនុវត្តកម្មវិធីជាតិ។ **ឯកសារយោង: កម្មវិធីជាតិ (២០១០_២០១៩):** ជំពូកទី៤ ទំព័រ ១១១_១១២។

## ៣-យុទ្ធសាស្ត្រសម្រាប់ការតាមដានត្រួតពិនិត្យ និងវាយតម្លៃកម្មវិធីនៅក្នុងដំណាក់កាលទី១ (២០១១_២០១៣)

សម្រាប់ការអនុវត្ត ផែនការអនុវត្តរយៈពេល៣ឆ្នាំ (២០១១_២០១៣) (ផអ៣) យុទ្ធសាស្ត្រតាមដានត្រួតពិនិត្យ និងវាយតម្លៃត្រូវមានដំណើរការប្រទាក់ក្រឡាគ្នាជាច្រើន។ លេខាធិការដ្ឋាន គ.ជ.អ.ប ទទួលខុសត្រូវក្នុងការតាមដានត្រួតពិនិត្យ និងវាយតម្លៃក្នុងកម្រិតកម្មវិធី និងការរៀបចំប្រព័ន្ធតាមដានត្រួតពិនិត្យ និងវាយតម្លៃដែលមានលក្ខណៈចម្រុះនិងប្រទាក់ក្រឡាគ្នានៅក្នុងរដ្ឋាភិបាលទាំងមូល។យុទ្ធសាស្ត្រតាមដានត្រួតពិនិត្យនិងវាយតម្លៃត្រូវរៀបចំឡើងដើម្បីឆ្លើយតបទៅនឹងផ្នែកសំខាន់ៗ ដូចខាងក្រោម :

១. ការវាយតម្លៃកម្មវិធី ជាការទទួលខុសត្រូវរបស់ការិយាល័យស្រាវជ្រាវវាយតម្លៃ និងឯកសាររបស់អង្គភាពគាំទ្រគោលនយោបាយនៃលេខាធិការដ្ឋាន គ.ជ.អ.ប។ ក្របខ័ណ្ឌតាមដានត្រួតពិនិត្យ និងវាយតម្លៃត្រូវរៀបចំឡើងដើម្បីជំរុញឱ្យមានការសិក្សារៀនសូត្រ និងដើម្បីឱ្យអ្នករៀបចំគោលនយោបាយទទួលបាននូវព័ត៌មាននិងធ្វើសេចក្តីសម្រេចចិត្តដោយមានហេតុផលច្បាស់លាស់។ ការតាមដានត្រួតពិនិត្យ និងវាយតម្លៃនឹងបញ្ចូលនូវ

សកម្មភាពសំខាន់ៗមួយចំនួន ពិសេសការវាយតម្លៃ លើប្រសិទ្ធភាពនៃការអនុវត្តសាកល្បង។ ការវាយតម្លៃរួមបញ្ចូលនូវការសិក្សា និងវាយតម្លៃលើ :

ក). លទ្ធផលកម្មវិធី

ខ). ផលប៉ះពាល់ពីការអនុវត្តកម្មវិធី

គ). ជម្រើសនៃការរៀបចំគោលនយោបាយ

២. ការតាមដានលើការអនុវត្តកម្មវិធីគឺជាការទទួលខុសត្រូវរបស់ការិយាល័យគាំទ្រការតានដានត្រួតពិនិត្យ របាយការណ៍ និងព័ត៌មានវិទ្យារបស់អង្គភាពគាំទ្រកម្មវិធីនៃលេខាធិការដ្ឋាន គ.ជ.អ.ប។ ការតាមដានលើការអនុវត្តកម្មវិធីនេះ រួមបញ្ចូលនូវ :

ក). តាមដានត្រួតពិនិត្យលើការអភិវឌ្ឍន៍សមត្ថភាព រួមមាន ធាតុចូល សកម្មភាពលទ្ធផលដោយផ្អែកលើកម្មវិធីដែលបានកំណត់នៅក្នុងផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ។ ដូច្នេះអនុកម្មវិធីនីមួយៗត្រូវបរិយាយអំពីការតាមដានត្រួតពិនិត្យសម្រាប់អនុកម្មវិធីរបស់ខ្លួន។ លេខាធិការដ្ឋានគ.ជ.អ.ប ត្រូវធ្វើការតាមដានត្រួតពិនិត្យលើភាពរីកចម្រើនដោយផ្អែកលើសូចនាករទាំងនោះ។

ខ). តាមដានលើសកម្មភាពអនុវត្ត និងសមត្ថភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ (សកម្មភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងលទ្ធផល) ដោយផ្តោតលើសកម្មភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងការវិនិយោគការទទួលហិរញ្ញប្បទានតាមរយៈការផ្តល់មូលនិធិតាមបែបវិមជ្ឈការ និងលទ្ធភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការតាមដានត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តនិងលទ្ធផលរបស់ពួកគេ (ការតាមដានត្រួតពិនិត្យនិងវាយតម្លៃរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ)។ រាជធានី ខេត្ត ក្រុង ស្រុក ឬ ឃុំ សង្កាត់ត្រូវបូកសរុប និងរាយការណ៍អំពីសូចនាករនៃការអនុវត្តដែលជាមូលដ្ឋានសម្រាប់រៀបចំ "League Table" របស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដោយមានការចង្អុលបង្ហាញនូវចង្វាក់លទ្ធផលនៅតាមរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ។ កិច្ចការនេះគឺជាការទទួលខុសត្រូវរបស់ក្រសួងមហាផ្ទៃ និង

គ). គាំទ្រដល់រដ្ឋបាលថ្នាក់ជាតិ លើការរៀបចំ និងប្រមូលព័ត៌មានសម្រាប់ត្រួតពិនិត្យមើលលើការអនុវត្តរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ការតាមដានលើ ការចំណាយសាធារណៈ ការគ្រប់គ្រងធនធានមនុស្ស និងការគ្រប់គ្រងទ្រព្យសម្បត្តិសាធារណៈ។ កិច្ចការទាំងនេះជាការទទួលខុសត្រូវរបស់ក្រសួង ស្ថាប័នសំខាន់ៗ ដូចជា

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងផែនការ និងរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ។ លេខាធិការដ្ឋាន គ.ជ.អ.ប នឹងគាំទ្រដល់ការរៀបចំក្រុមអធិការកិច្ចអន្តរក្រសួងដែលមានការគាំទ្រដោយប្រព័ន្ធទិន្នន័យមូលដ្ឋានចម្រុះ និងដែលគ្រប់គ្រងដោយក្រសួង ស្ថាប័ន នីមួយៗ ប៉ុន្តែអាចប្រើប្រាស់ដោយក្រសួង ស្ថាប័នទាំងអស់។

**ឯកសារយោង:** សេចក្តីព្រាងផែនការអនុវត្តរយៈពេល៣ឆ្នាំ (២០១១-២០១៣) ចំណុចលេខ ៩។

## ឯកសារចែកទី៣: ខ្សែគណនេយ្យភាពទាំងបួន

យន្តការគណនេយ្យភាពទាំងឡាយដែលធ្វើស្ថាប័នភាវូបនីយកម្មគណនេយ្យភាពផ្នែកច្បាប់ ហិរញ្ញវត្ថុ និងរដ្ឋបាល និងដែលធានាដល់ការការពារសិទ្ធិ និងសំឡេងរបស់ប្រជាពលរដ្ឋតាមរយៈកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ត្រូវអនុវត្តតាមខ្សែគណនេយ្យភាពជាក់លាក់។

**ខ្សែគណនេយ្យភាពដែលបានកំណត់ដោយកម្មវិធីជាតិ**

| ល.រ | ខ្សែគណនេយ្យភាព | ពីពណ៌នាពីការអនុវត្ត |
|---|---|---|
| ១ | គណនេយ្យភាពផ្ទៃក្នុង | សំដៅទៅលើគណនេយ្យភាពនៅក្នុងអង្គការចាត់តាំងមួយរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ឬនៅក្នុងរង្វង់រដ្ឋបាលមួយនៃរដ្ឋបាលថ្នាក់ក្រោមជាតិ។ |
| ២ | គណនេយ្យភាពអន្តររដ្ឋបាលថ្នាក់ក្រោមជាតិ | សំដៅទៅលើគណនេយ្យភាពរវាងរដ្ឋបាលថ្នាក់ក្រោមជាតិ ឬរវាងអង្គការចាត់តាំងនានានៃរដ្ឋបាលថ្នាក់ក្រោមជាតិដែលមានប្រភេទដូចគ្នា ឬប្រភេទផ្សេងគ្នា។ |
| ៣ | គណនេយ្យភាពអន្តររដ្ឋបាល | សំដៅទៅលើគណនេយ្យភាពរវាងក្រសួង ស្ថាប័ន មន្ទីរ ទីភ្នាក់ងារនានារបស់ក្រសួង ស្ថាប័ន ជាមួយនឹងរដ្ឋបាលនានានៃរដ្ឋបាលថ្នាក់ក្រោមជាតិ។ |
| ៤ | គណនេយ្យភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិចំពោះប្រជាពលរដ្ឋ | សំដៅទៅលើខ្សែគណនេយ្យភាព ផ្នែកនយោបាយរវាងរដ្ឋបាលថ្នាក់ក្រោមជាតិជាមួយប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ |

**ឯកសារយោង: កម្មវិធីជាតិ (២០១០-២០១៩): ជំពូកទី២ ទំព័រ ២៤-២៦**

ជំពូកទី២

**ឯកសារចែកទី៤:** ខ្សែគណនេយ្យភាពទាំងបួនប្រើនៅក្នុង សមាសធាតុកម្មវិធីនីមួយៗ

សមាសធាតុកម្មវិធីនីមួយៗអាចមានការពាក់ព័ន្ធនឹងខ្សែគណនេយ្យភាពមួយឬច្រើន។ ខាងក្រោមនេះបង្ហាញ ពីខ្សែគណនេយ្យភាពពាក់ព័ន្ធនៅក្នុងសមាសធាតុ កម្មវិធីនីមួយៗ

| សមាសធាតុកម្មវិធី | ខ្សែគណនេយ្យភាពដែលប្រើប្រាស់ |
|---|---|
| **សមាសធាតុកម្មវិធី ទី១** | • **គណនេយ្យភាពផ្ទៃក្នុង:** នឹងបង្ហាញឱ្យឃើញតាមរយៈការបង្កើតនូវប្រព័ន្ធរដ្ឋបាលដោយផ្អែកលើវិធាន នៃច្បាប់ និងតម្រូវការរបាយការណ៍<br>• **គណនេយ្យភាពអន្តររដ្ឋបាលថ្នាក់ក្រោមជាតិ:** នឹងបង្ហាញឱ្យឃើញតាមរយៈការបង្កើតអង្គភាពគាំទ្រ ឃុំ សង្កាត់របស់ថ្នាក់ស្រុក និងប្រព័ន្ធរបាយការណ៍រវាងរដ្ឋបាលនានានៃរដ្ឋបាលថ្នាក់ក្រោមជាតិ<br>• **គណនេយ្យភាពអន្តររដ្ឋបាល:** នឹងបង្ហាញឱ្យឃើញតាមរយៈការសម្របសម្រួលខ្សែទទឹងរវាងមន្ទីរ ការិយាល័យ ទីភ្នាក់ងារនានារបស់ក្រសួង ស្ថាប័ន ជាមួយនឹងរដ្ឋបាលនានានៃរដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងក្របខ័ណ្ឌនៃរដ្ឋបាល ឯកភាព<br>• **គណនេយ្យភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិចំពោះប្រជាពលរដ្ឋ:** នឹងបង្ហាញឱ្យឃើញតាមរយៈ (១)ការអង្កេតពីការពេញចិត្តរបស់ប្រជាពលរដ្ឋចំពោះសេវាសាធារណៈនានា (២)ការប្រើប្រាស់ព័ត៌មានវិទ្យាដើម្បីជួយឱ្យប្រជា-ពលរដ្ឋអាចទទួលបាននូវព័ត៌មាន និងសេវាសាធារណៈនានា (៣)គោលការណ៍ណែនាំសេចក្តីណែនាំ និងឧបករណ៍នានាសម្រាប់ការចូលរួមការទទួលបាននូវព័ត៌មាន និងការពិគ្រោះយោបល់របស់ប្រជាពលរដ្ឋ (៤)ការបង្កើតនូវកម្មវិធី និងយន្តការនានាសម្រាប់លើកកម្ពស់ការចូលរួមរបស់ប្រជាពលរដ្ឋ។ |

| | |
|---|---|
| **សមាសធាតុកម្មវិធីទី២** | គណនេយ្យភាពផ្ទៃក្នុងនឹងត្រូវអនុវត្តតាមរយៈតួនាទីជាក់លាក់ក្នុងការគ្រប់គ្រងមន្ត្រីរាជការស៊ីវិល ប្រព័ន្ធគ្រប់គ្រងធនធានមនុស្ស និងសេចក្តីណែនាំនានាដែលពាក់ព័ន្ធនឹងទំនាក់ទំនងរបស់មន្ត្រីជាមួយ សហគមន៍ប្រជាពលរដ្ឋ។ គណនេយ្យភាពអន្តរវដ្ឋបាលនឹងត្រូវស្តែងឡើងតាមរយៈការរៀបចំបុគ្គលិកឡើងវិញរបស់ក្រសួង ស្ថាប័នជាមួយនឹងការផ្ទេរមុខងារ និងធនធាន។ |
| **សមាសធាតុកម្មវិធីទី៣** | គណនេយ្យភាពអន្តរវដ្ឋបាលនឹងត្រូវស្តែងឡើងតាមរយៈបែបផែននៃការផ្ទេរមុខងារទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ (រួមមានធនធាន និងបុគ្គលិកដើម្បីធានាថាពុំមានការរំខានដល់ការផ្តល់សេវាសាធារណៈ) និងតាមរយៈយន្តការនៃការតាមដាន និងពិនិត្យមើលឡើងវិញនូវការអនុវត្តមុខងារដែលបានផ្ទេរឱ្យ។ គណនេយ្យភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិចំពោះប្រជាពលរដ្ឋ នឹងត្រូវស្តែងឡើងតាមរយៈការលើកកម្ពស់ទាំងបរិមាណ |
| | និងគុណភាពសេវាសាធារណៈដែលបានផ្តល់ទៅដល់ប្រជាពលរដ្ឋ ប៉ុន្តែនៅក្នុងពេលបណ្តោះអាសន្ន ត្រូវរៀបចំនូវវិធានការជាក់លាក់នានា ដើម្បីលើកកម្ពស់គណនេយ្យភាពស្របតាមប្រភេទសេវាសាធារណៈផ្សេងៗ និងមុខងារផ្សេងទៀតដែលចាំបាច់ដើម្បីអនុវត្តសាកល្បង និងវាយតម្លៃអំពីប្រសិទ្ធភាពនៃមុខងារទាំងនោះ ធៀបនឹងគោលដៅ និងគោលបំណងនានា របស់រាជរដ្ឋាភិបាលដែលបានកំណត់នៅក្នុងសមាសធាតុកម្មវិធីទី៣នេះ។ ជាងនេះទៀតគណនេយ្យភាពចំពោះប្រជាពលរដ្ឋ អាចលើកកម្ពស់តាមរយៈវេទិកាពិគ្រោះយោបល់ និងផ្សព្វផ្សាយជាសាធារណៈ និងការទទួលបានជាសាធារណៈនូវព័ត៌មានអំពីការបំពេញមុខងារនិងការផ្តល់សេវាសាធារណៈរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងតាមរយៈការសាកល្បងអំពីវិធីសាស្ត្រផ្សេងៗក្នុងការលើកកម្ពស់គណនេយ្យភាព និងការតាមដានទៅលើប្រសិទ្ធភាពនៃការអនុវត្តនៃវិធីសាស្ត្រទាំងនេះ។ |

ឧបសម្ព័ន្ធ

| | |
|---|---|
| **សមាសធាតុកម្មវិធីទី៤** | • **គណនេយ្យភាពផ្ទៃក្នុង** : នឹងស្ដែងឡើងតាមរយៈការធ្វើសវនកម្មផ្ទៃក្នុងទំនាក់ទំនង និងរបៀបរបបធ្វើ ការងាររវាងក្រុមប្រឹក្សា គណៈអភិបាល និងអង្គភាពនានារបស់ក្រុមប្រឹក្សាពាក់ព័ន្ធនឹងការអនុវត្តថវិកា។<br>• **គណនេយ្យភាពអន្តររដ្ឋបាលថ្នាក់ក្រោមជាតិ** : នឹងស្ដែងឡើងតាមរយៈការចែករំលែកចំណូលរវាងស្រុក និងឃុំ សង្កាត់នៅក្នុងស្រុក។<br>• **គណនេយ្យភាពអន្តររដ្ឋបាល** : នឹងស្ដែងឡើងតាមរយៈការធ្វើអធិការកិច្ចហិរញ្ញ-វត្ថុរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងការធ្វើសវនកម្មរបស់អាជ្ញាធរសវនកម្មជាតិ ទៅលើការអនុវត្តកិច្ចការហិរញ្ញវត្ថុរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។<br>• **គណនេយ្យភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិចំពោះប្រជាពលរដ្ឋ** : នឹងស្ដែងឡើងតាមរយៈការរៀបចំការសម្រេច និងការអនុវត្តថវិកា និងតាមរយៈវេទិកាពិគ្រោះយោបល់ និងផ្សព្វផ្សាយជាសាធារណៈពាក់ព័ន្ធនឹងកិច្ចការថវិកាការវិនិយោគ និងការអភិវឌ្ឍនានា ព្រមទាំងតាមរយៈការអនុវត្តសាកល្បងនូវយន្តការនានាដែលពាក់ព័ន្ធនឹងសវនកម្មផ្នែកសង្គមកិច្ច និងការផ្ដល់លទ្ធភាពឱ្យប្រជាពលរដ្ឋ ឬក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងការចូលរួមផ្ដល់យោបល់លើគម្រោងថវិកានានារបស់រដ្ឋបាលថ្នាក់ក្រោមជាតិប្រភេទផ្សេងទៀត។ |
| **សមាសធាតុកម្មវិធីទី៥** | គឺជាការបង្កើតនូវយន្តការមួយសម្រាប់ធ្វើការសម្របសម្រួលកិច្ចការរដ្ឋបាល និងដោះស្រាយវិវាទ ដើម្បីធានាឱ្យមានមធ្យោបាយសម្រាប់ពង្រឹងដំណើរការនានានៃគណនេយ្យភាពផ្ទៃក្នុងរបស់រដ្ឋបាល ថ្នាក់ក្រោមជាតិ។ |

**ឯកសារយោង:** កម្មវិធីជាតិ (២០១០-២០១៩): ជំពូកទី២ ទំព័រ ២៤-២៦

**ឯកសារចែកទី៥:** កត្តាជាគន្លឹះមួយចំនួនដែលមានឥទ្ធិពលលើលទ្ធផលរបស់កម្មវិធីជាតិ

- ការទទួលខុសត្រូវក្នុងការធានាឱ្យមានភាពត្រឹមត្រូវនៃការប្រើប្រាស់ហិរញ្ញប្បទានរបស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវមានសង្គតិភាពជាមួយនឹងការគ្រប់គ្រងចំណូល និងហិរញ្ញវត្ថុ។ ប្រសិនបើពុំមានការគាំទ្រគ្រប់គ្រាន់នៅក្នុងផ្នែកនេះទេ នោះអាចនឹងបណ្ដាលឱ្យកើតមាននូវភាពមិនជឿទុកចិត្តពីសាធារណជនព្រមទាំងអាចបង្កឱ្យមានសកម្មភាពពុករលួយ។
- ក្រុមប្រឹក្សាត្រូវមានលទ្ធភាពក្នុងការធ្វើសេចក្ដីសម្រេចលើការវិភាជន៍ធនធានដែលមានលក្ខណៈឆ្លើយតបនឹងតម្រូវការរបស់មូលដ្ឋាន។ ការធ្វើសេចក្ដីសម្រេចទៅលើការប្រើប្រាស់ធនធានរបស់ក្រុមប្រឹក្សា

ត្រូវធ្វើឡើងតាមរយៈដំណើរការកសាងផែនការ និងកម្មវិធីវិនិយោគមួយដែលមានការចូលរួម និងការឆ្លើយតប។ អាស្រ័យហេតុនេះ ក្នុងឆ្នាំដំបូងៗត្រូវយកចិត្តទុកដាក់ទៅលើការគាំទ្រដល់ក្រុមប្រឹក្សាក្នុងការកសាង ផែនការអភិវឌ្ឍន៍៥ឆ្នាំ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់ខ្លួន។

- តារាងប្រាក់បៀវត្សរ៍: នៅពេលដែលរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានប្រគល់ ការទទួលខុសត្រូវចំពោះផ្នែកមួយចំនួននៃការគ្រប់គ្រងមន្ត្រីរាជការស៊ីវិល រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវមានប្រព័ន្ធគ្រប់គ្រងបុគ្គលិក និងតារាងប្រាក់បៀវត្សរ៍ច្បាស់លាស់ដើម្បីធានាដល់ការការពារសិទ្ធិរបស់មន្ត្រី និងធានាដល់ការផ្ដល់ប្រាក់ បៀវត្សរ៍ឱ្យបានត្រឹមត្រូវទៅតាមប្រព័ន្ធប្រាក់បៀវត្សរ៍ដែលបានកំណត់ទន្ទឹមនេះត្រូវរៀបចំឱ្យមានប្រព័ន្ធតាមដាន និងវាយតម្លៃបុគ្គលិកឱ្យបានច្បាស់លាស់ដើម្បីលើកកម្ពស់ជំនឿទុកចិត្តពីប្រជាពលរដ្ឋមកលើមន្ត្រីរាជការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។
- វិធីសាស្ត្រដែលមានលក្ខណៈជាការចាប់ផ្ដើមជាមុនសិនមុននឹងឈានដល់ការពង្រីកវិសាលភាពនៃការអនុវត្តជាទូទៅ។

**ឯកសារយោង:** កម្មវិធីជាតិ (២០១០-២០១៩): ជំពូកទី៥ ទំព័រ ១៣០

**ឯកសារចែកទី៦:** ស្ថាប័នពាក់ព័ន្ធ និងតួនាទីសំខាន់ៗក្នុងការអនុវត្តកម្មវិធីជាតិ

| ស្ថាប័នពាក់ព័ន្ធ | ពណ៌នា |
|---|---|
| **១. ប្រជាពលរដ្ឋទូទៅ** | ប្រជាពលរដ្ឋទូទៅដែលរស់នៅក្នុងរដ្ឋបាលថ្នាក់ក្រោមជាតិ |
| **២. ស្ថាប័នជាតិ** | ក្រសួង, អាជ្ញាធរជាតិ,ក្រុមប្រឹក្សាជាតិ,គ្រឹះស្ថានសិក្សា,វិទ្យាស្ថានស្រាវជ្រាវ .. ។ល។ |
| **៣. គ.ជ.អ.ប** | លេខាធិការដ្ឋាន គ.ជ.អ.ប, អនុគណៈកម្មការនានា, អង្គភាពគាំទ្រ។ល។ |
| **៤.ដៃគូអភិវឌ្ឍ** | UNDP, UNCDF, WB, UNICEF, UNFPA, USAID,……. |
| **៥.រដ្ឋបាលថ្នាក់ក្រោមជាតិ** | រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ និងមន្ទីរវិស័យ |
| **៦.វិស័យឯកជន** | គ្រឹះស្ថានសិក្សាឯកជន,ក្រុមហ៊ុនឯកជន, អ្នកផ្ដល់សេវាប្រឹក្សាឯកជន រោងចក្រ, សហគ្រាស.. |
| **៧.អង្គការសង្គមស៊ីវិល** | អង្គការជាតិ និងអន្តរជាតិ, អង្គការសហគមន៍មូលដ្ឋាន សមាគម.... |

| ស្ថាប័នពាក់ព័ន្ធ | តួនាទីសំខាន់ៗក្នុងការចូលរួមអនុវត្តកម្មវិធីជាតិ |
|---|---|
| ១. ប្រជារដ្ឋទូទៅ | ចូលរួមធ្វើសេចក្តីសម្រេចចិត្ត, ចូលរួមអនុវត្ត, តាមដានការផ្តល់សេវា, ផ្តល់ព័ត៌មានត្រលប់, ចែករំលែកព័ត៌មាន, និងចូលរួមជ្រើសរើសតំណាងរបស់ខ្លួន..។ល។ |
| ២.ស្ថាប័នជាតិ | រៀបចំគោលនយោបាយ, យុទ្ធសាស្ត្រ, យន្តការអនុវត្ត, គោលការណ៍ណែនាំ, តាមដានការអនុវត្ត គោលនយោបាយ, ផ្តល់ព័ត៌មានត្រលប់,..។ល។ |
| ៣.គ.ជ.អ.ប | សេនាធិការឱ្យរាជរដ្ឋាភិបាល, សម្របសម្រួល, គាំទ្រ និងការពិនិត្យមើលលើការអនុវត្តកម្មវិធី កំណត់ តម្រូវការបុគ្គលិក សមត្ថភាព និងធនធានហិរញ្ញវត្ថុសម្រាប់ការអនុវត្តកម្មវិធី..។ល។ |
| ៤.ដៃគូអភិវឌ្ឍ | សហការ, ផ្តល់ប្រឹក្សាយោបល់, គាំទ្រផ្នែកហិរញ្ញវត្ថុ..។ល។ |
| ៥.រដ្ឋបាលថ្នាក់ក្រោមជាតិ | ចូលរួមអនុវត្តកម្មវិធីជាតិ, ផ្តល់យោបល់ត្រលប់សម្រាប់ការកែសម្រួលគោលនយោបាយ និងតាមដាន ការអនុវត្តកម្មវិធីជាតិ...។ល។ |
| ៦.វិស័យឯកជន | កសាងដៃគូជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិ, ចូលរួមផ្តល់សេវាកម្ម (រូបវន្ត និងអរូបវន្ត), បណ្តុះបណ្តាល និងកសាងសមត្ថភាពផ្នែកតាមតម្រូវការ, តាមដានការអនុវត្ត និងពង្រឹកគណនេយ្យភាព, ផ្តល់ព័តមាន ត្រលប់សម្រាប់,..។ល។ |
| ៧.អង្គការសង្គម ស៊ីវិល | កសាងដៃគូជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិ, ចូលរួមផ្តល់សេវាកម្ម (រូបវន្ត និងអរូបវន្ត), បណ្តុះបណ្តាល និងកសាងសមត្ថភាពផ្នែកតាមតម្រូវការ, តាមដានការអនុវត្ត និងពង្រឹកគណនេយ្យភាព, ផ្តល់ព័តមាន ត្រលប់សម្រាប់, ចូលរួមការពង្រឹកការពិគ្រោះយោបល់រវាងប្រជាពលរដ្ឋ និងក្រុមប្រឹក្សាថ្នាក់ក្រោមជាតិ, ចូលរួមពង្រឹងការផ្សារភ្ជាប់ទំនាក់ទំនងរវាងប្រជាពលរដ្ឋ និងថ្នាក់រដ្ឋបាលនីមួយៗនៅថ្នាក់ក្រោមជាតិ. ចែករំលែកព័ត៌មានដែលទទួលបានពីប្រជាពលរដ្ឋទៅក្រុមប្រឹក្សា និងពីក្រុមប្រឹក្សាទៅប្រជាពលរដ្ឋ...។ល។ |

# មេរៀនទី ២ ឯកសារផ្ទាំងរូបភាព







១១
ខ្សែគណនេយ្យភាព
ប្រជាពលរដ្ឋ
បោះឆ្នោត
គណនេយ្យភាពចំពោះប្រជាពលរដ្ឋ
ក្រុមប្រឹក្សាឃុំ សង្កាត់
បោះឆ្នោត
គណនេយ្យភាពអន្តររដ្ឋបាលថ្នាក់ក្រោមជាតិ
គណនេយ្យភាពចំពោះប្រជាពលរដ្ឋ
គណនេយ្យភាពទៅរាជរដ្ឋាភិបាល
រាជរដ្ឋាភិបាល
គ.ជ.អ.ប
ក្រសួងស្ថាប័ននានា
ក្រសួងស្ថាប័ននានា
គណនេយ្យភាពទៅក្រសួង
ក្រុមប្រឹក្សា
គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស
គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រីនិងកុមារ
គណៈកម្មាធិការលទ្ធកម្ម
គណៈកម្មាធិការនានា
មន្ទីរ
គណនេយ្យភាពអន្តររដ្ឋបាល
គណៈអភិបាល
នាយករដ្ឋបាល
អង្គភាព...
អង្គភាព...
អង្គភាព...
អង្គភាព...
រដ្ឋបាលថ្នាក់ក្រោមជាតិ
កំណត់សំគាល់ខ្សែគណនេយ្យភាព
គណនេយ្យភាពចំពោះប្រជាពលរដ្ឋ
គណនេយ្យភាពអន្តររដ្ឋបាល
គណនេយ្យភាពផ្ទៃក្នុង
គណនេយ្យភាពអន្តររដ្ឋបាលថ្នាក់ក្រោមជាតិ
VBNK

# មេរៀនទី២

## ចំណងជើងមេរៀន: ការគ្រប់គ្រងកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ នៅថ្នាក់ក្រោមជាតិ (២០១០-២០១៩)

**ពេលវេលា :** (១០០ នាទី)

### តើអនុវត្តការសម្របសម្រួលមេរៀនយ៉ាងដូចម្តេច?

| ពេលវេលា | សកម្មភាព និង វិធីសាស្ត្រ | សម្ភារៈ/ ឯកសារចែកជូន |
|---|---|---|
| (១០នាទី) | **១. <u>បង្ហាញនិងពិភាក្សាពេញអង្គ :</u>**<br>សេចក្តីផ្តើមនិងគោលបំណងមេរៀន<br>**ក. សេចក្តីផ្តើមរបស់មេរៀន**<br>• អ្នកសម្របសម្រួលចាប់ផ្តើមដោយចង្អុលបង្ហាញសិក្ខាកាមនូវផ្ទាំងរូបភាពទី ១០: ស្តីពីរចនាសម្ព័ន្ធរបស់កម្មវិធីជាតិទាក់ទងទៅនឹង: គោលដៅ, គោលបំណង, សមាសភាពកម្មវិធីទាំង៥ និងកម្មវិធីអន្តរវិស័យ (ដែលបានពន្យល់នៅក្នុងមេរៀនទី១នៅជំពូកទី២)។<br>• បន្ទាប់មកអ្នកសម្របសម្រួលពន្យល់បន្ថែមថាដើម្បីធានាបាននូវលទ្ធផលរំពឹងទុកកម្មវិធីជាតិបានរៀបចំការគ្រប់-គ្រង និងយុទ្ធសាស្ត្រសម្រាប់អនុវត្តយ៉ាងច្បាស់លាស់។ បន្ទាប់មកអ្នកសម្របសម្រួលត្រូវបន្តថា ដូច្នេះគោលបំណងនៃមេរៀននេះនឹងបរិយាយអំពីរបៀបគ្រប់គ្រង និងអនុវត្តនៃកម្មវិធីជាតិ។ | ក្រដាសផ្ទាំងធំ, ហ្វឺត និងស្កុត ផ្ទាំងរូបភាពទី ១០ បទបង្ហាញ (ស្លាយទី១-២) |

| | | |
|---|---|---|
| | ខ. គោលបំណងនៃមេរៀន<br>• អ្នកសម្របសម្រួលបង្ហាញចំណងជើងនៃប្រធានបទនៃមេរៀន (ស្លាយទី១)។ បន្ទាប់មកបង្ហាញគោលបំណង (ស្លាយទី២) នៃមេរៀនដោយឱ្យសិក្ខាកាមម្នាក់ឡើងអាន (ស្លាយទី២និងទី៣) នេះ។<br>• អ្នកសម្របសម្រួលសួរទៅសិក្ខាកាមថាតើមាន អ្វីត្រូវបញ្ជាក់បន្ថែម ទៅលើគោលបំណង និងលទ្ធផលរំពឹងទុកនេះដែរឬទេ? ប្រសិនបើមានអ្នកសម្របសម្រួលត្រូវបកស្រាយបន្ថែម និងសង្ខេបឱ្យបានខ្លីបំផុត។ | |
| (២០ នាទី) | **២. <u>បង្ហាញ និងពិភាក្សាពេញអង្គ:</u>** ដំណាក់កាលនីមួយៗនៃកម្មវិធីជាតិ និងលទ្ធផលរំពឹងទុកនៅក្នុងដំណាក់កាលទី១ (២០១១-២០១៣)<br>ក. ជាកិច្ចចាប់ផ្តើម អ្នកសម្របសម្រួលរំលឹកពីកម្មវិធីជាតិ១០ឆ្នាំ និងលទ្ធផលរំពឹងទុកនៃសមាសធាតុកម្មវិធីនីមួយៗព្រមទាំងកម្មវិធីអន្តរវិស័យ។ បន្ទាប់មកអ្នកសម្របសម្រួលបន្តដោយនិយាយថា ដើម្បីជួយដល់ការ ចាត់ចែងនិងអនុវត្តឱ្យកាន់តែមានប្រសិទ្ធភាពកម្មវិធីជាតិត្រូវបានចែកជា៣ដំណាក់ (ព្រមជាមួយនឹងបទបង្ហាញរបស់ខ្លួនត្រង់ ស្លាយទី៤)។<br>ខ. បន្ទាប់មកអ្នកសម្របសម្រួលត្រូវបន្តថា រាល់សកម្មភាពដែលមាននៅក្នុងសមាសធាតុកម្មទាំង៥ និងកម្មវិធីអន្តរវិស័យនឹងត្រូវអនុវត្តដើម្បីឱ្យសម្រេចបានគោលដៅនៃ កម្មវិធីជាតិទៅតាមដំណាក់កាលនីមួយៗ (ស្លាយទី៥)។ | ក្រដាសផ្ទាំងធំ៩ ហ្វឺត និងស្កុត រំលឹកបទបង្ហាញមេរៀនទី១ ជំពូកទី២ |

| | | |
|---|---|---|
| | គ. អ្នកសម្របសម្រួលប្រើសំណួរបំផុសថា: តើយើងទាំងអស់គ្នាគិតថារដ្ឋបាលថ្នាក់ក្រោមជាតិនឹងមានការផ្លាស់ប្តូរយ៉ាងដូចម្តេចនៅក្នុងដំណាក់កាលទី១នៃការអនុវត្តកម្មវិធីនេះ? អ្នកសម្របសម្រួលអាចអនុញ្ញាតឱ្យសិក្ខាកាម២ ឬ៣នាក់ឆ្លើយនឹងសំណួរនេះ និងកត់ត្រាចំលើយខ្លះៗនៅលើក្រដាសផ្ទាំងធំឬលើក្តារខៀន។ បន្ថែមលើចំលើយរបស់សិក្ខាកាមសម្របសម្រួលបង្ហាញ (ស្លាយ ទី៦ និងទី៧) ដោយពន្យល់បន្ថែមពីគោលដៅរំពឹងទុកការផ្លាស់ប្តូរផ្នែកស្ថាប័ន និងលទ្ធផលរំពឹងទុក ផ្នែកស្ថាប័ននៅក្នុងដំណាក់កាលទី១ ជាមួយនឹងការប្រាប់សិក្ខាកាមឱ្យពិនិត្យមើលលម្អិតលើឯកសារដែលបានចែកជូនទី១។<br>ឃ. នៅចុងបញ្ចប់អ្នកសម្របសម្រួលត្រូវបង្ហាញពីសារៈសំខាន់នៃការចែកកម្មវិធីជាតិជាដំណាក់កាលនេះដោយប្រើស្លាយទី៧។ | |
| (២០ នាទី) | **៣. <u>បង្ហាញនិងពិភាក្សាពេញអង្គ</u>:** សង្ខេបពីការងារតាមដាន និងវាយតម្លៃរបស់កម្មវិធីជាតិ<br>**ក.** អ្នកសម្របសម្រួលចាប់ផ្តើមដោយលើកជាសំណួរបំផុសឡើងថា តើយើងត្រូវធ្វើដូចម្តេច ដើម្បីដឹងថាលទ្ធផលរំពឹងទុកនៅក្នុងដំណាក់កាលទី១បានសម្រេច? អ្នកសម្របសម្រួលអាចអនុញ្ញាតឱ្យសិក្ខាកាម ២ឬ៣នាក់ឆ្លើយនឹងសំណួរនេះ និងកត់ត្រាចំលើយខ្លះៗ នៅលើក្រដាសផ្ទាំង។ ដើម្បីបំពេញទៅនឹងចំលើយរបស់សិក្ខាកាម អ្នកសម្របសម្រួល ចាប់ផ្តើមបង្ហាញ និងពន្យល់អំពីចំណុចសំខាន់ៗទាំង៣ ដែលមាននៅក្នុងស្លាយទី៨។ | |

| | | |
|---|---|---|
| | ខ. អ្នកសម្របសម្រួល សួរថា ដើម្បីសម្រេចបានលទ្ធផលនៅដំណាក់កាលទី១(២០១១-២០១៣) តើត្រូវធ្វើការតាមដានត្រួតពិនិត្យ និងវាយតម្លៃទៅលើអ្វីខ្លះ? បន្ទាប់មកអ្នកសម្របសម្រួលឱ្យសិក្ខាកាម២ឬ៣នាក់ឆ្លើយនឹងសំណួរនេះ និងកត់ត្រាចំលើយខ្លះៗនៅលើក្រដាស់ផ្ទាំងធំឬលើក្តារខៀន។ ដើម្បីបំពេញទៅនឹងចំលើយរបស់សិក្ខាកាម អ្នកសម្របសម្រួលចាប់ផ្តើមបង្ហាញ និងពន្យល់អំពីចំណុច២សំខាន់ៗ ដែលមាននៅក្នុងស្លាយទី៩-១១។ អ្នកសម្របសម្រួលបញ្ជាក់ថា**គ.ជ.អ.ប** នឹងបន្តរៀបចំគ្របខណ្ឌតាមដានត្រួតពិនិត្យ និងវាយតម្លៃ ដើម្បីធានាដល់ទ្ធផលដែលបាន ពោលគឺក្នុងគោលបំណងចម្បងពីរគឺ: ១)ការពង្រឹងគណនេយ្យភាព និង ២)ការលើកកម្ពស់សេវាសាធារណៈឱ្យកាន់តែមានប្រសិទ្ធភាព និងប្រាប់ឱ្យសិក្ខាកាមពិនិត្យមើលឯកសារចែកជូនទី២។ បន្ទាប់មក អ្នកសម្របសម្រួលត្រូវធ្វើការរំលឹកដល់សិក្ខាកាមថានៅក្នុងមេរៀនទី១ យើងបានដឹងខ្លះៗអំពីសមាសធាតុកម្មវិធីទាំង៥ និងពាក្យគណនេយ្យភាព នៅក្នុងកម្មវិធី អន្តរវិស័យរួចហើយ។<br>គ. អ្នកសម្របសម្រួលធ្វើការបូកសរុបដោយនិយាយថា ដូច្នេះ ដើម្បីធានាដល់លទ្ធផលដែលកើតចេញដោយកម្មវិធីជាតិទទួលបានការគាំទ្រ និងពេញចិត្តពីសំណាក់សាធារណៈគឺទាក់ទងទៅនឹងការចូលរួមពង្រឹងខ្សែគណនេយ្យភាពចំនួន៤ដែលយើងនឹងពិភាក្សានៅជំហានបន្ទាប់នេះ។ | ផ្ទាំងរូបភាពទី ១១<br>ក្រដាស ផ្ទាំងធំ,<br>ហ្វឺត និងស្កុត<br>បទបង្ហាញមេរៀន |

| | | |
|---|---|---|
| | ឃ. អ្នកសម្របសម្រួលធ្វើការបូកសរុបរាល់ចំណុចដែលបានលើក និងផ្តល់ពេលវេលាចំនួន ១ទៅ២នាទី ដើម្បីឱ្យសិក្ខាកាម សួរ និងបកស្រាយសំណួររបស់សិក្ខាកាម។ | |
| (២០ នាទី) | **៤.<u>បង្ហាញ និងពិភាក្សាពេញអង្គ:</u>** ពីខ្សែគណនេយ្យភាពទាំង៤<br>ក. អ្នកសម្របសម្រួលចាប់ផ្តើមដោយនិយាយថា ការតាមដានត្រួតពិនិត្យ និងវាយតម្លៃលើលទ្ធផលដែលរំពឹងទុកនៅក្នុងដំណាក់កាលនីមួយៗទាមទារឱ្យមានអន្តរកម្ម និងការចូលរួមពីសំណាក់ភាគីពាក់ព័ន្ធទាំងអស់ជាពិសេសពីអង្គការសង្គមស៊ីវិលតាមរយៈខ្សែគណនេយ្យភាពទាំង៤ ដែលបានកំណត់នៅកម្មវិធីជាតិ។ មុននឹងចាប់ផ្តើមបង្ហាញពីខ្សែគណនេយ្យភាពទាំង៤ អ្នកសម្របសម្រួល ត្រូវចោទជាសំណួរទៅសិក្ខាកាមថា តើគណនេយ្យភាពមានន័យយ៉ាងដូចម្តេច? តើខ្សែគណនេយ្យ-ភាពទាំង ៤មាន អ្វីខ្លះ? (ដោយមិនចាំបាច់ឱ្យសិក្ខាកាមឆ្លើយនឹងសំណួរទេ គឺអ្នកសម្របសម្រួលត្រូវបង្ហាញស្លាយទី១១ តែម្តង)។ បន្ទាប់មកអ្នកសម្របសម្រួលប្រាប់សិក្ខាកាមឱ្យឱ្យពិនិត្យមើល និងអានឯកសារចែកជូនទី៣ (ដោយទុកពេល៥នាទី)។ បន្ទាប់ពីការសិក្ខាកាមអានចប់អ្នកសម្រប-សម្រួលអាចសួរ ទៅសិក្ខាកាម ១ឬ២នាក់ ដើម្បីបកស្រាយលើខ្សែគណនេយ្យភាពទី១។ បន្ទាប់មក អ្នកសម្របសម្រួលបង្ហាញ (ស្លាយទី១២) និងត្រូវធ្វើការពន្យល់ពីខ្សែគណនេយ្យភាពនីមួយៗរហូតដល់ចប់។ ព្រមជាមួយនឹងការពន្យល់ | |

| | | |
|---|---|---|
| | អ្នកសម្របសម្រួលអាចរកឧទាហរណ៍ងាយៗទាក់ទងនឹងខ្សែគណនេយ្យភាពនីមួយៗ។<br>**ឧទាហរណ៍អំពីខ្សែគណនេយ្យភាពទី១:**<br>• គណៈអភិបាលនិងទីចាត់ការនានានៃរដ្ឋបាលខេត្ត "ក" អាចមកឆ្លើយបំភ្លឺនូវរាល់សំណួរ ឬចម្ងល់តាមការកោះអញ្ជើញរបស់ក្រុមប្រឹក្សាខេត្ត "ក" ក្នុងករណីដែលមានភាពមិនប្រក្រតីលើការចាយវាយថវិកាឬមិនបានអនុវត្តតាមសេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាខេត្តរបស់ខ្លួន។ ប្រសិនគណៈអភិបាលអាចធ្វើការបំភ្លឺដល់ក្រុមប្រឹក្សារបស់ខ្លួនបាន នោះមានន័យថា គណៈអភិបាលមានគណនេយ្យភាព ចំពោះក្រុមប្រឹក្សារបស់ខ្លួន។<br>**ខ.** អ្នកសម្របសម្រួលត្រូវរំលឹកដល់សិក្ខាកាថានៅក្នុងសមាស-ធាតុកម្មវិធីនីមួយៗអាចមានការពាក់ព័ន្ធនឹងខ្សែគណនេយ្យភាពមួយ ឬច្រើនទៅតាមដំណាក់កាលនីមួយៗ ដើម្បីធានាឱ្យសម្រេចបានលទ្ធផលរំពឹងទុក។ អ្នកសម្របសម្រួលឱ្យសិក្ខាកាមពិនិត្យមើលឯកសារចែកជូនទី៣ ហើយបង្ហាញសិក្ខាកាមលើស្លាយទី១៣ ដោយធ្វើការពន្យល់ជារួមពីការពាក់ព័ន្ធនឹងខ្សែគណនេយ្យភាពនៅក្នុងសមាសធាតកម្មវិធីទាំង៤ នៅក្នុងគ្រប់ដំណាក់កាលនៃកម្មវិធីជាតិ។<br>គ. អ្នកសម្របសម្រួលប្រាប់ឱ្យសិក្ខាកាមចាប់ដៃគូជាមួយអ្នកដែលអង្គុយជាប់ខ្លួន (១គូរៗ) ហើយឱ្យសិក្ខាកាមពិនិត្យមើលឯក-សារចែកជូនទី៣ដដែល ហើយលើកជាសំណួរបំផុសថា តើខ្សែគណនេយ្យភាពណាខ្លះ ដែលសមស្របជាងគេបំផុតសម្រាប់សមាសធាតុកម្មវិធីទី១ ដើម្បីធ្វើឱ្យសម្រេចបាន | ផ្ទាំងរូបភាពទី១១<br>ក្រដាសផ្ទាំងធំ,<br>ក្រដាសកាតព័ណ៌<br>ហ្វឺត និងស្កុត<br>បទបង្ហាញមេរៀន |

| | | |
|---|---|---|
| | លទ្ធផលក្នុងដំណាក់កាល ទី១? បន្ទាប់មកអ្នកសម្របសម្រួលអាចអនុញ្ញាតិឱ្យសិក្ខាកាមចំនួន៣នាទីដើម្បីពិភាក្សាជាមួយដៃគូរបស់ខ្លួន។ បន្ទាប់មកអ្នកសម្របសម្រួលឱ្យសិក្ខាកាម ២ ឬ៣នាក់ ដើម្បីផ្តល់ចំលើយចំពោះសំណួរនេះ និងកត់ត្រាចំលើយខ្លះៗនៅលើក្រដាសផ្ទាំងធំ ឬលើក្តារខៀនបន្ថែមលើចំលើយរបស់សិក្ខាកាមអ្នកសម្របសម្រួលបង្ហាញ (**ស្លាយទី១៥**) ដោយធ្វើការពន្យល់ពីខ្សែគណនេយ្យភាពនីមួយៗនៃសមាសធាតុកម្មវិធីនីមួយៗ រហូតដល់ចប់ហើយប្រាប់សិក្ខាកាមឱ្យពិនិត្យមើលឯកសារចែក**ជូនទី៤**។ បន្ទប់មកអ្នកសម្របសម្រួលបង្ហាញ (**ស្លាយទី១៥**) ពីកំណត់សម្គាល់ដែលមានចំណុចសំខាន់២ដែលស្នើឡើងដោយ អ.ជ.អ.ប ទាក់ទងទៅនឹងការរៀបចំឱ្យមានយន្តការនានាដើម្បីធានាដល់គណនេយ្យភាព។<br>ឃ. អ្នកសម្របសម្រួលធ្វើការបូកសរុបដោយសង្ខេបថាដូច្នេះ យើងឃើញ ហើយសមាសធាតុកម្មវិធីនីមួយៗ អាចមានការពាក់ព័ន្ធ នឹងខ្សែគណនេយ្យភាពមួយឬច្រើនទៅតាមដំណាក់កាល នីមួយៗ ដើម្បីធានាឱ្យ សម្រេចបានលទ្ធផលរំពឹងទុក។ | |
| (១០ នាទី) | **៥. បង្ហាញនិងពិភាក្សាពេញអង្គ** :កត្តាជាគន្លឹះសំខាន់ៗដែលមានឥទ្ធិពលលើ លទ្ធផលរបស់កម្មវិធីជាតិ<br>ក.អ្នកសម្របសម្រួលចាប់ផ្តើមដោយនិយាយថា យើងដឹងអ្វីដែលជាលទ្ធផល និងយន្តការមួយចំនួនសម្រាប់អនុវត្តកម្មវិធីជាតិ។ បន្ទាប់មកអ្នកសម្របសម្រួល លើកជាសំណួរបំផុសថាដោយ | |

| | | |
|---|---|---|
| | យោងតាមចំណេះដឹង និងបទពិសោធន៍របស់ខ្លួនថាៈ តើមានកិច្ចការជាអាទិភាពអ្វីខ្លះដែលអ្នកត្រូវរៀបចំដើម្បីអាចសម្រេចបានលទ្ធផលនៅក្នុងដំណាក់កាលទី១នៃកម្មវិធី?<br>ខ. បន្ទាប់មកអ្នកសម្របសម្រួលអាចអនុញ្ញាតិឱ្យសិក្ខាកាម២ ឬ៣នាក់ឆ្លើយនឹងសំណួរនេះ និងកត់ត្រាចំលើយខ្លះៗនៅលើក្រដាស់ផ្ទាំងធំ។ បន្ថែមលើចំលើយរបស់សិក្ខាកាមអ្នកសម្របសម្រួលបង្ហាញ (ស្លាយទី១៦) ដោយធ្វើការពន្យល់រាល់ចំណុចនីមួយៗរហូតដល់ចប់ ហើយប្រាប់សិក្ខាកាមឱ្យពិនិត្យមើលឯកសារចែកជូនទី៥។<br>គ. បន្ទាប់មកអ្នកសម្របសម្រួលធ្វើការសង្ខេប ដោយលើកឡើងថាកិច្ចការអាទិភាពដែលចាំបាច់ត្រូវធ្វើការពិចារណា ឬកត្តាអាចមានឥទ្ធិពល ដល់ការអនុវត្ត នៃកម្មវិធីជាតិក្នុងរយៈពេលអន្តរកាលនេះមានសារៈសំខាន់ដូច្នេះទាមទារឱ្យមានតួនាទីច្បាស់លាស់ពីស្ថាប័នពាក់ព័ន្ធគ្រប់លំដាប់ថ្នាក់ទាំងអស់ដែលយើង នឹងពិភាក្សានៅបន្តិចទៀតនេះ។<br>ឃ. អ្នកសម្របសម្រួលសួរទៅសិក្ខាកាមថា តើមានសំណួរ ឬចង្ងល់លើចំណុចណាដែលឬទេ យើងមានពេលវេលាចំនួន២នាទី?។ បន្ទាប់មក អ្នកសម្របសម្រួលធ្វើការបកស្រាយ (ប្រសិនបើមានសំណួរ) | ក្រដាសផ្ទាំងធំ, ក្រដាសកាតព័ណ៌ ហ្វឺត និងស្កុត<br>បទបង្ហាញមេរៀន<br>ឯកសារចែកជូនទី៥ |

| | | |
|---|---|---|
| (១៥ នាទី) | ៦.**<u>បង្ហាញនិងពិភាក្សាពេញអង្គ:</u>** ស្ថាប័នពាក់ព័ន្ធ និងសង្ខេបពីតួនាទីសំខាន់ៗ អ្នកសម្របសម្រួលចាប់ផ្តើមដោយលើកជាសំណួរបំផុសថា: តើស្ថាប័នណាខ្លះដែលគួរចូលរួមអនុវត្តកម្មវិធីជាតិ? ហើយស្ថាប័នទាំងនោះ មានតួនាទីសំខាន់អ្វីខ្លះដើម្បីចូលរួមក្នុងការអនុវត្តកម្មវិធីជាតិ? បន្ទាប់មកអ្នកសម្របសម្រួលអាចអនុញ្ញាតិឱ្យសិក្ខាកាម២ឬ៣នាក់ឆ្លើយនឹងសំណួរនេះនិងកត់ត្រាចំលើយខ្លះៗនៅលើក្រដាសផ្ទាំងធំ។ បន្ថែមលើចំលើយរបស់សិក្ខាកាម អ្នកសម្របសម្រួលបង្ហាញ (ស្លាយទី១៧-២០) ដោយធ្វើការពន្យល់។ បន្ទាប់មកអ្នក សម្របសម្រួលត្រូវធ្វើការសង្ខេបដោយលើកឡើងថា កម្មវិធីជាតិមានរយៈពេលវែង ដូច្នេះ ត្រូវមានការចូលរួមពីគ្រប់អ្នកពាក់ព័ន្ធជាពិសេសគឺការចូលរួមពីអង្គការសង្គមស៊ីវិល។ ចំពោះថាតើតួនាទីរបស់អង្គការសង្គមស៊ីវិលអាចចូលរួមយ៉ាងដូចម្តេចនោះយើងនឹងពិភាក្សាលម្អិតនៅមេរៀនក្រោយ។ | ក្រដាសផ្ទាំងធំ, ក្រដាសកាតពណ៌ ហ្វឺត និងស្កុត បទបង្ហាញមេរៀន |
| (៥ នាទី) | **៧. <u>សេចក្តីសន្និដ្ឋាន:</u>**<br>អ្នកសម្របសម្រួលត្រូវធ្វើការសង្ខេបមេរៀនដោយផ្តោតលើ:<br>១) ដំណាក់កាលនីមួយៗរបស់កម្មវិធីជាតិ<br>២) រំលឹកឡើងវិញពីខ្សែគណនេយ្យភាពទាំង៤<br>៣) កត្តាសំខាន់ៗដែលអាចមានឥទ្ធិពលលើលទ្ធផលនៃការអនុវត្តកម្មវិធីជាតិក្នុងដំណាក់កាលទី១ (២០១១-២០១៣)<br>៤) លើកឡើងពីស្ថាប័នពាក់ព័ន្ធ និងតួនាទីសំខាន់ៗមួយចំនួន( ហើយនឹងមានលម្អិតពីតួនាទីរបស់អង្គការសង្គមស៊ីវិលនៅមេរៀនក្រោយ)។ សិក្ខាកាមធ្វើការឆ្លុះបញ្ចាំងទៅលើគោលបំណង | |

| | | |
|---|---|---|
| | និងផ្តល់យោបល់ លើមេរៀននេះ។ | ក្រដាសផ្ទាំងធំ |

**សម្ភារៈបង្រៀន :**

- **ឯកសារចែកជូនសិក្ខាកាម:**

  ១– បទបង្ហាញ(ស្លាយ) នៅក្នុងមេរៀនទី២ នៃជំពូកទី២

  ២–ឯកសារចែកជូនទី១: តារាង: រយៈពេល និងលទ្ធផលរំពឹងទុកតាមដំណាក់កាលនីមួយៗនៃការផ្លាស់ប្តូរផ្នែកស្ថាប័នក្នុងកម្មវិធីជាតិ

  ៣– ឯកសារចែកជូនទី២: ការងារតាមដាន និងវាយតម្លៃ

  ៤– ឯកសារចែកទី៣: ខ្សែគណនេយ្យភាពទាំងបួន

  ៥– ឯកសារចែកទី៤: ខ្សែគណនេយ្យភាពទាំងបួនប្រើនៅក្នុង សមាសធាតុកម្មវិធីនីមួយៗ

  ៦– ឯកសារចែកទី៥: កត្តាជាគន្លឹះមួយចំនួនដែលមានឥទ្ធិពលលើលទ្ធផលរបស់កម្មវិធីជាតិ

  ៧– ឯកសារចែកទី៦: ស្ថាប័នពាក់ព័ន្ធ និងតួនាទីសំខាន់ៗក្នុងការអនុវត្តកម្មវិធីជាតិ

- **សម្ភារៈចាំបាច់:**

  - ក្រដាសផ្ទាំងធំ, ក្រដាសកាតពណ៌ ហ្វឺត និងស្កុត
  - ផ្ទាំងរូបភាពទី ៩: គោលដៅ_គោលបំណងរបស់កម្មវិធីជាតិ និង កម្មវិធីអន្តរវិស័យ
  - ផ្ទាំងរូបភាពទី ១១: ខ្សែគណៈនេយ្យភាព

**ឯកសារយោង:**

**១) កម្មវិធីជាតិ (២០១០_២០១៩):**

– តារាងលេខ២.១: រយៈពេល និងលទ្ធផលរំពឹងទុកតាម ដំណាក់កាលនីមួយៗនៃការផ្លាស់ប្តូរផ្នែកស្ថាប័នក្នុងកម្មវិធីជាតិ( ជំពូកទី២ ទំព័រ ២៩_៣១),

– ការងារតាមដាន និងវាយតម្លៃ: (ជំពូកទី៤ ទំព័រ ១១១_១១២),

– ខ្សែគណនេយ្យភាពទាំងបួន: (ជំពូកទី២ ទំព័រ ២៤_២៦),

– កត្តាជាគន្លឹះមួយចំនួនដែលមានឥទ្ធិពលលើលទ្ធផលរបស់កម្មវិធីជាតិ: ជំពូកទី៥ ទំព័រ ១៣០

២) សេចក្តីព្រាងផែនការអនុវត្តរយៈពេល៣ឆ្នាំ (២០១១_២០១៣): ទំព័រទី ១ ចំណុចលេខ ៩.១។

# មេរៀនទី ៣

## លិខិតបទដ្ឋានគតិយុត្តនានា
## សម្រាប់គាំទ្រដល់ដំណើរការ
## កំណែទម្រង់រដ្ឋបាលថ្នាក់ជាតិ

# មេរៀនទី ៣ លិខិតបទដ្ឋានគតិយុត្តនានាសម្រាប់គាំទ្រដល់ដំណើរការកំណែទម្រង់រដ្ឋបាលថ្នាក់ជាតិ

## ☞ គោលបំណងមេរៀន

នៅចុងបញ្ចប់នៃមេរៀនសិក្ខាកាមនឹង ៖

យល់ដឹងអំពីលិខិតបទដ្ឋានគតិយុត្តនានាសំរាប់គាំទ្រដល់ដំណើរការកំណែទម្រង់រដ្ឋបាលថ្នាក់ក្រោមជាតិ និងគាំទ្រដល់ការអនុវត្តកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។

## ☞ លទ្ធផលរំពឹងទុកនៃមេរៀន

១. សិក្ខាកាមយល់ដឹងបន្ថែមអំពី លិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធនឹងការអនុវត្តន៍កម្មវិធីជាតិ។

២. បង្កើនភាពជឿជាក់ដល់សិក្ខាកាមដើម្បីរួមចំណែកក្នុងដំណើរការអនុវត្តកម្មវិធីជាតិ ដោយផ្អែកលើលិខិតបទដ្ឋានគតិយុត្តនានាដែលពាក់ព័ន្ធ។

## ☞ ការណែនាំសម្រាប់អ្នកសម្របសម្រួល



អ្នកសម្របសម្រួលមានគោលបំណងសំខាន់៖

១ រំលឹកដល់សិក្ខាកាមអំពីទិដ្ឋភាពទូទៅនៃកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ នៅក្នុងមេរៀនទី១ និងទី២ នៃជំពូកទី២។

២ ជួយអោយសិក្ខាកាមបានយល់ដឹងអំពីលិខិតបទដ្ឋានគតិយុត្ត និងស្គាល់ច្បាស់អំពីស្ថាប័នមានសមត្ថកិច្ចចេញលិខិតបទដ្ឋានគតិយុត្ត។

៣ ជំរាបជូនសិក្ខាកាមថារាជរដ្ឋាភិបាលបានរៀបចំលិខិតបទដ្ឋានគតិយុត្តសម្រាប់គាំទ្រដល់ដំណើរការកំណែទម្រង់រដ្ឋបាលថ្នាក់ក្រោមជាតិ និងគាំទ្រដល់ការអនុវត្តកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។

# ជំពូកទី ២ : មេរៀនទី ៣

## លិខិតបទដ្ឋានគតិយុត្តនានាសម្រាប់គាំទ្រដល់ ដំណើរការកំណែទម្រង់រដ្ឋបាលថ្នាក់ក្រោមជាតិ

## លិខិតបទដ្ឋានគតិយុត្ត

សិក្ខាកាមនឹងយល់ដឹងអំពីលិខិតបទដ្ឋានគតិយុត្តនានាសំរាប់គាំទ្រដល់ ដំណើរការកំណែទម្រង់រដ្ឋបាលថ្នាក់ក្រោមជាតិ និងគាំទ្រដល់ការអនុវត្ត កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។

២

## សំណួរពិភាក្សាក្រុមធំ

១.ដូចម្តេចដែលហៅថាលិខិតបទដ្ឋានគតិយុត្ត?

២.តើស្ថាប័នណាខ្លះមានសមត្ថកិច្ចចេញលិខិតបទដ្ឋានគតិយុត្ត?

៣

## លិខិតបទដ្ឋានគតិយុត្ត

លិខិតបទដ្ឋានគតិយុត្ត គឺជាលិខិតដែលកំណត់ជាក្បួនច្បាប់មានអានុភាពគតិយុត្តិ តម្រូវឱ្យអនុវត្តក្នុងការគ្រប់គ្រងសង្គម គ្រប់គ្រងរដ្ឋលើវិស័យ នយោបាយ សេដ្ឋកិច្ច វប្បធម៌ សង្គម ...។

លិខិតបទដ្ឋានគតិយុត្តរៀបចំតាក់តែងឡើងដោយផ្អែកលើរដ្ឋធម្មនុញ្ញជាគោល ដោយមានលំដាប់លំដោយ ដូចជា (១)ច្បាប់ (២)ព្រះរាជក្រម (៣)ព្រះរាជក្រឹត្យ (៤)អនុក្រឹត្យ (៥) ប្រកាស (៦) សេចក្តីសម្រេច (៧)សារាចរ (៨) ដីកា............. ។

៤

## ស្ថាប័នមានសមត្ថកិច្ចចេញលិខិតបទដ្ឋានគតិយុត្ត

| | | |
|---|---|---|
| ព្រះមហា-ក្សត្រ | ព្រះរាជក្រម | ជាច្បាប់ទាំងឡាយណាដែលបានអនុម័តដោយរដ្ឋសភា និង ត្រួតពិនិត្យផ្ទៀងផ្ទាត់ដោយព្រឹទ្ធសភា រួចបាន បញ្ជូន មករាជរដ្ឋាភិបាល ដើម្បីរៀបចំដាក់ទូលថ្វាយព្រះមហាក្សត្រ។ |
| | ព្រះរាជក្រឹត្យ | តាមការទូលថ្វាយស្នើសុំរបស់នាយករដ្ឋមន្ត្រី ព្រះមហាក្សត្រទ្រង់ឡាយព្រះហស្ថលេខាលើព្រះរាជក្រឹត្យ។ |

៥

## ស្ថាប័នមានសមត្ថកិច្ចចេញលិខិតបទដ្ឋានគតិយុត្ត "ត"

| | | |
|---|---|---|
| ស្ថាប័ននីតិបញ្ញតិ | រដ្ឋសភា | ពិនិត្យពិភាក្សាអនុម័តលើសេចក្តីព្រាងច្បាប់ស្នើសុំដោយរាជរដ្ឋាភិបាលបានស្នើឡើង និងសេចក្តីព្រាងច្បាប់របស់សមាជិកសភា |
| | ព្រឹទ្ធសភា | ពិនិត្យផ្ទៀងផ្ទាត់ឡើងវិញនូវអត្ថបទច្បាប់ដែលរដ្ឋសភាបានអនុម័តរួចហើយ។ |

៦

ជំពូកទី២

## ស្ថាប័នមានសមត្ថកិច្ចចេញលិខិតបទដ្ឋានគតិយុត្ត "ត"

| | | |
|---|---|---|
| ស្ថាប័ននីតិប្រតិបត្តិ | រាជរដ្ឋាភិបាល | • មានមុខនាទីអនុវត្តច្បាប់ដែលអនុម័តដោយរដ្ឋសភា និងព្រឹទ្ធសភា ។<br>• មានសិទ្ធិចេញលិខិតបទដ្ឋានគតិយុត្តិ ដូចជា អនុក្រឹត្យ ប្រកាស សេចក្តីណែនាំ. ..។ |
| រដ្ឋបាលថ្នាក់ក្រោមជាតិ | ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ | ប្រើប្រាស់សិទ្ធិអំណាចបញ្ញតិរបស់ខ្លួនដោយចេញដីកា ស្របទៅតាមបទបញ្ញត្តិដូចមានចែងក្នុងជំពូកទី២ ផ្នែកទី ៣ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ។ |

៧

## ស្ថាប័នមានសមត្ថកិច្ចចេញលិខិតបទដ្ឋានគតិយុត្ត "ត"

| | | |
|---|---|---|
| រដ្ឋបាលថ្នាក់ក្រោមជាតិ | ក្រុមប្រឹក្សាឃុំ សង្កាត់ | • មានអំណាចបញ្ញត្តិ និងអំណាចប្រតិបត្តិ។<br>• អំណាចបញ្ញត្តិរបស់ឃុំ សង្កាត់ត្រូវធ្វើឡើងតាមរយៈដីកាសំរាប់គ្រប់គ្រងកិច្ចការនានាក្នុងក្របខ័ណ្ឌ តួនាទី មុខងារ និងអំណាចរបស់ខ្លួន។ |

៨

## តារាងស្តីពីលិខិតបទដ្ឋានគតិយុត្តនានាក្នុងការគាំទ្រកម្មវិធីជាតិ

| សមាសធាតុនៃកម្មវិធី | ទិសដៅ | លិខិតបទដ្ឋាននានា |
|---|---|---|
| សមាសធាតុកម្មវិធីទី១ : ការរៀបចំ ស្ថាប័នរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ | បង្កើតតួនាទីស្ថាប័នរដ្ឋបាលថ្នាក់ក្រោមជាតិ ។ | - អនុក្រឹត្យលេខ ២១៥ អនក្រ. បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ។<br>- អនុក្រឹត្យលេខ២១៦ អនក្រ. បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ។<br>- អនុក្រឹត្យលេខ២១៧ អនក្រ. បក ចុះថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០០៩ ។<br>- អនុក្រឹត្យលេខ២១៨ អនក្រ. បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ។<br>៩ |

## តារាងស្តីពីលិខិតបទដ្ឋានគតិយុត្តនានាក្នុងការគាំទ្រកម្មវិធីជាតិ "ត"

| សមាសធាតុនៃកម្មវិធី | ទិសដៅ | លិខិតបទដ្ឋាននានា |
|---|---|---|
| សមាសធាតុកម្មវិធីទី១ : ការរៀបចំ ស្ថាប័នរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ | បង្កើតតួនាទីស្ថាប័នរដ្ឋបាល ថ្នាក់ក្រោមជាតិ ។ | - ប្រកាសលេខ ៤២៧៣ ប្រក ចុះថ្ងៃទី ៣០ ខែធ្នូ ឆ្នាំ២០០៩ របស់ក្រសួងមហាផ្ទៃ ។<br>- ប្រកាសលេខ ៤២៧៤ ប្រក ចុះថ្ងៃទី ៣០ ខែធ្នូ ឆ្នាំ២០០៩ របស់ក្រសួងមហាផ្ទៃ ។<br>- ប្រកាសលេខ ៤២៧៥ ប្រក ចុះថ្ងៃទី ៣០ ខែធ្នូ ឆ្នាំ២០០៩ របស់ក្រសួងមហាផ្ទៃ ។ ១០ |

ជំពូកទី២

## តារាងស្តីពីលិខិតបទដ្ឋានគតិយុត្តនានាក្នុងការគាំទ្រកម្មវិធីជាតិ "ត"

| សមាសធាតុនៃកម្មវិធី | ទិសដៅ | លិខិតបទដ្ឋាននានា |
|---|---|---|
| សមាសធាតុកម្មវិធីទី ២: ប្រព័ន្ធគ្រប់គ្រង និងអភិវឌ្ឍធនធានមនុស្ស | រៀបចំឱ្យមានមន្ត្រីរាជការស៊ីវិល ប្រកបដោយវិជ្ជាជីវៈ និងមានឆន្ទៈមោះមុតក្នុងការបំពេញការងារនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលមានគណនេយ្យភាពចំពោះក្រុមប្រឹក្សា និងគ្រប់គ្រងដោយក្រុមប្រឹក្សា ។ | - ជំពូកទី៤ ផ្នែកទី១ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ស្តីពីបុគ្គលិក របស់ក្រុមប្រឹក្សា ។<br>- ជំពូកទី៥ ផ្នែកទី៨ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ស្តីពីបុគ្គលិក ។ |

១១

## តារាងស្តីពីលិខិតបទដ្ឋានគតិយុត្តនានាក្នុងការគាំទ្រកម្មវិធីជាតិ "ត"

| សមាសធាតុនៃកម្មវិធី | ទិសដៅ | លិខិតបទដ្ឋាននានា |
|---|---|---|
| សមាសធាតុកម្មវិធីទី៣: ការផ្ទេរមុខងារ | ផ្ទេរមុខងារឱ្យទៅរដ្ឋបាលថ្នាក់ក្រោមជាតិ ដោយភ្ជាប់ជាមួយនូវការទទួលខុសត្រូវ សិទ្ធិអំណាច និងធនធាន ។ | ជំពូកទី ៥ ផ្នែកទី៨ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ស្តីពីបុគ្គលិក។ |

១២

## តារាងស្តីពីលិខិតបទដ្ឋានគតិយុត្តនានាក្នុងការគាំទ្រកម្មវិធីជាតិ "គ"

| សមាសធាតុនៃកម្មវិធី | ទិសដៅ | លិខិតបទដ្ឋាននានា |
|---|---|---|
| សមាសធាតុកម្មវិធី ទី ៤: ប្រព័ន្ធ គ្រប់គ្រងថវិកា ហិរញ្ញវត្ថុនិងទ្រព្យសម្បត្តិ។ | បង្កើតប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុរបស់ រដ្ឋបាលថ្នាក់ក្រោមជាតិលទ្ធភាពកៀរគរ ទទួលធនធានគ្រប់គ្រាន់ មានសិទ្ធិគ្រប់គ្រង ។ បែងចែកធនធានដោយតម្លាភាព និង គណនេយ្យភាព ។ | -ជំពូកទី៥ ផ្នែកទី៦ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ស្តីពីរបបហិរញ្ញវត្ថុរបស់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ។<br>-ជំពូកទី៥ ផ្នែកទី៧ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌស្តីពី ការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។[១៣] |

## តារាងស្តីពីលិខិតបទដ្ឋានគតិយុត្តនានាក្នុងការគាំទ្រកម្មវិធីជាតិ "គ"

| សមាសធាតុនៃកម្មវិធី | ទិសដៅ | លិខិតបទដ្ឋាននានា |
|---|---|---|
| សមាសធាតុកម្មវិធីទី៥: ស្ថាប័នគាំទ្រកំណែទម្រង់ វិមជ្ឈការ និង វិសហមជ្ឈការ ។ | ពង្រឹងស្ថាប័នថ្នាក់ជាតិនានា សម្រាប់ដឹកនាំការអនុវត្តកម្មវិធីជាតិ។ | ព្រះរាជក្រឹត្យលេខ នស/រកត/១២០៨/១៤២៩ ស្តីពី ការបង្កើតគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិប្បតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប)។[១៤] |

៣ មេរៀនទី ឯកសារចែក

# លិខិតបទដ្ឋានគតិយុត្តសម្រាប់គាំទ្រដល់ដំណើរការ កំណែទម្រង់រដ្ឋបាលថ្នាក់ក្រោមជាតិ

## ១ ~ លិខិតបទដ្ឋានគតិយុត្ត

លិខិតបទដ្ឋានគតិយុត្ត គឺជាលិខិតដែលកំណត់ជាក្បួនច្បាប់មានអានុភាពគតិយុត្ត តម្រូវឱ្យអនុវត្តក្នុងការគ្រប់គ្រងសង្គម គ្រប់គ្រងរដ្ឋលើវិស័យ នយោបាយ សេដ្ឋកិច្ច វប្បធម៌ សង្គម។ លិខិតបទដ្ឋានគតិយុត្តចែកចេញជា ២ប្រភេទ គឺលិខិតមានលក្ខណៈជាបទបញ្ញាសម្រាប់បង្កើត និងលិខិតឯកត្តភូតសម្រាប់ការតែងតាំង ។ លិខិតបទដ្ឋានគតិយុត្តរៀបចំតាក់តែងឡើងដោយផ្អែកលើរដ្ឋធម្មនុញ្ញជាគោលដោយមានលំដាប់លំដោយដូចជា (១)ច្បាប់ (២)ព្រះរាជក្រម(៣)ព្រះរាជក្រឹត្យ (៤)អនុក្រឹត្យ (៥) ប្រកាស (៦)សេចក្ដីសម្រេច (៧)សារាចរ និង(៨)ដីកា។

### ស្ថាប័នមានសមត្ថកិច្ចចេញលិខិតបទដ្ឋានគតិយុត្តរួមមាន

### ក.ព្រះមហាក្សត្រ

- **ព្រះរាជក្រម:** ជាច្បាប់ទាំងឡាយណាដែលបានអនុម័តដោយរដ្ឋសភា និងត្រួតពិនិត្យផ្ទៀងផ្ទាត់ដោយព្រឹទ្ធសភារួចបានបញ្ជូនមករាជរដ្ឋាភិបាលដើម្បីរៀបចំដាក់ទូលថ្វាយព្រះមហាក្សត្រទ្រង់ឡាយព្រះហស្ថលេខាលើព្រះរាជក្រមប្រកាសអោយប្រើច្បាប់។
- **ព្រះរាជក្រឹត្យ:** តាមការទូលថ្វាយស្នើសុំរបស់នាយករដ្ឋមន្ត្រី ព្រះមហាក្សត្រទ្រង់ឡាយព្រះហស្ថលេខាលើព្រះរាជក្រឹត្យ ដើម្បីបង្កើតស្ថាប័ន និងតែងតាំង ឬផ្លាស់ប្ដូរមន្ត្រីជាន់ខ្ពស់ ឬវីរៈជនរបស់ជាតិ។

### ខ.ស្ថាប័ននីតិបញ្ញត្តិ

- **រដ្ឋសភា:** ពិនិត្យពិភាក្សាអនុម័តលើសេចក្ដីព្រាងច្បាប់ស្នើសុំដោយរាជរដ្ឋាភិបាលបានស្នើឡើង និងសេចក្ដីព្រាងច្បាប់របស់សមាជិកសភា។
- **ព្រឹទ្ធសភា:** ពិនិត្យផ្ទៀងផ្ទាត់ឡើងវិញនូវអត្ថបទច្បាប់ដែលរដ្ឋសភាបានអនុម័តរួចហើយ។ បើក្នុងករណីមិនមានយល់ព្រមលើមាត្រាណាមួយនោះ ត្រូវផ្ញើត្រឡប់ទៅរដ្ឋសភាដើម្បីពិនិត្យឡើងវិញ ។ ប៉ុន្តែបើសិនជាអង្គប្រជុំព្រឹទ្ធសភាឯកភាព យល់ព្រមទាំងស្រុង ត្រូវ

ជំពូកទី២

បញ្ជូនអត្ថបទច្បាប់នោះត្រឡប់មករាជរដ្ឋាភិបាលវិញ ដើម្បីរៀបចំព្រាងព្រះរាជក្រម ដាក់ថ្វាយព្រះមហាក្សត្រឡាយព្រះហស្ថលេខាប្រកាសអោយប្រើច្បាប់។

**គ.ស្ថាប័ននីតិប្រតិបត្តិ**

- **រាជរដ្ឋាភិបាល :** រាជរដ្ឋាភិបាលមានមុខនាទីអនុវត្តច្បាប់ដែលអនុម័តដោយរដ្ឋសភា និងព្រឹទ្ធសភា និងមានសិទ្ធិចេញលិខិតបទដ្ឋានក្រោមច្បាប់ ដូចជា អនុក្រឹត្យ ប្រកាស សេចក្តីណែនាំ សេចក្តីសម្រេច ក្នុងការគ្រប់គ្រងប្រទេសជាតិ។
- **ក្រសួង :**ក្រសួងចំណុះអោយរាជរដ្ឋាភិបាលទៅលើផ្នែកជំនាញ និងបច្ចេកទេស។ រាជរដ្ឋាភិបាលលផ្ទេរសិទ្ធិអំណាចអោយក្រសួងក្នុងការចេញនូវប្រកាស សារាចរ សេចក្តីសម្រេចក្នុងការបង្កើត ឬ តែងតាំង។

**ឃ.រដ្ឋបាលថ្នាក់ក្រោមជាតិ**

- **ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ :** ប្រើប្រាស់សិទ្ធិអំណាចបញ្ញត្តិរបស់ខ្លួនដោយចេញដីកាស្របទៅតាមបទបញ្ញត្តិដូចមានចែងក្នុងជំពូកទី ២ ផ្នែកទី ៣ នៃច្បាប់ស្តីពីការគ្រប់គ្រងរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ។
- **ក្រុមប្រឹក្សាឃុំ សង្កាត់:** មានអំណាចបញ្ញត្តិ និងអំណាចប្រតិបត្តិ។ អំណាចបញ្ញត្តិរបស់ឃុំ សង្កាត់ត្រូវធ្វើឡើងតាមរយៈដីកាសំរាប់គ្រប់គ្រងកិច្ចការនានាក្នុងក្របខ័ណ្ឌតួនាទី មុខងារ និងអំណាចរបស់ខ្លួន។

## ២ . លិខិតបទដ្ឋានគតិយុត្តដែលរាជរដ្ឋាភិបាលបានចេញសម្រាប់គាំទ្រដល់ដំណើរការកំណែទម្រង់រដ្ឋបាលថ្នាក់ក្រោមជាតិ និងគាំទ្រការអនុវត្តកម្មវិធីជាតិ

កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិមាន សមាសធាតុកម្មវិធីចំនួន ៥ ។ ការអនុវត្តកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ រាជរដ្ឋាភិបាលចាំបាច់ត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្តនានាសម្រាប់គាំទ្រដល់ ដំណើរការកំណែទម្រង់រដ្ឋបាលថ្នាក់ក្រោមជាតិ ហើយទាមទារឱ្យមានការពិនិត្យ និងកែសម្រួលលិខិតបទដ្ឋានទាំងនោះជាបន្ត

បន្ទាប់ផងដែរ ។ សមាសធាតុកម្មវិធីនីមួយៗត្រូវអមដោយលិខិតបទដ្ឋានគតិយុត្តនានាដើម្បីធានាដល់ការអនុវត្តមានប្រសិទ្ធភាព។ នៅខែឧសភា ឆ្នាំ២០១០ លេខាធិការដ្ឋាន គ.ជ.អ.ប បានរៀបចំចងក្រងសៀវភៅបទដ្ឋានគតិយុត្តសម្រាប់គាំទ្រ ដល់ដំណើរការកំណែទម្រង់រដ្ឋបាលថ្នាក់ក្រោមជាតិ និងគាំទ្រដល់ការអនុវត្តកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិដែលរួមមានអនុក្រឹត្យចំនួន ៦ និងប្រកាសចំនួន ៣ ។

### ✍ សមាសធាតុកម្មវិធីទី១: ការរៀបចំស្ថាប័នរដ្ឋបាលថ្នាក់ក្រោមជាតិ

- **អនុក្រឹត្យលេខ ២១៥ អនក្រ.បក** ស្តីពី តួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលរាជធានីភ្នំពេញ និងក្រុមប្រឹក្សា គណៈអភិបាលខណ្ឌនៃរាជធានីភ្នំពេញ។ អនុក្រឹត្យនេះមាន ៦ជំពូក និង ១៤៩មាត្រា។ មានមាត្រាសំខាន់ៗ មួយចំនួនត្រូវយកចិត្តទុកដាក់ដូចជា:
    - **មាត្រា៥.**រដ្ឋបាលរាជធានី រដ្ឋបាលខណ្ឌ រដ្ឋបាលសង្កាត់ ទទួលសិទ្ធិអំណាច របស់ខ្លួនដោយរដ្ឋធម្មនុញ្ញ ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ និងលិខិតបទដ្ឋានគតិយុត្តដទៃទៀតដែលស្របនឹងច្បាប់ ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់។
    - **មាត្រា៨.**ក្រុមប្រឹក្សារាជធានីភ្នំពេញ មានតួនាទីចាត់ចែងកិច្ចការចាំបាច់នានា ដើម្បីសម្រេចគោលបំណងក្នុងការបង្កើតការជំរុញ និង ការធ្វើឱ្យមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ ព្រមទាំងដើម្បីបំពេញមុខងារភារកិច្ចដែលបានប្រគល់ និងបានធ្វើប្រតិភូកម្មស្របតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ។
    - **មាត្រា១០.**ក្រុមប្រឹក្សារាជធានីភ្នំពេញ ត្រូវបំពេញមុខងារ និងភារកិច្ចរបស់ខ្លួនដោយធ្វើសេចក្តីសម្រេចខាងបញ្ញត្តិ និងសេចក្តីសម្រេចខាងប្រតិបត្តិតាមរយៈដីកា និងសេចក្តីសម្រេចនានាក្នុងអង្គប្រជុំក្រុមប្រឹក្សារបស់ខ្លួន និងត្រូវធានាថាសេចក្តីសម្រេចទាំងនេះត្រូវបានអនុវត្តដោយមានការតាមដាន និងវាយតម្លៃជាប្រចាំ។

- **មាត្រា១៧.** អំណាចបញ្ញត្តិ និងអំណាចប្រតិបត្តិទាំងអស់ដែលក្រុមប្រឹក្សារាជធានីភ្នំពេញបានសម្រេចរួចហើយ គណៈអភិបាលរាជធានីភ្នំពេញ ត្រូវទទួលខុសត្រូវការចាត់ចែងអនុវត្តក្នុងនាមក្រុមប្រឹក្សារបស់ខ្លួន។ គណៈអភិបាលរាជធានីត្រូវធ្វើសេចក្តីរាយការណ៍ជូនក្រុមប្រឹក្សារបស់ខ្លួនរៀងរាល់កិច្ចប្រជុំសាមញ្ញ ឬ វិសាមញ្ញរបស់ក្រុមប្រឹក្សារាជធានីដូចមានចែងក្នុងមាត្រា១៤ និងមាត្រា១៥ នៃអនុក្រឹត្យនេះ។

ក្រុមប្រឹក្សារាជធានីត្រូវតាមដានត្រួតពិនិត្យ និងវាយតម្លៃលើកិច្ចការដែលអនុវត្តដោយគណៈអភិបាលរាជធានី ដើម្បីធានាថាគណៈអភិបាលរាជធានីអនុវត្តកិច្ចការទាំងនេះបានត្រឹមត្រូវតាមច្បាប់លិខិតបទដ្ឋានគតិយុត្តនានា និងការសម្រេចរបស់ក្រុមប្រឹក្សារាជធានី។

គ.ជ.អ.ប ត្រូវដាក់ចេញនូវគោលការណ៍ណែនាំគាំទ្រដល់ក្រុមប្រឹក្សារាជធានីក្នុងការរៀបចំនូវប្រពន្ធ័តាមដានត្រួតពិនិត្យ និង វាយតម្លៃលើការអនុវត្តសេចក្តីសម្រេចនានារបស់ក្រុមប្រឹក្សារាជធានី ។

- **អនុក្រឹត្យលេខ ២១៦ អនក្រ.បក:** ស្តីពី តួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក។ អនុក្រឹត្យនេះមាន៧ ជំពូក និង២១២មាត្រា។ មានមាត្រាសំខាន់ៗ មួយចំនួនត្រូវយកចិត្តទុកដាក់ដូចជា:

  - **មាត្រា៥.**រដ្ឋបាលខេត្ត រដ្ឋបាលក្រុង រដ្ឋបាលស្រុក រដ្ឋបាលឃុំ និងរដ្ឋបាលសង្កាត់ ទទួលសិទ្ធិអំណាចរបស់ខ្លួនដោយរដ្ឋធម្មនុញ្ញ ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ និងលិខិតបទដ្ឋានគតិយុត្តិដទៃទៀតដែលស្របនឹងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ។

  - **មាត្រា៨.**ក្រុមប្រឹក្សាខេត្ត មានតួនាទីចាត់ចែងកិច្ចការចាំបាច់នានា ដើម្បីសម្រេចគោលបំណងក្នុងការបង្កើត ការជំរុញ និងការធ្វើឱ្យមានចីរភាពដល់ការអភិវឌ្ឍតាមបែប

ប្រជាធិបតេយ្យ ព្រមទាំងដើម្បីបំពេញមុខងារ ភារកិច្ចដែលបានប្រគល់ និងដែលបានធ្វើប្រតិភូកម្មស្របតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

- **មាត្រា១០.** ក្រុមប្រឹក្សាខេត្ត ត្រូវបំពេញមុខងារ និងភារកិច្ចរបស់ខ្លួនដោយធ្វើសេចក្តីសម្រេចខាងបញ្ញត្តិ និងសេចក្តីសម្រេចខាងប្រតិបត្តិតាមរយៈដីកា និងសេចក្តីសម្រេចនានាក្នុងអង្គប្រជុំក្រុមប្រឹក្សារបស់ខ្លួន និងត្រូវធានាថាសេចក្តីសម្រេចទាំងនេះត្រូវបានអនុវត្តដោយមានការតាមដាននិង វាយតម្លៃជាប្រចាំ ។

- **មាត្រា១៧.** អំណាចបញ្ញត្តិ និងអំណាចប្រតិបត្តិទាំងអស់ដែលក្រុមប្រឹក្សាខេត្តបានសម្រេចរួចហើយ គណៈអភិបាលខេត្តត្រូវទទួលខុសត្រូវការចាត់ចែងអនុវត្តក្នុងនាមក្រុមប្រឹក្សារបស់ខ្លួន។ គណៈអភិបាលខេត្តត្រូវធ្វើសេចក្តីរាយការណ៍ជូនក្រុមប្រឹក្សារបស់ខ្លួនរៀងរាល់កិច្ចប្រជុំសាមញ្ញ ឬ វិសាមញ្ញរបស់ក្រុមប្រឹក្សាខេត្ត ដូចមានចែងក្នុងមាត្រា ១៤ និងមាត្រា១៥នៃអនុក្រឹត្យនេះ។ ក្រុមប្រឹក្សាខេត្ត ត្រូវតាមដានត្រួតពិនិត្យនិងវាយតម្លៃលើកិច្ចការដែលអនុវត្តដោយគណៈអភិបាលខេត្ត ។ ដើម្បីធានាថាគណៈអភិបាលខេត្តអនុវត្តកិច្ចការទាំងនេះបានត្រឹមត្រូវតាមច្បាប់ លិខិតបទដ្ឋានគតិយុត្តនានា និងការសម្រេចរបស់ក្រុមប្រឹក្សាខេត្ត ។

គ.ជ.អ.ប ត្រូវដាក់ចេញនូវគោលការណ៍ណែនាំ គាំទ្រដល់ក្រុមប្រឹក្សាខេត្តក្នុងការរៀបចំនូវប្រព័ន្ធតាមដានត្រួតពិនិត្យ និង វាយតម្លៃលើការអនុវត្តសេចក្តីសម្រេចចិត្តនានារបស់ក្រុមប្រឹក្សាខេត្ត។

- **អនុក្រឹត្យលេខ២១៧ អនក្រ បក** ស្តីពី ការបង្កើត ការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសក្រុមប្រឹក្សារាជធានីភ្នំពេញនិងគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសក្រុមប្រឹក្សាខណ្ឌនៃរាជធានីភ្នំពេញ។ អនុក្រឹត្យនេះមាន៥ ជំពូក និង២៤មាត្រា។ មានមាត្រាចំនួនមួយត្រូវយកចិត្តទុកដាក់:
  - **មាត្រា២.** ក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខណ្ឌនៃរាជធានីភ្នំពេញ ត្រូវរៀបចំឱ្យមាន

គណៈកម្មាធិការសម្របសម្រួលបច្ចេកទេសរៀង១ខ្លួន ដើម្បីជួយសិក្សា និងផ្តល់យោបល់ដល់ក្រុមប្រឹក្សា និងគណៈអភិបាលរបស់ខ្លួន លើបញ្ហាទាក់ទងនឹងការងារ ផែនការ ថវិកា ការសម្របសម្រួលកិច្ចការនានា ជាមួយមន្ទីរ អង្គភាពខ្សែបណ្តោយរបស់ក្រសួង ស្ថាប័ននានា និងក្រុមប្រឹក្សាប្រភេទផ្សេងទៀត និងបញ្ហាទាក់ទងនឹងមុខងារ ធនធានដែលបានប្រគល់ ឬបានធ្វើប្រតិភូកម្មឱ្យក្រុមប្រឹក្សារាជធានី និងក្រុមប្រឹក្សាខណ្ឌ ។

- **អនុក្រឹត្យលេខ២១៨ អនក្រ.បក** ស្តីពីការបង្កើត ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសក្រុមប្រឹក្សាខេត្ត គណៈកម្មាធិការសម្របសម្រួលបច្ចេកទេសក្រុមប្រឹក្សាក្រុង និងគណៈកម្មាធិការសម្របសម្រួលបច្ចេកទេស ក្រុមប្រឹក្សាស្រុក។ អនុក្រឹត្យនេះ មាន៦ ជំពូក និង ៣៣ មាត្រា។ មានមាត្រាចំនួនមួយត្រូវយកចិត្តទុកដាក់:
  - **មាត្រា២.**ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង និងក្រុមប្រឹក្សាស្រុក ត្រូវរៀបចំឱ្យមានគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសរៀង១ខ្លួន ដើម្បីជួយសិក្សា និងផ្តល់យោបល់ដល់ក្រុមប្រឹក្សា និងគណៈអភិបាលរបស់ខ្លួនលើបញ្ហាទាក់ទងនឹងការងារ ផែនការ ថវិកា ការសម្របសម្រួលកិច្ចការនានារបស់ក្រុមប្រឹក្សាជាមួយមន្ទីរ អង្គភាពខ្សែបណ្តោយរបស់ក្រសួង ស្ថាប័ននានា និងក្រុមប្រឹក្សាប្រភេទផ្សេងទៀត និងបញ្ហាទាក់ទងនឹងមុខងារធនធានដែលបានប្រគល់ឬបានធ្វើប្រតិភូកម្មឱ្យក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង និងក្រុមប្រឹក្សាស្រុក ។

- **ប្រកាសលេខ៤២៧៣ ប្រក:** ស្តីពីការបង្កើតការិយាល័យចំណុះទីចាត់ការនៃសាលារាជធានីភ្នំពេញ ការបង្កើតការិយាល័យនៃសាលាខណ្ឌ និងការកំណត់តួនាទី ភារកិច្ច របៀបរបបការងារនៃការិយាល័យទាំងនោះ។ ប្រកាសនេះមាន ៤ ជំពូក និង ៣១ មាត្រា។ មានមាត្រាចំនួនមួយត្រូវយកចិត្តទុកដាក់ :
  - **មាត្រា២.** ផ្អែកតាមមាត្រា៥៥នៃអនុក្រឹត្យលេខ២១៥អនក្រ.បកចុះថ្ងៃទី១៤ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ចនិងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលរាជធានីភ្នំពេញ

និងក្រុមប្រឹក្សា គណៈអភិបាលខណ្ឌនៃរាជធានីភ្នំពេញ។ សាលារាជធានីភ្នំពេញត្រូវមានទីចាត់ការចំណុះចាំបាច់ដូចខាងក្រោម:

- ទីចាត់ការរដ្ឋបាល
- ទីចាត់ការផែនការ និងវិនិយោគ
- ទីចាត់ការហិរញ្ញវត្ថុ
- ទីចាត់ការរៀបចំក្រុង
- ទីចាត់ការគ្រប់គ្រងធនធានមនុស្ស
- ទីចាត់ការអន្តរវិស័យ
- ទីចាត់ការកិច្ចការច្បាប់ និងសិទ្ធិមនុស្ស
- ទីចាត់ការកិច្ចការគ្រប់គ្រងកាកសំណល់។

ទីចាត់ការនីមួយៗត្រូវបំពេញតួនាទី ភារកិច្ចដូចមានចែងក្នុងមាត្រា ៥៨ នៃអនុក្រឹត្យលេខ ២១៥ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សាគណៈអភិបាលរាជធានីភ្នំពេញ និងក្រុមប្រឹក្សាគណៈអភិបាលខណ្ឌនៃរាជធានីភ្នំពេញ។ ទីចាត់ការនីមួយៗត្រូវមានការិយាល័យចំណុះដែលកំណត់ដោយប្រកាសនេះ។ ការិយាល័យនីមួយៗត្រូវដឹកនាំដោយប្រធាន ១រូប និងមានអនុប្រធានយ៉ាងច្រើន០២រូបជាជំនួយការ។

លក្ខខណ្ឌនៃការតែងតាំងប្រធាន អនុប្រធានការិយាល័យនៃទីចាត់ការនីមួយៗត្រូវផ្អែកលើលក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ។

- **ប្រកាសលេខ៤២៧៤ ប្រក :** ស្តីពី ការបង្កើតការិយាល័យចំណុះទីចាត់ការនៃសាលាខេត្ត ការបង្កើតការិយាល័យនៃសាលាក្រុង ការបង្កើតការិយាល័យនៃសាលាស្រុក និង ការកំណត់តួនាទី ភារកិច្ច របៀបរបបការងារនៃការការិយាល័យទាំងនោះ។ ប្រកាសនេះ មាន ៥ ជំពូក និង ៣៨ មាត្រា។ មានមាត្រាចំនួន មួយ ត្រូវ យកចិត្តទុកដាក់ :

ជំពូកទី២

- **មាត្រា២.** ផ្អែកតាមមាត្រា៥៥ នៃអនុក្រឹត្យលេខ ២១៦ អនក្រ.បក ចុះថ្ងៃទី១៤ ខែ ធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈ-អភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក សាលាខេត្តត្រូវមានទីចាត់ការចំណុះចាំបាច់ដូចខាងក្រោម :
    - ទីចាត់ការរដ្ឋបាល
    - ទីចាត់ការផែនការ និងវិនិយោគ
    - ទីចាត់ការហិរញ្ញវត្ថុ
    - ទីចាត់ការគ្រប់គ្រងធនធានមនុស្ស
    - ទីចាត់ការអន្តរវិស័យ ។

ទីចាត់ការនីមួយៗត្រូវបំពេញតួនាទី ភារកិច្ចដូចមានចែងក្នុងមាត្រា៥៨ នៃអនុក្រឹត្យលេខ ២១៦ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងារ របស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត និងក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សាគណៈអភិបាលស្រុក។ ទីចាត់ការនីមួយៗត្រូវមានការិយាល័យចំណុះដែលកំណត់ដោយប្រកាសនេះ។ ការិយាល័យនីមួយៗត្រូវដឹកនាំដោយប្រធាន ១រូប និងមានអនុប្រធានយ៉ាងច្រើន ០២រូបជាជំនួយការ។

លក្ខខណ្ឌនៃការតែងតាំងប្រធាន អនុប្រធានការិយាល័យនៃទីចាត់ការនីមួយៗត្រូវផ្អែកលើលក្ខន្តិកៈ ដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ ។

- **ប្រកាសលេខ៤២៧៥ ប្រក :** ស្តីពី ការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារនៅក្នុងក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ។ ប្រកាសនេះមាន ៥ ជំពូក និង ៣៨ មាត្រា។ មានមាត្រាចំនួនមួយត្រូវយកចិត្តទុកដាក់ :
    - **មាត្រា២.**ក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ត្រូវរៀបចំឱ្យមានគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ ដែលមានសិទ្ធិ និងមានភារកិច្ចផ្តល់យោបល់ និងលើកអនុសាសន៍ជូនក្រុមប្រឹក្សា

គណៈអភិបាល និងគណៈកម្មាធិការដទៃទៀតរបស់ក្រុមប្រឹក្សា លើបញ្ហា ពាក់ព័ន្ធនឹង សមភាពយេនឌ័រ បញ្ហាស្ត្រី យុវវ័យ និងកុមារ ដែលស្ថិតនៅក្នុងអំណាច មុខងារ និង ភារកិច្ចរបស់ក្រុមប្រឹក្សា ។

### ✍ សមាសធាតុកម្មវិធីទី២: ប្រព័ន្ធគ្រប់គ្រងនិងអភិវឌ្ឍន៍ធនធានមនុស្ស

តាមការស្វែងយល់ទៅលើឯកសារយោងក្នុងការគាំទ្រដល់ដំណើរការអនុវត្តសមាសធាតុកម្មវិធីទី២ នៃកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ យើងពុំទាន់ទទួលបាននូវការផ្សព្វផ្សាយអំពីលិខិតបទដ្ឋានគតិយុត្តពីរាជរដ្ឋាភិបាល ឬ/និងក្រសួង ពាក់ព័ន្ធឡើយ។ ដូចនេះឯកសារជាសំខាន់នៅពេលនេះ គឺផ្តោតយកចិត្តទុកដាក់ទៅលើខ្លឹមសារនៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ជំពូកទី៤ ផ្នែកទី៣ និង ជំពូកទី៥ ផ្នែកទី៨។

### ✍ សមាសធាតុកម្មវិធីទី៣: ការផ្ទេរមុខងារ

តាមការស្វែងយល់ទៅលើឯកសារយោង ក្នុងការគាំទ្រដល់ដំណើរការអនុវត្តសមាសធាតុកម្មវិធីទី៣ នៃកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ក៏ដូចជា សមាសធាតុកម្មវិធីទី២ដែរ មកដល់ពេលនេះ យើងពុំទាន់ទទួលបានការផ្សព្វផ្សាយនូវលិខិតបទដ្ឋានគតិយុត្តពីរាជរដ្ឋាភិបាល ឬ/និងក្រសួងពាក់ព័ន្ធឡើយ។ ដូចនេះឯកសារជាសំខាន់នៅពេលនេះ គឺផ្តោតយកចិត្តទុកដាក់ទៅលើខ្លឹមសារនៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ជំពូកទី៥ ផ្នែកទី៨។

### ✍ សមាសធាតុកម្មវិធីទី៤: ប្រព័ន្ធគ្រប់គ្រងថវិកា ហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិ

សមាសធាតុកម្មវិធីទី ៤ ក៏ដូចជាសមាធាតុកម្មវិធីទី ២ និងទី ៣ដែរ មកដល់ពេលនេះ យើងពុំទាន់ទទួលបាននូវការផ្សព្វផ្សាយលិខិតបទដ្ឋានគតិយុត្តពីរាជរដ្ឋាភិបាល ឬ/និង ក្រសួងពាក់ព័ន្ធឡើយ។ ដូចនេះឯកសារជាសំខាន់នៅពេលនេះគឺផ្តោតយកចិត្តទុកដាក់ ជំពូកទី៥ ផ្នែកទី ៦ និង ជំពូកទី ៥ ផ្នែកទី ៧ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ។

### ✍ សមាសធាតុកម្មវិធីទី៥: ស្ថាប័នគាំទ្រកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ

ជំពូកទី២

- **ព្រះរាជក្រឹត្យលេខ នស/រកត/១២០៨/១៤២៩:** ស្តីពីការបង្កើតគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប) ។ ព្រះរាជក្រឹត្យនេះមាន ៧ ជំពូក ២៦ មាត្រា ។ មានមាត្រាមួយចំនួនត្រូវផ្តោតយកចិត្តទុកដាក់

  - **មាត្រា១.** ត្រូវបានបង្កើតគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិដែលមានឈ្មោះជាអក្សរកាត់ថា"**គ.ជ.អ.ប**" ដើម្បីសម្របសម្រួលដឹកនាំការអនុវតច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និងការអនុវត្តគោលនយោបាយកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ។

  - **មាត្រា ២ . គ.ជ.អ.ប** មានសមាសភាពដូចខាងក្រោម :

| | |
|---|---|
| ១. រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ | ជាប្រធាន |
| ២. រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ជាអនុប្រធាន |
| ៣. រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី | ជាអនុប្រធាន |
| ៤. រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីកម្ម និងសំណង់ | ជាសមាជិក |
| ៥. រដ្ឋមន្ត្រីក្រសួងផែនការ | ជាសមាជិក |
| ៦. រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ | ជាសមាជិក |
| ៧. រដ្ឋមន្ត្រីក្រសួងកិច្ចការនារី | ជាសមាជិក |
| ៨. រដ្ឋមន្ត្រីក្រសួងសុខាភិបាល | ជាសមាជិក |
| ៩. រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ជាសមាជិក |
| ១០. រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា | ជាសមាជិក |
| ១១. ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល | ជាសមាជិក |
| ១២. រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ | ជាសមាជិក |
| ១៣. រដ្ឋលេខាធិការក្រសួងមហាផ្ទៃ ០១ រូប | ជាសមាជិក |
| ១៤. រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ០១រូប | ជាសមាជិក |

១៥. តំណាងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ០១រូប ជាសមាជិក
១៦. ប្រធានលេខាធិការដ្ឋាននៃ គ.ជ.អ.ប ជាសមាជិកអចិន្ត្រៃយ៍

ក្រៅពីសមាជិកខាងលើនេះ គ.ជ.អ.ប អាចស្នើបន្ថែមសមាជិកជារដ្ឋមន្ត្រី ឬ ប្រធានស្ថាប័ននៃក្រសួង ស្ថាប័នពាក់ព័ន្ធនៃរាជរដ្ឋាភិបាលតាមការចាំបាច់ ។

សមាជិកម្នាក់ៗត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធានគ.ជ.អ.ប ។ ក្នុងករណីមិនអាចចូលរួមប្រជុំបាន សមាជិកនោះអាចតែងតាំងតំណាងមួយរូបដែលជាសមាជិករដ្ឋាភិបាល ដើម្បីជំនួសខ្លួននៅក្នុងការចូលរួមកិច្ចប្រជុំ ដោយធ្វើប្រតិភូកម្មអំណាច ឱ្យតំណាងរូបនោះមានសិទ្ធិសម្រេចជំនួសខ្លួន ។

គ.ជ.អ.ប អាចអញ្ជើញរដ្ឋមន្ត្រីក្រសួង ស្ថាប័ន ឬអាជ្ញាធរ ឬអ្នកពាក់ព័ន្ធផ្សេងៗទៀតឱ្យចូលរួមប្រជុំ ការពិភាក្សា ឬសហការការងារតាមការចាំបាច់។



- **មាត្រា ៤.** គ.ជ.អ.ប មានការទទួលខុសត្រូវចំពោះមុខរាជរដ្ឋាភិបាល អំពីការអនុវត្តច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និងគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ ។

- **មាត្រា ៥.** គ.ជ.អ.ប ត្រូវធានាឱ្យច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ត្រូវបានអនុវត្តដោយក្រសួង ស្ថាប័នពាក់ព័ន្ធនានានៅថ្នាក់ជាតិ មន្ទីរ អង្គភាពនានារបស់រាជរដ្ឋាភិបាល និងក្រុមប្រឹក្សានៅរដ្ឋបាលថ្នាក់ក្រោមជាតិ ។



- **មាត្រា ៦.** គ.ជ.អ.ប ត្រូវធានាឱ្យគោលនយោបាយ យុទ្ធសាស្ត្រ និងកម្មវិធីកំណែទម្រង់នានាមានសង្គតិភាពជាមួយច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និងគោលនយោបាយវិមជ្ឈការ និង វិសហមជ្ឈការ ។

- **មាត្រា៧.** គ.ជ.អ.ប អាចដោះស្រាយ ឬលើកសំណើសុំសេចក្តីសម្រេចពីរាជរដ្ឋាភិបាល លើការមិនចុះសម្រុងគ្នា ដែលអាចកើតមានឡើងទាក់ទងនឹងការអនុវត្តច្បាប់ស្តីពី ការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ។

# មេរៀនទី ៣ ប្លង់មេរៀន

**ចំណងជើងមេរៀន:** លិខិតបទដ្ឋានគតិយុត្តិនានាគាំទ្រដល់ការអនុវត្តកម្មវិធីជាតិ សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

**រយៈពេលសរុប: ២ ម៉ោង**

## សកម្មភាពសម្របសម្រួលវគ្គ

| រយៈពេល | សកម្មភាព និងវិធីសាស្ត្រ | សម្ភារៈ/ឯកសារ |
|---|---|---|
| ១០ នាទី | <u>**សកម្មភាពទី១:**</u>រំលឹកអំពីទិដ្ឋភាពទូទៅនៃកម្មវិធីជាតិនិងបង្ហាញគោលបំណងមេរៀន:<br>• អ្នកសម្របសម្រួលចាប់ផ្តើមដោយរំលឹកដល់សិក្ខាកាមអំពីទិដ្ឋភាពទូទៅនៃកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិនៅក្នុងមេរៀនទី១ និង ទី២ នៃជំពូកទី២។<br>• អ្នកសម្របសម្រួលជម្រាបជូនសិក្ខាកាមថាដើម្បីគាំទ្រដល់ដំណើរការកំណែទម្រង់រដ្ឋបាលថ្នាក់ក្រោមជាតិរាជរដ្ឋាភិបាលបានចេញលិខិតបទដ្ឋានគតិយុត្តសម្រាប់ការអនុវត្តកម្មវិធីជាតិឱ្យមានប្រសិទ្ធភាព។<br>• អ្នកសម្របសម្រួលជម្រាបជូនសិក្ខាកាមថាដំបូងយើងត្រូវយល់លិខិតបទដ្ឋានគតិយុត្ត និងស្គាល់ស្ថាប័នមានសមត្ថកិច្ចចេញលិខិតបទដ្ឋានគតិយុត្ត។<br>• អ្នកសម្របសម្រួលអញ្ជើញសិក្ខាកាមម្នាក់អានគោលបំណងមេរៀន បន្ទាប់មកអ្នកសម្របសម្រួលជម្រាបជូនសិក្ខាកាមថាមេរៀននេះយើងនឹងមានបង្ហាញអំពីលិខិតបទដ្ឋានគតិយុត្ត ស្ថាប័នមានសមត្ថកិច្ចចេញលិខិតបទដ្ឋានគតិយុត្ត និងលិខិតបទដ្ឋានគតិយុត្តនានាដែលរាជរដ្ឋាភិបាលបានចេញសម្រាប់គាំទ្រដល់ដំណើរការកំណែទម្រង់ | 🗐 បទបង្ហាញស្លីតគោលបំណង<br>💻LCD និងកុំព្យូទ័រ<br>✎ ហ្វឺត<br>✂ ក្រដាស ផ្ទាំងធំ ស្កុត |

| រយៈពេល | សកម្មភាព និងវិធីសាស្រ្ត | សម្ភារៈ/ឯកសារ |
|---|---|---|
| | រដ្ឋបាលថ្នាក់ក្រោមជាតិ។ | |
| ១៥ នាទី | **<u>សកម្មភាពទី២</u>**:ការណែនាំអោយស្គាល់អំពីលិខិតបទដ្ឋានគតិយុត្ត<br>• អ្នកសម្រសម្រួលបង្ហាញសំនួរចំនួន ២ ដល់ សិក្ខាកាមដើម្បីពិភាក្សាក្នុងក្រុមធំ :<br>○ សំនួរទី១:ដូចម្តេចដែលហៅថាលិខិតបទដ្ឋានគតិយុត្ត?<br>○ សំនួរទី២:តើស្ថាប័នណាខ្លះមានសមត្ថកិច្ចចេញលិខិតបទដ្ឋានគតិយុត្ត?<br>• អ្នកសម្របសម្រួលផ្តល់ពេលវេលា១០នាទីសម្រាប់សិក្ខាកាមចំនួន ៣ នាក់ ដោយម្នាក់ៗឆ្លើយសំនួរទាំងពីរ និងលើកឧទាហរណ៍បញ្ជាក់អំពីលិខិតបទដ្ឋានគតិយុត្តដែលធ្លាប់ស្គាល់និងចូលរួមអនុវត្ត។<br>• អ្នកសម្របសម្រួលកត់ត្រាចម្លើយលើក្រដាសផ្ទាំងធំ<br>• អ្នកសម្របសម្រួលបង្ហាញ អត្ថន័យនៃលិខិតបទដ្ឋានគតិយុត្តនិងស្ថាប័នមានសមត្ថកិច្ចចេញលិខិតបទដ្ឋានគតិយុត្ត។ | 💻LCD និងកុំព្យូទ័រ<br>🗐បទបង្ហាញស្តីពីលិខិតបទដ្ឋានគតិយុត្ត<br>✏ហ្វឺត<br>✂ ក្រដាសផ្ទាំងធំស្កុត |
| ៤៥ នាទី | **<u>សកម្មភាពទី៣</u>**.ការបង្ហាញប្រភេទលិខិតបទដ្ឋានគតិយុត្តសម្រាប់គាំទ្រសមាសធាតុកម្មវិធីនីមួយៗ:<br>• អ្នកសម្របសម្រួលចាប់ផ្តើមដោយសួរសំនួរក្នុងក្រុមធំ(**តើមានលិខិតបទដ្ឋានគតិយុត្តចំនួនប៉ុន្មានសម្រាប់គាំទ្រដល់ដំណើរការកំណែទម្រង់រដ្ឋបាលថ្នាក់ក្រោមជាតិ?គឺលិខិតបទដ្ឋានអ្វីខ្លះ?**)<br>• អ្នកសម្របសម្រួលផ្តល់ពេលវេលា១០នាទីដល់សិក្ខាកាមចំនួន២នាក់ដោយម្នាក់ៗផ្តល់ចម្លើយទាំង២ ។<br>• អ្នកសម្របសម្រួលកត់ត្រាចម្លើយលើក្រដាសផ្ទាំងធំ<br>• អ្នកសម្របសម្រួលបន្តដោយបង្ហាញលិខិតបទដ្ឋានគតិយុត្តនានាសម្រាប់គាំទ្រដល់សមាសភាពកម្មវិធីនីមួយៗ ដោយរំលឹកដល់ | 🗐បទបង្ហាញស្តីពីលិខិតបទដ្ឋានពាក់ពន្ធ័នឹងសមាសធាតុកម្មវិធីនានានៃកម្មវិធី។<br>💻LCDនិងកុំព្យូទ័រ<br>✏ហ្វឺត<br>✂ក្រដាសផ្ទាំងធំស្កុត |

| រយៈពេល | សកម្មភាព និងវិធីសាស្ត្រ | សម្ភារៈ/ឯកសារ |
|---|---|---|
| | សិក្ខាកាមយកចិត្តទុកដាក់មាត្រាមួយចំនួននៃលិខិតបទដ្ឋានគតិយុត្ត។<br><br>☞**សមាសធាតុកម្មវិធីទី១**:អ្នកសម្របសម្រួលចាប់ផ្ដើមដោយជំរាបសិក្ខាកាមថា សមាសធាតុកម្មវិធីទី១ មានអនុក្រឹត្យចំនួន៤ និងប្រកាសចំនួន ៣ សម្រាប់គាំទ្រដល់ការអនុវត្តៈ<br>• អនុក្រឹត្យលេខ ២១៥អនក្រ.បកស្ដីពីតួនាទីភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលរាជធានីភ្នំពេញ និងក្រុមប្រឹក្សា គណៈអភិបាលខណ្ឌនៃរាជធានីភ្នំពេញ ។<br>• អនុក្រឹត្យលេខ ២១៦ អនក្រ.បកស្ដីពីតួនាទីភារកិច្ចនិងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សាគណៈអភិបាលខេត្ត ក្រុមប្រឹក្សាគណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក។<br>• អនុក្រឹត្យលេខ ២១៧ និង ២១៨ អនក្រ.បក. ព័ត៌មានទាក់ទងនឹងការបង្កើតគណៈកម្មាធិការសម្របសម្រួលបច្ចេកទេស ។<br>• ប្រកាសលេខ ៤២៧៣ប្រកចុះថ្ងៃទី ៣០ ខែធ្នូ ឆ្នាំ២០០៩ របស់ក្រសួងមហាផ្ទៃស្ដីពីការបង្កើតការិយាល័យចំណុះទីចាត់ការនៃសាលារាជធានីភ្នំពេញ ការបង្កើតការិយាល័យនៃសាលាខណ្ឌ និងការកំណត់តួនាទីភារកិច្ច របៀបរបបការងារនៃការិយាល័យទាំងនោះ។<br>• ប្រកាសលេខ ៤២៧៤ប្រកចុះថ្ងៃទី ៣០ ខែធ្នូ ឆ្នាំ២០០៩ របស់ក្រសួងមហាផ្ទៃស្ដីពីការបង្កើតការិយាល័យចំណុះទីចាត់ការនៃសាលាខេត្ត ការបង្កើតការិយាល័យនៃសាលាក្រុង ការបង្កើតការិយាល័យនៃសាលាស្រុកនិងការកំណត់ តួនាទីភារកិច្ច របៀបរបបការងារនៃការិយាល័យទាំងនោះ។<br>• ប្រកាសលេខ ៤២៧៥ ប្រកចុះថ្ងៃទី ៣០ ខែធ្នូ ឆ្នាំ២០០៩ របស់ក្រសួងមហាផ្ទៃស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មាធិការ | |

| រយៈពេល | សកម្មភាព និងវិធីសាស្ត្រ | សម្ភារៈ/ឯកសារ |
|---|---|---|
| | ពិគ្រោះយោបល់កិច្ចការស្ត្រីនិងកុមារនៅក្នុងក្រុមប្រឹក្សារាជធានីក្រុមប្រឹក្សាខេត្តក្រុមប្រឹក្សាក្រុងក្រុមប្រឹក្សាស្រុកក្រុមប្រឹក្សាខណ្ឌ។<br><br>☞ **សមាសធាតុកម្មវិធីទី២:** អ្នកសម្របសម្រួលត្រូវលើកឡើងថាតាមការស្វែងយល់ទៅលើឯកសារយោងក្នុងការគាំទ្រដល់ដំណើរការអនុវត្តសមាសធាតុកម្មវិធីទី២នៃកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិយើងពុំទាន់ទទួលបាននូវការផ្សព្វផ្សាយអំពីលិខិតបទដ្ឋានគតិយុត្តពីរាជរដ្ឋាភិបាល ឬ/និងក្រសួងពាក់ព័ន្ធឡើយ។ឯកសារជាសំខាន់នៅពេលនេះគឺផ្តោតទៅលើខ្លឹមសារនៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានីខេត្តក្រុងស្រុកខណ្ឌ ជំពូកទី៤ ផ្នែកទី១ និងជំពូកទី៥ ផ្នែកទី៨។<br><br>☞ **សមាសធាតុកម្មវិធីទី៣:** អ្នកសម្របសម្រួលបញ្ជាក់ថាតាមការស្វែងយល់ទៅលើឯកសារយោងក្នុងការគាំទ្រដល់ដំណើរការអនុវត្តសមាសធាតុកម្មវិធីទី ៣ នៃកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ក៏ដូចជាសមាសធាតុកម្មវិធីទី២ដែរមកដល់ពេលនេះយើងពុំទាន់ទទួលបានការផ្សព្វផ្សាយនូវលិខិតបទដ្ឋានគតិយុត្តពីរាជរដ្ឋាភិបាលឬ/និងក្រសួងពាក់ព័ន្ធឡើយ។ ឯកសារជាសំខាន់នៅពេលនេះគឺផ្តោតយកចិត្តទុកដាក់ទៅលើខ្លឹមសារនៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានីខេត្តក្រុងស្រុកខណ្ឌ ជំពូកទី៥ ផ្នែកទី៨។<br><br>☞ **សមាសធាតុកម្មវិធីទី៤:** សមាសធាតុទី៤ ក៏ដូចជាសមាធាតុកម្មវិធីទី២ និងទី៣ដែរ មកដល់ពេលនេះពុំទាន់ទទួលបាននូវការផ្សព្វផ្សាយលិខិតបទដ្ឋានគតិយុត្តពីរាជរដ្ឋាភិបាល ឬ/និងក្រសួងពាក់ព័ន្ធឡើយ។ ឯកសារជាសំខាន់នៅពេលនេះគឺយោងទៅលើជំពូកទី៥ ផ្នែកទី ៦ និងជំពូកទី ៥ | |

| រយៈពេល | សកម្មភាព និងវិធីសាស្ត្រ | សម្ភារៈ/ឯកសារ |
|---|---|---|
| | ផ្នែកទី ៧នៃច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានីខេត្ត ក្រុង ស្រុក ខណ្ឌ។<br><br>☞ **សមាសធាតុកម្មវិធីទី៥**:អ្នកសម្របសម្រួលជំរាបសិក្ខាកាមថាមានព្រះរាជក្រឹត្យចំនួន ១ សម្រាប់គាំទ្រដល់ការអនុវត្តសមាសធាតុកម្មវិធីទី៥នេះ។ព្រះរាជក្រឹត្យនេះ មាន ៧ ជំពូក ២៦ មាត្រាដោយបញ្ជាក់ឱ្យសិក្ខាកាមផ្តោតទៅលើមាត្រា ១, មាត្រា ២, មាត្រា៤, មាត្រា ៥, មាត្រា ៦ និងមាត្រា ៥ ។<br>• ព្រះរាជក្រឹត្យលេខ នស/រកត/១២០៨/១៤២៩: ស្តីពីការបង្កើតគណៈកម្មធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប) ។ | |
| ៥ នាទី | **<u>សកម្មភាព ៤</u>** :សេចក្តីសន្និដ្ឋានមេរៀន<br>អ្នកសម្របសម្រួលត្រូវសង្ខេបមេរៀនឡើងវិញដោយបញ្ជាក់ថា:<br>• កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិមានសមាសធាតុកម្មវិធីចំនួន៥ សមាសធាតុកម្មវិធីនិមួយៗត្រូវមានអមជាមួយដោយលិខិតបទដ្ឋានគតិយុត្ត ដើម្បីឱ្យការអនុវត្តមានភាពជាក់លាក់ និងមានប្រសិទ្ធភាពខ្ពស់។<br>• រាជរដ្ឋាភិបាលបានចេញអនុក្រឹត្យចំនួន ៦ និងប្រកាសចំនួន ៣ សម្រាប់គាំទ្រដល់ដំណើរការកំណែទម្រង់រដ្ឋភាលថ្នាក់ក្រោមជាតិ និងការអនុវត្តកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។ | |

<u>បញ្ជាក់</u>: អ្នកសម្របសម្រួលត្រូវលៃពេលសម្រាប់ពេលសម្រាកពិសារអាហារសម្រន់ក្នុងករណីមេរៀនវែងដូចនេះ ។

ជំពូកទី២

## សម្ភារៈឧបទ្ទេសសម្រាប់បង្រៀន

- ឯកសារចែកនិងឯកសារបង្ហាញ
- ហ្វឺតសរសេរក្រដាស ក្រដាសផ្ទាំងធំ ស្កុត ក្រដាស និងកាតពណ៌
- ផ្ទាំងប៉ាណូ
- ម៉ាស៊ីនបញ្ចាំង (LCD)
- កុំព្យូទ័រយួរដៃ (Laptop)

## ឯកសារយោង និងប្រភពព័ត៌មានបន្ថែម

- សៀវភៅស្ដីពីកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- សៀវភៅលិខិតបទដ្ឋានគតិយុត្តសម្រាប់គាំទ្រដល់ដំណើរការកំណែទម្រង់រដ្ឋបាលថ្នាក់ក្រោមជាតិ ខែឧសភា ឆ្នាំ២០១០។
- ច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- www.ncdd.gov.kh

# ជំពូកទី ៣

## ការភ្ជាប់ទំនាក់ទំនង
## សង្គមស៊ីវិលក្នុងការអនុវត្ត
## កម្មវិធីជាតិ

# មេរៀនទី ១

## ការយល់ឃើញរបស់អង្គការសង្គមស៊ីវិលក្នុងការភ្ជាប់ទំនាក់ទំនងជាមួយក្រុមប្រឹក្សាថ្នាក់ក្រោមជាតិ

# មេរៀនទី ១ ការយល់ឃើញរបស់អង្គការសង្គមស៊ីវិលក្នុងការភ្ជាប់ទំនាក់ទំនងជាមួយក្រុមប្រឹក្សាថ្នាក់ក្រោមជាតិ

## គោលបំណង

នៅចុងបញ្ចប់នៃមេរៀននេះ សិក្ខាកាមនឹងអាច

☞ ពន្យល់ពីហេតុអ្វីបានជាអង្គការសង្គមស៊ីវិលមានសារៈសំខាន់ក្នុងការភ្ជាប់ទំនាក់ទំនងជាមួយកម្មវិធីជាតសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។

☞ ពិពណ៌នាយ៉ាងហោចណាស់ឱ្យបានឱកាសពីរផ្សេងគ្នារបស់អង្គការសង្គមស៊ីវិលក្នុងការទំនាក់ទំនងជាមួយកម្មវិធីជាតិ ។

## លទ្ធផលមេរៀន/ការប្រើលទ្ធផលរំពឹងទុក

☞ សិក្ខាកាមមានព័ត៌មានពីប្រវត្តិដែលបង្កើតនូវការចាប់អារម្មណ៍ដល់មេរៀនផ្សេងៗបន្ទាប់ទៀត។

☞ សិក្ខាកាមចាប់ផ្តើមគិតអំពីការទំនាក់ទំនង និងមើលឃើញថា តើអង្គការសង្គមស៊ីវិលអាចទំនាក់ទំនងជាមួយកម្មវិធីជាតិសំរាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិលើសកម្មភាពអ្វីខ្លះ?

## កំណត់សម្គាល់អ្នកសម្របសម្រួល

នៅក្នុងមេរៀននេះ អ្នកសម្របសម្រួលមានគោលបំណងចំនួនបី

១. សិក្ខាកាមបានពិភាក្សារួចហើយពីបទពិសោធន៍ក្នុងការធ្វើការងារជាអង្គការសង្គមស៊ីវិល។ មេរៀនទី ៣ ជំពូកទី ១ បានទាក់ទាញសិក្ខាកាមឱ្យនិយាយពីបទពិសោធន៍ជាក់លាក់ដែលទាក់ទងទៅនឹងការអភិវឌ្ឍលទ្ធិប្រជាធិបតេយ្យ។ អ្នកសម្របសម្រួលចង់ឱ្យអ្នកចូលរួមផ្ទុះបញ្ចាំងទៅអនាគតនូវអ្វីដែលអង្គការសង្គមស៊ីវិលអាចធ្វើបានខ្លះ ដើម្បីបន្តផ្តោតលើការអភិវឌ្ឍលទ្ធិប្រជាធិបតេយ្យ។



២. សិក្ខាកាមបានដឹងរួចហើយពីលិខិតបទដ្ឋានគតិយុត្តនានាដែលគាំទ្រដល់ដំណើរការកំណែទម្រង់រដ្ឋបាលថ្នាក់ក្រោមជាតិ។ មេរៀននេះស្តីពី ការយល់ឃើញរបស់អង្គការសង្គមស៊ីវិលក្នុងការភ្ជាប់ទំនាក់ទំនងជាមួយក្រុមប្រឹក្សាថ្នាក់ក្រោមជាតិ ក្នុងគោលបំណងបង្ហាញដល់សិក្ខាកាមពីឱកាស និងលទ្ធភាពដែលអាចធ្វើបានក្នុងដំណើរការនេះ។ នៅក្នុងមេរៀននេះ អ្នកចូលរួមនឹងគិតពីចំណុចដែលត្រូវចាប់ផ្តើម និងហេតុអ្វីបានជាអង្គការសង្គមស៊ីវិលគាំទ្រដល់ការទំនាក់ទំនង។

៣. អ្នកសម្របសម្រួលមិនគួរពន្យល់ស៊ីជម្រៅនៅក្នុងមេរៀននេះទេ។ គោលបំណងគ្រាន់តែបង្ហាញពីឱកាស និងលទ្ធភាពដែលអង្គការសង្គមស៊ីវិលអាចភ្ជាប់ទំនាក់ទំនងជាមួយក្រុមប្រឹក្សាថ្នាក់ក្រោមជាតិ។ អ្នកសម្របសម្រួលនឹងធ្វើការពន្យល់ និងពិភាក្សាស៊ីជម្រៅបន្ថែមទៀតនៅមេរៀនបន្ទាប់ ថាតើអង្គការសង្គមស៊ីវិលត្រូវភ្ជាប់ទំនាក់ទំនងជាមួយក្រុមប្រឹក្សាថ្នាក់ក្រោមជាតិក្នុងការអនុវត្តកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។

១ រៀនទី

ឯកសារបន្ទាញ

# ជំពូកទី ៣ : មេរៀនទី ១

# ការយល់ឃើញរបស់អង្គការសង្គមស៊ីវិល ក្នុងការភ្ជាប់ទំនាក់ទំនងជាមួយ ក្រុមប្រឹក្សាថ្នាក់ក្រោមជាតិ

## ១_គោលបំណងមេរៀន

- ✓ ពន្យល់ពីហេតុអ្វីបានជាអង្គការសង្គមស៊ីវិលមានសារៈសំខាន់ក្នុងការភ្ជាប់ទំនាក់ទំនងជាមួយកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។
- ✓ ពិពណ៌នាយ៉ាងហោចណាស់ឱ្យបានឱកាសពីរផ្សេងគ្នារបស់អង្គការសង្គមស៊ីវិលក្នុងការភ្ជាប់ទំនាក់ទំនងជាមួយក្រុមប្រឹក្សាថ្នាក់ក្រោមជាតិ។

២

ជំពូកទី៣

## ២_ហេតុអ្វីបានជាអង្គការសង្គមស៊ីវិលត្រូវភ្ជាប់ទំនាក់ទំនង ជាមួយក្រុមប្រឹក្សាថ្នាក់ក្រោមជាតិ?

☞ ការធ្វើសេចក្តីសម្រេចចិត្តដោយថ្នាក់ខេត្ត និងស្រុក នឹងមានផលប៉ះពាល់ធំធេងទៅលើម្ចាស់ឆ្នោត/សហគមន៍។

☞ ការផ្លាស់ប្តូរយោបល់រវាងអាជ្ញាធរ និងប្រជាពលរដ្ឋមានសារៈសំខាន់ណាស់ចំពោះប្រសិទ្ធភាពនៃប្រព័ន្ធប្រជាធិបតេយ្យនានា។

☞ ការឆ្លើយតប និងប្រសិទ្ធភាពរបស់ក្រុមប្រឹក្សាគួរផ្តល់ឱកាសដល់ប្រជាពលរដ្ឋ និង អង្គការសង្គមស៊ីវិលបានចូលរួមក្នុងការធ្វើសេចក្តីសម្រេចចិត្ត *(ដោយមិនចាំបាច់កំណត់ពីពេលធ្វើផែនការ ថវិកា ការត្រួតពិនិត្យ និងដំណើរការវាយតម្លៃលើការអនុវត្ត)* ។

៣

## ៣_តើអង្គការសង្គមស៊ីវិលអាចចូលរួមធ្វើអ្វីខ្លះ?

➢ អង្គការសង្គមស៊ីវិលអាចធ្វើការបញ្ចុះបញ្ចូលឱ្យមានការចាប់អារម្មណ៍ពីផលប្រយោជន៍របស់ខ្លួន និងតម្រូវការទូទៅរបស់សហគមន៍ ឬរបស់ក្រុមដែលមានតម្រូវការពិសេស។

➢ អង្គការសង្គមស៊ីវិលអាចផ្តល់យោបល់ ដើម្បីជួយកែលំអគោលនយោបាយ។

➢ អង្គការសង្គមស៊ីវិលអាចធ្វើការជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិដើម្បីអនុវត្តកម្មវិធីនានា។

➢ អង្គការសង្គមស៊ីវិលអាចត្រួតពិនិត្យសកម្មភាពដែលអនុវត្តដោយរដ្ឋបាលថ្នាក់ក្រោមជាតិ ឬ អ្នកម៉ៅការ ដើម្បីឱ្យប្រាកដថាអ្នកអនុវត្តធ្វើការងារនោះបានល្អ។

***"វិមជ្ឈការប្រជាធិបតេយ្យ នឹងមិនអាចទទួលបានជោគជ័យទេ បើគ្មានការចូលរួមភ្ជាប់ទំនាក់ទំនងរវាងរដ្ឋបាលមូលដ្ឋាន និងអង្គការសង្គមស៊ីវិល"***

៤

## ៤. តើអង្គការសង្គមស៊ីវិលអាចចូលរួមដោយរបៀបណា?

- ខ្លឹមសារមាត្រា ៦៨, ៧៥ និង ៧៦ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ បានចែងថា កិច្ចប្រជុំ/ព្រឹត្តិការណ៍នានារបស់ក្រុមប្រឹក្សា ត្រូវផ្សព្វផ្សាយជាសាធារណៈពីកាលបរិច្ឆេទ និងទីកន្លែងជាក់លាក់ ។
- អង្គការសង្គមស៊ីវិលអាចជួយអភិវឌ្ឍ និងពង្រឹងឱ្យមានគណនេយ្យភាព និងយន្តការនៃការឆ្លើយតប។
- ដើរតួជាអន្តរការីដ៏មានតម្លៃរវាងប្រជាពលរដ្ឋ និងមន្ត្រីនានា (ឧទាហរណ៍ ផ្សព្វផ្សាយព័ត៌មានដល់ប្រជាពលរដ្ឋ និងប្រមូលព័ត៌មានពីម្ចាស់ឆ្នោត / ប្រជាពលរដ្ឋ)។

៥

## ៤. តើអង្គការសង្គមស៊ីវិលអាចចូលរួមដោយរបៀបណា? "ត"

- កសាងសមត្ថភាព និងជំនឿចិត្តនៃសមាគមអ្នកស្ម័គ្រចិត្ត និងអង្គការសហគមន៍មូលដ្ឋាន (CBO) ដើម្បីដើរតួជាអ្នកកសាងស្ពានទំនាក់ទំនងរវាងប្រជាពលរដ្ឋម្នាក់ៗ និងក្រុមប្រឹក្សា។
- ដៃគូជាមួយក្រុមប្រឹក្សាថ្នាក់ក្រោមជាតិ ដើម្បីផ្តល់សេវាកម្មប្រកបដោយគុណភាពដល់ប្រជាពលរដ្ឋ (ទាំងហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត និងហេដ្ឋារចនាសម្ព័ន្ធអរូបវ័ន្ត)។

៦

## ៤_តើអង្គការសង្គមស៊ីវិលអាចចូលរួមដោយរបៀបណា? "ឥ"

➢ ដៃគូជាមួយសមាគមក្រុមប្រឹក្សាឃុំ សង្កាត់ថ្នាក់ខេត្ត ដើម្បីបង្កើនសមត្ថភាព និងជំនឿចិត្តរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ( *គាំទ្របណ្តាញការងារក្រុមប្រឹក្សាឃុំ សង្កាត់ ដើម្បីបញ្ចេញសម្លេងក្នុងនាមផលប្រយោជន៍ និងការព្រួយបារម្ភ របស់ខ្លួន ក្នុងពេលប្រជុំជាមួយក្រុមប្រឹក្សាស្រុក ខេត្ត ឬ ការប្រជុំរបស់ក្រុមការងារគណនេយ្យភាពខេត្ត* )។

៧

## ៥_ការគាំទ្រដល់អង្គការសង្គមស៊ីវិល

➢ អង្គការសង្គមស៊ីវិល/អង្គការមិនមែនរដ្ឋាភិបាលត្រូវពង្រឹងការយល់ដឹងឱ្យកាន់តែស៊ីជម្រៅអំពីកំណែទម្រង់វិមជ្ឈការ និងអភិបាលកិច្ច *"រៀនពីការអនុវត្ត"*។

➢ ដំណើរការភ្ជាប់ទំនាក់ទំនងរបស់អង្គការសង្គមស៊ីវិល / អង្គការមិនមែនរដ្ឋាភិបាលត្រូវចាប់ផ្តើមឱ្យបានឆាប់រហ័ស ដូច្នេះសមត្ថភាព និងចំណេះដឹងត្រូវបានកសាង។

➢ លើកកម្ពស់ការពិភាក្សាបណ្តាញការងារនៅថ្នាក់ខេត្ត ក្នុងចំណោមអង្គការសង្គមស៊ីវិល ដើម្បីពង្រឹងសមត្ថភាព និងជំនឿចិត្តរបស់ខ្លួន។

➢ លើកកម្ពស់ទំនាក់ទំនងរវាងបណ្តាញអង្គការសង្គមស៊ីវិលនៅថ្នាក់ខេត្ត និងថ្នាក់ជាតិ អំពីគោលនយោបាយ និងការចែករំលែកបទពិសោធន៍អំពីការអនុវត្តល្អៗ។

៨

# សេចក្តីសន្និដ្ឋាន

- ការភ្ជាប់ទំនាក់ទំនងមិនមែនជាការងាយស្រួលទេសម្រាប់អង្គការសង្គមស៊ីវិល នៅគ្រប់ដំណាក់កាលនៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ គឺវាអាស្រ័យលើឥរិយាបទ និងការតាំងចិត្តរបស់អ្នកអនុវត្ត។
- ការបើកចិត្តឱ្យទូលាយដើម្បីស្តាប់ ការផ្តល់នូវគុណតម្លៃទៅវិញទៅមករវាងក្រុមប្រឹក្សាថ្នាក់ក្រោមជាតិ និងអង្គការសង្គមស៊ីវិលគឺជាការចាំបាច់ ដើម្បីធ្វើឱ្យសម្រេចនូវគោលដៅរួម។
- វិមជ្ឈការប្រជាធិបតេយ្យ នឹងមិនអាចទទួលបានជោគជ័យទេ បើគ្មានការចូលរួមភ្ជាប់ទំនាក់ទំនងរវាងរដ្ឋបាលមូលដ្ឋាន និងអង្គការសង្គមស៊ីវិល។

៩

១ ឯកសារចែក

# ការយល់ឃើញរបស់អង្គការសង្គមស៊ីវិលក្នុងការភ្ជាប់ទំនាក់ទំនងជាមួយក្រុមប្រឹក្សាថ្នាក់ក្រោមជាតិ

**១. គោលបំណង:** នៅចុងបញ្ចប់នៃមេរៀននេះសិក្ខាកាមនឹងអាចៈ

☞ ពន្យល់ពីហេតុអ្វីបានជាអង្គការសង្គមស៊ីវិលមានសារៈសំខាន់ក្នុងទំនាក់ទំនងជាមួយកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។

☞ ពិពណ៌នាយ៉ាងហោចណាស់ឱ្យបានឱកាសពីរផ្សេងគ្នារបស់អង្គការសង្គមស៊ីវិលក្នុងការទំនាក់ទំនងជាមួយក្រុមប្រឹក្សាថ្នាក់ក្រោមជាតិ។

## ២. ហេតុអ្វីបានជាអង្គការសង្គមស៊ីវិលត្រូវភ្ជាប់ទំនាក់ទំនងជាមួយក្រុមប្រឹក្សាថ្នាក់ក្រោមជាតិ

- ការធ្វើសេចក្តីសម្រេចចិត្តដោយថ្នាក់ខេត្ត និងស្រុកអាចនឹងមានផលប៉ះពាល់ធំធេងទៅលើម្ចាស់ឆ្នោត/សហគមន៍។



- ការផ្លាស់ប្តូរយោបល់រវាងអាជ្ញាធរ និងប្រជាពលរដ្ឋមានសារៈសំខាន់ណាស់ចំពោះប្រសិទ្ធភាព នៃប្រព័ន្ធប្រជាធិបតេយ្យនានា។

- ការឆ្លើយតប និងប្រសិទ្ធភាពរបស់ក្រុមប្រឹក្សាគួរផ្តល់ឱកាសដល់ប្រជាពរដ្ឋ និងអង្គការសង្គមស៊ីវិលបានចូលរួមក្នុងការធ្វើសេចក្តីសម្រេចចិត្ត (ដោយ

មិនចាំបាច់កំណត់ពីពេលធ្វើផែនការ ថវិកា ការត្រួតពិនិត្យ និងដំណើរការវាយតម្លៃលើការអនុវត្ត)។

" វិមជ្ឈការប្រជាធិបតេយ្យនឹងមិនអាចទទួលបានជោគជ័យទេ បើគ្មានការចូលរួមភ្ជាប់ទំនាក់ទំនងរវាងរដ្ឋបាលមូលដ្ឋាន និងអង្គការសង្គមស៊ីវិល "

## ៣. តើអង្គការសង្គមស៊ីវិលអាចចូលរួមធ្វើអ្វីខ្លះ?

- អង្គការសង្គមស៊ីវិលអាចធ្វើការបញ្ចុះបញ្ចូលឱ្យមានការចាប់អារម្មណ៍ពីផលប្រយោជន៍របស់ខ្លួន និងតម្រូវការទូទៅរបស់សហគមន៍ ឬ របស់ក្រុមដែលមានតម្រូវការពិសេស។
- អង្គការសង្គមស៊ីវិលអាចផ្តល់យោបល់ ដើម្បីជួយកែលំអគោលនយោបាយ។
- អង្គការសង្គមស៊ីវិលអាចធ្វើការជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីអនុវត្តកម្មវិធីនានា។
- អង្គការសង្គមស៊ីវិលអាចត្រួតពិនិត្យសកម្មភាពដែលអនុវត្តដោយរដ្ឋបាលថ្នាក់ក្រោមជាតិ ឬ អ្នកម៉ៅការ ដើម្បីឱ្យប្រាកដថាអ្នកអនុវត្តធ្វើការងារនោះបានល្អ ។



## ៤. តើអង្គការសង្គមស៊ីវិលចូលរួមដោយរបៀបណា?

ខ្លឹមសារមាត្រា ៦៨ , ៧៥ និង ៧៦ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ បានចែងថា កិច្ចប្រជុំ/ព្រឹត្តិការណ៍នានារបស់ក្រុមប្រឹក្សាត្រូវផ្សព្វផ្សាយជាសាធារណៈពីកាលបរិច្ឆេទ និង ទីកន្លែងជាក់លាក់។

- អង្គការសង្គមស៊ីវិលអាចជួយអភិវឌ្ឍ និងពង្រឹងឱ្យមានគណនេយ្យភាព និងយន្តការនៃការឆ្លើយតប។
- ដើរតួជាអន្តរការីដ៏មានតម្លៃរវាងប្រជាពលរដ្ឋ និងមន្ត្រីនានា (ឧទាហរណ៍ ផ្សព្វផ្សាយព័ត៌មានដល់ប្រជាពលរដ្ឋ និងប្រមូលព័ត៌មានពីម្ចាស់ឆ្នោត/ប្រជាពលរដ្ឋ)។
- កសាងសមត្ថភាព និងជំនឿចិត្តនៃសមាគមអ្នកស្ម័គ្រចិត្ត និងអង្គការសហគមន៍មូលដ្ឋាន (CBO) ដើម្បីដើរតួជាអ្នកកសាងស្ពានទំនាក់ទំនងរវាងប្រជាពលរដ្ឋម្នាក់ៗ និងមន្ត្រីដែលបានជាប់ឆ្នោត។



- ដៃគូជាមួយក្រុមប្រឹក្សាថ្នាក់ក្រោមជាតិ ដើម្បីផ្តល់សេវាកម្មប្រកបដោយគុណភាពដល់ប្រជាពលរដ្ឋ (ទាំងហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត និងហេដ្ឋារចនាសម្ព័ន្ធអរូបវ័ន្ត)។

- ដៃគូជាមួយសមាគមក្រុមប្រឹក្សាឃុំ/សង្កាត់ថ្នាក់ខេត្ត ដើម្បីបង្កើនសមត្ថភាព និងជំនឿចិត្តរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ (គាំទ្របណ្ដាញការងារក្រុមប្រឹក្សាឃុំ សង្កាត់ ដើម្បីបញ្ចេញសម្លេងក្នុងនាមផលប្រយោជន៍ និងការព្រួយបារម្ភរបស់ខ្លួនក្នុងពេលប្រជុំជាមួយក្រុមប្រឹក្សាស្រុក/ខេត្ត ឬការប្រជុំរបស់ក្រុមការងារគណនេយ្យភាពខេត្ត)។

- ធ្វើការបញ្ចុះបញ្ចូលសម្រាប់ការឆ្លើយតបនូវសេវាកម្មនានា។

- គាំទ្រយន្តការនានាដែលអនុញ្ញាតឱ្យប្រជាពលរដ្ឋចូលរួមយ៉ាងសកម្មនៅក្នុងកិច្ចការរបស់ក្រុមប្រឹក្សាថ្នាក់ខេត្ត និងស្រុក (*ឧ. ក្រុមប្រឹក្សាចូលរួមផ្ទាល់ជាមួយគណៈកម្មការនានារបស់សហគមន៍ ដើម្បីប្រមូលព័ត៌មានដែលជាអាទិភាព និងប្រាប់ពីចំណូល ចំណាយ និងការសម្រេចចិត្តរបស់ក្រុមប្រឹក្សា*)។

- ជួយដល់ក្រុមមិនសូវមានតំណាងដែលមានតម្រូវការពិសេស (ជនជាតិដើមភាគតិច ស្ត្រី និងកុមារ)។



- យកចិត្តទុកដាក់ចំពោះសមធម៌ និងយេនឌ័រ ការគ្រប់គ្រងធនធានធម្មជាតិ និងយន្តការគណនេយ្យភាពក្នុងគ្រប់ទិដ្ឋភាពការងាររបស់ក្រុមប្រឹក្សា។

- រួមចំណែកដល់ការសន្ទនាអំពីគោលនយោបាយ និងការបង្កើតគោលនយោបាយ ថ្នាក់ស្រុក និងថ្នាក់ខេត្ត។

- បញ្ចុះបញ្ចូល ឬ ផ្តល់យោបល់ត្រឡប់ដល់ថ្នាក់ជាតិ សម្រាប់ធ្វើឱ្យប្រសើរឡើងនូវគោលការណ៍ និងនិតិវិធី ជាពិសេសយន្តការសម្រាប់ការភ្ជាប់ទំនាក់ទំនង។

## ៥. ការគាំទ្រដល់អង្គការសង្គមស៊ីវិល

- អង្គការសង្គមស៊ីវិល/អង្គការមិនមែនរដ្ឋាភិបាល ត្រូវពង្រឹងការយល់ដឹងឱ្យកាន់តែស៊ីជម្រៅអំពីកំណែទម្រង់វិមជ្ឈការ និងអភិបាលកិច្ច *"រៀនពីការអនុវត្ត"*។
- ដំណើរការភ្ជាប់ទំនាក់ទំនងរបស់អង្គការសង្គមស៊ីវិល/អង្គការមិនមែនរដ្ឋាភិបាលត្រូវចាប់ផ្តើមឱ្យបានឆាប់រហ័ស ដូច្នេះសមត្ថភាព និងចំណេះដឹងត្រូវបានកសាង។
- លើកកម្ពស់ការពិភាក្សាបណ្តាញការងារនៅថ្នាក់ខេត្ត ក្នុងចំណោមអង្គការសង្គមស៊ីវិល ដើម្បីពង្រឹងសមត្ថភាព និងជំនឿចិត្តរបស់ខ្លួន។
- លើកកម្ពស់ទំនាក់ទំនងរវាងបណ្តាញអង្គការសង្គមស៊ីវិលនៅថ្នាក់ខេត្ត និងថ្នាក់ជាតិអំពីគោលនយោបាយ និងការចែករំលែកបទពិសោធន៍អំពីការអនុវត្តល្អៗ។

## ៦. សេចក្តីសន្និដ្ឋាន

- វិមជ្ឈការប្រជាធិបតេយ្យ នឹងមិនអាចទទួលបានជោគជ័យទេ បើគ្មានការចូលរួមភ្ជាប់ទំនាក់ទំនងរវាងរដ្ឋបាលមូលដ្ឋាន និងអង្គការសង្គមស៊ីវិល។

- ការផ្សារភ្ជាប់ទំនាក់ទំនងវាមិនមែនជាការងាយស្រួលទេ សម្រាប់អង្គការសង្គមស៊ីវិលនៅគ្រប់ដំណាក់កាលនៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ គឺវាអាស្រ័យលើឥរិយាបទ និងការតាំងចិត្តរបស់អ្នកអនុវត្ត។

- ការបើកចិត្តឱ្យទូលាយដើម្បីស្តាប់ ការបង្ហាញនូវការគោរពរវាងក្រុមប្រឹក្សាថ្នាក់ក្រោមជាតិ និងអង្គការសង្គមស៊ីវិលគឺជាការចាំបាច់ដើម្បីធ្វើឱ្យសម្រេចនូវដល់គោលដៅរួម។

# មេរៀន ១ ប្លង់មេរៀន

**ចំណងជើងមេរៀន:** ការយល់ឃើញរបស់អង្គការសង្គមស៊ីវិលក្នុងការភ្ជាប់ទំនាក់ទំនងជាមួយក្រុមប្រឹក្សាថ្នាក់ក្រោមជាតិ

**រយៈពេល** : ៦០ នាទី

## របៀបសម្របសម្រួលមេរៀន

| ពេល | សកម្មភាព និងវិធីសាស្ត្រ | សម្ភារៈ/ឯកសារ |
|---|---|---|
| ១០ នាទី | **<u>សកម្មភាពទី១:</u> ការណែនាំពីគោលបំណងនៃមេរៀន**<br><br>ក) ពន្យល់សង្ខេប ដោយចាប់ផ្ដើមគិតពីអ្វីខ្លះ ដែលមានឥទ្ធិពលដល់អង្គការសង្គមស៊ីវិលទាក់ទងទៅនឹងរដ្ឋបាលថ្នាក់ក្រោមជាតិ។<br>• យើងបានពិភាក្សារួចហើយក្នុងមេរៀនទី ៣ ជំពូកទី ១ ថាតើអ្នកណាខ្លះជាសង្គមស៊ីវិល ហើយមានតួនាទីអ្វីខ្លះនៅក្នុងការអភិវឌ្ឍលទ្ធិប្រជាធិបតេយ្យ។<br><br>ខ) សង្ខេបគោលបំណងនៃមេរៀន<br>• ពន្យល់ពីហេតុអ្វីបានជាអង្គការសង្គមស៊ីវិលមានសារៈសំខាន់ក្នុងការភ្ជាប់ទំនាក់ទំនងជាមួយកម្មវិធីនីមួយៗនៃកម្មវិធីជាតិ ដើម្បីអភិវឌ្ឍវិមជ្ឈការថ្នាក់ក្រោមជាតិ។<br>• ពិពណ៌នាយ៉ាងហោចណាស់ឱ្យបានឱកាសពីរផ្សេងគ្នារបស់សង្គមស៊ីវិលក្នុងការទំនាក់ទំនងជាមួយក្រុមប្រឹក្សាថ្នាក់ក្រោមជាតិ។<br>• អ្នកសម្របសម្រួលរំលឹកសិក្ខាកាមថាមេរៀននេះគ្រាន់តែបង្ហាញត្រួសៗចំណែកចំនុចលម្អិតនឹងបន្តពិភាក្សានៅមេរៀនទី ២បន្ទាប់នេះ។ | **បទបង្ហាញ ទី ១ គោលបំណង** |

| ពេល | សកម្មភាព និងវិធីសាស្រ្ត | សម្ភារៈ/ឯកសារ |
|---|---|---|
| ១៥ នាទី | **សកម្មភាពទី២**: ការបង្ហាញពី ការយល់ឃើញរបស់អង្គការសង្គមស៊ីវិល ក្នុងការភ្ជាប់ទំនាក់ទំនងជាមួយក្រុមប្រឹក្សាថ្នាក់ក្រោមជាតិ<br><br>ក) មានបីចំណុចដែលត្រូវបង្ហាញ:<br>• ហេតុអ្វីបានជាចាំបាច់មានការទំនាក់ទំនងពីអង្គការសង្គមស៊ីវិល?<br>• តើអង្គការសង្គមស៊ីវិលអាចចូលរួមធ្វើអ្វីបានខ្លះ?<br>• តើអង្គការសង្គមស៊ីវិលអាចចូលរួមដោយរបៀបណា?<br><br>**ខ) អ្នកសម្របសម្រួលសួរសំនួរថា តើការទំនាក់ទំនងជាអ្វី** ?<br>• ឱ្យសិក្ខាកាមមួយចំនួនពន្យល់ពីការយល់ដឹងរបស់ពួកគេនូវអត្ថន័យនៃការទំនាក់ទំនងមានន័យដូចម្តេច?<br>• អ្នកសម្របសម្រួលកត់ត្រាចំលើយលើក្រដាសផ្ទាំងធំ។<br><br>**គ) អ្នកសម្របសម្រួលធ្វើបទបង្ហាញ/រូបភាព ពីការទំនាក់ទំនងរវាងរដ្ឋាភិបាល សង្គមស៊ីវិល និងវិស័យឯកជន**<br>(*ឬ ពន្យល់លើផ្ទាំងរូបភាពទី ៦*)<br>• ការចូលរួមបង្កើតស្ថាប័នបង្ហាញឯកសារតាមរយៈការអនុវត្តជាក់ស្តែងក្នុងដំណើរការលទ្ធិប្រជាធិបតេយ្យ។<br>• សកម្មក្នុងការទំនាក់ទំនងដែលមាននិរន្តភាពរវាងអង្គការសង្គមស៊ីវិល និងក្រុមប្រឹក្សា។<br>• ធ្វើការងាររួមគ្នាក្នុងភាពជាដៃគូរវាងអង្គការសង្គមស៊ីវិល វិស័យឯកជនជាមួយនឹងរដ្ឋាភិបាល។ | <br><br>**បទបង្ហាញ** |

| ពេល | សកម្មភាព និងវិធីសាស្ត្រ | សម្ភារៈ/ឯកសារ |
|---|---|---|
| ១៥ នាទី | **សកម្មភាពទី៣: ហេតុអ្វីបានជាចាំបាច់មានការទំនាក់ទំនងជាមួយអង្គការសង្គមស៊ីវិល?**<br><br>អ្នកសម្របសម្រួលបញ្ជាក់ទៅលើបទបង្ហាញ ឬ ក្រដាសផ្ទាំងធំ<br>• ការធ្វើសេចក្ដីសំរេចចិត្តរបស់ក្រុមប្រឹក្សាថ្នាក់ក្រោមជាតិ ដែលមានឥទ្ធិពលទៅលើសហគមន៍ និងអាទិភាពរបស់ពួកគេ។<br>• អង្គការសង្គមស៊ីវិលគឺជាស្ពាន ឬ ជាភ្នែកសំរាប់ជួយការងាររបស់ក្រុមប្រឹក្សាថ្នាក់ក្រោមជាតិអនុវត្តបានប្រសើរឡើង និង ឆ្លើយតបទៅនឹងផលប្រយោជន៍របស់ប្រជាពលរដ្ឋ និងតម្រូវការនានា។<br>• ជួយពង្រឹងប្រព័ន្ធលទ្ធិប្រជាធិបតេយ្យឱ្យមានប្រសិទ្ធភាព។ | បទបង្ហាញទី ២ និងទី ៣ |
| ១៥ នាទី | **សកម្មភាពទី៤: តើអង្គការសង្គមស៊ីវិលចូលរួមដោយរបៀបណា ឬយ៉ាងដូម្ដេច?**<br>អ្នកសម្របសម្រួលបញ្ជាក់ទៅលើបទបង្ហាញ ឬ ក្រដាស ផ្ទាំងធំ អង្គការសង្គមស៊ីវិលជាឆ្អឹងខ្នងដ៏សំខាន់នៃការអភិវឌ្ឍលទ្ធិប្រជាធិបតេយ្យគឺមាន ការចូលរួម តម្លាភាព គណនេយ្យភាព និងភាពជាដៃគូ ។<br>- ឧទាហរណ៍ : ការថ្លែងក្នុងលិខិតបទដ្ឋានគតិយុត្តស្ដីពីការចូលរួមរបស់ប្រជាពលរដ្ឋក្នុងពេលប្រជុំជាក់លាក់ (*មានក្នុងមាត្រា ៦៨ ៧៥ និង៧៦*)។<br>• អង្គការសង្គមស៊ីវិលគឺជាបណ្ដាញ ដើម្បីជួយផ្សព្វផ្សាយព័ត៌មានវិជ្ជមាន និងផលប៉ះពាល់ជាអវិជ្ជមានទៅដល់ | បទបង្ហាញទី ៤ , ៥ និង ៦ |

ជំពូកទី៣

| ពេល | សកម្មភាព និងវិធីសាស្ត្រ | សម្ភារៈ/ឯកសារ |
|---|---|---|
| | ប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធនានា។<br>• អង្គការសង្គមស៊ីវិលជួយដល់ការសន្ទនាទៅលើគោលនយោបាយនៅថ្នាក់ស្រុក និងខេត្ត។ | |
| ៥ នាទី | **<u>សកម្មភាពទី ៥</u>: ការសន្និដ្ឋាន/នៅចុងបញ្ចប់**<br><br>១, វិមជ្ឈការប្រជាធិបតេយ្យនឹងមិនទទួលបានជោគជ័យទេ បើគ្មានការចូលរួមភ្ជាប់ទំនាក់ទំនងរវាងរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិល។<br><br>២, ការភ្ជាប់ទំនាក់ទំនងមិនមែនជាការងាយស្រួលទេសំរាប់អង្គការសង្គមស៊ីវិលនៅក្នុងគ្រប់ដំណាក់កាលនៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ គឺអាស្រ័យលើឥរិយាបទ និងការតាំងចិត្តរបស់អ្នកអនុវត្ត។<br><br>៣, ការបើកចិត្តឱ្យទូលាយដើម្បីស្តាប់ ការបង្ហាញនូវការគោរពរវាងក្រុមប្រឹក្សាថ្នាក់ក្រោមជាតិ និងអង្គការសង្គមស៊ីវិលជាការងារចាំបាច់ណាស់ ដើម្បីធ្វើឱ្យសំរេចបាននូវគោលដៅរួមគ្នា។ | បទបង្ហាញទី ៧ |

**សម្ភារៈ និងឧបករណ៍សម្រាប់មេរៀន :**

- បង្ហាញអំពី ការយល់ឃើញរបស់អង្គការសង្គមស៊ីវិលក្នុងការភ្ជាប់ទំនាក់ទំនងជាមួយក្រុមប្រឹក្សាថ្នាក់ក្រោមជាតិ។

**សម្ភារៈសំរាប់ចែក :** ឯកសារការយល់ឃើញរបស់អង្គការសង្គមស៊ីវិលក្នុងការភ្ជាប់ទំនាក់ទំនងជាមួយក្រុមប្រឹក្សាថ្នាក់ក្រោមជាតិ។

# មេរៀនទី ២

## ការចូលរួមរបស់អង្គការសង្គមស៊ីវិល ក្នុងការភ្ជាប់ទំនាក់ទំនងជាមួយ ក្រុមប្រឹក្សាថ្នាក់ក្រោមជាតិ

# មេរៀនទី ២ ការចូលរួមរបស់អង្គការសង្គមស៊ីវិលក្នុងការភ្ជាប់ទំនាក់ទំនងជាមួយក្រុមប្រឹក្សាថ្នាក់ក្រោមជាតិ

**គោលបំណងៈ** នៅចុងបញ្ចប់នៃមេរៀននេះសិក្ខាកាមអាច

១. ពិពណ៌នាសកម្មភាពអាទិភាពសម្រាប់ការភ្ជាប់ទំនាក់ទំនង

២. កំនត់បានពីវិធីសាស្ត្រក្នុងការអនុវត្តសកម្មភាពសម្រាប់ការភ្ជាប់ទំនាក់ទំនងជាមួយក្រុមប្រឹក្សាថ្នាក់ក្រោមជាតិក្នុងការអនុវត្តកម្មវិធីជាតិ

៣. កំនត់បានពីវិធីសាស្ត្រដើម្បីលើកទឹកចិត្តក្រុមមិនសូវមានតំណាងឱ្យមានសម្លេងនៅក្នុងកិច្ចការមូលដ្ឋាន និងកិច្ចការនៅថ្នាក់ក្រោមជាតិ។

## លទ្ធផលរំពឹងទុក

១. សិក្ខាកាមមានភាពជឿជាក់ក្នុងការសម្របសម្រួលមេរៀនដែលទាក់ទងនឹងសកម្មភាពចំបងៗនៃការភ្ជាប់ទំនាក់ទំនងបន្តដល់អ្នកផ្សេងទៀត។

២. អ្នកចូលរួមសម្រេចលើសកម្មភាពចំបងៗនៃការភ្ជាប់ទំនាក់ទំនងសម្រាប់បញ្ចូលទៅក្នុងប្រតិបត្តិការអង្គការរបស់ខ្លួន។

## កំណត់សំគាល់សម្រាប់អ្នកសម្របសម្រួល

នៅក្នុងមេរៀននេះ អ្នកសម្របសម្រួលមានគោលបំណងចំនួន ៥ :

១. ចាត់តាំងអ្នកសម្របសម្រួលម្នាក់ (សមាជិកក្នុងក្រុមអ្នកសម្របសម្រួល) ដើម្បីប្រមូលសំនួរដែលមិនអាចឆ្លើយ ឬ មិនទាន់បានឆ្លើយក្នុងជំពូកទី៣។

២. មេរៀននេះគឺជាមេរៀនមួយដែលយើងនឹងធ្វើការពិភាក្សាបន្តពីមេរៀនទី៣ជំពូកទី១ និងមេរៀនទី ១ ជំពូកទី ៣។ រំលឹកសិក្ខាកាមឱ្យមើលអ្វីដែលគេបានកត់ត្រាពីការពិភាក្សារបស់យើងកន្លងមកស្តីពីអង្គការសង្គមស៊ីវិល។

៣. មានឧទាហរណ៍ខ្លះដើម្បីជំរាបជូនអ្នកចូលរួមនៅពេលដែលអ្នកសម្របសម្រួលបង្ហាញសកម្មភាពចំបងៗទាំង៥នៃការភ្ជាប់ទំនាក់ទំនងជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិ។

៤. មេរៀនសង្កត់ធ្ងន់លើការងារជាក្រុម។ អ្នកសម្របសម្រួលត្រូវផ្តល់ការណែនាំឱ្យបានច្បាស់លាស់មុនពេលបំបែកក្រុមពិភាក្សា។ *ការគ្រប់គ្រងពេលវេលា និងមានឥទ្ធិពលទៅលើភាពជោគជ័យនៃសកម្មភាពនេះ។*

៥. អ្នកសម្របសម្រួលជម្រាបដល់អ្នកចូលរួមថា ការអនុវត្តជាក់ស្តែងលើគំរូទម្រង់សកម្មភាពចំបងៗនេះ នឹងមានប្រយោជន៍សម្រាប់ការងាររបស់ពួកគេនៅថ្ងៃខាងមុខ។

## ជំពូកទី ៣ : មេរៀនទី ២

# ការចូលរួមរបស់អង្គការសង្គមស៊ីវិល ក្នុងការភ្ជាប់ទំនាក់ទំនងជាមួយក្រុមប្រឹក្សាថ្នាក់ក្រោមជាតិ

## មាតិកា

១. គោលបំណងមេរៀន

២. អត្ថន័យការភ្ជាប់ទំនាក់ទំនង

៣. គំរូទម្រង់សកម្មភាពចំបងៗនៃការភ្ជាប់ទំនាក់ទំនង

៤. គោលការណ៍ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានាដែលផ្តល់ឱកាសដល់សង្គមស៊ីវិលក្នុងការភ្ជាប់ទំនាក់ទំនងជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិ

- ការចូលរួមក្នុងការរៀបចំផែនការ និងថវិកាជាមួយក្រុមប្រឹក្សា
- ការចូលរួមក្នុងកិច្ចប្រជុំសាធារណៈ
- ការផ្សព្វផ្សាយព័ត៌មាន
- ចូលរួមតាមដានការអនុវត្តការងាររបស់ក្រុមប្រឹក្សា
- ការផ្តល់ព័ត៌មានត្រឡប់ផ្នែកគោលនយោបាយ
- ការកសាងសមត្ថភាព

២

## ១_គោលបំណង

១. ពិពណ៌នាសកម្មភាពអាទិភាពសម្រាប់ការភ្ជាប់ទំនាក់ទំនង

២. កំនត់បានពីវិធីសាស្ត្រក្នុងការអនុវត្តសកម្មភាពសម្រាប់ការភ្ជាប់ទំនាក់ទំនងជាមួយក្រុមប្រឹក្សាថ្នាក់ក្រោមជាតិក្នុងការអនុវត្តកម្មវិធីជាតិ

៣. កំនត់បានពីវិធីសាស្ត្រដើម្បីលើកទឹកចិត្តក្រុមមិនសូវមានតំណាងឱ្យមានសម្លេងនៅក្នុងកិច្ចការមូលដ្ឋាន និងកិច្ចការនៅថ្នាក់ក្រោមជាតិ។

៣

## ២_អត្ថន័យនៃការភ្ជាប់ទំនាក់ទំនង

### តើការភ្ជាប់ទំនាក់ទំនងអភិបាលកិច្ចមានន័យដូចម្តេច?

- ការភ្ជាប់ទំនាក់ទំនងអភិបាលកិច្ច គឺជាយន្តការសម្រាប់ភ្ជាប់សម្លេងរបស់ប្រជាពលរដ្ឋ និង សេចក្តីសម្រេចចិត្តទៅក្នុងគោលនយោបាយសាធារណៈ និងកម្មវិធីនានារបស់រដ្ឋាភិបាល ហើយត្រូវធានាថាយន្តការនេះ មានឥទ្ធិពលទៅលើការអនុវត្ត។

*Civic engagement in public policy, United Nations New York, 2007*
email: bertucci@un.org

៤

## ២_អត្ថន័យនៃការភ្ជាប់ទំនាក់ទំនង "គ"

### តើការភ្ជាប់ទំនាក់ទំនងសហគមន៍មានន័យដូចម្តេច?

ការភ្ជាប់ទំនាក់ទំនងសហគមន៍ គឺជាមុខងាររបស់រដ្ឋាភិបាល ក្នុងការទំនាក់ទំនងជាមួយប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធនៅក្នុងការបង្កើតការអនុវត្តគោលនយោបាយ កម្មវិធី និង ការផ្តល់សេវាកម្មនានាប្រកបដោយប្រសិទ្ធភាព មានគុណភាព និងធានាឱ្យមានយន្តការផ្តល់ព័ត៌មានត្រឡប់របស់ប្រជាពលរដ្ឋ។

*Civic engagement in public policy, United Nations New York, 2007*
email: bertucci@un.org

៥

## ៣_គំរូទម្រង់សកម្មភាពចំបងៗ

### សកម្មភាពចំបងទី១
### ចូលរួមក្នុងការរៀបចំផែនការ និងថវិកា

ក. កំណត់សកម្មភាពដែលបានអនុវត្តកន្លងមក

ខ. គោលបំណង

គ. តើអង្គការសង្គមស៊ីវិលអាចធ្វើអ្វីខ្លះដើម្បីលើកកម្ពស់ការចូលរួមរបស់ក្រុមមិនសូវមានតំណាងក្នុងការធ្វើផែនការ និងថវិកាជាមួយក្រុមប្រឹក្សាថ្នាក់ក្រោមជាតិ?

ឃ. តើអង្គការសង្គមស៊ីវិលអាចធ្វើអ្វីខ្លះដើម្បីចូលរួមកសាងសមត្ថភាពរបស់ក្រុមប្រឹក្សាថ្នាក់ក្រោមជាតិក្នុងការរៀបចំផែនការ និងថវិកា?

ង. តើមានអនុសាសន៍អ្វីខ្លះ ដើម្បីធ្វើឱ្យប្រសើរឡើងក្នុងការភ្ជាប់ទំនាក់ទំនងជាមួយក្រុមប្រឹក្សាថ្នាក់ក្រោមជាតិក្នុងការរៀបចំផែនការ និងថវិកា?

៦

***សូមមើលឯកសារដែលបានចែកជូន***

ជំពូកទី៣

# ៤. គោលការណ៍ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត ដែលផ្តល់ឱកាសដល់អង្គការសង្គមស៊ីវិលក្នុងការភ្ជាប់ទំនាក់ទំនងជាមួយក្រុមប្រឹក្សាថ្នាក់ក្រោមជាតិ

៧

## សកម្មភាពចំបងៗនៃការភ្ជាប់ទំនាក់ទំនង

- ការរៀបចំផែនការ និងថវិកា
- ការចូលរួមក្នុងកិច្ចប្រជុំសាធារណៈ
- ការផ្សព្វផ្សាយព័ត៌មាន
- ការតាមដានការអនុវត្តការងាររបស់ក្រុមប្រឹក្សា និង
- ការផ្តល់ព័ត៌មានត្រឡប់ផ្នែកគោលនយោបាយ
- ការកសាងសមត្ថភាព

៨

## គោលការណ៍តម្រង់ទិស

- ជំរុញឱ្យមានការកសាងសមត្ថភាពស្ថាប័ន និងធានាឱ្យមានការផ្លាស់ប្តូរ អាកប្បកិរិយា និងឥរិយាបទនៃការបំពេញការងារ ដើម្បីឱ្យរចនាសម្ព័ន្ធរដ្ឋបាលថ្មីប្រតិបត្តិ និងសម្រេចបាននូវលទ្ធផលតាមការរំពឹងទុក។
- ធានាថារាល់តម្រូវការជាបន្ទាន់របស់ប្រជាពលរដ្ឋត្រូវបានដោះស្រាយ។

៩

## គោលការណ៍តម្រង់ទិស "ត"

- ធានាថាប្រជាពលរដ្ឋជាពិសេសក្រុមជនងាយគ្រោះ ដូចជាស្ត្រី កុមារ និងជនជាតិដើមភាគតិចជាដើម មានសិទ្ធិចូលរួមនៅក្នុងដំណើរការនៃការធ្វើសេចក្តីសម្រេចនៅរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ ។ *(កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ទំព័រទី១៣)*

១០

ជំពូកទី៣

## គោលការណ៍តម្រង់ទិស "គ"

**កម្មវិធីជាតិ - សមាសធាតុកម្មវិធីទី១: ខ្សែគណនេយ្យភាពទី៤ (ទំព័រទី ២៤)**

គណនេយ្យភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិចំពោះប្រជាពលរដ្ឋ នឹងបង្ហាញឱ្យឃើញតាមរយៈ (១) ការអង្កេតពីការពេញចិត្តរបស់ប្រជាពលរដ្ឋចំពោះសេវាសាធារណៈនានា (២) ការប្រើប្រាស់ព័ត៌មានវិទ្យា ដើម្បីជួយឱ្យប្រជាពលរដ្ឋអាចទទួលបាននូវព័ត៌មាន និងសេវាសាធារណៈនានា (៣) គោលការណ៍ណែនាំ សេចក្ដីណែនាំ និងឧបករណ៍នានាសម្រាប់ការចូលរួម ការទទួលបានព័ត៌មាន និងការពិគ្រោះយោបល់របស់ប្រជាពលរដ្ឋ (៤) ការបង្កើតកម្មវិធី និងយន្តការសម្រាប់លើកកម្ពស់ការចូលរួមរបស់ប្រជាពលរដ្ឋ។

១១

## ការរៀបចំផែនការ និងថវិកា

**ច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ**

ក្រុមប្រឹក្សាត្រូវមានគណនេយ្យភាពដោយផ្ទាល់ចំពោះប្រជាពលរដ្ឋទាំងអស់អំពី ជម្រើសជាអាទិភាពដើម្បីធ្វើសេចក្ដីសម្រេចធានាបានការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ *មាត្រា៣៤(ទំព័រទី៨)*

**កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ:**

**២.២ការប្ដេជ្ញាចិត្តខាងនយោបាយ...ចំនុចទី៣:**

ធានាឱ្យមានការចូលរួមពីប្រជាពលរដ្ឋ ក្នុងដំណើរការធ្វើសេចក្ដីសម្រេចរបស់ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិ និងការតាមដាននិងវាយតម្លៃទៅលើការអនុវត្តការងាររបស់ក្រុមប្រឹក្សាជាប់ឆ្នោតនិងមន្ត្រីរបស់ក្រុមប្រឹក្សា ព្រមទាំងគណៈអភិបាល ដើម្បីធានាថាក្រុមប្រឹក្សា និងមន្ត្រីទាំងនោះមានការឆ្លើយតប និងមានគណនេយ្យភាពចំពោះប្រជាពលរដ្ឋ។ *(ទំព័រទី១៨)*

**លទ្ធផលរំពឹងទុក ១.៣ -គោលបំណងទី១:** រៀបចំនិងដាក់ឱ្យអនុវត្តកម្មវិធីនានាដើម្បីលើកកម្ពស់ការចូលរួមរបស់ប្រជាពលរដ្ឋ និងការការពារសិទ្ធិរបស់ប្រជាពលរដ្ឋ។ *(ទំព័រទី៥៣)*

១២

# ចូលរួមប្រជុំសាធារណៈ

**ច្បាប់រៀបចំអង្គការៈ មាត្រា ៣៨**

ក្នុងការរៀបចំ និងការអនុវត្តផែនការអភិវឌ្ឍក្រុមប្រឹក្សាត្រូវពិគ្រោះយោបល់ជាមួយ :

- ប្រជាពលរដ្ឋនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
- ប្រភេទក្រុមប្រឹក្សាផ្សេងទៀតនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
- ក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធនានារបស់រាជរដ្ឋាភិបាល
- អ្នកពាក់ព័ន្ធនានា។

**អនុក្រឹត្យស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា.....មាត្រា៩**

វេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់នេះ ត្រូវចូលរួមដោយសមាជិកក្រុមប្រឹក្សាខេត្ត គណៈអភិបាលខេត្ត សមាជិកក្រុមប្រឹក្សាក្រុង គណៈអភិបាលក្រុង សមាជិកក្រុមប្រឹក្សាស្រុក គណៈអភិបាលស្រុក សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងខេត្ត តំណាងសហគមន៍ប្រជាពលរដ្ឋ ឬ/និងអ្នកពាក់ព័ន្ធដទៃទៀតតាមការសម្រេចពីក្រុមប្រឹក្សាខេត្ត។

១៣

# ការផ្សព្វផ្សាយព័ត៌មាន

**<u>ច្បាប់រៀបចំអង្គការ មាត្រា៥២</u>**: ក្រុមប្រឹក្សានីមួយៗត្រូវមានក្តារព័ត៌មានជាសាធារណៈ ឬមធ្យោបាយផ្សព្វផ្សាយព័ត៌មានផ្សេងទៀតនៅការិយាល័យកណ្តាលរបស់ខ្លួន និងនៅតាមទីកន្លែងនានាក្នុងដែនសមត្ថកិច្ចរបស់ខ្លួនតាមការចាំបាច់ ហើយទីកន្លែងទាំងនោះមានភាពងាយស្រួលសម្រាប់ប្រជាពលរដ្ឋទទួលបានព័ត៌មានជាសាធារណៈទាំងនោះ។

**<u>អនុក្រឹត្យស្តីពីតួនាទី ភារកិច្ច....មាត្រា៥៤</u>**: ក្រៅពីរៀបចំឱ្យមានក្តារព័ត៌មានសាធារណៈ ក្រុមប្រឹក្សា ខេត្ត ត្រូវស្វះស្វែងរកមធ្យោបាយផ្សព្វផ្សាយព័ត៌មានផ្សេងៗទៀត ដើម្បីជូនដំណឹងអំពីកិច្ចការនានានៃរដ្ឋបាលរបស់ខ្លួនដល់ប្រជាពលរដ្ឋ ។

១៤

## តាមដានការអនុវត្តការងាររបស់ក្រុមប្រឹក្សា

**ច្បាប់រៀបចំអង្គការ  មាត្រា ៤០ (ទំព័រទី ១១)**

ក្រុមប្រឹក្សាត្រូវតាមដាន និងវាយតម្លៃជាទៀងរាល់ឆ្នាំ ទៅលើការអនុវត្តផែនការអភិវឌ្ឍរបស់ខ្លួន ដោយរាប់ទាំងផ្នែកនៃផែនការអភិវឌ្ឍដែលស្ថិតនៅក្រោមការគ្រប់គ្រង និងការត្រួតពិនិត្យរបស់

- ក្រុមប្រឹក្សាប្រភេទរួមគ្នា
- ប្រភេទក្រុមប្រឹក្សាផ្សេងៗទៀត
- ក្រសួង ស្ថាប័ន អង្គភាពនានារបស់រាជរដ្ឋាភិបាល
- អ្នកពាក់ព័ន្ធនានា។

**កម្មវិធីជាតិ សមាសធាតុកម្មវិធីទី៣ (ទំព័រទី ៦៣)** ការលើកកម្ពស់សេវាសាធារណៈ គឺជាដំណើរការដែលមានលក្ខណៈពីក្រោមឡើងលើ ដូច្នេះត្រូវរៀបចំយន្តការ គណនេយ្យភាពនានា ដែលមានភាពរឹងមាំ ដើម្បីធានាថាក្រុមប្រឹក្សាឃុំ សង្កាត់ ប្រជាពលរដ្ឋ និងសង្គមស៊ីវិលអាចប្រើប្រាស់យន្តការទាំងនេះក្នុងការលើកកម្ពស់ប្រសិទ្ធភាពនៃការផ្តល់សេវាទាំងនេះ។

១៥

## ការផ្តល់ព័ត៌មានត្រឡប់ផ្នែកគោលនយោបាយ

**<u>កម្មវិធីជាតិ សមាសធាតុកម្មវិធីទី៥</u>** ***(ទំព័រទី ៩៦)***

សម្ព័ន្ធភាពជាតិសមាគមក្រុមប្រឹក្សាឃុំ សង្កាត់ និងសមាគមក្រុមប្រឹក្សាឃុំ សង្កាត់ប្រចាំរាជធានី ខេត្ត ព្រមទាំង សមាគមក្រុមប្រឹក្សាតាមប្រភេទផ្សេងទៀត គឺជាសំឡេងមួយដ៏សំខាន់របស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងចាំបាច់ត្រូវទទួលបាននូវការគាំទ្រនានាក្នុងគោលបំណងលើកកម្ពស់ផលប្រយោជន៍រួមរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ការពង្រឹងស្វ័យភាព និងការចូលរួមរបស់រដ្ឋបាលទាំងនេះ នៅក្នុងការរៀបចំគោលនយោបាយនានារបស់រាជរដ្ឋាភិបាល ព្រមទាំងការកំណត់ និងការលើកឡើងនូវសេចក្តីត្រូវការផ្នែកកសាងសមត្ថភាពរបស់ខ្លួន។

១៦

# ការកសាងសមត្ថភាព

ការកសាងសមត្ថភាពរដ្ឋបាលថ្នាក់ក្រោមជាតិ និងស្ថាប័នដទៃទៀតត្រូវយកចិត្តទុកដាក់ជាពិសេសទៅលើ

- ការកសាងក្រុមអ្នកមានវិជ្ជាជីវៈវ័យក្មេង ដែលនឹងអាចចូលរួមបម្រើការងារជាមន្ត្រីរាជការសម្រាប់មុខតំណែងនានា និងសម្រាប់បន្តវេនពីមន្ត្រីរាជការចូលនិវត្តន៍ទាំងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ និងថ្នាក់ជាតិ។
- ការធានាថា មន្ត្រីមានសមត្ថភាពគ្រប់គ្រាន់ក្នុងការអនុវត្តការទទួលខុសត្រូវរបស់ខ្លួន។
- ការធានាឱ្យមន្ត្រីរាជការដែលបំពេញការងារនៅថ្នាក់ក្រោមជាតិមានទម្លាប់ និងឥរិយាបទថ្មីជាមួយខ្សែគណនេយ្យភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិចំពោះប្រជាពលរដ្ឋរបស់ខ្លួន។

១៧

# ការកសាងសមត្ថភាព "ត"

- ការកសាងសមត្ថភាពដល់បេក្ខជនក្រុមប្រឹក្សាអាណត្តិបន្ទាប់ ។
- ប្រជាពលរដ្ឋដែលមានការចាប់អារម្មណ៍នៅក្នុងកិច្ចដំណើរការអភិបាលកិច្ចនិងអភិវឌ្ឍន៍មូលដ្ឋានឬក្រុមប្រឹក្សាដែលទើបជាប់ឆ្នោតថ្មីនៅរដ្ឋបាលក្រោមជាតិ.... ។

***កម្មវិធីកសាងសមត្ថភាពរបស់ក្រសួង ស្ថាប័ន នឹងមិនអាចបំពេញនូវតម្រូវការនៃការកសាងសមត្ថភាពដ៏ធំធេងនេះបានទេ ដូច្នេះចាំបាច់ត្រូវសហការជាមួយអង្គការសង្គមស៊ីវិល និងស្ថាប័នបណ្តុះបណ្តាលឯកជននានា ។ (កម្មវិធីជាតិ ទំព័រ ៩៥)***

១៨

## តើអង្គការសង្គមស៊ីវិលអាចធ្វើអ្វីបន្ថែមទៀត ដើម្បីពង្រឹងការភ្ជាប់ទំនាក់ទំនាក់ជាមួយក្រុមប្រឹក្សាថ្នាក់ក្រោមជាតិ

- ពង្រឹងបណ្ដាញការងាររបស់អង្គការសង្គមស៊ីវិល រៀបចំកម្មវិធីការងាររបស់ខ្លួនឱ្យបានច្បាស់លាស់ និងបន្សុីកម្មវិធីការងារជាមួយកម្មវិធីការងាររបស់ក្រុមប្រឹក្សាថ្នាក់ក្រោមជាតិ។
- បង្កើនភាពជាដៃគូជាមួយក្រុមប្រឹក្សាថ្នាក់ក្រោមជាតិក្នុងដំណើរការរៀបចំផែនការ និងថវិកា ការសិក្សាលទ្ធភាពគម្រោង ការអនុវត្តគម្រោង ការតាមដានត្រួតពិនិត្យគម្រោង និងធានាដំណើរការនេះស្របតាមគោលការណ៍ណែនាំ។

១៩

## តើអង្គការសង្គមស៊ីវិលអាចធ្វើអ្វីបន្ថែមទៀត ដើម្បីពង្រឹងការភ្ជាប់ទំនាក់ទំនាក់ជាមួយក្រុមប្រឹក្សាថ្នាក់ក្រោមជាតិ "ត"

- បន្តជំរុញលើកទឹកចិត្តប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធចូលរួមយ៉ាងសកម្មក្នុងដំណើរការរៀបចំផែនការ និងថវិកាជាមួយក្រុមប្រឹក្សាថ្នាក់ក្រោមជាតិ។
- បង្កើនការពិភាក្សាជាមួយក្រុមប្រឹក្សាថ្នាក់ក្រោមជាតិដើម្បីរៀបចំយន្តការក្នុងការផ្សព្វផ្សាយព័ត៌មានឱ្យបានទូលំទូលាយដល់ប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធផ្សេងៗ និងផ្ដល់ព័ត៌មានត្រឡប់ដល់ក្រុមប្រឹក្សា។
- គាំទ្រ និងចូលរួមក្នុងការពិគ្រោះយោបល់ ការប្រជុំកសាងកម្មវិធីអភិវឌ្ឍ និងកសាងកម្មវិធីវិនិយោគរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ និងសង្កាត់។

២០

# សំណួរសម្រាប់ក្រុមពិភាក្សា

អានសន្លឹកកិច្ចការដែលបានចែកជូន បន្ទាប់មកកំនត់ថាតើសកម្មភាពអ្វីខ្លះ ដែលបានអនុវត្តរួចហើយ។ បន្ទាប់មកឆ្លើយនិងសំនួរបីខាងក្រោម

១. តើសង្គមស៊ីវិលអាចធ្វើអ្វីខ្លះដើម្បីលើកទឹកចិត្តក្រុមដែលមិនសូវមានតំណាងឱ្យមានសម្លេង នៅក្នុងកិច្ចការមូលដ្ឋាន និងនៅថ្នាក់ក្រោមជាតិ?

២. តើអង្គការសង្គមសីវិលអាចរួមចំណែកអ្វីខ្លះដល់ការកសាងសមត្ថភាពរបស់ក្រុមប្រឹក្សាថ្នាក់ក្រោមជាតិ ?
*(យោងលើសកម្មភាពចំបង៧ទាំងប្រាំដែលបានបង្ហាញ)*

៣. តើអ្នកមានអនុសាសន៍អ្វីខ្លះដើម្បីធ្វើឱ្យប្រសើរឡើង/ ពង្រឹងដល់ការភ្ជាប់ជាមួយក្រុមប្រឹក្សានៅថ្នាក់ក្រោមជាតិ? (*ផ្តោតជារួម*)

២១

ជំពូកទី៣

## ឯកសារចែក

## មេរៀនទី២

## ការចូលរួមរបស់អង្គការសង្គមស៊ីវិលក្នុងការភ្ជាប់ទំនាក់ទំនងជាមួយក្រុមប្រឹក្សាថ្នាក់ក្រោមជាតិ



## សកម្មភាពចំបងទី១

## ចូលរួមក្នុងការរៀបចំផែនការ និងថវិកា

### ក. គោលបំណង

- ដើម្បីបង្កើនការពាក់ព័ន្ធរបស់អង្គការសង្គមស៊ីវិលនៅក្នុងដំណើរការរៀបចំផែនការ និងថវិការបស់ក្រុមប្រឹក្សា
- ដើម្បីកំនត់សកម្មភាពចំបងៗនៃការភ្ជាប់ទំនាក់ទំនង និងបញ្ចូលទៅក្នុងប្រតិបត្តិការអង្គការរបស់ខ្លួន។

* នេះគឺផ្តោតទៅលើការភ្ជាប់ទំនាក់ទំនងដែលគាំទ្រដោយគោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្ត។

*** ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ :**

- ផែនការហិរញ្ញវត្ថុ ដោយត្រូវរាប់បញ្ចូលទាំងផែនការអភិវឌ្ឍមូលធន ការគ្រោងថវិកា សម្រាប់រយៈពេលដប់ពីរខែ(១២)ខែ ចាប់ពីពេលរៀបចំផែនការ និងសម្រាប់រយៈពេលបី(៣)ឆ្នាំចាប់ពីពេលរៀបចំផែនការហើយត្រូវធ្វើបច្ចុប្បន្នភាពជារៀងរាល់ឆ្នាំ។ *មាត្រា៣៩ (ទំព័រទី ១០)*

⬇

*** អនុក្រឹត្យស្តីពី តួនាទី ភារកិច្ច និងទំនាក់ទំនងរបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត....**

- ផែនការអភិវឌ្ឍរយៈពេលប្រាំ (០៥)ឆ្នាំ និងកម្មវិធីវិនិយោគបី (០៣) ឆ្នាំរំកិលប្រចាំឆ្នាំ រួមទាំងសមាសភាគនៃផែនការដែលស្ថិតក្រោមការគ្រប់គ្រង និងការត្រួតពិនិត្យរបស់ក្រុមប្រឹក្សាប្រភេទរួមគ្នា ប្រភេទក្រុមប្រឹក្សាផ្សេងៗគ្នា ក្រសួង ស្ថាប័ន ឬ មន្ទីរ អង្គភាពរបស់រាជរដ្ឋាភិបាល និងដៃគូពាក់ព័ន្ធនានា។ *(មាត្រា១៤ ទំព័រទី៥)*

⬇

*** កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ**

២.២ ការប្តេជ្ញាចិត្តខាងនយោបាយរបស់រាជរដ្ឋាភិបាល : ធានាឱ្យមានការចូលរួមពីប្រជាពលរដ្ឋក្នុងដំណើរការធ្វើសេចក្តីសម្រេចរបស់ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិ និងការតាមដាន និងវាយតម្លៃទៅលើការអនុវត្តការងាររបស់ក្រុមប្រឹក្សាជាប់ឆ្នោត និងមន្ត្រីរបស់ក្រុមប្រឹក្សា ព្រមទាំងគណៈអភិបាល ដើម្បីធានាថាក្រុមប្រឹក្សា និងមន្ត្រីទាំងនោះមានការឆ្លើយតប និងមានគណនេយ្យភាពចំពោះប្រជាពលរដ្ឋ។ *ចំនុចទី៣ (ទំព័រទី១២)*

### ខ. កន្លែងណា/ពេលណាដែលអង្គការសង្គមស៊ីវិលអាចចូលរួមក្នុងការរៀបចំផែនការ និងថវិកា?

- តំណាងប្រជាពលរដ្ឋ អង្គការមិនមែនរដ្ឋាភិបាល និង អង្គការសហគមន៍មូលដ្ឋានត្រូវបានអញ្ជើញឱ្យចូលរួមនៅក្នុងដំណើរការរៀបចំផែនការអភិវឌ្ឍទាំងថ្នាក់ខេត្ត ស្រុក និងឃុំ សង្កាត់ និងនៅក្នុងដំណើរការកសាងកម្មវិធីវិនិយោគបីឆ្នាំ ប្រចាំឆ្នាំផងដែរ។
- ការប្រជុំពិគ្រោះយោបល់សាធារណៈ។ *ឧទាហរណ៍ : គណៈកម្មការគៀរគរសហគមន៍ (កម្មវិធីល្អ) ជួយសម្របសម្រួលអញ្ជើញប្រជាពលរដ្ឋចូលរួមក្នុងការប្រជុំពិគ្រោះយោបល់នៅថ្នាក់ភូមិ និងការប្រជុំធ្វើផែនការ និងថវិកានៅសាលាឃុំ សង្កាត់។*

### គ. តើអង្គការសង្គមស៊ីវិលអាចធ្វើអ្វីខ្លះដើម្បីចូលរួមក្នុងការរៀបចំផែនការ និងថវិកាជាមួយក្រុមប្រឹក្សា?

- ភាពជាដៃគូជាមួយក្រុមប្រឹក្សានៅថ្នាក់ក្រោមជាតិដើម្បីផ្តល់សេវាកម្មដែលមានគុណភាពដល់ប្រជាពលរដ្ឋ (ទាំងផ្នែកហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត និងហេដ្ឋារចនាសម្ព័ន្ធអរូបវ័ន្ត)
- បន្តជំរុញលើកទឹកចិត្តឱ្យមានការចូលរួមរបស់ប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធសំខាន់ៗក្នុងដំណើរការរៀបចំផែនការ និងថវិកាជាមួយក្រុមប្រឹក្សាថ្នាក់ក្រោមជាតិ គណៈកម្មការគៀរគរសហគមន៍ និងអង្គការសហគមន៍មូលដ្ឋានចូលរួមនៅក្នុងការរៀបចំផែនការ និងថវិកាជាមួយក្រុមប្រឹក្សាឃុំ សង្កាត់។
- បញ្ចូលផែនការសកម្មភាពរបស់ខ្លួនជាមួយផែនការរបស់ក្រុមប្រឹក្សាថ្នាក់ក្រោមជាតិ ដើម្បីដំណើរការគាំទ្រស្របគ្នាក្នុងការរៀបចំផែនការ និងថវិកា និងធានាថាការព្រួយបារម្ភ និងតម្រូវការរបស់ប្រជាពលរដ្ឋត្រូវបានបញ្ចូលជាមួយផែនការអភិវឌ្ឍ។

### ឃ. <u>ឯកសារយោង</u>

១) ច្បាប់រៀបចំអង្គការ មាត្រា ៣៩, ៤២, ៤៣, ៤៤, និង ៤៥ (www.ncdd.gov.kh)

២) អនុក្រឹត្យស្តីពី តួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត...
(មាត្រា១៤, ៧០ និង ១៣២) (www.ncdd.gov.kh)

៣) កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (www.ncdd.gov.kh)

៤) បទបង្ហាញរបស់កម្មវិធីល្អក្នុងកិច្ចប្រជុំក្រុមការងារភាពជាដៃគូវិមជ្ឈការ
ថ្ងៃទី២៧ សីហា ២០១០ www.pactcambodia.org

៥) ការភ្ជាប់ទំនាក់ទំនងប្រជាពលរដ្ឋនៅក្នុងគោលនយោបាយសាធារណៈ កញ្ចប់ឧបករណ៍អង្គការសហប្រជាជាតិ, ញូវយ៉ក, ២០០៧, bertucci@un.org

## សកម្មភាពចំបងទី២
# ការចូលរួមក្នុងកិច្ចប្រជុំសាធារណៈ

### ក. គោលបំណង

- ដើម្បីឱ្យសម្លេងរបស់ប្រជាពលរដ្ឋ និងរបស់សង្គមស៊ីវិលបានឮ និងទទួលយកដោយក្រុមប្រឹក្សាថ្នាក់ក្រោមជាតិ
- វិធានការ និងដំណោះស្រាយនានារបស់ក្រុមប្រឹក្សាថ្នាក់ក្រោមជាតិត្រូវបានពិភាក្សាដោយបើកចំហរ មានតម្លាភាព និងស្មើភាព។

* នេះគឺផ្តោតទៅលើការភ្ជាប់ទំនាក់ទំនងដែលគាំទ្រដោយគោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្ត។

* **ច្បាប់រៀបចំអង្គការ** ( មាត្រា ៣៨ )

ក្នុងការរៀបចំ និងការអនុវត្តផែនការអភិវឌ្ឍ ក្រុមប្រឹក្សាត្រូវពិគ្រោះយោបល់ជាមួយ:

- ប្រជាពលរដ្ឋនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
- ប្រភេទក្រុមប្រឹក្សាផ្សេងទៀតនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
- ក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធនានារបស់រាជរដ្ឋាភិបាល
- អ្នកពាក់ព័ន្ធនានា។

* ***អនុក្រឹត្យស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត...*** **( មាត្រា៩ )**

វេទិកាផ្សព្វផ្សាយនឹងពិគ្រោះយោបល់នេះត្រូវចូលរួមដោយសមាជិកក្រុមប្រឹក្សាខេត្ត គណៈអភិបាលខេត្ត សមាជិកក្រុមប្រឹក្សាក្រុង គណៈអភិបាលក្រុង សមាជិកក្រុមប្រឹក្សាស្រុក គណៈអភិបាលស្រុក សមាជិកក្រុមប្រឹក្សាឃុំ សមាជិកក្រុមប្រឹក្សាសង្កាត់ក្នុងខេត្ត តំណាងសហគមន៍ប្រជាពលរដ្ឋ ឬ/និងអ្នកពាក់ព័ន្ធដទៃទៀត តាមការសម្រេចពីក្រុមប្រឹក្សាខេត្ត។

* **កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ**

***សមាសធាតុកម្មវិធីទី ៣ — ៩.៣ :*** ជាងនេះទៀត គណនេយ្យភាពចំពោះប្រជាពលរដ្ឋអាចលើកកម្ពស់តាមរយៈវេទិកាពិគ្រោះយោបល់និងផ្សព្វផ្សាយជាសាធារណៈ និងការទទួលបានជាសាធារណៈនូវព័ត៌មានអំពីការបំពេញមុខងារ និងការផ្តល់សេវាសាធារណៈរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងតាមរយៈការសាកល្បងអំពីវិធីសាស្ត្រផ្សេងៗក្នុងការលើកកម្ពស់គណនេយ្យភាព និងការតាមដានទៅលើប្រសិទ្ធភាពនៃការអនុវត្តវិធីសាស្ត្រទាំងនេះ។ *(ទំព័រទី២៥)*

***សមាសធាតុកម្មវិធីទី ៤ :*** គណនេយ្យភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិចំពោះប្រជាពលរដ្ឋ និងស្តែងឡើងតាមរយៈ ការរៀបចំ ការសម្រេច និងការអនុវត្តថវិកា និងតាមរយៈវេទិកាពិគ្រោះយោបល់ និងផ្សព្វផ្សាយជាសាធារណៈពាក់ព័ន្ធនឹងកិច្ចការថវិកា ការវិនិយោគ និង ការអភិវឌ្ឍនានា ព្រមទាំងតាមរយៈការអនុវត្តសាកល្បងនូវយន្តការនានាដែលពាក់ព័ន្ធនឹងសវនកម្ម សង្គមកិច្ច និងការផ្តល់លទ្ធភាពឱ្យប្រជាពលរដ្ឋ ឬ ក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងការចូលរួមផ្តល់យោបល់លើគម្រោងថវិកានានារបស់រដ្ឋបាលថ្នាក់ក្រោមជាតិប្រភេទផ្សេងទៀត។ *(ទំព័រទី២៥)*

## ខ. កន្លែងណា/ពេលណាសម្រាប់អង្គការសង្គមស៊ីវិលចូលរួមក្នុងកិច្ចប្រជុំសាធារណៈរបស់ក្រុមប្រឹក្សា?

- កិច្ចប្រជុំប្រចាំខែ ឬ ប្រចាំត្រីមាសរបស់ក្រុមប្រឹក្សាថ្នាក់ក្រោមជាតិ។
- វេទិកាសាធារណៈរបស់ក្រុមប្រឹក្សាថ្នាក់ក្រោមជាតិ *(បទពិសោធន៍កម្មវិធីល្អ - វេទិកាសាធារណៈថ្នាក់ឃុំ)*។
- កិច្ចប្រជុំពិគ្រោះយោបល់ជាសាធារណៈនៅថ្នាក់ឃុំ សង្កាត់ ស្រុក និង ថ្នាក់ខេត្ត ។
- ការពិភាក្សាសាធារណៈជាទៀងទាត់ជាមួយក្រុមប្រឹក្សាថ្នាក់ក្រោមជាតិ ។

## គ. តើអង្គការសង្គមស៊ីវិលអាចធ្វើអ្វីខ្លះដើម្បីចូលរួមក្នុងកិច្ចប្រជុំជាសាធារណៈ?

- ធ្វើការចរចារ និងទទួលយកផែនការសកម្មភាពដើម្បីភ្ជាប់ទំនាក់ទំនងជាមួយក្រុមប្រឹក្សាថ្នាក់ក្រោមជាតិ

- រៀបចំបង្កើត និងបង្ហាញការអនុវត្តគម្រោងដែលសមស្របជាមួយកម្មវិធីថ្នាក់ក្រោមជាតិ។
- ការរៀបចំផែនការសកម្មភាពនិងការព្រមព្រៀងទៅលើការអនុវត្តដោយមានការចូលរួមពេញលេញរបស់អ្នកពាក់ព័ន្ធទាំងអស់។

## ឃ. ឯកសារយោង

១) ច្បាប់រៀបចំអង្គការ - មាត្រា ១២, ៣៨ (www.ncdd.gov.kh)
២) អនុក្រឹត្យស្តីពី តួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត... (មាត្រា៩ និង ៥៨-១) (www.ncdd.gov.kh)
៣) កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ, ទំព័រទី២៥ (www.ncdd.gov.kh)
៤) បទបង្ហាញរបស់កម្មវិធីល្អក្នុងកិច្ចប្រជុំក្រុមការងារភាពជាដៃគូវិមជ្ឈការ, ថ្ងៃទី២៧ សីហា ២០១០ www.pactcambodia.org
៥) ការភ្ជាប់ទំនាក់ទំនងប្រជាពលរដ្ឋនៅក្នុងគោលនយោបាយសាធារណៈ កញ្ចប់ឧបករណ៍អង្គការសហប្រជាជាតិ, ញូវយ៉ក, ២០០៧, bertucci@un.org

ជំពូកទី៣

## សកម្មភាពចំបងទី៣

# ការចូលរួមក្នុងការផ្សព្វផ្សាយព័ត៌មាន

### ក. គោលបំណង

- ដើម្បីផ្តល់ព័ត៌មានគ្រប់គ្រាន់ដល់ប្រជាពលរដ្ឋ ស្តីពីការអនុវត្តកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។
- ដើម្បីពង្រីកកិច្ចសហការរវាងអង្គការសង្គមស៊ីវិលជាមួយក្រុមប្រឹក្សាថ្នាក់ក្រោមជាតិក្នុងការផ្សព្វផ្សាយពីការអនុវត្តកម្មវិធីដល់ប្រជាពលរដ្ឋ។

* នេះគឺផ្តោតទៅលើការភ្ជាប់ទំនាក់ទំនងដែលគាំទ្រដោយគោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្ត

***ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ - មាត្រា ៥២ (ទំព័រទី១៦)**

ក្រុមប្រឹក្សានីមួយៗត្រូវមានក្តារព័ត៌មានជាសាធារណៈ ឬ មធ្យោបាយផ្សព្វផ្សាយព័ត៌មានផ្សេងទៀតនៅការិយាល័យកណ្តាលរបស់ខ្លួន និងនៅតាមទីកន្លែងនានាក្នុងដែនសមត្ថកិច្ចរបស់ខ្លួនតាមការចាំបាច់ ហើយទីកន្លែងទាំងនោះមានភាពងាយស្រួលសម្រាប់ប្រជាពលរដ្ឋទទួលបានព័ត៌មានជាសាធារណៈទាំងនោះ។

*** អនុក្រឹត្យស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត... (មាត្រា៥៤ )**

- រដ្ឋបាលខេត្តត្រូវរៀបចំឱ្យមានក្តារព័ត៌មានសាធារណៈនៅមុខសាលាខេត្ត ដែលសាធារណៈជនអាចពិនិត្យមើលបានដោយងាយស្រួល។
- ក្រៅពីការរៀបចំឱ្យមានក្តារព័ត៌មានសាធារណៈក្រុមប្រឹក្សាខេត្តត្រូវស្វះស្វែងរកមធ្យោបាយផ្សព្វផ្សាយព័ត៌មានផ្សេងៗទៀត ដើម្បីជូនដំណឹងអំពីកិច្ចការនានានៃរដ្ឋបាលរបស់ខ្លួនដល់ប្រជាពលរដ្ឋ។ (ទំព័រទី១៩)

***កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ៤.១.៥ (ទំព័រទី៦៥)**

លេខាធិការដ្ឋាន គ.ជ.អ.ប ត្រូវធានាថារាល់ឯកសារពាក់ព័ន្ធនឹងការអនុវត្តកម្មវិធីជាតិរួមមាន

របាយការណ៍រីកចម្រើន ផែនការសកម្មភាព ថវិកា ការពិនិត្យឡើងវិញនូវផ្នែកបច្ចេកទេស និង ការសិក្សានានា ត្រូវបានរៀបចំឡើង និងដាក់ឱ្យមានការពិភាក្សា ដោយមានការចូលរួមនិងមានតម្លាភាពតាមរយៈកិច្ចប្រជុំរបស់អនុគណៈកម្មាធិការនានានៃ គ.ជ.អ.ប និង សិក្ខាសាលានានា។

* **បទពិសោធន៍ពីកម្មវិធីល្អ**

- ដើរតួរជាអន្តរការី (ជាអ្នកភ្ជាប់ទំនាក់ទំនង) រវាងប្រជាពលរដ្ឋ និងអាជ្ញាធរ (ឧ.ហ: ចែករំលែកព័ត៌មាន និងប្រមូលព័ត៌មានពីប្រជាពលរដ្ឋវិញ)។
- ការផ្លាស់ប្តូរព័ត៌មានរវាងអាជ្ញាធរនិងប្រជាពលរដ្ឋគឺមានសារសំខាន់ដល់ប្រសិទ្ធភាពនៃប្រព័ន្ធប្រជាធិបតេយ្យនានា។

## ខ. កន្លែងណា/ពេលណាដែលអង្គការសង្គមស៊ីវិលអាចចូលរួមក្នុងការផ្សព្វផ្សាយព័ត៌មាន?

- នៅពេលរៀបចំការប្រជុំសាធារណៈ ឬវេទិកាសាធារណៈនៅថ្នាក់ភូមិ និងថ្នាក់ឃុំ សង្កាត់។ ឧ. គណៈកម្មការកៀរគរសហគមន៍ សហការជាមួយប្រធានភូមិ ដើម្បីផ្សព្វផ្សាយព័ត៌មានដែលទទួលបានពីក្រុមប្រឹក្សាឃុំ សង្កាត់ ពិសេសព័ត៌មានដែលពាក់ព័ន្ធ និងកម្មវិធីវិនិយោគ ចំណូល និងចំណាយនានា។
- នៅពេលចូលរួមវគ្គបណ្តុះបណ្តាល សិក្ខាសាលា ឬ ការពិភាក្សាតុមូល។
- ការប្រជុំ ឬ ការពិភាក្សានៅថ្នាក់ស្រុក និងថ្នាក់ខេត្ត។

## គ. តើអង្គការសង្គមស៊ីវិលអាចធ្វើអ្វីខ្លះដើម្បីចូលរួមក្នុងការផ្សព្វផ្សាយព័ត៌មាន?

- ចូលរួមជាទៀងទាត់ក្នុងកិច្ចប្រជុំក្រុមប្រឹក្សាថ្នាក់ក្រោមជាតិបន្ទាប់មកបញ្ជូនព័ត៌មានបន្តទៅឱ្យក្រុមគោលដៅរបស់ខ្លួន. ឧ. អង្គការសហគមន៍មូលដ្ឋានជួយក្នុងការជូនដំណឹងដល់ប្រជាពលរដ្ឋពីកាលវិភាគសម្រាប់កិច្ចប្រជុំពិគ្រោះយោបល់ វេទិកាសាធារណៈ និងការប្រជុំជាសាធារណៈដែលរៀបចំឡើងដោយក្រុមប្រឹក្សាឃុំ សង្កាត់។
- ជួយបិទផ្សាយព័ត៌មានដែលទទួលបានពីក្រុមប្រឹក្សាថ្នាក់ក្រោមជាតិលើក្តារព័ត៌មាន និងលើកទឹកចិត្តប្រជាពលរដ្ឋអានព័ត៌មានទាំងនោះ។ ឧ.ហ: *គណៈកម្មការកៀរគរសហគមន៍ សហការជាមួយប្រធានភូមិ បិទព័ត៌មាន និងផ្ទាំងរូបភាពផ្សព្វផ្សាយស្តីពីវិមជ្ឈការ និង*

*វិសហមជ្ឈការ តម្លៃសម្រាប់ការធ្វើលិខិតអាត្រានុកូលដ្ឋាន និងតម្លៃសម្រាប់ចុះបញ្ជីក្បាលដីជាដើម។*

## ឃ. ឯកសារយោង

១) ច្បាប់រៀបចំអង្គការ មាត្រា ៥២ (www.ncdd.gov.kh)

២) អនុក្រឹត្យស្តីពី តួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត... (មាត្រា៥៤) (www.ncdd.gov.kh)

៣) កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ, ទំព័រទី៦៥ (www.ncdd.gov.kh)

៤) បទបង្ហាញរបស់កម្មវិធីល្អក្នុងកិច្ចប្រជុំក្រុមការងារភាពជាដៃគូវិមជ្ឈការ, www.pactcambodia.org

# សកម្មភាពចំបងទី៤
# ចូលរួមតាមដានការអនុវត្តការងាររបស់ក្រុមប្រឹក្សាថ្នាក់ក្រោមជាតិ

## ក. គោលបំណង

- ក្រុមប្រឹក្សាថ្នាក់ក្រោមជាតិទទួលយក និងចាត់វិធានការម៉ឺងម៉ាត់ដើម្បីធ្វើឱ្យប្រសើរឡើង និងពង្រឹងការអនុវត្តការងាររបស់ខ្លួន។
- បណ្តាញអង្គការសង្គមស៊ីវិលតាមដានអំពីវិធានការណ៍របស់ក្រុមប្រឹក្សាថ្នាក់ក្រោមជាតិ និងផ្តល់ព័ត៌មានត្រឡប់សម្រាប់ធ្វើការកែលំអ។

* នេះគឺផ្តោតទៅលើការភ្ជាប់ទំនាក់ទំនងដែលគាំទ្រដោយគោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្ត

* **ច្បាប់រៀបចំអង្គការ មាត្រា ៤០ (ទំព័រទី១១)**

ក្រុមប្រឹក្សាត្រូវតាមដាន និងវាយតម្លៃជាទៀងរាល់ឆ្នាំ ទៅលើការអនុវត្តផែនការអភិវឌ្ឍរបស់ខ្លួន ដោយរាប់ទាំងផ្នែកនៃផែនការអភិវឌ្ឍដែលស្ថិតនៅក្រោមការគ្រប់គ្រង និងការត្រួតពិនិត្យរបស់

- ក្រុមប្រឹក្សាប្រភេទរួមគ្នា
- ប្រភេទក្រុមប្រឹក្សាផ្សេងៗទៀត
- ក្រសួង ស្ថាប័ន អង្គភាពនានារបស់រាជរដ្ឋាភិបាល
- អ្នកពាក់ព័ន្ធនានា។

* **កម្មវិធីជាតិ — សមាសធាតុកម្មវិធីទី ៣ ទំព័រទី៦៣**

ការលើកកម្ពស់សេវាសាធារណៈ គឺជាដំណើរការដែលមានលក្ខណៈពីក្រោមឡើងលើ ដូច្នេះត្រូវរៀបចំយន្តការគណនេយ្យភាពនានា ដែលមានភាពរឹងមាំ ដើម្បីធានាថាក្រុមប្រឹក្សាឃុំ សង្កាត់ ប្រជាពលរដ្ឋ និងសង្គមស៊ីវិល អាចប្រើប្រាស់យន្តការទាំងនេះក្នុងការលើកកម្ពស់ប្រសិទ្ធភាពនៃការផ្តល់សេវាទាំងនេះ។

***កម្មវិធីជាតិ: សមាសធាតុកម្មវិធីទី ៣ ចំនុច ខ ទំព័រទី៦៥***

យន្តការ និងកម្មវិធីទាំងនេះអាចធ្វើឡើងតាមមធ្យោបាយផ្សេងៗ ដូចជា កិច្ចសហការជាមួយអង្គការសង្គមស៊ីវិល ការចុះកិច្ចសន្យាជាមួយក្រុមហ៊ុនឯកជន និងការចុះកិច្ចព្រមព្រៀងជាមួយអង្គភាពរដ្ឋបាលផ្សេងៗទៀតក្នុងការផ្តល់សេវាសាធារណៈ។ ការសម្រេចចិត្តនានាទាក់ទងនឹងបរិមាណ គុណភាព និងអាទិភាពនៃសេវាសាធារណៈត្រូវផ្អែកតាមតម្រូវការរបស់ប្រជាពលរដ្ឋតាមរយៈដំណើរការនៃការចូលរួមប្រកបដោយតម្លាភាព។

### ខ. កន្លែងណា/ពេលណាដែលអង្គការសង្គមស៊ីវិលចូលរួមតាមដានការអនុវត្តការងាររបស់ក្រុមប្រឹក្សា?

- ការវាយតម្លៃការងារអនុវត្តការងារប្រចាំឆ្នាំនៅថ្នាក់ភូមិ និងថ្នាក់ឃុំ
- កិច្ចប្រជុំផ្ទះបញ្ចាំងគម្រោង ឬកម្មវិធី ឬសិក្ខាសាលានៅថ្នាក់ឃុំ សង្កាត់ ស្រុក និងថ្នាក់ខេត្ត
- កិច្ចប្រជុំប្រចាំខែ ឬប្រចាំត្រីមាសរបស់ក្រុមការងារគណនេយ្យភាពខេត្ត
- កិច្ចប្រជុំអាណត្តិរបស់សមាគមក្រុមប្រឹក្សាឃុំ សង្កាត់ខេត្ត។

### គ. តើអង្គការសង្គមស៊ីវិលអាចធ្វើអ្វីខ្លះដើម្បីតាមដានការអនុវត្តការងាររបស់ក្រុមប្រឹក្សា?

- ពង្រឹងសមត្ថភាពក្រុមប្រឹក្សាឃុំ សង្កាត់ និងក្រុមសហគមន៍ឱ្យស្គាល់ឧបករណ៍វាយតម្លៃការអនុវត្តការងាររបស់ក្រុមប្រឹក្សាឃុំ សង្កាត់

  ( *បទពិសោធន៍របស់កម្មវិធីល្អ* www.pactcambodia.org )
- ចូលរួមតាមដានសកម្មភាពរបស់ក្រុមប្រឹក្សាថ្នាក់ក្រោមជាតិ ឬ អ្នកផ្តល់សេវា ដើម្បីធានាថាពួកគេបំពេញការងារបានល្អ
- រៀបចំបណ្តាញអង្គការសង្គមស៊ីវិលនៅថ្នាក់ឃុំ សង្កាត់ ថ្នាក់ស្រុក ថ្នាក់ខេត្ត និងថ្នាក់ជាតិដើម្បីស្វែងរកការគាំទ្រមតិពីក្រុមប្រឹក្សាថ្នាក់ជាតិ និងអ្នកផ្តល់សេវាឱ្យមានគណនេយ្យភាពចំពោះសកម្មភាព និងការសម្រេចចិត្តរបស់ខ្លួន។

## ឃ. ឯកសារយោង

១) ច្បាប់ស្តីពីការគ្រប់គ្រងរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មាត្រា ៤០ (www.ncdd.gov.kh)

២) កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ទំព័រទី ៦៣,៦៥ (www.ncdd.gov.kh)

៣) បទបង្ហាញរបស់កម្មវិធីល្អក្នុងកិច្ចប្រជុំក្រុមការងារភាពជាដៃគូវិមជ្ឈការ, www.pactcambodia.org

# សកម្មភាពចំបងទី៥
# ការផ្តល់ព័ត៌មានត្រឡប់ផ្នែកគោលនយោបាយ

## ក. គោលបំណង

- បណ្តាញការងារអង្គការមិនមែនរដ្ឋាភិបាល និងអង្គការសហគមន៍មូលដ្ឋានតាមដាន និងផ្តល់យោបល់ត្រឡប់ស្តីពីគោលនយោបាយ និងការអនុវត្តកម្មវិធីដល់ក្រុមប្រឹក្សាថ្នាក់ក្រោមជាតិ។
- ទទួលស្គាល់តួនាទីរបស់អង្គការសង្គមស៊ីវិល និងប្រជាពលរដ្ឋក្នុងការស្នើ ឬរៀបចំការពិភាក្សាអំពីគោលនយោបាយ និងការអនុវត្តកម្មវិធី។

* នេះគឺផ្តោតទៅលើការភ្ជាប់ទំនាក់ទំនងដែលគាំទ្រដោយគោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្ត

*** កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ**
**សមាសធាតុកម្មវិធីទី ៥ ចំនុច (ច): ការគាំទ្រគោលនយោបាយ**

សម្ព័ន្ធភាពជាតិសមាគមក្រុមប្រឹក្សាឃុំ សង្កាត់ និង សមាគមក្រុមប្រឹក្សាឃុំ សង្កាត់ប្រចាំរាជធានី ខេត្ត ព្រមទាំងសមាគមក្រុមប្រឹក្សាតាមប្រភេទផ្សេងទៀត គឺជាសំឡេងមួយដ៏សំខាន់របស់រដ្ឋបាលថ្នាក់ក្រោមជាតិ និង ចាំបាច់ត្រូវទទួលបាននូវការគាំទ្រនានាក្នុងគោលបំណងលើកកម្ពស់ផលប្រយោជន៍រួមរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ការពង្រឹងស្វយ័តភាពនិងការចូលរួមរបស់រដ្ឋបាលទាំងនេះនៅក្នុងការរៀបចំគោលនយោបាយនានារបស់រាជរដ្ឋាភិបាល ព្រមទាំងការកំណត់ និងការលើកឡើងនូវសេចក្តីត្រូវការផ្នែកកសាងសមត្ថភាពរបស់ខ្លួន។ *(ទំព័រទី ៩៦)*

## ខ. កន្លែងណា/ពេលណាដែលអង្គការសង្គមស៊ីវិលអាចផ្តល់ព័ត៌មានត្រឡប់ផ្នែកគោលនយោបាយ?

- កិច្ចប្រជុំពិគ្រោះយោបល់រៀបចំបង្កើតគោលនយោបាយ-ឧ.ក្រុមការងារអង្គការសង្គមស៊ីវិលចូលរួមជាទៀងទាត់ក្នុងកិច្ចប្រជុំក្រុមការងារវិមជ្ឈការ និងវិសហមជ្ឈការដែលសម្របសម្រួលដោយកម្មវិធីល្អ និងការិយាល័យទំនាក់ទំនងអង្គការមិនមែនរដ្ឋាភិបាល។

- វេទិកាសាធារណៈនៅថ្នាក់ឃុំ សង្កាត់ ស្រុក និងថ្នាក់ខេត្ត ។
- កិច្ចប្រជុំប្រចាំខែរបស់បណ្តាញអង្គការមិនមែនរដ្ឋាភិបាល ។ល។

## គ. តើអង្គការសង្គមស៊ីវិលអាចធ្វើអ្វីខ្លះដើម្បីផ្តល់ព័ត៌មានត្រឡប់ផ្នែកគោលនយោបាយដល់ក្រុមប្រឹក្សា?

- ចូលរួមកិច្ចប្រជុំពិគ្រោះយោបល់លើការរៀបចំគោលនយោបាយនៅថ្នាក់ស្រុក និងថ្នាក់ខេត្ត ឧ. កម្មវិធីល្អចូលរួមប្រជុំជាទៀងទាត់ក្នុងការរៀបចំគោលនយោបាយ និងកម្មវិធី។
- ស្វែងរកការគាំទ្រមតិ និងផ្តល់ព័ត៌មានត្រឡប់ដល់ថ្នាក់ជាតិសម្រាប់ធ្វើឱ្យប្រសើរឡើង គោលការណ៍ណែនាំ និងនិតិវិធី ជាពិសេសយន្តការសម្រាប់ការភ្ជាប់ទំនាក់ទំនង។
- លើកកម្ពស់ការពិភាក្សានៅថ្នាក់ខេត្ត / រៀបចំបណ្តាញការងារសង្គមស៊ីវិល ដើម្បីពង្រឹងសមត្ថភាព និងជំនឿចិត្តរបស់ខ្លួន (ក្រុមការងារភាពជាដៃគូវិមជ្ឈការ)។

## ឃ. ឯកសារយោង

១) កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
សមាសធាតុកម្មវិធីទី៥ ចំនុច (ច) ទំព័រទី៩៦ (www.ncdd.gov.kh)
២) បទបង្ហាញរបស់កម្មវិធីល្អក្នុងកិច្ចប្រជុំក្រុមការងារភាពជាដៃគូវិមជ្ឈការ, www.pactcambodia.org

## សកម្មភាពអានិភាព ទី១

## ការចូលរួមក្នុងការរៀបចំផែនការ និងថវិកា

ក. កំណត់សកម្មភាពដែលបានអនុវត្តរួចហើយ

ខ. គោលបំណង:

គ. តើអង្គការសង្គមស៊ីវិលអាចធ្វើអ្វីខ្លះដើម្បីលើកកម្ពស់ការចូលរួមរបស់ក្រុមមិនសូវមានតំណាងក្នុងការធ្វើផែនការ និងថវិកាជាមួយក្រុមប្រឹក្សាថ្នាក់ក្រោមជាតិ?

ឃ. តើអង្គការសង្គមស៊ីវិលអាចធ្វើអ្វីខ្លះដើម្បីកសាងសមត្ថភាពរបស់ក្រុមប្រឹក្សាថ្នាក់ក្រោមជាតិក្នុងការរៀបចំផែនការ និងថវិកា?

ង. តើមានអនុសាសន៍អ្វីខ្លះដើម្បីធ្វើឱ្យប្រសើរឡើងក្នុងការភ្ជាប់ទំនាក់ទំនងជាមួយក្រុមប្រឹក្សាថ្នាក់ក្រោមជាតិក្នុងការរៀបចំផែនការ និងថវិកា?

# សកម្មភាពអានិភាព ទី២

## ការចូលរួមក្នុងកិច្ចប្រជុំសាធារណៈ

ក. កំណត់សកម្មភាពដែលបានអនុវត្តរួចហើយ

ខ. គោលបំណង:

គ. តើអង្គការសង្គមស៊ីវិលអាចធ្វើអ្វីខ្លះដើម្បីលើកកម្ពស់ការចូលរួមរបស់ក្រុមមិនសូវមានតំណាងក្នុងកិច្ចប្រជុំសាធារណៈរបស់ក្រុមប្រឹក្សាថ្នាក់ក្រោមជាតិ?

ឃ. តើអង្គការសង្គមស៊ីវិលអាចធ្វើអ្វីខ្លះដើម្បីកសាងសមត្ថភាពរបស់ក្រុមប្រឹក្សាថ្នាក់ក្រោមជាតិក្នុងការរៀបចំកិច្ចប្រជុំសាធារណៈ?

ង. តើអ្នកមានអនុសាសន៍អ្វីខ្លះដើម្បីធ្វើឱ្យប្រសើរឡើងក្នុងការចូលរួមកិច្ចប្រជុំសាធារណៈរបស់ក្រុមប្រឹក្សាថ្នាក់ក្រោមជាតិ?

## សកម្មភាពអានិភាព ទី៣

## ការចូលរួមក្នុងការផ្សព្វផ្សាយព័ត៌មាន

ក. កំណត់សកម្មភាពដែលបានអនុវត្តរួចហើយ

ខ. គោលបំណង

គ. តើអង្គការសង្គមស៊ីវិលអាចធ្វើអ្វីខ្លះដើម្បីផ្សព្វផ្សាយព័ត៌មានអំពីកម្មវិធីជាតិដល់ក្រុមមិនសូវមានតំណាង?

ឃ. តើអង្គការសង្គមស៊ីវិលអាចធ្វើអ្វីខ្លះដើម្បីកសាងសមត្ថភាពក្រុមប្រឹក្សាថ្នាក់ក្រោមជាតិក្នុងការផ្សព្វផ្សាយព័ត៌មាន?

ង. តើមានអនុសាសន៍អ្វីខ្លះដើម្បីធ្វើឱ្យប្រសើរឡើងក្នុងការចូលរួមផ្សព្វផ្សាយព័ត៌មានអំពីកម្មវិធីជាតិ?

## សកម្មភាពអានិភាព ទី៤

## ចូលរួមតាមដានការអនុវត្តការងាររបស់ក្រុមប្រឹក្សា

ក. កំណត់សកម្មភាពដែលបានអនុវត្តរួចហើយ

ខ. គោលបំណង

គ. តើអង្គការសង្គមស៊ីវិលអាចធ្វើអ្វីខ្លះដើម្បីលើកទឹកចិត្តក្រុមមិនសូវមានតំណាង ក្នុងការតាមដានការអនុវត្តការងាររបស់ក្រុមប្រឹក្សាថ្នាក់ក្រោមជាតិ?

ឃ. តើអង្គការសង្គមស៊ីវិលអាចធ្វើអ្វីខ្លះដើម្បីតាមដានការអនុវត្តការងាររបស់ក្រុមប្រឹក្សាថ្នាក់ក្រោមជាតិ?

ង. តើអ្នកមានអនុសាសន៍អ្វីខ្លះដើម្បីពង្រឹងការតាមដានការអនុវត្តការងាររបស់ក្រុមប្រឹក្សាថ្នាក់ក្រោមជាតិ?

# សកម្មភាពអានិភាព ទី៥

## សកម្មភាពចំបងៗក្នុងការផ្តល់ព័ត៌មានត្រឡប់ផ្នែកគោលនយោបាយ

ក. កំណត់សកម្មភាពដែលបានអនុវត្តរួចហើយ

ខ. គោលបំណង

គ. តើអង្គការសង្គមស៊ីវិលអាចធ្វើអ្វីខ្លះដើម្បីធ្វើឱ្យក្រុមមិនសូវមានតំណាងអាចផ្តល់ព័ត៌មានត្រឡប់ផ្នែកគោលនយោបាយដល់ក្រុមប្រឹក្សាថ្នាក់ក្រោមជាតិ?

ឃ. តើអង្គការសង្គមស៊ីវិលអាចធ្វើអ្វីខ្លះដើម្បីកសាងសមត្ថភាពក្រុមប្រឹក្សាថ្នាក់ក្រោមជាតិក្នុងការផ្តល់ព័ត៌មានត្រឡប់ផ្នែកគោលនយោបាយដល់លេខាដ្ឋានគ.ជ.អ.ប?

ង. តើអ្នកមានអនុសាសន៍អ្វីខ្លះដើម្បីធ្វើឱ្យប្រសើរឡើងការផ្តល់ព័ត៌មានត្រឡប់ផ្នែកគោលនយោបាយទាក់ទងនឹងកម្មវិធីជាតិដល់ គ.ជ.អ.ប?

៣ មេរៀន

ប្លង់មេរៀន

## ប្លង់មេរៀនទី ២

**ចំណងជើងមេរៀន** : ការចូលរួមរបស់អង្គការសង្គមស៊ីវិលក្នុងការភ្ជាប់ទំនាក់ទំនងជាមួយក្រុមប្រឹក្សាថ្នាក់ក្រោមជាតិ

**ពេលវេលា** : ២.៣០ នាទី

**របៀបសម្របសម្រួលមេរៀន** :

| ម៉ោង | សកម្មភាព និង វិធីសាស្ត្រ | សម្ភារៈ/ឯកសារ |
|---|---|---|
| ១០ នាទី | **១. កិច្ចស្វាគមន៍** : អ្វីដែលយើងមានដូចគ្នា<br>អ្នកសម្របសម្រួល ហៅលក្ខណៈមនុស្សនៅក្នុងក្រុមដូចជា : អ្នកណាខ្លះមានកូន។ អ្នកណាដែលមានកូនរត់ទៅកន្លែងមួយដែលបានកំណត់នៅក្នុងបន្ទប់។ អ្នកសម្របសម្រួលបន្តហៅដូចជា "*អ្នកចូលចិត្តបាល់ទាត់*" អ្នកដែលចូលចិត្តបាល់ទាត់រត់ទៅរកកន្លែងដែលបានកំណត់នៅក្នុងបន្ទប់។ អ្នកសម្របសម្រួលបន្តហៅរហូតដល់សិក្ខាកាមទាំងអស់រកកន្លែងដែលត្រូវនឹងលក្ខណៈរបស់គេម្នាក់ៗ។ | |
| ១០ នាទី | **២. ការពិភាក្សាពេញអង្គ/បទបង្ហាញ**<br>ក. ការណែនាំពីមេរៀន អ្នកសម្របសម្រួលពន្យល់ថា មេរៀននេះ គឺនិយាយពីការចូលរួមរបស់សង្គមស៊ីវិលក្នុងការភ្ជាប់ទំនាក់ទំនងជាមួយក្រុមប្រឹក្សាថ្នាក់ក្រោមជាតិ ដើម្បីអនុវត្តកម្មវិធីជាតិ។ យើងនឹងផ្តោតទៅលើចំនុចសំខាន់ពីរ:<br>១) ទទួលព័ត៌មានត្រឡប់ផ្អែកលើបទពិសោធន៍របស់សិក្ខាកាម និង<br>២) លើកកម្ពស់ការយល់ដឹងអំពីឱកាសសម្រាប់ការភ្ជាប់ទំនាក់ | ☐ បទបង្ហាញទី៣ គោលបំណង |

ជំពូកទី៣

| ម៉ោង | សកម្មភាព និង វិធីសាស្ត្រ | សម្ភារៈ/ឯកសារ |
|---|---|---|
| | ទំនង។ បន្ទាប់មកអ្នកសម្របសម្រួលសួរទៅសិក្ខាកាម<br>• តើលោក-លោកស្រីណាខ្លះមានបទពិសោធន៍ក្នុងការភ្ជាប់ទំនាក់ទំនងជាមួយរដ្ឋបាលកិច្ចថ្នាក់ក្រោមជាតិ? សូមលើកដៃ។<br>• អ្នកសម្របសម្រួលកត់ត្រាចំនួនអ្នកដែលបានលើកដៃលើក្រដាសផ្ទាំងធំ។<br>ខ- ការបង្ហាញគោលបំណង: បន្ទាប់មកអ្នកសម្របសម្រួលបង្ហាញគោលបំណងនៃមេរៀន (បញ្ចាំងបទបង្ហាញ ទី២)<br>១. ពិពណ៌នាសកម្មភាពអាទិភាពសម្រាប់ការភ្ជាប់ទំនាក់ទំនង។<br>២. កំនត់បានពីវិធីសាស្ត្រក្នុងការអនុវត្តសកម្មភាពសម្រាប់ការភ្ជាប់ទំនាក់ទំនងជាមួយក្រុមប្រឹក្សាថ្នាក់ក្រោមជាតិក្នុងការអនុវត្តកម្មវិធីជាតិ។<br>៣. កំនត់បានពីវិធីសាស្ត្រដើម្បីលើកទឹកចិត្តក្រុមមិនសូវមានតំណាងឱ្យមានសម្លេងនៅក្នុងកិច្ចការមូលដ្ឋាន និងកិច្ចការនៅថ្នាក់ក្រោមជាតិ។ | |
| ១០ នាទី | ៣- បទបង្ហាញ និងការពិភាក្សាពេញអង្គ<br>ក- អ្នកសម្របសម្រួលរំលឹកសិក្ខាកាមឱ្យពិនិត្យមើលឯកសារមេរៀនដែលគេបានទទួលក្នុងមេរៀនទី ១ជំពូកទី ៣ ស្ដីពីទស្សនៈរបស់សង្គមស៊ីវិលក្នុងការភ្ជាប់ទំនាក់ទំនងជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិ។<br><br>ខ- នៅក្នុងមេរៀននេះ យើងនឹងផ្ដល់ឱ្យអ្នកយល់កាន់តែច្បាស់ថែមទៀតអំពីសកម្មភាពដែលអ្នកអាចទទួលយក និងអាច | ▢ បទបង្ហាញស្ដីពីអត្ថន័យនៃការភ្ជាប់ទំនាក់ទំនង-**បទបង្ហាញទី ៥ និងទី៦**<br>▤ បទបង្ហាញទី ១១<br>- មាត្រា ៣៤ |

| ម៉ោង | សកម្មភាព និង វិធីសាស្ត្រ | សម្ភារៈ/ឯកសារ |
|---|---|---|
| | អនុវត្តសម្រាប់អង្គការរបស់អ្នកនៅពេលអនាគត។<br>គ. អ្នកសម្របសម្រួលបង្ហាញបទបង្ហាញទី៣.៤ បន្ទាប់មកលើកជាសំនួរតើពាក្យគន្លឹះនៅក្នុងស្លាយនេះមានអ្វីខ្លះ?<br>អ្នកសម្របសម្រួល កត់ត្រាចំលើយ របស់សិក្ខាកាមលើក្រដាសផ្ទាំងធំ។<br><br>ការភ្ជាប់ទំនាក់ទំនងអភិបាលកិច្ច គឺជាយន្តការសម្រាប់ភ្ជាប់សម្លេងរបស់ប្រជាពលរដ្ឋ និង សេចក្ដីសម្រេចចិត្តនៅក្នុងគោលនយោបាយសាធារណៈ និង កម្មវិធីនានារបស់រដ្ឋាភិបាល ហើយត្រូវធានាថាយន្តការនេះមានឥទ្ធិពលទៅលើការអនុវត្ត។ *Civic engagement in public policy, United Nations New York, 2007* *email: bertucci@un.org*<br><br>ការភ្ជាប់ទំនាក់ទំនងសហគមន៍ *គឺជាមុខងាររបស់រដ្ឋាភិបាលក្នុងការទំនាក់ទំនងជាមួយប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធនៅក្នុងការបង្កើតការអនុវត្តគោលនយោបាយកម្មវិធីនិងការផ្ដល់សេវាកម្មនានាប្រកបដោយប្រសិទ្ធភាពមានគុណភាព និងធានាឱ្យមានយន្តការផ្ដល់ព័ត៌មានត្រឡប់ដល់ប្រជាពលរដ្ឋ ។* *Civic engagement in public policy, United Nations New York, 2007* email: *bertucci@un.org*<br><br>**ច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ**<br>ក្រុមប្រឹក្សាត្រូវមានគណនេយ្យភាពដោយផ្ទាល់ចំពោះប្រជាពលរដ្ឋទាំងអស់អំពីជម្រើសជាអាទិភាព ដើម្បីធ្វើសេចក្ដីសម្រេចធានាបានការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ *មាត្រា៣៤(ទំព័រទី៨)* | |

| ម៉ោង | សកម្មភាព និង វិធីសាស្ត្រ | សម្ភារៈ/ឯកសារ |
|---|---|---|
| ២៥ នាទី | ៤. បទបង្ហាញ និងការពិភាក្សាពេញអង្គ<br>ក. អ្នកសម្របសម្រួលបង្ហាញទម្រង់សកម្មភាពសម្រាប់ការភ្ជាប់ទំនាក់ទំនង។ ពន្យល់ពីទម្រង់នីមួយៗ។ អ្នកសម្របសម្រួលពន្យល់ថា យើងនឹងប្រើទម្រង់សកម្មភាពចំបងៗនិមួយៗនៃការភ្ជាប់ទំនាក់ទំនងទាំងអស់នេះ សម្រាប់ការងារជាក្រុមនៅសកម្មភាពបន្ទាប់ទៀត។<br><br>**សកម្មភាពចំបង ទី១: (ទម្រង់សម្រាប់ក្រុមពិភាក្សា) សម្រាប់ភ្ជាប់ទំនាក់ទំនងក្នុងការរៀបចំផែនការ និងថវិកា**<br>ក. កំណត់សកម្មភាពដែលបានអនុវត្តកន្លងមក<br><br>ខ. គោលបំណង<br><br>គ. តើអង្គការសង្គមស៊ីវិលអាចធ្វើអ្វីខ្លះដើម្បីលើកទឹកចិត្តក្រុមមិនសូវមានតំណាង ចូលរួមក្នុងការរៀបចំផែនការ និងថវិកាជាមួយក្រុមប្រឹក្សាថ្នាក់ក្រោមជាតិ?<br><br>ឃ. តើអង្គការសង្គមស៊ីវិលអាចធ្វើអ្វីខ្លះដើម្បីកសាងសមត្ថភាពក្រុមប្រឹក្សាថ្នាក់ក្រោម ជាតិក្នុងការរៀបចំផែនការ និងថវិកា?<br><br>ង. តើអ្នកមានអនុសាសន៍អ្វីខ្លះដើម្បីធ្វើឱ្យប្រសើរឡើង ការភ្ជាប់ទំនាក់ទំនងជា មួយក្រុមប្រឹក្សាថ្នាក់ក្រោមជាតិក្នុងការរៀបចំផែនការ និងថវិកា? | ☐ គោលការណ៍តម្រង់ទិស បទបង្ហាញទី១០ - ១១<br>☐ បទបង្ហាញស្តីពីសកម្មភាពចំបងៗនៃការភ្ជាប់ទំនាក់ទំនង<br>☐ បទបង្ហាញទី១២, ១៣,១៤,១៥, ១៦, ១៧ |

| ម៉ោង | សកម្មភាព និង វិធីសាស្ត្រ | សម្ភារៈ/ឯកសារ |
|---|---|---|
| | ខ. អ្នកសម្របសម្រួលបង្ហាញសន្លឹកកិច្ចការនីមួយៗដល់សិក្ខាកាម។ សិក្ខាកាមអាចនឹងលើកសំនួរខ្លះទាក់ទងនឹងសកម្មភាពនេះ។ អ្នកសម្របសម្រួលប្រាប់សិក្ខាកាមថានឹងជួយពិនិត្យមើលក្រុមនីមួយៗ នៅពេលពិភាក្សាក្រុម ដើម្បីពន្យល់បន្ថែមចំពោះសំនួរដែលបានលើកឡើងនេះ។<br>ជំហានទី១: ពន្យល់ទម្រង់សកម្មភាពចំបងៗនីមួយៗ<br>ជំហានទី២: បង្ហាញនិងពន្យល់ទម្រង់ទី១: ការរៀបចំផែនការ និងថវិកា (អាចចំណាយពេលប្រាំនាទី)។ ផ្តោតតែលើចំនុច ក គ ឃ និង ង។<br>*អ្នកសម្របសម្រួលអនុវត្តជំហាននេះដដែលៗរហូតគ្រប់សកម្មភាពទាំងអស់។* | |
| ៨៥ នាទី | **៥. បទបង្ហាញ ការពិភាក្សាក្រុមតូច និងការពិភាក្សាពេញអង្គ**<br>ក. ការងារក្រុមតូច<br>• អ្នកសម្របសម្រួលពន្យល់ថានឹងមានក្រុមការងារតូចចំនួន ៥ក្រុម។<br>• អ្នកសម្របសម្រួលពន្យល់ថាក្រុមនីមួយៗនឹងឆ្លើយសំនួរបីដូចខាងក្រោម<br>១. តើសង្គមស៊ីវិលអាចធ្វើអ្វីខ្លះដើម្បីលើកទឹកចិត្តក្រុមដែលមិនសូវមានតំណាងឱ្យចូលរួមក្នុងកិច្ចការមូលដ្ឋាន និងនៅថ្នាក់ក្រោមជាតិ? *(សំដៅលើសកម្មភាពចំបងៗខាងលើ)*<br>២. តើអង្គការសង្គមស៊ីវិលអាចធ្វើអ្វីខ្លះដើម្បីកសាងសមត្ថភាពក្រុមប្រឹក្សាថ្នាក់ក្រោមជាតិ? | បង្ហាញសកម្មភាពចំបងៗ សម្រាប់ការភ្ជាប់ទំនាក់ទំនង ទាំង៥<br>បទបង្ហាញទី១៩ សំនួរសម្រាប់ក្រុមពិភាក្សា |

| ម៉ោង | សកម្មភាព និង វិធីសាស្ត្រ | សម្ភារៈ/ឯកសារ |
|---|---|---|
| | *(សំដៅលើសកម្មភាពចំបង១ខាងលើ)*<br>៣. តើអ្នកមានអនុសាសន៍អ្វីខ្លះដើម្បីធ្វើឱ្យប្រសើរឡើង / ពង្រឹងដល់ការភ្ជាប់ជាមួយក្រុមប្រឹក្សានៅថ្នាក់ក្រោមជាតិ? *(សំដៅលើសកម្មភាពចំបង១ខាងលើ)*<br><br>អ្នកសម្របសម្រួលពន្យល់ពីដំណាក់កាលសម្រាប់ក្រុមការងារ។ ក្រុមនីមួយៗ មានពេលវេលា ៣០នាទី ដើម្បីបញ្ចប់ការងាររបស់ក្រុម និង២០នាទីសម្រាប់ការបង្ហាញលទ្ធផលរបស់ក្រុម។<br><u>ដំណាក់កាលសម្រាប់ក្រុមការងារ</u><br>១. អានសកម្មភាពចំបង១ដែលបានចែកឱ្យក្រុមនីមួយៗ<br>២. កំណត់អ្វីខ្លះដែលអ្នកបានធ្វើកន្លងមក<br>៣. ពិភាក្សាសំនួរទី១ និងសង្ខេបចម្លើយទាំងអស់<br>៤. ពិភាក្សាសំនួរទី២ និងសង្ខេបចម្លើយទាំងអស់<br>៥. ពិភាក្សាសំនួរទី៣ និងសង្ខេបចម្លើយទាំងអស់<br>៦. ក្រុមការងាររៀបចំដើម្បីបង្ហាញដល់ក្រុមផ្សេងៗទៀត។<br>បែងចែកសិក្ខាកាមជាប្រាំក្រុម រួចចែកសន្លឹកកិច្ចការជាមួយប្រធានបទឱ្យក្រុម នីមួយៗ។<br><br>ខ. <u>បទបង្ហាញតាមក្រុម</u> មានជម្រើសពីរសម្រាប់អនុវត្ត<br><u>ជម្រើសទី១</u>:<br>ប្រសិនបើមានទីកន្លែងគ្រប់គ្រាន់ការដើរមើលជាក្រុមត្រូវតែអនុវត្ត។<br><br><u>ជំហានសម្រាប់ការដើរមើលជាក្រុម</u><br>• សិក្ខាកាមបិទចម្លើយរបស់ខ្លួននៅលើជញ្ជាំង។ | |

| ម៉ោង | សកម្មភាព និង វិធីសាស្ត្រ | សម្ភារៈ/ឯកសារ |
|---|---|---|
| | • ក្រុមនីមួយៗជ្រើសរើសតំណាងក្រុមម្នាក់ឱ្យឈរនៅពីមុខក្រដាសចម្លើយរបស់ខ្លួន ដើម្បីឆ្លើយសំនួរ និងធ្វើការបញ្ជាក់បំភ្លឺរាល់សំនួរពីក្រុមដទៃទៀត។<br>• ក្រុមនីមួយៗមានរយៈពេល១០នាទីសម្រាប់ការសួរ និងឆ្លើយ ឬ ការបំភ្លឺ។<br>• សមាជិកក្រុមផ្សេងៗទៀតដើរជុំវិញដើម្បីពិនិត្យលទ្ធផលរបស់ក្រុមផ្សេងៗទៀត និងសួរសំនួរ ឬផ្តល់អនុសាសន៍ដល់អ្នកបង្ហាញសម្រាប់ពិចារណា ឬ ធ្វើការកែសម្រួល។<br>• អ្នកសម្របសម្រួលកត់ត្រាចម្លើយទាំងអស់និងសំនួរដែលមិនអាចឆ្លើយបាន។<br><br><u>ជម្រើសទី២:</u> ការបង្ហាញលទ្ធផលតាមក្រុមនីមួយៗ<br><u>ជំហានសម្រាប់ការបង្ហាញលទ្ធផលក្រុម:</u><br>▪ អ្នកសម្របសម្រួលអញ្ជើញតំណាងក្រុមដើម្បីបង្ហាញលទ្ធផលក្រុមរបស់ខ្លួន។<br>▪ ក្រុមនីមួយៗមានពេល៥នាទីសម្រាប់បង្ហាញ និង៥នាទីសម្រាប់សំនួរ ចម្លើយ។<br>▪ អ្នកសម្របសម្រួលលើកទឹកចិត្តសិក្ខាកាមដើម្បីលើកសំនួរ ឬផ្តល់អនុសាសន៍ដល់អ្នកធ្វើបទបង្ហាញ។<br>▪ បន្ទាប់ពីក្រុមនីមួយៗបានបញ្ចប់បទបង្ហាញរបស់ខ្លួនហើយ អ្នកសម្របសម្រួល ធ្វើការសង្ខេបចំនុចសំខាន់ៗដែលបានកត់ត្រានៅពេលក្រុមនីមួយៗកំពុងធ្វើបទបង្ហាញ។ | |
| ១០ នាទី | **៦. <u>សេចក្តីសន្និដ្ឋានមេរៀន</u>**<br>១) អ្នកសម្របសម្រួលសង្ខេបសកម្មភាពចំបងៗនៃការភ្ជាប់ | ▤ ក្រដាសផ្ទាំងធំសម្រាប់សង្ខេប |

| | | |
|---|---|---|
| | ទំនាក់ទំនងដែលសិក្ខាកាមភាគច្រើនមានបទពិសោធន៍<br>ឧ. ការរៀបចំផែនការ និងថវិកា ការចូលរួមក្នុងកិច្ចប្រជុំសាធារណៈ និងការចែករំលែកព័ត៌មាន។<br>២) អ្នកសម្របសម្រួលធ្វីការសង្ខេបនូវអ្វីដែលសិក្ខាកាមភាគច្រើនមានបទពិសោធន៍ក្នុងលើកកម្ពស់ការភ្ជាប់ទំនាក់ទំនង ក្រុមមិនស្វូវមានតំណាងជាមួយក្រុមប្រឹក្សានៅថ្នាក់ក្រោមជាតិ។<br>៣) អ្នកសម្របសម្រួលសង្ខេបនូវអ្វីដែលសិក្ខាកាមភាគច្រើនចង់ធ្វើថែមទៀត ដើម្បីធ្វើឱ្យប្រសើរឡើងនូវការភ្ជាប់ទំនាក់ទំនងជាមួយក្រុមប្រឹក្សានៅថ្នាក់ក្រោមជាតិនៅថ្ងៃអនាគត។<br>៤) អ្នកសម្របសម្រួលសង្ខេបសកម្មភាពសំខាន់ៗដែលអង្គការសង្គមស៊ីវិល នឹងរួមចំណែកក្នុងការកសាងសមត្ថភាពដល់ក្រុមប្រឹក្សាថ្នាក់ក្រោមជាតិ។ | |

## សម្ភារៈ និងឧបករណ៍សម្រាប់មេរៀន

- សកម្មភាពចំបងទី១: ការរៀបចំផែនការ និងថវិកា
- សកម្មភាពចំបងទី២: ការចូលរួមកិច្ចប្រជុំជាសាធារណៈ
- សកម្មភាពចំបងទី៣: ការចែករំលែកព័ត៌មាន
- សកម្មភាពចំបងទី៤: ការចូលរួមក្នុងការគ្រប់គ្រងតាមដានការអនុវត្ត
- សកម្មភាពចំបងទី៥: ការផ្តល់ព័ត៌មានត្រឡប់លើគោលនយោបាយ

ហ្វឹត ក្រដាសផ្ទាំងធំ ស្កុត ក្រដាសពណ៌

- ឯកសារបញ្ចាំង
- ម៉ាស៊ីន LCD និងកំព្យូទ័រ

## ឯកសារយោង និងប្រភពសម្រាប់ព័ត៌មានបន្ថែម

- ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ (ការរៀបចំផែនការ មាត្រា ៣៤,៣៨,៣៩ និង ៨៩) (ហិរញ្ញវត្ថុ មាត្រា៤២, ៤៣, ៤៥ និង៥០), (ចែករំលែកព័ត៌មាន: មាត្រា ៤១, ៥១ និង៥២) (កិច្ចប្រជុំសាធារណ: មាត្រា ៦៨, ៧៥ និង ៧៦) www.ncdd.gov.kh
- អនុក្រិត្យស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងរបស់ក្រុមប្រឹក្សា និងគណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក មាត្រា៩ កថាខ័ណ្ឌទី២ (ទំព័រទី៣), មាត្រា ១៤ ចំនុចទី៤ (ទំព័រទី៥), មាត្រា៥៤ (ទំព័រទី១៩)។ www.ncdd.gov.kh
- កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ២.២ ការប្តេជ្ញាចិត្តខាងនយោបាយ ទំព័រទី ១២, ១៥, ១៧, **៣.១ សមាសធាតុកម្មវិធីទី១:** ទំព័រទី ២៨, **៣.៣ សមាសធាតុកម្មវិធីទី៣:** ទំព័រទី ៣៨, ៣៩, ៤១ **សមាសធាតុកម្មវិធីទី៤:** ទំព័រទី៤៧, **សមាសធាតុកម្មវិធី ទី៥:** ទំព័ទី៥៧ និង៦៥។ www.ncdd.gov.kh
- បទបង្ហាញកម្មវិធីល្អក្នុងកិច្ចប្រជុំក្រុមការងារភាពជាដៃគូវិមជ្ឈការ: ទស្សន:នៃការភ្ជាប់ទំនាក់ទំនង របស់អង្គការសង្គមស៊ីវិលជាមួយក្រុមប្រឹក្សានៅថ្នាក់ក្រោមជាតិ ថ្ងៃទី ២៧ សីហា ២០១០។ www.pactcambodia.org
- ការភ្ជាប់ទំនាក់ទំនងប្រជាពលរដ្ឋនៅក្នុងគោលនយោបាយសាធារណ:កញ្ចប់ឧបករណ៍ អង្គការសហប្រជាជាតិ, ញូយ៉ក, ២០០៧, bertucci@un.org

# មេរៀនទី ៣

## ការលើកកម្ពស់ការប្រើប្រាស់បណ្តាញអង្គការសង្គមស៊ីវិល និងព័ត៌មាននៅរដ្ឋបាលថ្នាក់ក្រោមជាតិ

# ៣ មេរៀន

# ការលើកកម្ពស់ការប្រើប្រាស់បណ្តាញអង្គការសង្គមស៊ីវិល និងព័ត៌មាននៅរដ្ឋបាលថ្នាក់ក្រោមជាតិ



**គោលបំណង:** នៅចុងបញ្ចប់នៃមេរៀននេះ សិក្ខាកាមអាច

ក) ពិពណ៌នាអំពីអាទិភាពនៃការប្រើប្រាស់ និងពង្រឹងវិសាលភាពនៃបណ្តាញអង្គការសង្គមស៊ីវិលឱ្យបានកាន់តែទូលំទូលាយ ហើយបានដឹងថាតើបណ្តាញ ឬស្ថាប័នណាខ្លះដែលកំពុងអនុវត្តនៅថ្នាក់ខេត្ត តំបន់ និងថ្នាក់ជាតិ។

ខ) ស្វែងរកប្រភពព័ត៌មាន ដែលអាចប្រើប្រាស់បាននៅតាមគេហទំព័រ និងសម្ភារៈផ្សេងៗ ដូចជាសម្ភារៈអប់រំផ្សព្វផ្សាយ។

គ) យល់ពីអត្ថប្រយោជន៍នៃការប្រើប្រាស់សម្ភារៈជំនួយស្មារតីដែលបានចែកនៅក្នុងវគ្គបណ្តុះបណ្តាល ។

## លទ្ធផលរំពឹងទុកនៃមេរៀន

ក). មានទំនុកចិត្តក្នុងការពន្យល់អំពីជម្រើសផ្សេងៗដែលត្រូវផ្សព្វផ្សាយបន្តដល់អ្នកផ្សេងទៀតអំពីអ្វីដែលបានរៀនសូត្រក្នុងអំឡុងពេល៣ថ្ងៃនេះ។

ខ). ប្រើប្រាស់បណ្តាញនិងលើកកំពស់ការចែករំលែកព័ត៌មាននៅក្នុងចំណោមបណ្តាញ

គ). ជំរុញអោយមានការប្រើប្រាស់ប្រភពព័ត៌មានដែលមានស្រាប់ និងស្វែងរកព័ត៌មានដែលអាចជួយអោយការយល់ដឹងនេះកាន់តែមានប្រសិទ្ធភាព។

## កំណត់ចំណាំសម្រាប់អ្នកសម្របសម្រួល

នៅក្នុងមេរៀននេះអ្នកសម្របសម្រួលមានគោលបំណង ៣សំខាន់ៗ:

១. ពង្រឹងប្រសិទ្ធភាពការអនុវត្តកម្មវិធីជាតិនៅពេលដែល CSOs/NOGs ប្រើប្រាស់បណ្តាញពួកគេដើម្បីគាំទ្រអ្នកផ្សេងទៀតឱ្យចែករំលែកនូវព័ត៌មាន និងសម្ភារៈអប់រំផ្សព្វផ្សាយផ្សេងៗ។



មេរៀនទី៣

អ្នកសម្របសម្រួលជួយដល់សិក្ខាកាមក្នុងការធ្វើយ៉ាងណា ដើម្បីអោយពួកគេដឹងថាតើមានបណ្តាញណាខ្លះហើយ។ អ្នកសម្របសម្រួលគួរតែរៀបចំនូវបទបង្ហាញ ឬក្រដាសផ្ទាំងធំ ដើម្បីកត់ត្រានូវបណ្តាញដែលមានស្រាប់ដូចជា (ឈ្មោះបណ្តាញ គោលបំណង និងអាស័យដ្ឋានជាដើម)។

២. សិក្ខាកាមនឹងត្រូវបានទទួលគុណភាពនៃព័ត៌មានក្នុងអំឡុងពេលនៃការបណ្តុះបណ្តាលនេះ។ អ្នកសម្របសម្រួលគួរណែនាំដល់សិក្ខាកាមទាំងអស់ថា តើត្រូវស្វែងរកព័ត៌មានយ៉ាងដូចម្តេចក្រោយពេលបញ្ចប់វគ្គបណ្តុះបណ្តាលនេះទៅ ហើយតើត្រូវរកឯកសារ និង សម្ភារៈដែលពាក់ព័ន្ធផ្សេងទៀតយ៉ាងដូចម្តេចដែរ។ អ្នកសម្របសម្រួលត្រូវរៀបចំបញ្ជីអោយរួចរាល់មុនពេលចាប់ផ្តើមមេរៀននេះ។

៣. សិក្ខាកាមបានយល់អំពីអត្ថប្រយោជន៍នៃឯកសារនិងសម្ភារៈដែលពាក់ព័ន្ធផ្សេងទៀតចែកនៅក្នុងវគ្គបណ្តុះបណ្តាល។

# ជំពូកទី ៣ : មេរៀនទី ៣

# ការលើកកម្ពស់ការប្រើប្រាស់បណ្តាញអង្គការសង្គមស៊ីវិល និងព័ត៌មាននៅរដ្ឋបាលថ្នាក់ក្រោមជាតិ

## ១_គោលបំណងនៃមេរៀន

នៅចុងបញ្ចប់នៃមេរៀនសិក្ខាកាមនឹង :

១) អាចពិពណ៌នាអំពីទិដ្ឋភាពនៃការប្រើប្រាស់ និងការពង្រីកវិសាលភាពបណ្តាញអង្គការសង្គមស៊ីវិលឱ្យបានកាន់តែទូលំទូលាយ ហើយបានដឹងថា តើបណ្តាញ/ស្ថាប័នណាខ្លះដែលកំពុងអនុវត្តនៅថ្នាក់ខេត្ត តំបន់ និងថ្នាក់ជាតិ ។

២) អាចស្វែងរកប្រភពព័ត៌មាន និងសម្ភារៈផ្សេងៗ ស្តីពីកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិឱ្យបានកាន់តែទូលំទូលាយ ។

៣) យល់ពីអត្ថប្រយោជន៍ការប្រើប្រាស់សម្ភារៈជំនួយស្មារតី ដែលបានចែកចាយនៅក្នុងវគ្គបណ្តុះបណ្តាល ។

២

## ២.ការលើកកម្ពស់ការប្រើប្រាស់បណ្ដាញ អង្គការសង្គមស៊ីវិលនៅថ្នាក់ក្រោមជាតិ

និយមន័យនៃពាក្យបណ្តាញ?

តាមនិយមន័យ ដែលស្វែងរកតាមប្រព័ន្ធអ៊ិនធឺណេត ឃើញថាមានចម្លើយជាច្រើនទាក់ទងទៅនឹងពាក្យ "**បណ្តាញ**" មាននិយមន័យបីខុសគ្នាដូចជាមានរៀបរាប់ខាងក្រោម:

- បណ្តាញ គឺការចងក្រងគ្នាជាក្រុមរវាងបុគ្គល និងបុគ្គល រវាងស្ថាប័ន និងស្ថានប័ន រវាងខេត្ត/ស្រុក និងខេត្ត/ស្រុក ដែលមានទស្សនៈវិស័យដូចគ្នាក្នុងន័យដើម្បីសម្រេចនូវគោលដៅរួម។
- ចងក្រងអាស័យដ្ឋានសម្រាប់ធ្វើការចែករំលែក ឬការផ្លាស់ប្តូរព័ត៌មានជាមួយអ្នកដទៃទៀតនៅក្នុងក្រុមជាមួយ។
- បណ្តុំកំព្យូទ័រ ដែលចងជាប្រព័ន្ធភ្ជាប់គ្នា ប្រើប្រាស់នៅក្នុងស្ថាប័ន។

៣

## ២.ការលើកកម្ពស់ការប្រើប្រាស់បណ្ដាញ អង្គការសង្គមស៊ីវិលនៅថ្នាក់ក្រោមជាតិ "ត"

❖ **ហេតុអ្វីចាំបាច់លើកកម្ពស់ការប្រើប្រាស់បណ្តាញ?**

បណ្តាញបានផ្តល់ឱកាសដ៏សំខាន់ក្នុងការ :

- បង្កើតនូវទំនាក់ទំនង ជួយពង្រឹងឱ្យមានភាពរឹងប៉ឹង និងសាមគ្គីភាពក្នុងការជួយគាំទ្រគ្នាទៅវិញមកក្នុងកិច្ចការស្វែងរកការគាំទ្រ/តស៊ូមតិ ការដោះស្រាយបញ្ហា និងការបង្ហាញនូវកង្វល់រួមគ្នា ។ល។
- ចែករំលែកនូវព័ត៌មានបទពិសោធន៍ចំណេះដឹងរបាយការណ៍ និងការស្វែងរកថវិកាសម្រាប់ទ្រទ្រង់ស្ថាប័ន។ល។

៤

## ២_ការលើកកម្ពស់ការប្រើប្រាស់បណ្តាញអង្គការសង្គមស៊ីវិលនៅថ្នាក់ក្រោមជាតិ "ត"

- ចូលរួមចំណែកជម្រុញឱ្យមានអភិបាលកិច្ចល្អនៅថ្នាក់ក្រោមជាតិ
- ជួយលើកកម្ពស់ការយល់ដឹងរបស់ប្រជាពលរដ្ឋ
- ជួយគាំទ្រធ្វើឱ្យមានការអភិវឌ្ឍសង្គម។

៥

## ២_ការលើកកម្ពស់ការប្រើប្រាស់បណ្តាញអង្គការសង្គមស៊ីវិលនៅថ្នាក់ក្រោមជាតិ "ត"

❖ **ការពង្រីកវិសាលភាពបណ្តាញអង្គការសង្គមស៊ីវិលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ**

បណ្តាញអង្គការសង្គមស៊ីវិលមានតួនាទីយ៉ាងសំខាន់ជួយគាំទ្រដល់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការលើកកម្ពស់ការយល់ដឹងអំពីកម្មវិធីជាតិដល់អង្គការសង្គមស៊ីវិល និងប្រជាពលរដ្ឋផ្តោតជាសំខាន់ទៅលើ ៖

- ការធ្វើកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ
- សមាសធាតុកម្មវិធីទាំង៥ និងអន្តរវិស័យទាំង៣

៦

ជំពូកទី៣

## ២. ការលើកកម្ពស់ការប្រើប្រាស់បណ្តាញអង្គការសង្គមស៊ីវិលនៅថ្នាក់ក្រោមជាតិ "ត"

- ទំនាក់ទំនងរវាងច្បាប់ស្តីពីរការគ្រប់គ្រងរដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងកម្មវិធីជាតិ
- ជួយគាំទ្រ និងពង្រឹងសមត្ថភាពរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការធ្វើផែនការ គ្រប់គ្រងហិរញ្ញវត្ថុ
- ការតាមដានត្រួតពិនិត្យ និងវាយតម្លៃ ការគ្រប់គ្រងបុគ្គលិក ការរៀបចំរបាយការណ៍ ការផ្សព្វផ្សាយព័ត៌មាន និងការដោះស្រាយវិវាទ
- ផ្តល់ព័ត៌មានត្រលប់ផ្នែកគោលនយោបាយជូនទៅក្រុមប្រឹក្សា

៧

## ២. ការលើកកម្ពស់ការប្រើប្រាស់បណ្តាញអង្គការសង្គមស៊ីវិលនៅថ្នាក់ក្រោមជាតិ "ត"

- លើកទឹកចិត្តប្រជាពលរដ្ឋឱ្យចូលរួមក្នុងកិច្ចប្រជុំនានារបស់រដ្ឋបាលនៅថ្នាក់ក្រោមជាតិទាក់ទង និងការរៀបចំផែនការ និងថវិកាសម្រាប់ការអភិវឌ្ឍសហគមន៍មូលដ្ឋាន
- ធ្វើជាស្ពានចម្លង ឬពាំនាំនូវអ្វីដែលជាកង្វល់ មតិយោបល់ ការយល់ឃើញរបស់ប្រជាពលរដ្ឋតាមរយៈ
  - ❖ ការផ្សព្វផ្សាយអប់រំ ដើម្បីលើកកម្ពស់ការយល់ដឹងប្រជាពលរដ្ឋ
  - ❖ ពង្រឹងសមត្ថភាពអង្គការដៃគូ

៨

## ២. ការលើកកម្ពស់ការប្រើប្រាស់បណ្តាញ អង្គការសង្គមស៊ីវិលនៅថ្នាក់ក្រោមជាតិ "ត"

- ស្វែងយល់ និងបង្កើនការយល់ដឹងឱ្យបានច្បាស់លាស់ អំពីកម្មវិធីថ្នាក់ជាតិ
- ប្រមើមើលឱកាសដើម្បីបញ្ជៀបកម្មវិធីជាតិនឹងបេសកកម្មរបស់បណ្តាញរបស់ខ្លួន
- ត្រូវចាត់ទុកកម្មវិធីជាតិជាអាទិភាពរបស់បណ្តាញ
- ស្វែងយល់ ថាតើមានក្រសួង/ស្ថាប័នណាខ្លះ ដែលជាស្ថាប័នពាក់ព័ន្ធទៅនឹង លើកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- បង្កើនទំនាក់ទំនងជាមួយបណ្តាញ ឬ ស្ថាប័នពាក់ព័ន្ធទាំងនោះ

៩

## ២. ការលើកកម្ពស់ការប្រើប្រាស់បណ្តាញ អង្គការសង្គមស៊ីវិលនៅថ្នាក់ក្រោមជាតិ "ត"

ខាងក្រោមនេះ គឺជាឧទាហរណ៍ អំពីបណ្តាញអង្គការសង្គមស៊ីវិលមួយចំនួនដែលយើងបាន ស្គាល់មានដូចជា :

- គណ:កម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា (អង្គការ CCC) www.ccc.cambobia.org
- គម្រោងគាំទ្រក្រុមប្រឹក្សា ឃុំ សង្កាត់ (ccsp ) www.ccspcambodia.prg
- ការិយាល័យទំនាក់ទំនងអង្គការសង្គមស៊ីវិល (NLO)
- វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា (The NGO Forum on Cambodia ) www.ngoforumcambodia.org.kh
- ក្រុមការងារវិមជ្ឈការតាមរយ:ភាពជាដៃគូ (WGPD) ។ល។

**កំណត់សម្គាល់ :** មានបណ្តាញជាច្រើនផ្សេងទៀតមិនបានរៀបរាប់លំអិត។ ១០

# ៣_លើកកម្ពស់ការប្រើប្រាស់ព័ត៌មាន "ត"

❖ **តើអ្វីទៅជាព័ត៌មាន?**

ពាក្យថា "ព័ត៌មាន"មាននិយមជាច្រើនដូចជា :

➢ ព័ត៌មាន ត្រូវបានទទួលស្គាល់ថាជាពាក្យបច្ចេកទេសមួយម៉ាត់ដែលអត្ថន័យរបស់វាមានវិសាលភាពធំធេងគ្រប់បណ្តប់ទាំងបច្ច័យល្អ និងបច្ច័យអាក្រក់ ។

➢ ព័ត៌មាន គឺជាការពាំនាំនូវដំណឹងនានាប្រាប់ដល់សាធារណៈជនឱ្យបានដឹងពីព្រឹត្តិការណ៍ ហេតុការណ៍ដំណឹងស្តីពីកិច្ចសហប្រតិបត្តិការណ៍ កិច្ចការសាធារណៈ កិច្ចការរដ្ឋ កិច្ចការជំនួញភាពរីកចំរើន ឬចុះអន់ថយនៃសេដ្ឋកិច្ចនៅក្នុងប្រទេស តំបន់ និងសកលលោក។

១១

# ៣_លើកកម្ពស់ការប្រើប្រាស់ព័ត៌មាន "ត"

❖ ព័ត៌មាន មានលក្ខណៈជាដំណឹងទាន់ហេតុការណ៍ សេចក្តីជូនដំណឹង សេចក្តីណែនាំ អត្ថបទបង្ហាញនូវក្តីកង្វល់ រួមទៅលើបញ្ហា ផលប៉ះពាល់អ្វីមួយទៅលើជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ។

❖ ការផ្សព្វផ្សាយព័ត៌មាន ក៏មានលក្ខណៈរសើបផងដែរ ហើយទាមទារឱ្យមានការកំណត់ព្រំដែនផងដែរ ជាពិសេសព័ត៌មានដែលចាត់ទុកថាជាព័ត៌មានសម្ងាត់ និងព័ត៌មានផ្ទាល់ខ្លួន ។

១២

## ៣.លើកកម្ពស់ការប្រើប្រាស់ព័ត៌មាន "ត"

### ❖ ហេតុអ្វីព័ត៌មានសំខាន់?

ព័ត៌មាន មានសារៈសំខាន់ជាច្រើនដូចជាៈ

- ✓ ជួយឱ្យទំនាក់ទំនងកាន់តែល្អ ឬអាក្រក់អាស្រ័យព័ត៌មានដែលទទួលបាន
- ✓ មានការជឿជាក់ និងមានទំនុកចិត្តក្នុងការធ្វើការងារ ធ្វើបទបង្ហាញការថ្លែងសុន្ទរកថាសាធារណៈការបញ្ចេញនូវមតិយោបល់ ។ល។ ដោយសារតែការមានព័ត៌មានគ្រប់គ្រាន់ និងប្រភពដែលទុកចិត្ត
- ✓ មានចំណេះដឹងខ្ពង់ខ្ពស់ និងមានទស្សនៈទូលំទូលាយ

១៣

## ៣.លើកកម្ពស់ការប្រើប្រាស់ព័ត៌មាន "ត"

- ✓ ជួយអ្នកដទៃឱ្យមានទំនាក់ទំនងកាន់តែប្រសើរ (ក្នុងន័យផ្សះផ្សារ)
- ✓ ចែករំលែកទៅអ្នក ដែលនៅក្នុងបណ្តាញ
- ✓ ជួយឱ្យប្រតិបត្តិការបានកាន់តែល្អប្រសើរឡើង និងបង្កើនស្នាដៃ
- ✓ បានដឹងថាស្ថាប័នណាកំពុងធ្វើអ្វី? ស្ថាប័នណាខ្លះ ដែលធ្វើការនៅក្នុងវិស័យដូចគ្នា? ស្ថាប័នណាខ្លះដែលមានការពាក់ព័ន្ធកម្មវិធីជាតិ ?
- ✓ ស្វែងរកការគាំទ្រទាំងខាងជំនួយស្មារតី និងថវិកាទ្រទ្រង់ស្ថាប័ន

១៤

## ៣_លើកកម្ពស់ការប្រើប្រាស់ព័ត៌មាន "គ"

❖ **តើព័ត៌មានអាចស្វែងរកបានតាមមធ្យោបាយណាខ្លះ?**

យើងអាចស្វែងរក ព័ត៌មាន អាចរកបានតាមមធ្យោបាយផ្សេងៗ រួមមាន:

- វិទ្យុ
- ទស្សនាវដ្តី
- ទូរទស្សន៍
- បណ្ណាល័យ ឬបណ្ណាគារ និង
- កាសែត
- អ៊ិនធឺណេត ។ល។

១៥

## ៣_លើកកម្ពស់ការប្រើប្រាស់ព័ត៌មាន "គ"

❖ **តើព័ត៌មានស្តីពីកម្មវិធីសម្រាប់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅក្រោមជាតិមានអ្វីខ្លះ?**

ខាងក្រោមនេះ គឺចំណងជើងឯកសារទំនាក់ទំនងនឹងកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ :

- កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (២០១០_២០១៩)
- ក្របខណ្ឌយុទ្ធសាស្ត្រកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ (២០០៥ )

១៦

## ៣_លើកកម្ពស់ការប្រើប្រាស់ព័ត៌មាន “ត”

- ច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- អនុក្រឹត្យស្ដីពីតួនាទី ភារៈទំនាក់ទំនងការងារក្រុមប្រឹក្សា គណៈអភិបាល (២០០៩)
- សៀវភៅណែនាំ ស្ដីពីគ្រូឧទ្ទេស គណនេយ្យភាពសង្គម (របស់អង្គការសីលការ ២០១០)
- សៀវភៅណែនាំ គ្រូឧទ្ទេសរបស់ GTZ ច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បញ្ជាក់ : ព័ត៌មានខាងលើអាចរកបាននៅលើវិបសាយ www.ncdd.gov.kh

១៧

## ៣_លើកកម្ពស់ការប្រើប្រាស់ព័ត៌មាន “ត”



## ៣_លើកកម្ពស់ការប្រើប្រាស់ព័ត៌មាន "គ"




១៩

## អត្ថប្រយោជន៍ប្រើប្រាស់សម្ភារៈជំនួយស្មារតី ដែលបានចែកផ្សាយនៅក្នុងវគ្គបណ្តុះបណ្តាល

ឯកសារយោងនានាទាក់ទងនឹងកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍនៅថ្នាក់ក្រោមជាតិមានអត្ថប្រយោជន៍ប្រើប្រាស់ :

- ឯកសារជំនួយស្មារតីសម្រាប់ធ្វើការអប់រំផ្សព្វផ្សាយបន្ត
- លើកកម្ពស់ការយល់ដឹងរបស់ប្រជាពលរដ្ឋឱ្យបានទូលំទូលាយ
- ជួយឱ្យប្រតិបត្តិការបានកាន់តែល្អប្រសើរឡើង និងបង្កើនស្នាដៃ
- ជាជំនួយស្មារតីក្នុងការស្វែងរកថវិកាដើម្បីទ្រទ្រង់ស្ថាប័ន

២០

# សន្និដ្ឋាន

១) ការលើកកម្ពស់ការប្រើប្រាស់បណ្តាញ (Network ) ដែលមានស្រាប់ មានអត្ថប្រយោជន៍ និងសារៈសំខាន់ណាស់ក្នុងការជួយជម្រុញឱ្យ ការអនុវត្តកម្មវិធីជាតិកាន់តែមានប្រសិទ្ធភាព និងប្រកបដោយតម្លាភាព។

២) លើកកម្ពស់ការប្រើប្រាស់ព័ត៌មាន ដែលមានស្រាប់ ដើម្បីបង្កើនការ ជឿជាក់ និងទំនុកចិត្ត ។

២១

មេរៀន ៣ ឯកសារចែក

# ការលើកកម្ពស់ការប្រើប្រាស់បណ្តាញអង្គការសង្គមស៊ីវិល និងព័ត៌មាននៅរដ្ឋបាលថ្នាក់ក្រោមជាតិ

## ១. គោលបំណងនៃមេរៀន

ចំពោះមេរៀនក្នុងផ្នែកទី៣នេះ បានរៀបចំឡើងក្នុងគោលបំណងដោយរំពឹងថា បន្ទាប់ពីសិក្សាមេរៀននេះចប់សិក្ខាកាមទាំងអស់ :

១. អាចពិពណ៌នាអំពីអាទិភាពនៃការប្រើប្រាស់ និងការពង្រីកវិសាលភាពបណ្តាញអង្គការសង្គមស៊ីវិលឱ្យបានកាន់តែទូលំទូលាយ ហើយបានដឹងថាតើបណ្តាញ/ស្ថាប័នណាខ្លះដែលកំពុងអនុវត្តនៅថ្នាក់ខេត្ត និងថ្នាក់ជាតិ ។

២. អាចស្វែងរកប្រភពព័ត៌មាន និងសម្ភារៈផ្សេងៗ ស្តីពីកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ តំបន់ និងថ្នាក់ជាតិ ។

៣. យល់ពីអត្ថប្រយោជន៍ការប្រើប្រាស់សម្ភារៈជំនួយស្មារតី ដែលបានចែកចាយនៅក្នុងវគ្គបណ្តុះបណ្តាល ។

## ២. ការលើកកម្ពស់ការប្រើប្រាស់បណ្តាញអង្គការសង្គមស៊ីវិលនៅថ្នាក់ក្រោមជាតិ

### ☞ និយមន័យនៃពាក្យបណ្តាញ?

តាមនិយមន័យ ដែលស្វែងរកតាមប្រព័ន្ធអ៊ិនធឺណេតឃើញថា មានចម្លើយជាច្រើនទាក់ទងនឹងពាក្យ “បណ្តាញ”។

**បណ្តាញ** មាននិយមន័យខុសគ្នាដូចមានរៀបរាប់ខាងក្រោម :

★ គឺការចងក្រងគ្នាជាក្រុមរវាងបុគ្គល និងបុគ្គល រវាងស្ថាប័ន និងស្ថាប័ន រវាងខេត្ត/ស្រុក និងខេត្ត/ស្រុក ដោយមានទស្សនវិស័យ បេសកកម្ម គោលដៅ គោលបំណង ឬ ការចាប់អារម្មណ៍ដូចគ្នា ដើម្បីសម្រេចនូវសមិទ្ធិផលអ្វីមួយ ឧទាហរណ៍ កិច្ចការ សង្គម ឬ

កិច្ចការជំនាញ ។

☆ **បណ្តាញ** គឺការចងក្រងអាស័យដ្ឋានសម្រាប់ធ្វើការចែករំលែក ផ្សព្វផ្សាយ ឬ ផ្លាស់ប្តូរព័ត៌មានរវាងសមាជិកនៅក្នុងក្រុមជាមួយ ឧទាហរណ៍ ព័ត៌មានស្តីពីការងារប្រកាសជេញថ្លៃគម្រោង វគ្គ បណ្តុះបណ្តាលនៅលើវិបសាយ ។ល។

☆ បណ្តុំកំព្យូទ័រ ដែលចងជាប្រព័ន្ធតភ្ជាប់គ្នាប្រើប្រាស់នៅក្នុងស្ថាប័ន ។

**បញ្ជាក់** : និយមន័យនៃពាក្យបណ្តាញអាចរកបានតាមអ៊ិនធឺណេត ដោយការស្វែងរកលើវិបសាយ www.google.com ហើយវាយពាក្យ «definition of network » រួចចុច «Enter» វិបសាយជាច្រើននឹងបង្ហាញនៅលើអេក្រង់ យើងអាចជ្រើសរើសយកវិបសាយណាមួយដែលគិតថាមានអត្ថន័យត្រូវជាងគេ។

☞ **ហេតុអ្វីចាំបាច់លើកកម្ពស់ការប្រើប្រាស់បណ្តាញ?**

ដោយហេតុថា **បណ្តាញអង្គការសង្គមស៊ីវិល** បានផ្តល់ឱកាសដ៏សំខាន់ក្នុងការ :

☆ បង្កើតនូវទំនាក់ទំនង ជួយពង្រឹងឱ្យមានភាពរឹងប៉ឹង និងសាមគ្គីភាព ក្នុងការជួយគាំទ្រគ្នាទៅវិញទៅមកក្នុងកិច្ចការស្វែងរកការគាំទ្រ/តស៊ូមតិ ការដោះស្រាយបញ្ហា និងការបង្ហាញនូវកង្វល់រួមគ្នា ។ល។

☆ ចែករំលែកនូវព័ត៌មានបទពិសោធន៍ ចំណេះដឹង របាយការណ៍ និងការស្វែងរកថវិកាសម្រាប់ទ្រទ្រង់ស្ថាប័ន

☆ ចូលរួមចំណែកជម្រុញឱ្យមានអភិបាលកិច្ចល្អនៅថ្នាក់ក្រោមជាតិ

☆ ជួយលើកកម្ពស់ការយល់ដឹងរបស់ប្រជាពលរដ្ឋ

☆ ជួយគាំទ្រធ្វើឱ្យមានការអភិវឌ្ឍសង្គម។

ដោយមើលឃើញនូវគុណប្រយោជន៍នៃអង្គការសង្គមស៊ីវិលនោះហើយ ទើបគណៈកម្មការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គជអប) រៀបចំវគ្គបណ្តុះបណ្តាលនេះ

ដល់អង្គការសង្គមស៊ីវិល ដើម្បីឱ្យការអនុវត្តកម្មវិធីជាតិប្រកបដោយតម្លាភាព និងទទួលបាននូវភាពជោគជ័យកាន់តែមានប្រសិទ្ធភាព ។

ក្នុងភាពជាដៃគូ បណ្តាញអង្គការសង្គមស៊ីវិល មានកាតព្វកិច្ច និងតួនាទីដ៏សំខាន់ក្នុងការជួយជម្រុញដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិកាន់តែមានប្រសិទ្ធភាព ។

### ☞ ការពង្រឹងវិសាលភាពបណ្តាញអង្គការសង្គមស៊ីវិលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ

នៅក្នុងការអនុវត្តកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ បានផ្តល់ឱកាសឱ្យអង្គការសង្គមស៊ីវិលក្នុងការពង្រីងវិសាលភាពរបស់ខ្លួន ដើម្បីផ្សារភ្ជាប់ស្ថាប័ន និងបញ្ច្រាបបេសកកម្ម ឬ កម្មវិធីរបស់ខ្លួនទៅនឹងបេសកកម្មរបស់រាជរដ្ឋាភិបាល សំដៅធ្វើឱ្យការអភិវឌ្ឍនៅកម្ពុជាប្រកបដោយប្រជាធិបតេយ្យ និងមានប្រសិទ្ធភាព ។ បណ្តាញអង្គការសង្គមស៊ីវិលមានតួនាទីយ៉ាងសំខាន់ជួយគាំទ្រដល់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការអនុវត្តកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ក្នុងការលើកកម្ពស់ការយល់ដឹងដល់អង្គការសង្គមស៊ីវិល និងប្រជាពលរដ្ឋផ្តោតជាសំខាន់ទៅលើ :

- ✯ ការធ្វើកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ នៅក្នុងបរិបទការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ
- ✯ សមាសធាតុកម្មវិធីទាំង ៥:

១) ការរៀបចំស្ថាប័នរដ្ឋបាលថ្នាក់ក្រោមជាតិ

២) ប្រព័ន្ធគ្រប់គ្រង និងអភិវឌ្ឍធនធានមនុស្ស

៣) ការផ្ទេរមុខងារ

៤) ប្រព័ន្ធគ្រប់គ្រងថវិកាហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិនានា

៥) ស្ថាប័នគាំទ្រកំណែទម្រង់វិមជ្ឈការ និងវិហាសមជ្ឈការ និងអន្តរវិស័យទាំង៣ :

១) ការបញ្ជ្រាបយេនឌ័រ

២) ការប្រែប្រួលអាកាសធាតុ

៣) គណនេយ្យភាព និងការពារក្រុមជនក្រីក្រ និងក្រុមជនងាយរងគ្រោះ

- ✯ ទំនាក់ទំនងរវាងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និង កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- ✯ ជួយគាំទ្រ និងពង្រឹងសមត្ថភាពរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការធ្វើផែនការ ការគ្រប់គ្រង ហិរញ្ញវត្ថុ
- ✯ ការតាមដានត្រួតពិនិត្យ និងវាយតម្លៃការគ្រប់គ្រងបុគ្គលិក ការរៀបចំរបាយការណ៍ ការផ្សព្វផ្សាយព័ត៌មាន និងការដោះស្រាយវិវាទ សំដៅធ្វើយ៉ាងណាឱ្យការផ្តល់សេវាកម្ម នៅថ្នាក់ក្រោមជាតិប្រកបដោយប្រសិទ្ធិភាព និងមានគុណភាព ។
- ✯ ផ្តល់ព័ត៌មានត្រលប់ផ្នែកគោលនយោបាយជូនទៅរដ្ឋាភិបាល ឬក្រុមប្រឹក្សា
- ✯ លើកទឹកចិត្តប្រជាពលរដ្ឋឱ្យចូលរួមក្នុងកិច្ចប្រជុំនានារបស់រដ្ឋបាលនៅថ្នាក់ក្រោមជាតិ ទាក់ទងនឹងការរៀបចំផែនការ និងថវិការសម្រាប់ការអភិវឌ្ឍសហគមន៍មូលដ្ឋាន
- ✯ ត្រូវចាក់ទុកកម្មវិធីជាតិបេសកកម្មអាទិភាពរបស់បណ្តាញ

**☞ ឧទាហរណ៍ បណ្តាញអង្គការសង្គមស៊ីវិល/ស្ថាប័ន ដែលមានស្រាប់**

ខាងក្រោមនេះ គឺជាឧទាហរណ៍ អំពីបណ្តាញអង្គការសង្គមស៊ីវិលមួយចំនួនដែលយើងបានស្គាល់ មានដូចជា :

1. គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា (អង្គការ CCC) www.ccc-cambodia.org
2. គម្រោងគាំទ្រក្រុមប្រឹក្សា ឃុំ សង្កាត់ (CCSP) www.ccc-cambodia.org

3. ការិយាល័យទំនាក់ទំនងអង្គការសង្គមស៊ីវិល (NLO)

4. វេទិការអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា (The NGO Forum on Cambodia )

   www.ngoforumcambodia.org.kh

5. ក្រុមការងារវិមជ្ឈការតាមវយៈភាពដៃគូ (WGPD) ។ល។

## ៣. លើកកម្ពស់ប្រើប្រាស់ព័ត៌មាន

### តើអ្វីទៅជាព័ត៌មាន?

ពាក្យថា "ព័ត៌មាន " មាននិយមន័យជាច្រើនដូចជា:

- ✫ **ព័ត៌មាន** ត្រូវបានទទួលស្គាល់ថាជាពាក្យបច្ចេកទេសមួយម៉ាត់ ដែលអត្ថន័យរបស់វាមានវិសាលភាពធំធេង គ្រប់ដណ្តប់ទាំងបច្ច័យល្អ និងបច្ច័យអាក្រក់ ។
- ✫ **ព័ត៌មាន** គឺជាការនាំនូវដំណឹងនានាប្រាប់ដល់សាធារណៈជនឱ្យបានដឹងពីព្រឹត្តិការណ៍ ឬហេតុការណ៍ផ្សេងៗ ទាក់ទងនឹងកិច្ចសហប្រតិបត្តិការណ៍ កិច្ចការសាធារណៈ កិច្ចការរដ្ឋ កិច្ចការជំនួញ ភាពរីកចំរើន ឬចុះអន់ថយនៃសេដ្ឋកិច្ច នៅក្នុងប្រទេស តំបន់ និងសកលលោក ។
- ✫ **ព័ត៌មាន** មានទម្រង់ជាដំណឹងទាន់ហេតុការណ៍ សេចក្តីជូនដំណឹង សេចក្តីណែនាំ អត្ថបង្ហាញនូវក្តីកង្វល់រួមទៅលើបញ្ហាផលប៉ះពាល់អ្វីមួយទៅលើជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ។

### ❖ ហេតុអ្វីត្រូវលើកកម្ពស់ការប្រើប្រាស់ព័ត៌មាន?

មាន "**ព័ត៌មាន**" ជាច្រើនដែលបានផលិតហើយផ្ទុកដោយមធ្យោបាយផ្សេងៗ ពេលខ្លះព័ត៌មានមិនត្រូវបានយកមកប្រើប្រាស់ឱ្យអស់លទ្ធភាព និងមានប្រសិទ្ធភាពឡើយ។ ការប្រើប្រាស់ព័ត៌មានដ៏សំបូរបែបមានសារៈសំខាន់ជាច្រើន និងជំរុញជួយឱ្យ :

- ✯ ទំនាក់ទំនងកាន់តែល្អ ឬអាក្រក់ អាស្រ័យព័ត៌មាន ដែលយកប្រើប្រាស់
- ✯ មានការជឿជាក់ និងមានទំនុកចិត្តក្នុងការធ្វើការងារ ធ្វើបទបង្ហាញការថ្លែងសុន្ទរកថាសាធារណៈ ការបញ្ចេញនូវមតិយោបល់ ។ល។ ដោយសារតែការមានព័ត៌មានគ្រប់គ្រាន់ និងប្រភពដែលទុកចិត្ត ។
- ✯ មានចំណេះដឹងខ្ពង់ខ្ពស់ និងមានទស្សនៈទូលំទូលាយ
- ✯ ជួយអ្នកដទៃឱ្យមានទំនាក់ទំនងកាន់តែប្រសើរ (ក្នុងន័យផ្សះផ្សារ)
- ✯ ចែករំលែកទៅអ្នកដែលក្នុងបណ្តាញ
- ✯ ជួយឱ្យប្រតិបត្តិការបានកាន់តែល្អប្រសើរឡើង និងបង្កើនស្នាដៃ
- ✯ បានដឹងថាស្ថាប័នណាកំពុងធ្វើអ្វី? ស្ថាប័នណាខ្លះ ដែលធ្វើការនៅក្នុងវិស័យក្នុងដូចគ្នា? ស្ថាប័នណាខ្លះ ដែលធ្វើការពាក់ព័ន្ធនឹងកម្មវិធីជាតិ?
- ✯ ស្វែងរកការគាំទ្រទាំងខាងជំនួញ ស្មារតី និងថវិកាទ្រទង់ស្ថាប័ន

### ❖ តើព័ត៌មានអាចស្វែងរកបានតាមមធ្យោបាយណាខ្លះ?

យើងអាចស្វែងរក ព័ត៌មាន អាចរកបានតាមមធ្យោបាយផ្សេងៗ រួមមានៈ

- ✯ វិទ្យុ
- ✯ ទូរទស្សន៍
- ✯ ការសែត
- ✯ ទស្សនាវដ្តី
- ✯ បណ្ណាល័យ ឬបណ្ណាគារ និង

- និងអ៊ិនធឺណេត ។ល។

**តើព័ត៌មានស្តីពីកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ មានអ្វីខ្លះ?**

ខាងក្រោមនេះ គឺចំណងជើងឯកសារទាក់ទងនឹងកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ :

- កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ (២០១០-២០១៩)
- ក្របខណ្ឌយុទ្ធសាស្ត្រកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ (២០០៥)
- ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- អនុក្រឹត្យស្តីពីតួនាទី ភារៈកិច្ចទំនាក់ទំនងការងារក្រុមប្រឹក្សា គណៈអភិបាល (២០០៩ )
- សៀវភៅណែនាំ ស្តីពីគ្រូឧទ្ទេស គណនេយ្យភាពសង្គម (របស់អង្គការលើសការ ២០១០ )
- សៀវភៅណែនាំ គ្រូឧទ្ទេសរបស់ GTZ លើប្រធានបទ ច្បាប់ស្តីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

**បញ្ជាក់ :** ព័ត៌មានខាងលើអាចរកបាននៅលើវិបសាយ www.ncdd.gov.kh តាមទំព័រដូចខាងក្រោម :


Welcome to NCDD - Cambodia D&D - Windows Internet Explorer
http://www.ncdd.gov.kh/
NCDD
The National Committee for Sub-National Democratic Development
Home
About NCDD
Legal Framework
National Program
News/Events
Partners/Projects
Accountability
Resources
Jobs & Procurement
Contact us
NCDD Logo
Annual Workplan and Budget
Capacity Development
Database
Documents
Procedures
Structures
Visual material
Others
Workshop
Brochures/ Posters
Case study
Manual & Guidelines
Reports
Speeches
Studies
District and Provincial Data Books
Safeguard
D&D Basic Principles
The reform of the sub-national governance system shall aim to: (i) consolidate and deepen the...
D&D Strategy
This Strategic Framework for Decentralization and De-concentration Reforms is a policy statement of how the...
Working Calendar
Working calendar for the implementation of the Law on Administrative Management of the Capital, ...
Preliminary Implementation Framework
The reform on decentralization and deconcentration
Message from the Chairman
On behalf of the National Committee for Sub-National
POPULAR
2011 Contractor
Announcement of ICC and DI
Schedule in 2010
Announcement of NRML Project Bidding Schedule in 2010


Downloads | Manual & Guidelines | Documents - Windows Internet Explorer
http://www.ncdd.gov.kh/resources/documents/manual-a-guidelines
Manual & Guidelines
Home
Search
Documents
Order by : Name | Date | Hits [ Ascendant ]
2010 National Program (English) Hits: 1279 Size : 744.31 kB
2010 National Program (Khmer) Hits: 1362 Size : 2.01 MB
District Databook User Manual 2009 Hits: 812 Size : 799.5 kB
2009 NCDD CSF Technical Manual Volume III Construction Supervision KH Hits: 568 Size : 605.16 kB
2009 NCDD CSF Technical Manual Volume II Specifications for Construction KH Hits: 546 Size : 875.24 kB
2009 NCDD CSF Technical Manual Vol 1 Study & Design Guidelines KH Hits: 805 Size : 9.58 MB
2009 NCDD CSF Technical Manual Volume III Construction Supervision Hits: 568 Size : 460.22 kB
Announcements
An Analysis of the Commune Development Planning Data Base
Poverty and Select CMDGs Maps and Charts 2003-2009
Search
Other Menu
D&D Strategy
D&D Basic Principles
List of abbreviations
Announcement
Visitor Statistic
Today: 199
This month: 576

## ៤. អត្ថប្រយោជន៍ការប្រើប្រាស់សម្ភារៈជំនួយស្មារតីដែលបានចែកក្នុងផ្សព្វផ្សាយនៅក្នុងវគ្គបណ្តុះបណ្តាល

សម្ភារៈដែលចែកចាយជាឯកសារយោងនានាទាក់ទងនឹងកម្មវិធីសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិមានអត្ថប្រយោជន៍ប្រើប្រាស់ :

- ✯ រៀបចំវគ្គបណ្តុះបណ្តាលបន្តនៅក្នុងតំបន់របស់ខ្លួន
- ✯ ឯកសារជំនួយស្មារតីសម្រាប់ធ្វើការអប់រំផ្សព្វផ្សាយបន្ត
- ✯ សម្រាប់លើកកម្ពស់ការយល់ដឹងរបស់ប្រជាពលរដ្ឋឱ្យបានទូលំទូលាយ
- ✯ ជួយឱ្យប្រតិបត្តិការបានកាន់តែល្អប្រសើរ និងបង្កើតស្នាដៃ
- ✯ ជាជំនួញស្មារតីក្នុងការស្វែងរកថវិកាដើម្បីទ្រទ្រង់ស្ថាប័ន

## ៥. សេចក្តីសន្និដ្ឋាន

១) ការលើកកម្ពស់ការប្រើប្រាស់ (Network ) ដែលមានស្រាប់មានអត្ថប្រយោជន៍ និងសារៈសំខាន់ក្នុងការជួយជម្រុញឱ្យអនុវត្តកម្មវិធីជាតិកាន់តែមានប្រសិទ្ធភាព និងប្រកបដោយតម្លាភាព

២) លើកកម្ពស់ការប្រើប្រាស់ព័ត៌មានដែលមានស្រាប់ ដើម្បីបង្កើនការជឿជាក់ និងទំនុកចិត្ត។

៣ មេរៀនទី

ប្លង់មេរៀន

# ការលើកកម្ពស់ការប្រើប្រាស់បណ្តាញអង្គការសង្គមស៊ីវិល និងព័ត៌មាននៅរដ្ឋបាលថ្នាក់ក្រោមជាតិ

**រយៈពេល:** ៦៥ នាទី

## តើត្រូវសម្របសម្រួលមេរៀននេះយ៉ាងដូចម្តេច?

| ម៉ោង | សកម្មភាព និងវិធីសាស្ត្រ | សម្ភារៈ/ឯកសារ |
|---|---|---|
| ៥ នាទី | **សកម្មភាពទី ១ ល្បែងថាមពល**<br>លេងល្បែងថាមពលដើម្បីអោយសិក្ខាកាមសកម្ម និងមានថាមពល<br>**កំណត់សម្គាល់:** អ្នកសម្របសម្រួលអាចដឹកនាំលេងខ្លួនឯង ឬស្នើឱ្យអ្នកចូលរួមដឹកនាំលេងក៏បាន | |
| ១០ នាទី | **សកម្មភាពទី ១: ការណែនាំ និងបង្ហាញអំពីគោលបំណង**<br>១. បង្ហាញស្លាយ និងក្រដាសផ្ទាំងធំ ដើម្បីបង្ហាញដោយសង្ខេបអំពីគោលបំណងនៃមេរៀន<br>២. បញ្ជាក់អំពីគោលបំណងចំបងៗរបស់មេរៀននេះ ហើយពន្យល់ឱ្យបានច្បាស់ ដើម្បីឱ្យអ្នកចូលរួមបានកាន់តែយល់អំពីគោលបំណងបន្ទាប់ពីបានរៀនចប់មេរៀននេះ។ | -ផ្ទាំងរូបភាព<br>-ក្រដាសផ្ទាំងធំ<br>-ហ្វីត |
| ២០ នាទី | **សកម្មភាពទី ២: បទបង្ហាញ ស្តីពី ការលើកកម្ពស់ ការប្រើប្រាស់បណ្តាញ អង្គការ សង្គមស៊ីវិល នៅថ្នាក់ក្រោម ជាតិ**<br>១. សិក្ខាកាមអំពីហេតុផលនៃការធ្វើជាបណ្តាញ ឧទាហរណ៍: បណ្តាញ និងជួយដល់អង្គការសង្គមស៊ីវិល NGOs/CBOs ដូចជា: | -ក្រដាសផ្ទាំងធំ<br>-ហ្វីត |

| ម៉ោង | សកម្មភាព និងវិធីសាស្រ្ត | សម្ភារៈ/ឯកសារ |
|---|---|---|
| | ➢ ចែករំលែកព័ត៌មាន<br>➢ ជួយគ្នាទៅវិញទៅមក<br>➢ ផ្តល់ព័ត៌មានបានច្បាស់លាស់<br>២. ផ្តល់ជាឧទាហរណ៍ជាក់ស្តែងខ្លះៗ ដែលមានរៀបរាប់នៅក្នុងមេរៀន<br>៣. ផ្តល់នូវសំណួរគន្លឹះមួយចំនួនដល់សិក្ខាកាម ថាតើពួកគេបានស្គាល់បណ្តាញណាខ្លះនៅក្នុងខេត្ត តំបន់ និងថា្នក់ជាតិ ដូចជា:<br>➢ តើអ្នកដើរតួរជាអ្វីនៅក្នុងបណ្តាញនៅក្នុងលោកអ្នក?<br>➢ តើវាជាបណ្តាញអ្វីនៅក្នុងតំបន់នោះ<br>➢ តើអ្វីទៅដែលភ្ជាប់ទំនាក់ទំនងជាមួយអ្នក ហើយមានអ្វីកើតឡើងទេនៅ ភ្នំពេញ (ទូទាំងប្រទេស)<br>៤. សង្ខេបឡើងវិញដើម្បីអោយដឹងច្បាស់អំពីបណ្តាញដែលមានស្រាប់ | - ស្លាយ |
| ២០ នាទី | **<u>សកម្មភាពទី ៣: បទបង្ហាញ:</u>**<br>**លើកកម្ពស់ការប្រើប្រាស់ប្រភពព័ត៌មាន**<br>១. បង្ហាញស្លាយ និងក្រដាសផ្ទាំងធំ ដើម្បីផ្តល់ព័ត៌មានដល់សិក្ខាកាមដើម្បីកំណត់ ការប្រើប្រាស់គេហទំព័រ និងការចែករំលែកព័ត៌មាន។ បង្ហាញស្លាយរាយឈ្មោះឯកសារទាំងឡាយដែលមាននៅលើវិបសាយរបស់ **គ.ជ.អ.ប** (NP-SNDD)។<br>២. ផ្តល់នូវឯកសារមួយចំនួនទាំង អេឡិចត្រូនិច និង ឯកសារ | -ក្រដាសផ្ទាំងធំ<br>- ស្លាយ<br>www.ncdd.gov.kh<br>-តារាង សម្ភារៈសម្រាប់អប់រំផ្សព្វផ្សាយ |

| ម៉ោង | សកម្មភាព និងវិធីសាស្ត្រ | សម្ភារៈ/ឯកសារ |
|---|---|---|
| | ថតចម្លង និងសម្ភារៈសម្រាប់អប់រំផ្សព្វផ្សាយ | |
| ១០ នាទី | **សកម្មភាពទី ៤: សេចក្តីសន្និដ្ឋាន**<br>ផ្តល់នូវការសន្និដ្ឋានដ៏ខ្លីជាថ្មីម្តងទៀត ដែលជាការសំយោគមេរៀនដល់អ្នកចូលរួម អំពីអត្ថប្រយោជន៍នៃការប្រើប្រាស់បណ្តាញ និងព័ត៌មាន។<br>**ចប់មេរៀនទី៣ ថ្ងៃទី៣** | |

## សម្ភារៈនិងឧបករណ៍សម្រាប់ប្រើប្រាស់នៅក្នុងមេរៀននេះ

- តារាងនៃប្រភពព័ត៌មានផ្សេងៗបន្ថែមទៀត
- ឯកសារក្រដាសមេរៀន
- ហ្វីត ក្រដាសផ្ទាំងធំ ស្កុត ក្រដាសពណ៌
- បទបង្ហាញ

## ឯកសារយោងនិងប្រភពព័ត៌មានផ្សេងៗទៀត:

- សម្ភារៈអប់រំផ្សព្វផ្សាយដែលមានស្រាប់សំរាប់ប្រើប្រាស់នៅមេរៀនមុនៗ
- វិបសាយ www.ncdd.gov.kh
- ភ្ជាប់ទំនាក់ទំនងអ្នកពាក់ព័ន្ធផ្សេងៗដូចជា GTZ, WB, ជាដើម

# មេរៀនទី ៤

## ការរំលឹកមេរៀន និងទស្សនៈវិស័យរបស់សិក្ខាកាមក្នុងការលើកកម្ពស់ការយល់ដឹងបន្តដល់សង្គមស៊ីវិលអំពីកម្មវិធីជាតិ

មេរៀនទី ៤

# ការរំលឹកមេរៀន និងទស្សនៈវិស័យរបស់សិក្ខាកាមក្នុងការលើកកម្ពស់ការយល់ដឹងបន្តដល់សង្គមស៊ីវិលអំពីកម្មវិធីជាតិ

**គោលបំណង** : នៅចុងបញ្ចប់នៃមេរៀននេះសិក្ខាកាមអាចៈ

- មានការជឿជាក់ និងមានទំនុកចិត្តលើសមត្ថភាពកាន់តែខ្លាំង និងសម្រេចចិត្តថាគួរជ្រើសរើសវិធីសាស្ត្រយ៉ាងដូចម្តេច ក្នុងការផ្ទេរ ពន្យល់ ផ្សព្វផ្សាយ និងប្រើប្រាស់ចំណេះដឹងដែលទទួលបានពីវគ្គបណ្តុះបណ្តាល ដើម្បីចែករំលែកបន្តដល់ប្រធាន អ្នកគ្រប់គ្រង សហសេវិក និងអង្គការដៃគូ នៅក្នុងសហគមន៍របស់ខ្លួន។
- សង្ខេបអំពីអ្វីដែលបានរៀនកន្លងមក
- សួរបញ្ជាក់អំពីសំនួរដែលមិនទាន់បានឆ្លើយ និងផ្តល់យោបល់ត្រឡប់នៅក្នុងរយៈពេល៣ថ្ងៃនេះ

## លទ្ធផលរំពឹងទុកនៃមេរៀន

ក). សិក្ខាកាមមានការយល់ច្បាស់អំពីហេតុការណ៍ និងដឹងថាតើពេលណាដែលត្រូវរៀនបន្ថែមទៀត

ខ). សិក្ខាកាមទទួលស្គាល់ពីដំណើរការរបស់កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដែលមិនទាន់បានឆ្លើយសំនួរ ហើយអាចរៀនសូត្របន្តនូវព័ត៌មានលំអិតបន្ថែមទៀត

គ). សិក្ខាកាមត្រូវបានជ្រើសរើសសម្រាប់វគ្គបណ្តុះបណ្តាលគ្រូបង្គោល និងវគ្គបន្ទាប់ត្រូវបានលើកទឹកចិត្តអោយចូលរួម។

## កំណត់ចំណាំសម្រាប់អ្នកសម្របសម្រួល

នៅក្នុងមេរៀននេះអ្នកសម្របសម្រួលមានគោលបំណង២សំខាន់ៗ:

១. ការបណ្តុះបណ្តាលរយៈពេល៣ថ្ងៃទៅលើការយល់ដឹងអំពីប្រវត្តិរបស់ កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ចក្ខុវិស័យ



ជំពូកទី៣

និងគោលបំណងជាពិសេសនៅក្នុងទម្រង់ទី១ (២០១១-២០១៣)។ សិក្ខាកាមបានដឹងអំពីព័ត៌មាននេះជាលើកទី១ ហើយទន្ទឹមនឹងនេះផងដែរ អ្នកសម្របសម្រួលក៏បានរៀនសូត្រអំពីកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិដែរ។ មានសំនួរជាច្រើនត្រូវបានសួរ ប៉ុន្តែសំនួរខ្លះពុំត្រូវបានឆ្លើយភ្លាមៗទេនៅក្នុងអំឡុងពេលនៃការបណ្តុះបណ្តាលនេះ។ យើងនឹងបញ្ជាក់ឡើងវិញនូវសំនួរដែលមានសារៈសំខាន់ហើយពុំទាន់បានឆ្លើយ។ មុនពេលចាប់ផ្តើមមេរៀនអ្នកសម្របសម្រួលត្រូវកត់សំនួរដែលប្រមូលបានក្នុងរយៈពេលបណ្តុះបណ្តាល ៣ថ្ងៃកន្លងមក។ អ្នកសម្របសម្រួលត្រូវរក្សាបញ្ជីសំនួរចាប់តាំងពីថ្ងៃទី១មក។

២. សិក្ខាកាមបានប្រមូលព័ត៌មានរួចហើយកាលពីថ្ងៃទី១ និងថ្ងៃទី២ ប៉ុន្តែពុំបានពិភាក្សាល្អិតល្អន់នៅឡើយទេថាតើអ្វីខ្លះដែលត្រូវធ្វើបន្ទាប់ពីវគ្គបណ្តុះបណ្តាលនេះ។ គោលបំណងទី១ របស់អ្នកសម្របសម្រួលគឺត្រូវធ្វើយ៉ាងណា អោយសិក្ខាកាមមានទំនុកចិត្ត ដើម្បីពង្រីកការយល់ដឹងលើកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិក្នុងចំណោមបុគ្គលិក និងអ្នកដឹកនាំអង្គការសង្គមស៊ីវិល។

# ជំពូកទី ៣ : មេរៀនទី ៤

# ការរំលឹកមេរៀន និងទស្សនៈវិស័យរបស់សិក្ខាកាមក្នុងការលើកកម្ពស់ការយល់ដឹងបន្តដល់សង្គមស៊ីវិលអំពីកម្មវិធីជាតិ

## គោលបំណងនៃមេរៀន

១) មានការជឿជាក់ និងមានទំនុកចិត្តលើសមត្ថភាពកាន់តែខ្លាំង និងសម្រេចចិត្តថាគួរជ្រើសរើសវិធីសាស្ត្រយ៉ាងដូចម្តេចក្នុងការផ្ទេរ ពន្យល់ ផ្សព្វផ្សាយ និងប្រើប្រាស់ចំណេះដឹងដែលទទួលបានពីវគ្គបណ្តុះបណ្តាល ដើម្បីចែករំលែកបន្ត ដល់ប្រធានអ្នកគ្រប់គ្រងសហសេវិក និងអង្គការដៃគូនៅក្នុងសហគមន៍របស់ខ្លួន ។

២) បានយល់កាន់តែច្បាស់ ហើយអាចសង្ខេបបាននូវអ្វី ដែលបានសិក្សាក្នុងរយៈពេលបីថ្ងៃមកនេះ នឹងដឹងថាតើត្រូវស្វែងយល់ និងរៀនបន្ថែមអ្វីទៀត ។

៣) ទទួលស្គាល់ពីសំនួរទាំងឡាយអំពីដំណើរការកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដែលមិនទាន់បានឆ្លើយ ហើយទាមទារឱ្យមានការរៀនសូត្របន្តដោយស្វែងរកនូវព័ត៌មានលំអិតថែមទៀត ។

2

## ទស្សនៈវិស័យរបស់សិក្ខាកាមក្នុងការលើកកម្ពស់ ការយល់ដឹងបន្តដល់សង្គមស៊ីវិលអំពីកម្មវិធីជាតិ

**ការពិភាក្សាជាក្រុម**

“តើសិក្ខាកាមមានទស្សនៈវិស័យក្នុងការលើកកម្ពស់ ការយល់ដឹងអំពីកម្មវិធីជាតិដល់ប្រធាន អ្នកគ្រប់គ្រង សហសេវិក និងអង្គការដៃគូយ៉ាងដូចម្តេចបន្ទាប់ពីវគ្គបណ្តុះបណ្តាលនេះ ?”

3

## ទស្សនៈវិស័យរបស់សិក្ខាកាមក្នុងការលើកកម្ពស់ ការយល់ដឹងបន្តដល់សង្គមស៊ីវិលអំពីកម្មវិធីជាតិ “ត”

ការបង្ហាញលទ្ធផលក្រុមពិភាក្សា

- សូមស្ម័គ្រចិត្តពីក្រុម មកធ្វើបទបង្ហាញក្រុមនីមួយៗ មានពេល ៥ នាទី
- ចំពោះក្រុមដទៃទៀត អាចចូលរួមផ្តល់គំនិតយោបល់ប្រសិនបើមានអ្វី ចង់បន្ថែមលើក្រុមទាំងពីរ

?

4

## រំលឹកមេរៀន

ឧទាហរណ៍អំពីចំណុចសំខាន់ៗ នៅក្នុងមេរៀនដែលបានរៀនកន្លងមករយៈពេលបីថ្ងៃមានដូចជា :

- ប្រវត្តិកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ
- អភិបាលកិច្ច និងទស្សនទាននៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ
- តួនាទី និងការទទួលខុសត្រូវរបស់សង្គមស៊ីវិលក្នុងកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ
- ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- ការណែនាំពីកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ

5

## រំលឹកមេរៀន "ត"

- ការគ្រប់គ្រងកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ
- លិខិតបទដ្ឋានគតិយុត្តគាំទ្រការអនុវត្តកម្មវិធីជាតិ
- ការយល់ឃើញរបស់អង្គការសង្គមស៊ីវិលក្នុងការភ្ជាប់ទំនាក់ទំនងជាមួយក្រុមប្រឹក្សាថ្នាក់ក្រោមជាតិ
- ការចូលរួមរបស់អង្គការសង្គមស៊ីវិលក្នុងការភ្ជាប់ទំនាក់ទំនងជាមួយក្រុមប្រឹក្សាថ្នាក់ក្រោមជាតិ
- លើកកម្ពស់ការប្រើប្រាស់បណ្តាញអង្គការសង្គមស៊ីវិល និងព័ត៌មាននៅរដ្ឋបាលថ្នាក់ក្រោមជាតិ។

?

6

ជំពូកទី៣

## សំនួរដែលមិនមានចម្លើយ និងយោបល់ត្រឡប់




7

## បញ្ជីសំណួរដែលមិនមានចម្លើយ

គួរបញ្ចូលទិន្នន័យប្រសិនបើអាចធ្វើបាន

# សន្និដ្ឋាន

វគ្គបណ្តុះបណ្តាលនេះនឹងជួយអោយសិក្ខាកាមមានការយល់ដឹងច្រើនពីកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ហើយក៏រំពឹងថាសិក្ខាកាមម្នាក់ៗ ដែលបានចូលរួមក្នុងវគ្គបណ្តុះបណ្តាលរយៈពេល បីថ្ងៃនេះនឹងធ្វើការចែករំលែកព័ត៌មានទាំងនេះទៅអោយអ្នកដទៃទៀត នៅពេលដែលពួលគេត្រឡប់ទៅធ្វើការងារវិញ ។

**សូមអរគុណ!**

9

**ឯកសារចែក**

# ការរំលឹកមេរៀន និងទស្សនៈវិស័យរបស់សិក្ខាកាមក្នុងការលើកកម្ពស់ការយល់ដឹងបន្តដល់សង្គមស៊ីវិលអំពីកម្មវិធីជាតិ

## ១. គោលបំណងនៃមេរៀន

ចំពោះមេរៀនក្នុងផ្នែកនេះ បានរៀបចំឡើងក្នុងគោលបំណង ដោយរំពឹងថាបន្ទាប់ពីសិក្សាមេរៀននេះចប់សិក្ខាកាមទាំងអស់ :

១) មានការជឿជាក់ និងមានទំនុកចិត្តលើសមត្ថភាពកាន់តែខ្លាំង និងសម្រេចចិត្តថាគួរជ្រើសរើសវិធីសាស្ត្រយ៉ាងដូចម្តេចក្នុងការផ្ទេរ និងប្រើប្រាស់ចំណេះដឹង ដែលទទួលបានពីវគ្គបណ្តុះបណ្តាល ដើម្បីចែករំលែកបន្តដល់ ប្រធាន អ្នកគ្រប់គ្រង សហសេវិក និងអង្គការដៃគូនៅក្នុងសហគមន៍ខ្លួន ។

២) បានយល់កាន់តែច្បាស់ ហើយអាចសង្ខេបបាននូវអ្វី ដែលបានសិក្សាក្នុងរយៈពេលបីថ្ងៃមកនេះ និងដឹងថាតើត្រូវស្វែងយល់ និងរៀនបន្ថែមអ្វីទៀត ។

៣) ទទួលស្គាល់ពីសំនួរទាំងឡាយអំពីដំណើរការកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដែលមិនទាន់ឆ្លើយ ហើយទាមទារឱ្យមានការរៀនសូត្របន្តដោយការស្វែងរកនូវព័ត៌មានលំអិតថែមទៀត។

## ២. ទស្សនៈវិស័យរបស់សិក្ខាកាមក្នុងការលើកកម្ពស់ការយល់ដឹងបន្តដល់សង្គមស៊ីវិលអំពីកម្មវិធីជាតិ

ការពិភាក្សាជាក្រុមរៀបចំឡើង ដើម្បីស្តាប់ស្ទង់ពីទស្សនៈរបស់សិក្ខាកាមក្នុងការលើកកម្ពស់ការយល់ដឹង ដែលអង្គការសង្គមស៊ីវិលបន្តនូវអ្វីដែលបានសិក្សាក្នុងរយៈពេលបីថ្ងៃមកនេះ ។

ការពិភាក្សានឹងប្រព្រឹត្តទៅតាមសំនួរ ដែលសរសេរថា តើសិក្ខាកាមមានទស្សនវិស័យក្នុងការលើកកម្ពស់ការយល់ដឹងអំពីកម្មវិធីជាតិដល់ប្រធាន អ្នកគ្រប់គ្រង សហសេវិក និងសហការី ឬដៃគូយ៉ាង

ដូចម្តេចបន្ទាប់ពីវគ្គបណ្តុះបណ្តាលនេះ។ លទ្ធផលនៃការសិក្សា អាស្រ័យលើការជជែក ផ្លាស់ប្តូរយោបល់នៃក្រុមនីមួយៗ ក៏ប៉ុន្តែសង្ឃឹមថាការលទ្ធផលនឹងមិនសូវខុសប្លែកពីឧទាហរណ៍ចូលរួមខាងក្រោមឡើយៈ

ការផ្ទេរចំណេះដឹងអាចរៀបចំបានតាមរយៈ

- ការប្រជុំគណៈកម្មាធិការប្រតិបត្តិ ប្រជុំគណៈកម្មាធិការគ្រប់គ្រង ឬប្រជុំបុគ្គលិកប្រចាំខែ
- ការបញ្ជ្រាប និងកែសម្រួលផែនការយុទ្ធសាស្រ្តស្ថាប័ន
- បញ្ជ្រាបតាមកម្មវិធីដែលមានស្រាប់"

## ៣. ការរំលឹកមេរៀន

តាមរយៈការបណ្តុះបណ្តាលចំនួនពីរថ្ងៃកន្លះកន្លងមកនេះ សិក្ខាកាមបានយល់ដឹងអំពីទិដ្ឋភាពទូទៅហើយក៏បានយល់ពីតួនាទីអង្គការសង្គមស៊ីវិលក្នុងការចូលរួមគាំទ្រដល់ការអនុវត្តកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រធិបតេយ្យនៅថ្នាក់ក្រោមជាតិ។ ចំពោះវគ្គបណ្តុះបណ្តាលចុងក្រោយនេះបានរៀបចំឡើងក្នុងគោលបំណងធ្វើយ៉ាងណាឱ្យសិក្ខាកាមមានទំនុកចិត្ត និងមានការជឿជាក់លើខ្លួនឯងកាន់តែខ្លាំងថែមទៀតក្នុងការផ្ទេរ និងប្រើប្រាស់ចំណេះដឹង ដែលទទួលបានពីវគ្គបណ្តុះបណ្តាល ដើម្បីចែករំលែកបន្ត ។ ដូច្នេះការរំលឹកមេរៀនឡើងវិញ គឺជាវិធីសាស្រ្តជួយឱ្យសិក្ខាកាមបានយល់កាន់ច្បាស់។ មេរៀនសំខាន់ៗ ដែលវគ្គបណ្តុះបណ្តាលបានផ្តល់ដល់សិក្ខាកាមរួមមាន :

### ថ្ងៃទី១:

១) ប្រវត្តិកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ : ខ្លឹមសារនៅក្នុងមេរៀននេះផ្តោតសំខាន់លើរឿងរ៉ាវនានាទាក់ទងទៅនឹងក្របខណ្ឌយុទ្ធសាស្រ្តកំណែទម្រង់វិមជ្ឈការ និង វិសហមជ្ឈការនៅក្នុងបរិបទការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ

២) អភិបាលកិច្ច និងទស្សនទានៃកំណែទម្រង់ វិមជ្ឈការ និង វិសហមជ្ឈការ : ខ្លឹមសារនៅក្នុងមេរៀននេះផ្តោតសំខាន់ធ្វើយ៉ាងណាឱ្យសិក្ខាកាមបានស្វែងយល់អំពីអភិបាលកិច្ចនិងការអភិវឌ្ឍ

តាមបែបប្រជាធិបតេយ្យ និងការចូលរួមជាសាធារណៈ ហើយក៏ពិពណ៌នាអំពីការរីកចម្រើន និងឥទ្ធិពល នៃកំណែទម្រង់វិមជ្ឈការ និងសហវិមជ្ឈការ (២០០៥-២០០៩) ដោយការរំលឹកឡើងវិញនូវគោលបំណង និងគោលការណ៍ទាំង៦ នៃវិមជ្ឈការ និងវិសហមជ្ឈការ ។

៣) តួនាទី និងការរួមចំណែករបស់សង្គមស៊ីវិលក្នុងកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ : ខ្លឹមសារមេរៀនផ្ដោតសំខាន់ទៅលើតួនាទី និងការរួមចំណែករបស់ប្រជាពលរដ្ឋ និងអង្គការសង្គមស៊ីវិល។

៤) ច្បាប់ស្ដីពីការគ្រប់គ្រប់រដ្ឋបាល រាជធានី ខេត្ត ស្រុក ខ័ណ្ឌ : ខ្លឹមសារនៅក្នុងមេរៀននេះសំខាន់ធ្វើយ៉ាងណាឱ្យសិក្ខាកាមបានយល់ច្បាស់ ហើយមានការជឿជាក់ថាខ្លួនអាចពន្យល់បាននូវបញ្ហាដែលជាឥទ្ធិពលកើតចេញពីច្បាប់ស្ដីពីការគ្រប់គ្រង រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ផ្សារភ្ជាប់ទៅនឹងការរៀបចំផែនការជាតិផងដែរ។

**ថ្ងៃទី២:**

១) ការណែនាំស្ដីពីកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ខ្លឹមសារមេរៀនបានរៀបរាប់: ១) ពីគោលបំណង និងទិសដៅ ២) បរិយាយអំពីរចនាសម្ព័ន្ធនៃកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិផ្ដោតលើសមាសធាតុទាំង៥ និងកម្មវិធីអន្តរវិស័យទាំង៣ និង ៣) និយាយអំពីទំនាក់ទំនងរវាងច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។

២) ការគ្រប់គ្រងកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (២០១០-២០១៩) ខ្លឹមសារសំខាន់នៃមេរៀនរួមមាន : ១) ដំណាក់កាលសម្រាប់អនុវត្តកម្មវិធីជាតិ និងលទ្ធផលរំពឹងទុកក្នុងដំណាក់កាលទី១ ២) ទិដ្ឋភាពទូទៅនៃក្របខណ្ឌការងារតាមដាន និងវាយតម្លៃសម្រាប់កត់ត្រាលទ្ធផលរីកចំរើនរបស់កម្មវិធីជាតិ ៣) ទិដ្ឋភាពទូទៅនៃខ្សែគណនេយ្យភាពទាំង៤សម្រាប់អនុវត្តសមាធាតុកម្មវិធីនៅក្នុងកម្មវិធីជាតិ ៤) ទិដ្ឋភាព

ទូទៅនៃកត្តាសំខាន់ៗ មួយចំនួន ដែលមានឥទ្ធិពលលើលទ្ធផលរបស់កម្មវិធី និង ៥) គូសបញ្ជាក់ពីតួនាទី និងការទទួលខុសត្រូវរបស់អ្នកពាក់ព័ន្ធ ។

៣) លិខិតបទដ្ឋានគតិយុត្តគាំទ្រកម្មវិធី: ខ្លឹមសារមេរៀនផ្តោតយ៉ាងណាឱ្យសិក្ខាកាមបាន : ១) យល់ដឹងអំពីលិខិតបទដ្ឋានគតិយុត្តគាំទ្រដល់ការអនុវត្តកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ២) យល់ដឹងអំពីគោលនយោបាយដែលបានអនុម័តពាក់ព័ន្ធនឹងការចូលរួមរបស់អង្គការសង្គមស៊ីវិលក្នុងដំណើរការអនុវត្តកម្មវិធីជាតិ ៣) បង្ហាញពីការណែនាំខាងគោលនយោបាយស្តីពីវិមជ្ឈការ និងសហវិមជ្ឈការក្នុងការអនុវត្តកម្មវិធីជាតិ។

៤) ទស្សនៈទាននៃការផ្សារភ្ជាប់ទំនាក់ទំនងជាមួយកម្មវិធីជាតិ: ខ្លឹមសារមេរៀនផ្តោតជាសំខាន់ធ្វើយ៉ាងណាឱ្យសិក្ខាកាមបានយល់ដឹងពីភាពចាំបាច់ត្រូវមានការភ្ជាប់ទំនាក់ទំនងសង្គមស៊ីវិលជាមួយកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងពិពណ៌នាទូវឱកាសចំនួនពីរផ្សេងៗគ្នាសម្រាប់ សង្គមស៊ីវិលក្នុងការទំនាក់ទំនង។

**ថ្ងៃទី៣:**

មេរៀនថ្ងៃទី៣ពេលព្រឹក បានផ្តោតជាសំខាន់លើការចូលរួមរបស់សង្គមស៊ីវិលក្នុងការភ្ជាប់ទំនាក់ទំនងជាមួយក្រុមប្រឹក្សាថ្នាក់ក្រោមជាតិ ដែលបទបង្ហាញបានគូសបញ្ជាក់អំពីយុទ្ធសាស្ត្រជាមូលដ្ឋានគ្រឹះមួយចំនួនដើម្បីឱ្យសង្គមស៊ីវិលបានដឹង ១) សកម្មភាពអាទិភាពសម្រាប់ការភ្ជាប់ទំនាក់ទំនងរវាងសង្គមស៊ីវិលទៅនឹងកម្មវិធីជាតិ ២) គោលការណ៍ណែនាំលើចំណុចដើម្បីភ្ជាប់ទំនាក់ទំនងក្នុងកំឡុងពេលនៃការអនុវត្តកម្មវិធីជាតិ ដោយរួមបញ្ចូលការតាមដានការអនុវត្ត និងការផ្តល់ព័ត៌មានត្រលប់ដល់ គ.ជ.អ.ប និង ៣) គោលការណ៍ណែនាំលើចំណុច ដើម្បីលើកទឹកចិត្តក្រុមមិនសូវមានតំណាងឱ្យមានតំណាងឱ្យមានសម្លេងនៅក្នុង កិច្ចការមូលដ្ឋាន និងកិច្ចការនៅថ្នាក់ក្រោមជាតិ ។

## ៤. សំណួរមិនមានចម្លើយ

ការប្រមូលសំណួរមិនមានចម្លើយធ្វើឡើង ដើម្បីស្តាប់ស្ទង់អំពីយោបល់ជុំវិញប្រធានបទ។ បញ្ជីសំណួរ និងសំណើរទាំងអស់ ដែលបានលើកឡើងក្នុងកំឡុងពេលបណ្តុះបណ្តាល៣ថ្ងៃ និងបង្ហាញ

ឡើងវិញឱ្យសិក្ខាកាមបានដឹង។ ការសរុបសេចក្តីនូវរាល់សំនួរដែលបានសរសេរឡើងនោះនឹងបញ្ជូនបន្តទៅគ.ជ.អ.ប ដើម្បីអោយពួកគេដឹងពីចំណាប់អារម្មណ៍របស់អង្គការសង្គមស៊ីវិលក្នុងការចង់ចេះចង់ដឹងបន្ថែមទៀត ។

## ៥. សេចក្តីសន្និដ្ឋាន

វគ្គបណ្តុះបណ្តាលនេះ នឹងជួយអោយសិក្ខាកាមមានការយល់ដឹងច្រើនពីកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ហើយក៏រំពឹងថាសិក្ខាកាមម្នាក់ៗ ដែលបានចូលរួមក្នុងវគ្គបណ្តុះបណ្តាលរយៈពេលបីថ្ងៃនេះ នឹងធ្វើការចែករំលែកព័ត៌មានទាំងនេះទៅអោយអ្នកដទៃទៀតនៅពេលដែលពួលគេត្រឡប់ទៅធ្វើការងារវិញ ។

# មេរៀនទី ៤

## ប្លង់មេរៀន

**ប្រធានបទ :** ការរំលឹកមេរៀន និងទស្សនៈវិស័យរបស់សិក្ខាកាមក្នុងការលើកកម្ពស់ការយល់ដឹងបន្តដល់សង្គមស៊ីវិលអំពីកម្មវិធីជាតិ

**រយៈពេល :** ៧០ នាទី

### តើគ្រូវសម្របសម្រួលមេរៀននេះយ៉ាងដូចម្តេច?

| ម៉ោង | សកម្មភាព និងវិធីសាស្ត្រ | សម្ភារៈ និងឯកសារ |
|---|---|---|
| ៥ នាទី | **សកម្មភាពទី ១: ការណែនាំ និងគោលបំណង**<br>១. បង្ហាញស្លាយ ឬក្រដាសផ្ទាំងធំ ដើម្បីបង្ហាញដោយសង្ខេបអំពីគោលបំណងនៃមេរៀន<br>២. បញ្ជាក់អំពីគោលបំណងចំបងៗរបស់មេរៀននេះក្នុងការជួយដល់សិក្ខាកាមឱ្យយល់ច្បាស់អំពីអ្វីពួកគាត់អាចធ្វើបានបន្ទាប់បញ្ចប់មេរៀននេះទៅ | - បទបង្ហាញទី២<br>- ផ្ទាំងរូបភាព<br>-ក្រដាសផ្ទាំងធំ<br>-ហ្វឺត |
| ១៥ នាទី | **សកម្មភាពទី ២:** បំផុសគំនិតអំពីចក្ខុវិស័យរបស់សិក្ខាកាមក្នុងការផ្ទេរ ពន្យល់ ផ្សព្វផ្សាយ និងប្រើប្រាស់ចំណេះដឹងដើម្បីចែករំលែកបន្តដល់ ប្រធាន អ្នកគ្រប់គ្រង សហសេវិក និងអង្គការដៃគូ នៅក្នុងសហគមន៍របស់ខ្លួន ក្រោយពីបញ្ចប់វគ្គបណ្តុះបណ្តាលនេះទៅ។<br>១. ឱ្យសិក្ខាកាមបែងចែកជា ៣ ឬ ៥ក្រុម យោងតាមស្ថានភាពជាក់ស្តែង។<br>២. ក្រុមនីមួយៗនឹងស្វែងយល់អំពីចក្ខុវិស័យរបស់សិក្ខាកាមនូវការយល់ ដឹងអំពី កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិក្នុងចំណោមអ្នកដឹកនាំអង្គការសង្គមស៊ីវិលព្រមទាំងបុគ្គលិករបស់ | -ផ្ទាំងរូបភាព<br>-ក្រដាសផ្ទាំងធំ<br>-ហ្វឺត |

ជំពូកទី៣

| ម៉ោង | សកម្មភាព និងវិធីសាស្ត្រ | សម្ភារៈ និងឯកសារ |
|---|---|---|
| | ពួកគេក្រោយពេលទទួលការបណ្តុះបណ្តាល។<br>៣. សិក្ខាកាមប្រើប្រាស់សម្ភារៈដូចជាក្រដាសផ្ទាំងធំ ឬ កុំព្យូទ័រ ដើម្បីកាត់ត្រាគំនិតយោបល់របស់ពួកគេ និង ជ្រើសរើសតំណាងក្រុមដើម្បីបង្ហាញ។<br>- **អ្នកសម្របសម្រួល ពិនិត្យមើលតាមក្រុមនីមួយៗដើម្បីផ្តល់នូវការណែនាំផ្សេងៗក្នុងការឆ្លើយសំនួរ។** | |
| ១៥ នាទី | **សកម្មភាពទី ៣: ការបង្ហាញក្រុមពិភាក្សា:**<br>✓ ការបង្ហាញលទ្ធផលក្រុមពិភាក្សា សិក្ខាកាមទាំងអស់ប្រើក្រដាសផ្ទាំងធំ ឬ កុំព្យូទ័រ ដើម្បីធ្វើបទបង្ហាញរបស់ក្រុមខ្លួន<br>១. ជ្រើសរើសក្រុមស្ម័គ្រចិត្តពីរ មកធ្វើបទបង្ហាញ ហើយក្រុមនីមួយៗមានពេល ៥នាទី<br>២. ចំពោះក្រុមដទៃទៀតអាចចូលរួមផ្តល់គំនិតយោបល់ប្រសិនបើមានអ្វីចង់បន្ថែមលើក្រុមទាំងពីរ | - បទបង្ហាញទី៣<br>- ក្រដាសផ្ទាំងធំ<br>- ហ្វឺត |
| ១៥ នាទី | **សកម្មភាពទី ៤:** បំផុសគំនិត:<br>តើបានរៀនអ្វីខ្លះក្នុងអំឡុងពេល៣ថ្ងៃនេះ ក្នុងការលើកកម្ពស់ការយល់ដឹងរបស់សិក្ខាកាមអំពីកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ?<br>១. ចោទសួរដល់សិក្ខាកាមឱ្យរំលឹកឡើងវិញអំពីចំណុចសំខាន់ៗ ដែល បានសិក្សានៅថ្ងៃទី១ សូមជ្រើសយកសិក្ខាកាមតែ ២នាក់ (១នាក់ឆ្លើយ ១សំណួរ) | -ក្រដាសផ្ទាំងធំ<br>-ហ្វឺត |

| ម៉ោង | សកម្មភាព និងវិធីសាស្ត្រ | សម្ភារៈ និងឯកសារ |
|---|---|---|
| | ២. ចោទសួរដល់សិក្ខាកាមឱ្យរំលឹកឡើងវិញអំពីចំណុចសំខាន់ៗ ដែលបានសិក្សានៅថ្ងៃទី២ សូមជ្រើសយកសិក្ខាកាមតែ២នាក់ (១នាក់ឆ្លើយ ១សំណួរ)<br>៣. ចោទសួរដល់សិក្ខាកាមឱ្យរំលឹកឡើងវិញអំពីចំណុចសំខាន់ៗ ដែលបានសិក្សា នៅថ្ងៃទី៣ សូមជ្រើសយកសិក្ខាកាមតែ២នាក់ (១នាក់ឆ្លើយ ១សំណួរ)<br>**អ្នកសម្របសម្រួល គួរសំណូមពរឱ្យដៃគូសម្របសម្រួលប្រើក្រដាសផ្ទាំងធំ ដើម្បីជួយកត់ត្រាចម្លើយរបស់សិក្ខាកាម។** | |
| ១០ នាទី | **<u>សកម្មភាពទី ៥: ការបង្ហាញ</u> សំនួរដែលមិនទាន់បានឆ្លើយ និង យោបល់ត្រឡប់ដែលបានកត់ត្រាទុករយៈពេល ៣ថ្ងៃកន្លងមក**<br>១. ប្រើប្រាស់ស្លាយ ឬ ក្រដាសផ្ទាំងធំដើម្បីកត់ត្រានូវរាល់ចម្លើយដែលពុំទាន់បានឆ្លើយ ដើម្បីបង្ហាញដល់សិក្ខាកាម។<br>២. សួរបញ្ជាក់ដល់សិក្ខាកាមប្រសិនបើគេចង់មានគំនិតយោបល់អ្វីចង់បន្ថែមទៀត។<br>៣. ត្រូវបញ្ជាក់ប្រាប់សិក្ខាកាមថាតារាងបញ្ជីនេះនិងផ្ញើរជូនទៅ NCCD និងអង្គការផេកកម្ពុជា ដើម្បីឱ្យពួកគេបានយល់អំពីចំណាប់អារម្មណ៍របស់សង្គមស៊ីវិលបន្ថែមទៀត។ | -រូបភាព<br>-ក្រដាសផ្ទាំងធំ<br>-ហ្វឹត<br>-បញ្ជីសំនួរដែលមិនទាន់បានឆ្លើយ និងយោបល់ត្រឡប់ដែលប្រមូលបានរយៈពេល៣ថ្ងៃកន្លងមក |
| ១០ នាទី | **<u>សកម្មភាពទី ៤: បញ្ចប់មេរៀន និងសំយោគ</u>**<br>១. សង្ខេបឡើងវិញអំពីអ្វីដែលជាទស្សនៈវិស័យរបស់សិក្ខាកាមក្រោយវគ្គបណ្តុះបណ្តាល | |

| ម៉ោង | សកម្មភាព និងវិធីសាស្ត្រ | សម្ភារៈ និងឯកសារ |
| --- | --- | --- |
| | ២. រំលឹកដល់សិក្ខាកាម និងបញ្ជាក់ឡើងវិញអំពីអ្វី ដែលបាន រៀនសូត្រក្នុងអំឡុងពេល៣ថ្ងៃកន្លងមក ហើយអាចជួយ ពួកគាត់អោយមានការយល់ដឹងអំពីកម្មវិធីជាតិសម្រាប់ ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ហើយរំពឹងថាសិក្ខាកាមដែលចូលរួមរៀនសូត្ររយៈពេល ៣ ថ្ងៃនេះ រំពឹងថានឹងអាចចែករំលែកព័ត៌មានទាំងនេះទៅ ដល់អ្នកផ្សេងទៀតបន្ទាប់ពីវគ្គបណ្តុះបណ្តាល។<br>៣. បញ្ជាក់ដល់សិក្ខាកាមឡើងវិញអំពីសំនួរដែលមិនទាន់បាន ឆ្លើយ និងសំណូមពររបស់សិក្ខាកាមនឹងត្រូវបញ្ជូនទៅ គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែប ប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និង អង្គការ ផែកកម្ពុជា។<br>**ចប់មេរៀនទី៤ ថ្ងៃទី ៣** | |

## សម្ភារៈសម្រាប់ប្រើប្រាស់នៅក្នុងមេរៀននេះ

- ហ្វឺត ក្រដាសផ្ទាំងធំ ស្កុត ក្រដាសពណ៌
- បទបង្ហាញ ស្លាយ ឬក្រដាសផ្ទាំងធំ

## ឯកសារយោង និងប្រភពព័ត៌មានផ្សេងៗទៀត

- កត់ត្រាសំនួរដែលមិនទាន់បានឆ្លើយក្នុងអំឡុងពេលបណ្តុះបណ្តាល។

# ឧបសម្ព័ន្ធ

# ឃ

# ឧបសម្ព័ន្ធ ការណែនាំពីការបើកវគ្គ

**គោលបំណង** : នៅចុងបញ្ចប់នៃវគ្គបណ្តុះបណ្តាលនេះ សិក្ខាកាមនឹងអាចៈ

១. រៀបរាប់ពីគោលបំណងរបស់វគ្គបណ្តុះបណ្តាល ដែលឆ្លើយតបទៅនឹងសេចក្តីរំពឹងទុករបស់សិក្ខាកាម និងលំហូរនៃវគ្គបណ្តុះបណ្តាល ។

២. ឯកភាពលើវិន័យសម្រាប់វគ្គ ដែលជួយឱ្យសម្រេចទៅតាមកាលវិភាគប្រចាំថ្ងៃ ។ ឯកភាពលើវិន័យសម្រាប់វគ្គ ដែលជួយឱ្យសម្រេចទៅតាមកាលវិភាគប្រចាំថ្ងៃ ។

## លទ្ធផលរំពឹងទុកនៃមេរៀនៈ

ក. សិក្ខាកាម ចាប់ផ្តើមបង្កើតបណ្តាញការងារមួយសម្រាប់ពេលអនាគត

ខ. ក្រោយពេលបញ្ចប់វគ្គ សិក្ខាកាមយល់ពីព័ត៌មានសំខាន់ៗ ដែលត្រូវចែករំលែកដល់អ្នកដទៃទៀត និងដឹងពីទីកន្លែងដែលអាចរកព័ត៌មានថ្មីៗ។

## កំណត់ចំណាំរបស់អ្នកសម្របសម្រួល

នៅក្នុងមេរៀននេះ អ្នកសម្របសម្រួលមានគោលបំណងចំនួន ២

១. កំណត់ឱ្យបានសមស្របនូវការរំពឹងទុករបស់សិក្ខាកាមដែលមិនស្ថិតនៅក្នុងវគ្គបណ្តុះបណ្តាលចំនួន៣ថ្ងៃ ហើយត្រូវជួយឱ្យសិក្ខាកាមបានយល់ច្បាស់ពីវគ្គបណ្តុះបណ្តាលដែលបានរៀបចំសម្រាប់ពេល៣ថ្ងៃតាមរយៈ ការផ្តល់ព័ត៌មានទូទៅ និងឈានទៅរកព័ត៌មាន ដែលកាន់តែជាក់លាក់ ស្តីពីកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។

២. បញ្ជាក់ពីការរៀបចំបញ្ជីឈ្មោះសិក្ខាកាមសម្រាប់ចុះឈ្មោះ និងចុះហត្ថលេខារៀងរាល់ថ្ងៃ។ បញ្ជីឈ្មោះសិក្ខាកាមត្រូវ មានព័ត៌មានស្តីពីឈ្មោះសិក្ខាកាម អង្គភាព/ស្ថាប័ន តួនាទី លេខទូរស័ព្ទ និងអ៊ីមែល។ បញ្ជីឈ្មោះនឹងផ្តល់ជូនសិក្ខាកាម ដើម្បីប្រើប្រាស់ជាបណ្តាញការងារនាពេលអនាគត។


១
លើកកម្ពស់ការយល់ដឹង និងភ្ជាប់ទំនាក់ទំនងរវាងសង្គមស៊ីវិលជាមួយ
កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
គោលបំណង
១. លើកកម្ពស់ការយល់ដឹងដល់អង្គការសង្គមស៊ីវិលស្តីពីកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែប
ប្រជាធិបតេយ្យ និងត្រៀមខ្លួនដើម្បីភ្ជាប់ទំនាក់ទំនងជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិ
២. លើកកម្ពស់ការចូលរួមរបស់សង្គមស៊ីវិលក្នុងដំណើរការ
អភិបាលកិច្ចនៅថ្នាក់ក្រោមជាតិ
១ លក្ខណៈទូទៅ
១. ប្រវត្តិកំណែទម្រង់វិមជ្ឈការ
និងវិសហមជ្ឈការ
២. អភិបាលកិច្ច និងទស្សនទាននៃកំណែ
ទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ
៣. តួនាទី និងការទទួលខុសត្រូវរបស់
សង្គមស៊ីវិលក្នុង
៤. ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល
រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
២ មូលហេតុ
១. ការណែនាំពីកម្មវិធីជាតិសម្រាប់
ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ
២. ការគ្រប់គ្រងកម្មវិធីជាតិសម្រាប់ការ
អភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យ
៣. លិខិតបទដ្ឋានគតិយុត្ត
គាំទ្រការអនុវត្តកម្មវិធីជាតិ
៣ ការចូលរួម
១. ការយល់ឃើញរបស់អង្គការសង្គម
ស៊ីវិលក្នុងការភ្ជាប់ទំនាក់ទំនង
ជាមួយក្រុមប្រឹក្សាថ្នាក់ក្រោមជាតិ
២. ការចូលរួមរបស់អង្គការសង្គមស៊ីវិល
ក្នុងការភ្ជាប់ទំនាក់ទំនងជាមួយក្រុម
ប្រឹក្សាថ្នាក់ក្រោមជាតិ
៣. លើកកម្ពស់ការប្រើប្រាស់បណ្តាញ
អង្គការសង្គមស៊ីវិល និងព័ត៌មាន
នៅរដ្ឋបាលថ្នាក់ក្រោមជាតិ
រៀបចំដោយ
ឧបត្ថម្ភដោយ
Pact Cambodia
VBNK
THE WORLD BANK
គជអប
NCDD

## ឧបសម្ព័ន្ធ ប្លង់ឧបសម្ព័ន្ធ

### របៀបសម្របសម្រួលមេរៀន (ពេលវេលា : ៤០ នាទី)

| ម៉ោង | សកម្មភាព និង វិធីសាស្ត្រ | សម្ភារៈ/ឯកសារចែក |
|---|---|---|
| (៥នាទី) | **សកម្មភាពទី១:ការចាប់ផ្តើមៈ**<br>គឺជាការស្វាគមន៍សិក្ខាកាម ដោយសំណេះសំណាល សួរនាំពីការធ្វើដំណើរ ការសម្រាន្តពីយប់មិញ ។ល។ | |
| (១០ នាទី) | **សកម្មភាពទី២: ការណែនាំខ្លួនរបស់អ្នកចូលរួមៈ**<br>១. ដើម្បីឱ្យវគ្គបណ្តុះបណ្តាលមានដំណើរការដោយរលូន និងទទួលបានជោគជ័យ យើងគួរតែធ្វើឱ្យមានបរិយាកាសល្អប្រកបដោយភាពរីករាយ។ នេះមានន័យថាសិក្ខាកាមទាំងអស់អាចធ្វើការចែករំលែកគំនិត យោបល់ ឱ្យគ្នាទៅវិញទៅមកដោយសេរី។ ដោយហេតុថាសិក្ខាកាមទាំងអស់មកពីកន្លែងផ្សេងៗ គ្នាហើយមានសិក្ខាកាមខ្លះក៏ធ្លាប់ស្គាល់គ្នាពីមុន និងសិក្ខាកាមខ្លះមិនដែលទាន់ស្គាល់។ដូច្នេះមុនពេលចាប់ផ្តើមវគ្គ អ្នកសម្របសម្រួលគួរផ្តើមឱ្យអ្នកចូលរួមបានស្គាល់គ្នាជាមុនសិន។<br>២. ស្នើឱ្យសិក្ខាកាមណែនាំឱ្យស្គាល់គ្នាទៅវិញទៅមក។ | |
| (១៥ នាទី) | **សកម្មភាពទី៣: ពិភាក្សាក្រុមធំ និងបទបង្ហាញៈ**<br>១. ធ្វើបទបង្ហាញដោយពន្យល់អំពីគោលបំណងនៃមេរៀនទី១នេះ។<br>២. ផ្គូរផ្គងគោលបំណងនៃវគ្គបណ្តុះបណ្តាលទៅនឹងការរំពឹងទុករបស់សិក្ខាកាមដោយចោទជាសំណួរ តើគោលបំណងវគ្គស្តីពីការលើកកម្ពស់ការយល់ដឹងដល់អង្គការសង្គមស៊ីវិលស្របគ្នាទៅនឹងការរំពឹងទុករបស់លោកអ្នកឬទេ? ទុកពេលឱ្យសិក្ខាកាម | |

| | | |
|---|---|---|
| (១៥ នាទី) | ចំនួន៣ ឬ៤នាក់ ឆ្លើយ និងបកស្រាយ។<br>៣. បង្ហាញកាលវិភាគទាំង៣ថ្ងៃ និងសុំការឯកភាពគ្នាលើម៉ោងចាប់ផ្តើម និង ម៉ោងបញ្ចប់សម្រាប់ថ្ងៃនីមួយៗ។<br>៤. បង្ហាញលំហូរមាតិការសម្រាប់វគ្គបណ្តុះបណ្តាលទាំង៣ថ្ងៃ (ប្រវត្តិសង្ខេបនៃវគ្គនៅថ្ងៃទី១ មានអ្វីខ្លះ? និងហេតុអ្វី? មាតិកាសំខាន់ៗ សម្រាប់ថ្ងៃទី២ និងទី៣)។<br>៥. វិន័យថ្នាក់រៀនៈ យើងចាំបាច់ត្រូវមានវិន័យសម្រាប់វគ្គ ដែលជួយឱ្យយើងគោរពគ្នាទៅវិញទៅមក ដើម្បីរក្សាបាននូវដំណើរការបណ្តុះបណ្តាល ប្រកបដោយភាពរលូន។ តើយើងត្រូវមានវិន័យអ្វីខ្លះ ដែលចាំបាច់ត្រូវគោរព?<br>៦. កត់ត្រារាល់វិន័យ ដែលសិក្ខាកាមលើកឡើងលើក្រដាសផ្ទាំងធំរួចបិទលើជញ្ជាំង។<br>៧. ណែនាំសិក្ខាកាមអានសន្ទានុក្រម (ពាក្យបកស្រាយ) និងសរសេរអត្ថន័យនៃពាក្យបច្ចេកទេស ដែលមាននៅក្នុងឯកសារចែកនៅពេលត្រលប់ទៅផ្ទះ ឬបន្ទប់វិញ ហើយពួកគាត់នឹងចែករំលែកពីការយល់ដឹងនូវពាក្យដែលបានអាននៅពេលយប់។ | ប្រើប្រាស់:<br>• ឯកសារបញ្ចាំង<br>• ប៉ុស្ត័រផ្ទាំងធំស្តីពីកាលវិភាគនៃវគ្គបណ្តុះបណ្តាល និងកំណត់វិន័យសម្រាប់វគ្គ |
| (១០ នាទី) | <u>សកម្មភាពទី៥: បូកសរុបវគ្គបណ្តុះបណ្តាល</u><br>បញ្ជាក់ឡើងវិញពីការយល់ដឹងរបស់សិក្ខាកាមអំពីគោលបំណងវគ្គទាំង៣ថ្ងៃ ជាពិសេសលំហូនៃវគ្គបណ្តុះបណ្តាល និងលក្ខខ័ណ្ឌ។ | |

## សម្ភារៈឧបទេ្ទសសម្រាប់មេរៀនៈ

- ឯកសារចែកជូនៈ
  - ☆ ឯកសារបញ្ចាំង ស្តីពីគោលបំណង និងកាលវិភាគនៃវគ្គបណ្តុះបណ្តាល ។
  - ☆ សន្ទានុក្រមនៃពាក្យបច្ចេទេសដែលទាក់ទងនឹងកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ។
  - ☆ ហ្វីតសរសេរក្រដាស ក្រដាសផ្ទាំងធំ ស្កុតក្រដាស
  - ☆ កុំព្យូទ័រយួរដៃ និងម៉ាស៊ីនបញ្ចាំងឯកសារ

## សម្ភារៈចាំបាច់ និងប្រភពឯកសារយោងសម្រាប់ជាព័ត៌មានបន្ថែមៈ

- ☆ ស៊ីឌីដាក់ឯកសារសម្រាប់ចែកឱ្យសិក្ខាកាម
- ☆ សន្ទានុក្រមនៃពាក្យបច្ចេទេស

# ឧបសម្ព័ន្ធ គំរូសម្រាប់ការរំលឹកមេរៀនប្រចាំថ្ងៃ (គំរូទី១)

**គោលបំណង** : នៅចុងបញ្ចប់នៃមេរៀននេះ អ្នកចូលរួមនឹងអាចៈ

១. នឹកឃើញឡើងវិញដោយខ្លួនឯង នូវចំនុចសំខាន់ៗដែលបានរៀនកាលពីមេរៀនមុន

២. កំនត់បាននូវគំនិតសំខាន់ៗ តាមប្រធានបទនិមួយៗដែលបានរៀនរួចហើយ

៣. សង្ខេបនូវសារៈសំខាន់នៃឯកសារដែលបានចែកជូន។

**លទ្ធផលរំពឹងទុកនៃមេរៀនៈ**

ក. អ្នកចូលរួមយល់ និងចងចាំមេរៀនដែលបានរៀនរួចហើយ

ខ. អ្នកចូលរួមទទួលស្គាល់ថាថ្ងៃថ្មី បានរំលឹក និងបញ្ជាក់ឡើងវិញនូវអ្វីដែលស្រពិចស្រពិលពីថ្ងៃមុនធ្វើឱ្យការចងចាំកាន់តែប្រសើរឡើង ហើយអ្នកចូលរួមក៏បានដឹងអំពីទំនាក់ទំនងពីមេរៀនមួយ ទៅមេរៀនមួយទៀតតាមរយៈការរំលឹកមេរៀនឡើងវិញនូវរៀងរាល់ថ្ងៃថ្មីមុននឹងចាប់ផ្តើម មេរៀនថ្មី។

**កំណត់ចំណាំរបស់អ្នកសម្របសម្រួល**

ក្នុងមេរៀននេះ ដើម្បីប្រាកដថា ឬទាក់ទាញឱ្យអ្នកចូលរួម ក្នុងការរំលឹកមេរៀនឡើងវិញជារៀងរាល់ថ្ងៃនោះ អ្នកសម្របសម្រួលត្រូវប្រើប្រាស់វិធីសាស្ត្រដូចជាៈ ការលេងល្បែង ឬវិធីផ្សេងនានា ដើម្បីបង្កើនការចូលរួមរបស់សិក្ខាកាម។

១, អ្នកសម្របសម្រួលជំរាបទៅអ្នកចូលរួមទាំងអស់ថា ក្នុងរយៈពេលបីថ្ងៃនៃការបណ្តុះបណ្តាលនេះ តម្រូវឱ្យមានការចូលរួមពីសិក្ខាកាមទាំងអស់ក្នុងការរំលឹកមេរៀនប្រចាំថ្ងៃ។ ចំពោះវិធីសាស្ត្រនៃការរំលឹកមេរៀនអ្នកសម្របសម្រួលអាចអាចបត់បែនអាស្រ័យលើពេលវេលា និងចំនួនអ្នកចូលរួម។

២, អ្នកចូលរួមនឹងត្រូវអញ្ជើញឱ្យចូលរួមរំលឹកមេរៀន ដែលបានរៀនកាលពីថ្ងៃទី១។ ដំណើរការនៃការរំលឹកមេរៀនគឺប្រព្រឹត្តិដូចគ្នាចំពោះថ្ងៃទី២ និង ថ្ងៃទី៣។

៣, ចំនុចសំខាន់នៃមេរៀននេះ គឺរំលឹកនូវអ្វីដែលបានរៀនពីថ្ងៃមុនៗនឹងចូលមេរៀនថ្មី។

៤, គោលបំណងនៃការរំលឹកមេរៀននេះគឺ ដើម្បីជួយពង្រឹង អ្នកចូលរួមអោយយល់ពីភាពសំខាន់ នូវអ្វីដែលពួកគេកំពុងរៀន និងប្រាប់ពីមូលហេតុ ដែលមានប្រយោជន៍បន្ទាប់ពីវគ្គបណ្តុះបណ្តាល។

# ឧបសម្ព័ន្ធ គំរូសម្រាប់ការរំលឹកមេរៀនប្រចាំថ្ងៃ (គំរូទី១)

## របៀបសម្របសម្រួលមេរៀន (ពេលវេលា ២០ នាទី)

| ពេលវេលា | សកម្មភាព និង វិធីសាស្ត្រ | សម្ភារៈ/ឯកសារចែក |
|---|---|---|
| (៥ នាទី) | **សកម្មភាពទី១: បង្ហាញគោលបំណងមេរៀន**<br>អ្នកសម្របសម្រួលបង្ហាញ និងពន្យល់គោលបំណងនៃមេរៀនទី២នៅលើស្លាយ ដោយអ្នកសម្របសម្រួលស្នើឱ្យសិក្ខាកាមទាំងអស់ឱ្យក្រោកឈរជារង្វង់មូល។ | ស្លាយទី ១ |
| (១០ នាទី) | **សកម្មភាពទី២: ការពិភាក្សាពេញអង្គ:**<br>ការរំលឹកមេរៀនប្រចាំថ្ងៃ<br>**ក, ការណែនាំ:**<br>- ស្នើឱ្យសិក្ខាកាមក្រោកឈរជារង្វង់មូល<br>- ដើម្បីបង្កើនការចូលរួមរបស់សិក្ខាកាម ជាដំបូងអ្នកសម្របសម្រួលគួរពន្យល់អំពីវិធីសាស្ត្រប្រើប្រាស់សម្រាប់រំលឹកឡើងវិញនូវអ្វីដែលបានរៀនពីថ្ងៃទី១ ។<br>- អ្នកសម្របសម្រួល ចល័តកូនបាល់ ដោយការបោះទៅឱ្យសិក្ខាកាមៗ ដែលបានទទួលកូនបាល់តម្រូវឱ្យរំលឹកឡើងវិញនូវចំនុចសំខាន់មួយដែលគាត់ចាំ។<br>**ខ, ដំណើរការ:**<br>- អ្នកសម្របសម្រួលនិយាយថាពេលខ្ញុំនឹងបោះកូនបាល់នេះទៅចំសិក្ខាកាមណាសិក្ខាកាមនោះត្រូវនិយាយរំលឹកនូវចំនុចសំខាន់មួយដែលអ្នកបានចងចាំ ឬបានរៀនក្នុងថ្ងៃទី១។<br>- បន្ទាប់រំលឹករួចហើយ អ្នកនោះត្រូវបោះកូនបាល់ទៅ | |

| | | |
|---|---|---|
| | ឱ្យអ្នកផ្សេងទៀត។<br>- សិក្ខាកាមដែលបានទទួលកូនបាល់បន្ទាប់ត្រូវនិយាយនូវអ្វីដែលចំណុចសំខាន់ផ្សេងទៀតរៀនក្នុងថ្ងៃទី១ រួចហើយបោះទៅឱ្យអ្នកបន្ទាប់ទៀត។<br>- ការធ្វើបែបនេះនឹងដំណើរការតាមនិតិវិធីដូចខាងលើឱ្យបាន៥-៦នាក់ ។ | 🗐 ប៉ុស្ទ័រ<br>☯ កូនបាល់<br>🗐 ក្រដាសផ្ទាំងធំ ប្រដាប់គូសចំណាំ |
| (៥ នាទី) | **សកម្មភាពទី៣: សេចក្តីសន្និដ្ឋាន**<br>១, សិក្ខាកាមនឹងភ្ជាប់សកម្មភាពរបស់ពួកគេនាពេលអនាគតទៅនឹងវគ្គលើកកម្ពស់យល់ដឹង និង តួនាទី និងការចូលរួមចំណែករបស់អង្គការសង្គមស៊ីវិលផងដែរ។<br>២, សូមសេចក្តីបញ្ជាក់បន្ថែមប្រសិនបើមាន<br>៣, សង្ខេបមេរៀនថ្ងៃទី១ ដាក់លើក្រដាសមួយផ្ទាំង ហើយបិទលើជញ្ជាំង។ | 🗐 ក្រដាសផ្ទាំងធំ<br>🗐 ក្រដាសសង្ខេប មេរៀន |

**សម្ភារៈឧបទ្ទេសសំរាប់មេរៀនៈ**

- 🗐 ឯកសារចែកជូនសម្រាប់ក្រុមសង្ខេបមេរៀនៈ
- 🗐 ប្រដាប់គូសចំណាំ, ក្រដាសផ្ទាំងធំ, ក្រដាសកាតពណ៌
- 🗐 ប៉ុស្ទ័រ
- ☯ កូនបាល់

# ឧបសម្ព័ន្ធ គំរូសម្រាប់ការរំលឹកមេរៀនប្រចាំថ្ងៃ (គំរូទី២)

**គោលបំណង** : នៅចុងបញ្ចប់នៃមេរៀននេះ អ្នកចូលរួមនឹងអាចៈ

១. នឹកឃើញឡើងវិញដោយខ្លួនឯង នូវអ្វីដែលគេបានរៀនកាលពីមេរៀនមុន

២. កំណត់នូវគំនិតយោបល់ជាក់លាក់ ដែលគេបានរៀនពីថ្ងៃមុន

៣. សង្ខេបនូវសារៈសំខាន់នៃឯកសារដែលបានចែកជូន។

**លទ្ធផលរំពឹងទុកនៃមេរៀនៈ**

ក. សិក្ខាកាមចងចាំ និងយល់កាន់តែច្បាស់ពីមេរៀនពីដែលបានរៀនពីថ្ងៃមុន

ខ. សិក្ខាកាមទទួលស្គាល់ថា ថ្ងៃថ្មីធ្វើអោយការសិក្សាថ្ងៃមុនប្រសើរឡើង

គ. សិក្ខាកាមច្បាស់លាស់អំពីការធ្វើសេចក្តីសន្និដ្ឋានឱ្យដែលបានបង្កើនកាលពីមេរៀនមុនៗ

**កំណត់ចំណាំរបស់អ្នកសម្របសម្រួល**

ក្នុងមេរៀននេះ ដើម្បីប្រាកដថា ឬទាក់ទាញឱ្យសិក្ខាកាម ក្នុងការរំលឹកមេរៀនឡើងវិញជារៀងរាល់ថ្ងៃនោះ អ្នកសម្របសម្រួលត្រូវប្រើប្រាស់វិធីសាស្ត្រដូចជាៈ ការលេងល្បែង ឬវិធីផ្សេងនានា ដើម្បីបង្កើនការចូលរួមរបស់សិក្ខាកាម។

១. ប្រាប់សិក្ខាកាមថា ការរំលឹកមេរៀននឹងជួយឱ្យសិក្ខាកាមរឹតតែចងចាំនូវខ្លឹមសារសំខាន់ៗ និងអ្វីដែលបានរៀន ហើយយល់ថាហេតុអ្វីបានជាវគ្គបណ្តុះបណ្តាលនេះមានសារៈសំខាន់នៅពេលដែល វគ្គនេះចប់។

២.យើងនឹងរកឃើញនូវអ្វី ដែលសិក្ខាកាមមានការភ័ន្តច្រឡំអំពីទស្សនៈណាមួយ និង ពាក្យបច្ចេកទេស ដែលបានប្រើនៅថ្ងៃមុន។ ធ្វើដូចនេះនឹងជួយដល់អ្នកចូលរួមទាំងអស់ឱ្យកាន់តែសកម្មថែមទៀត និងការចូលរួមបានល្អជារៀងរាល់ថ្ងៃ។

៣. ចំនុចសំខាន់នៃមេរៀននេះ គឺរំលឹកនូវអ្វីដែលបានរៀនពីថ្ងៃមុនៗនឹងចូលមេរៀនថ្មី។

# ឧបសម្ព័ន្ធ គំរូសម្រាប់ការរំលឹកមេរៀនប្រចាំថ្ងៃ (គំរូទី២)

**របៀបសម្របសម្រួលមេរៀន** (ពេលវេលា ២០ នាទី)

| ពេលវេលា | សកម្មភាព និងយុទ្ធសាស្ត្រ | ឯកសារចែកចាយ |
|---|---|---|
| ២នាទី | **សកម្មភាពទី១: ការណែនាំ:**<br>អ្នកសម្របសម្រួល នែនាំក្រុមការងារទាំង ៣ក្រុម ដល់សិក្ខាកាម ហើយស្នើសុំអោយគេស្វាគមន៍ដល់ក្រុមការងារនេះដោយ សម្លេងទះដៃ។ | សកម្មភាព |
| ៥ នាទី | **សកម្មភាពទី២:** ការបង្ហាញ/ពេញអង្គ:<br>១. អ្នកសម្របសម្រួល ត្រូវប្រាប់ឱ្យតំណាងក្រុមទី១ ប្រើប្រាស់ក្រដាសផ្ទាំងធំ ដែលបានរៀបចំជាស្រេចកាលពីយប់អំពីគោលបំណងនៃមេរៀន មកពន្យល់ដោយប្រាប់សិក្ខាកាមថា "ដើម្បីរំលឹកឡើងវិញនូវអ្វី ដែលយើងបានរៀនពីថ្ងៃមុន"<br>២. ប្រាប់ក្រុមស្ម័គ្រចិត្តរបស់យើងឱ្យធ្វើការសង្ខេបមេរៀន ដែលការសង្ខេបនេះត្រូវភ្ជាប់ទៅមេរៀនក្រោយទៀត។ | |
| ៨ នាទី | **សកម្មភាពទី៣:** ការបង្ហាញ/ពេញអង្គ:<br>អ្នកសម្របសម្រួលត្រូវប្រាប់ឱ្យតំណាងក្រុមទី២ ប្រើប្រាស់ក្រដាសផ្ទាំងធំដែលបានរៀបចំជាស្រេចពីយប់មិញមកពន្យល់ដោយលើកឡើងប្រាប់សិក្ខាកាមនូវអ្វីដែលបានរៀននៅថ្ងៃទី២ ដោយចាប់ផ្តើមពីប្រធានបទដំបូងរហូតដល់មេរៀនដែលនឹងរៀនបន្ទាប់ពីការរំលឹកមេរៀននេះចប់។<br>ឧទាហរណ៍: ខ្លឹមសារគន្លឹះពីរថ្ងៃកន្លងមករួមមាន:<br>• កម្មវិធីជាតិសំរាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យថ្នាក់ក្រោមជាតិ<br>• ទំនាក់ទំនងរវាងកម្មវិធីជាតិសំរាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យថ្នាក់ក្រោមជាតិ និងច្បាប់របស់អង្គការការគ្រប់គ្រងកម្មវិធីជាតិ សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យថ្នាក់ក្រោមជាតិ ឆ្នាំ២០១០ — ២០១៩ យន្តការដែលធ្វើឱ្យមានគណនេយ្យភាព<br>• ការភ្ជាប់ទំនាក់ទំនងរបស់អង្គការសង្គមស៊ីវិល ជាមួយកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យថ្នាក់ក្រោមជាតិ | |

ឧបសម្ព័ន្ធក : គំរូសម្រាប់ការរំលឹកមេរៀនប្រចាំថ្ងៃ (គំរូទី២)

| | | |
|---|---|---|
| | • ជាបន្តគឺបទបង្ហាញអំពីការភ្ជាប់ទំនាក់ទំនងរបស់អង្គការសង្គមស៊ីវិលទៅនឹងកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យថ្នាក់ក្រោមជាតិមានអ្វីខ្លះ។ | |
| ៥នាទី | **<u>សកម្មភាពទី៤:</u>** ការបំផុសគំនិត<br>អ្នកសម្របសម្រួលគួរប្រាប់ឱ្យតំណាងក្រុមទី៣ឡើងមកដឹកនាំសួរសំនួរពី ២ ទៅ ៣សំនួរ ដោយប្រាប់អ្នកសួរសំនួរឱ្យសង្ខេបខ្លី ហើយច្បាស់ ដោយហេតុថាយើងមានពេលតែ៥នាទីប៉ុណ្ណោះសម្រាប់ការសួរសំនួរ។ | |
| ៥ នាទី | <u>សកម្មភាពទី៥:</u> ការសន្និដ្ឋាន:<br>អ្នកសម្របសម្រួលគួរចង្អុលបង្ហាញ និងបញ្ជាក់ឱ្យច្បាស់អំពីគោលបំណង និងសារៈសំខាន់នៃការរំលឹកមេរៀនមេរៀនឡើងវិញ។ | |

## សំភារៈ ឧបទ្ទេសមេរៀន:

- ឯកជូនសម្រាប់ក្រុមសង្ខេបមេរៀនៈ : របៀបរៀបចំ និង សម្របសម្រួលការសង្ខេបមេរៀន
- ផ្ទាំងរូបភាព
- ស៊្វីត ក្រដាស់ កាសែត ក្រដាស់ពណ៌

## សំភារៈយោង និងឯកសារសំរាប់ពត៌មាននៅអនាគត:

- NP-CNDD (Website address: www.ncdd.gov.kh )
- SILAKA (Website address: www.silaka.org )
- Pact booklet (Website address: www.pactcambodia.org )

# ឧបសម្ព័ន្ធ ក ការបិទវគ្គបណ្តុះបណ្តាល

**គោលបំណង** : នៅចុងបញ្ចប់នៃមេរៀននេះ សិក្ខាកាមអាចៈ

១. បង្ហាញអំពីអ្វីដែលពួកគេបានរៀនសូត្រ ពិសេសការយល់ដឹងទៅលើ NP-SNDD

២. ផ្តល់យោបល់ត្រឡប់អំពីផលប្រយោជន៍ ដែលបានរៀនសូត្រ និងសំណូមពរ ដើម្បីធ្វើឱ្យប្រសើរឡើង នៅវគ្គបណ្តុះបណ្តាលលើកក្រោយ។

៣. សង្ខេបនូវសារៈសំខាន់នៃឯកសារដែលបានចែកជូន។

## លទ្ធផលរំពឹងទុកនៃមេរៀនៈ

ក. សិក្ខាកាមមានការពេញចិត្តទៅនិងបទពិសោធន៍ និងដំណើរការនៃការរៀនសូត្រអំពី NP-SNDD

ខ. សិក្ខាកាមអ្នកចូលរួមទទួលស្គាល់ថា ថ្ងៃថ្មីធ្វើអោយការសិក្សាថ្ងៃមុនប្រសើរឡើង

គ. យោបល់ត្រឡប់របស់សិក្ខាកាម ដែលបានលើកឡើងនៅក្នុងការវាយតម្លៃ នឹងប្រើប្រាស់សម្រាប់ កែលម្អខ្លឹមសារ និងវិធីសាស្រ្តសម្រាប់វគ្គបណ្តុះបណ្តាលក្រោយទៀត និងបញ្ជូនទៅ គជអប ។

## កំណត់ចំណាំរបស់អ្នកសម្របសម្រួល

នៅក្នុងមេរៀននេះអ្នកសម្របសម្រួលមានគោលបំណង២សំខាន់ៗ:

១. ការវាយតម្លៃរៀបចំឡើងដើម្បីវាស់ស្ទង់អំពីចំណេះដឹង និងការផ្លាស់ប្តូរក្នុងចំណោមសិក្ខាកាម។ សំនួរស្ទាប-ស្ទង់នឹងជួយឱ្យបានដឹងអំពីការយល់ដឹង និងផ្លាស់ប្តូររបស់សិក្ខាកាម។

២. ប្រមូលយោបល់ត្រលប់ ដើម្បីកែលម្អនៅវគ្គបណ្តុះបណ្តាលក្រោយៗ។ មួយវិញទៀត លទ្ធផលនៃការវាយតំលៃនេះនឹងជួយឱ្យអ្នកសម្របសម្រួលបានដឹងពីចំណុចខ្លាំង និងចំណុចខ្សោយ និងទទួលបានពត៌មានដឹងជាក់លាក់បន្ថែមទៀតអំពីអ្វីដែលយើងធ្វើបានល្អរួចហើយក្នុងអំឡុងវគ្គបណ្តុះបណ្តាល ហើយក៏បានដឹងអំពីអ្វីផ្សេងទៀតដែលនឹងត្រូវធ្វើឱ្យប្រសើរឡើងផងដែរ។

## ឧបសម្ព័ន្ធ គំរូសម្រាប់ការបិទវគ្គបណ្តុះបណ្តាល

### តើគ្រូវសម្របសម្រួលមេរៀននេះយ៉ាងដូចម្តេច? (រយៈពេល: ៣៥នាទី)

| ម៉ោង | សកម្មភាព និងវិធីសាស្ត្រ | សម្ភារៈ និង ឯកសារ |
|---|---|---|
| ១៥ នាទី | **សកម្មភាពទី ១:ពេញអង្គ:**<br>✓ ការវាយតំលៃវគ្គបណ្តុះបណ្តាល<br>**វិធីសាស្ត្រ:**<br>១. ពន្យល់ដល់សិក្ខាកាមអំពីការបំពេញទម្រង់វាយតំលៃវគ្គឱ្យបានត្រឹមត្រូវ ជៀសវាងនូវភាពស្រពិចស្រពិល<br>២. បញ្ជាក់អំពីពេលវេលានៃការបំពេញទម្រង់វាយតំលៃវគ្គ<br>៣. បញ្ជាក់ប្រាប់សិក្ខាកាមអំពីឈ្មោះអ្នកប្រមូលទម្រង់វាយតំលៃវគ្គ | - កម្រងសំនួរ វាយតំលៃ |
| ២០ នាទី | **សកម្មភាពទី ២: ពេញអង្គ:**<br>✓ ការបិទវគ្គបណ្តុះបណ្តាល<br>**វិធីសាស្ត្រ:**<br>១. វគ្គបណ្តុះបណ្តាលគួរតែបិទដោយមន្ត្រីជាន់ខ្ពស់ ឬអ្នកគ្រប់គ្រង កម្មវិធី ឬអ្នកដឹកនាំអ្នកសម្របសម្រួល<br>២. សារសម្រាប់ការបិទវគ្គបណ្តុះបណ្តាល គួរតែខ្លី ហើយគួរឆ្លុះបញ្ចាំង<br>**អំពីលទ្ធផល និងការថ្លែងអំណរគុណដល់:**<br>➢ អ្នករៀបចំវគ្គបណ្តុះបណ្តាល<br>➢ អ្នកពាក់ព័ន្ធ<br>➢ ក្រុមបណ្តុះបណ្តាល<br>➢ សិក្ខាកាម ។ល។ | |

### សម្ភារៈសម្រាប់ប្រើប្រាស់នៅក្នុងមេរៀននេះ

- តារាងវាយតំលៃនៅចុងបញ្ចប់វគ្គ

# ឧបសម្ព័ន្ធ ការវាយតម្លៃប្រចាំថ្ងៃ

☐ ស្រី ☐ ប្រុស

វគ្គបណ្តុះបណ្តាលស្តីពី

## លើកកម្ពស់ការយល់ដឹងរបស់អង្គការសង្គមស៊ីវិលស្តីពីកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍបែបប្រជាធិបតេយ្យ

**ថ្ងៃទី ............. ខែ វិច្ឆិកា ឆ្នាំ ២០១០**

១. សូមលោកអ្នកគូសសញ្ញា ( ✓ ) បញ្ជាក់ពីអារម្មណ៍ទូទៅសំរាប់ថ្ងៃនេះ ។



មិនរីករាយសោះ ធម្មតា រីករាយ រីករាយណាស់

២. សូមលោកអ្នកគូសសញ្ញានេះ ( ✓ ) ក្នុងប្រអប់ណាមួយខាងក្រោម :

| **លក្ខណវិនិច្ឆ័យ** | **អន់** | **មធ្យម** | **ល្អ** | **ល្អណាស់** |
|---|---|---|---|---|
| ខ្លឹមសារ និងផលប្រយោជន៍នៃមេរៀន | | | | |
| វិធីសាស្ត្របង្រៀន (សម្របសម្រួល) | | | | |
| ការបំពេញការងាររបស់អ្នកសម្របសម្រួល | | | | |
| ការចូលរួមរបស់សិក្ខាកាម | | | | |
| សម្ភារៈសិក្សា | | | | |

៣. តើអ្វី(វិធីសាស្ត្របង្រៀន/សំរបសំរួល ឬ ចំណុចណា)ដែលអ្នកពេញចិត្តបំផុត (ដែលជួយឱ្យអ្នករៀនសូត្របានប្រសើរបំផុត)?

..........................................................................................................................................
..........................................................................................................................................
..........................................................................................................................................
..........................................................................................................................................
..........................................................................................................................................

៤. សូមផ្តល់ជាយោបល់ និង ចម្ងល់ ផ្សេងៗ

..........................................................................................................................................
..........................................................................................................................................
..........................................................................................................................................
..........................................................................................................................................
..........................................................................................................................................

សូមអរគុណចំពោះការផ្តល់ព័ត៌មានត្រឡប់របស់លោក លោកស្រី ។

ឧបសម្ព័ន្ធ **គំរូការវាយតំលៃបញ្ចប់វគ្គ**

## ទំរង់វាយតម្លៃវគ្គបណ្តុះបណ្តាលរបស់សិក្ខាកាម

**គោលបំណងនៃការវាយតំលៃមានពីរ:** ទីមួយ យើងចង់ដឹងដោយផ្ទាល់ពីសិក្ខាកាមថាតើយើងបានសំរេចគោលបំណងរបស់វគ្គ ដែលបានព្រមព្រៀងគ្នាឬទេ និងតើអ្វីខ្លះមានឥទ្ធិពល (ជួយ) ដល់ការសំរេច គោលបំណង ឬអ្វីបានរាំងស្ទះដល់ប្រសិទ្ធភាពនៃការបណ្តុះបណ្តាលរបស់យើង។ មួយទៀតការវាយតំលៃនេះ នឹងប្រាប់ឱ្យយើងដឹងថា ការណែនាំរបស់យើងជួយឱ្យអ្នកអាចលើកកម្ពស់ការយល់ដឹងទៅអ្នកដ៏ទៃទៀត បាននៅកំរិតណា ។

ព័ត៌មានទូទៅ: សូមបំពេញភេទក្នុងប្រអប់ (បុរស/នារី) ដោយសញ្ញា√

| | |
|---|---|
| ប្រធានបទវគ្គ | លើកកម្ពស់ការយល់ដឹងដល់អង្គការសង្គមស៊ីវិលស្តីពីកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ |
| រយៈពេល | |
| ភេទ | បុរស ☐ ស្ត្រី ☐ |
| ទីកន្លែង | |
| ទិសដៅរយៈពេល ៣ ថ្ងៃ | លើកកម្ពស់ការយល់ដឹងសង្គមស៊ីវិលស្តីពីកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍបែបប្រជាធិបតេយ្យ និងជួយ រៀបចំសង្គមស៊ីវិលផ្សារភ្ជាប់ទំនាក់ទំនងជាមួយរដ្ឋាភិបាលថ្នាក់ក្រោមជាតិនិងថ្នាក់-មូលដ្ឋាន និង ចូលរួមដើម្បីអភិបាលកិច្ចល្អនៅថ្នាក់ក្រោមជាតិ |

**១. អារម្មណ៍ទូទៅចំពោះសិក្ខាសាលា:** សូមដាក់ពិន្ទុខាងក្រោមទៅតាមកំរិត ពី ១ ដល់ ៤

(១=អន់ណាស់, ២=មធ្យម, ៣=ល្អ, ៤=ល្អណាស់)

| ល.រ | លក្ខណៈវិនិច្ឆ័យ | ដាក់ពិន្ទុ ពី ១ ដល់ ៤ | | | | សូមផ្តល់ជាឧទាហរណ៍ ឬយោបល់ជាក់លាក់ |
|---|---|---|---|---|---|---|
| ១.១ | ខ្លឹមសារនៃវគ្គទាក់ទងនឹងការងាររបស់អ្នក | | | | | |
| ១.២ | វិធីសាស្ត្រនៃការបណ្តុះបណ្តាលដែលជួយអ្នករៀនសូត្រមានប្រសិទ្ធភាព | | | | | |
| ១.៣ | អ្នកសំរបសំរួលបានផ្តល់ការណែនាំដើម្បីជួយអ្នកឱ្យយល់ដឹងគ្រប់ខ្លឹមសារមេរៀន របស់វគ្គ ក | | | | | |
| ១.៤ | តើសម្ភារៈ និងឯកសាររបស់វគ្គសមស្របកំរិតណា? | | | | | |
| ១.៥ | ការណែនាំអំពីរបៀបអនុវត្តការរៀនសូត្រទៅក្នុងការងាររបស់អ្នក | | | | | |

ឧបសម្ព័ន្ធក : ការបិទវគ្គបណ្តុះបណ្តាល

តើអ្វីខ្លះដែលអ្នកយល់ស្របថាមានប្រយោជន៍បំផុតសំរាប់ជួយគាំទ្រការរៀនសូត្ររបស់អ្នក ក្នុងវគ្គបណ្តុះបណ្តាល នេះ?

..........................................................................................................................

..........................................................................................................................

**១. លទ្ធផលសម្រេចបាននៃវគ្គបណ្តុះបណ្តាលៈ** សូមដាក់ពិន្ទុខាងក្រោមទៅតាមកំរិត ពី ១ ដល់ ៤
(១=អត់ទេ. ២= បានខ្លះ, ៣=បានភាគច្រើន, ៤=បានទាំងអស់)

| **តាមយោបល់អ្នក តើវគ្គបណ្តុះបណ្តាលនេះឆ្លើយតបទៅ នឹងគោលបំណង ដែលបានកំណត់ពីដំបូងវគ្គបានកំរិតណា?** | **១** | **២** | **៣** | **៤** | **យោបល់** |
|---|---|---|---|---|---|
| ១. លើកកម្ពស់ការយល់ដឹងអំពីសារៈសំខាន់នៃច្បាប់រដ្ឋបាលថ្នាក់ក្រោមជាតិ និង អ្វីដែលត្រូវផ្លាស់ប្តូរ | | | | | |
| ២. លើកកម្ពស់ការយល់ដឹងអំពីគោលបំណងនៃ កម្មវិធីជាតិ សម្រាប់ការ អភិវឌ្ឍតាមបែបប្រជាធិបតេយ្យ នៅថ្នាក់ក្រោមជាតិ | | | | | |
| ៣. មានព័ត៌មានច្បាស់យកទៅចែករំលែកអ្នកដទៃដើម្បីជួយឱ្យគាត់យល់អំពី កម្មវិធី ជាតិសម្រាប់ការ អភិវឌ្ឍតាម បែបប្រជាធិបតេយ្យនៅថ្នាក់ក្រោម ជាតិបានល្អជាងមុន | | | | | |
| ៤. និយាយពីតួនាទីរបស់សង្គមស៊ីវិលក្នុងដំណើរការអនុវត្តកម្មវិធីជាតិ សម្រាប់ការអភិវឌ្ឍតាមបែបប្រជា ធិបតេយ្យនៅ ថ្នាក់ក្រោមជាតិ | | | | | |
| ៥. ពន្យល់អំពីឱកាសសម្រាប់ការចូលរួមរបស់សង្គមស៊ីវិលជាមួយក្រុម ប្រឹក្សាថ្នាក់ក្រោមជាតិ | | | | | |

**២. តើការណែនាំរបស់អ្នកសម្របសម្រួលមានប្រយោជន៍ដល់អ្នកក្នុងការលើកកម្ពស់ការយល់ដឹងនេះទៅអ្នកដទៃទៀតឬ ទេ? សូមផ្តល់ហេតុផល?**

..........................................................................................................................

..........................................................................................................................

តើអ្នកមានយោបល់/អនុសាសន៍អ្វីខ្លះដើម្បីកែលំអគោលបំណង និងខ្លឹមសារវគ្គបណ្តុះបណ្តាលនេះ?

..........................................................................................................................

..........................................................................................................................

# ឧបសម្ព័ន្ធ

# ១

# ឧបសម្ព័ន្ធ ២ សន្ទានុក្រម

## សន្ទានុក្រម

១. ការកែទម្រង់ស្ថាប័ន ឬកំណែទម្រង់ស្ថាប័ន (Institutional Reform) សំដៅទៅលើការផ្លាស់ប្តូររចនាសម្ព័ន្ធ ប្រព័ន្ធ នីតិវិធី និងរបៀបរបបធ្វើការងារ រួមទាំងខ្សែគណនេយ្យភាព ទំនាក់ទំនង និងដំណើរការនៃការធ្វើសេចក្តីសម្រេចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

២. ការឆ្លើយតប និងគណនេយ្យភាព (Responsiveness and Accountability) មានន័យថាក្នុងនាមជាតំណាងប្រជាពលរដ្ឋនៅមូលដ្ឋាន ក្រុមប្រឹក្សាត្រូវឆ្លើយតបចំពោះប្រជាពលរដ្ឋរបស់ខ្លួនក្នុងការធ្វើគោលនយោបាយ សេចក្តីសម្រេចចិត្ត សកម្មភាព និងការបំពេញការងាររបស់ខ្លួន ទទួលខុសត្រូវនូវអ្វី ដែលខ្លួនបានអនុវត្ត។ ក្រុមប្រឹក្សាក៏ទទួលខុសត្រូវផងដែរ ចំពោះរាជរដ្ឋាភិបាលក្នុងការប្រតិបត្តិតាមរដ្ឋធម្មនុញ្ញ និងច្បាប់នានា។

៣. ការទទួលខុសត្រូវ (Responsibility) សំដៅទៅលើតួនាទី និងកាតព្វកិច្ចដែលបានប្រគល់ឱ្យដោយច្បាប់ ឬលិខិតបទដ្ឋានគតិយុត្ត ទៅឱ្យបុគ្គល អង្គការចាត់តាំងនៃរដ្ឋបាលណាមួយ ឬរដ្ឋបាលនីមួយៗនៃរដ្ឋបាលថ្នាក់ក្រោមជាតិ។

៤. ការធ្វើប្រតិភូកម្ម ឬការធ្វើវិសហមជ្ឈការមុខងារ (Delegation of Function) សំដៅទៅលើការផ្ទេរនូវមុខងារ ការទទួលខុសត្រូវ សិទ្ធិអំណាច និងធនធានុសិទ្ធិ ទៅឱ្យរដ្ឋបាលនីមួយៗនៃរដ្ឋបាលថ្នាក់ក្រោមជាតិដើម្បីគ្រប់គ្រង និងអនុវត្តមុខងារ ក្នុងនាមអាជ្ញាធរដែលធ្វើប្រតិភូកម្ម ដោយផ្អែកតាមតម្រូវការនៃការធ្វើប្រតិភូកម្មនោះ។ អាជ្ញាធរដែលបានធ្វើប្រតិភូកម្ម នៅតែរក្សាភាពជាម្ចាស់លើកិច្ចការដែលបានធ្វើប្រតិភូកម្ម។

៥. ការធ្វើស្ថាប័នភាវូបនីយកម្ម (Institutionalization) សំដៅលើការរៀបចំរចនាសម្ព័ន្ធ ប្រព័ន្ធ នីតិវិធីប្រតិបត្តិការ និងនិយាមការងារ សមស្របនៅក្នុងស្ថាប័នមានសមត្ថកិច្ច ដើម្បីធានាដល់បំពេញការងារប្រកបដោយប្រសិទ្ធភាព និងនិរន្តរភាព។

៦. ការបង្កើនភាពអង់អាចដល់ស្ត្រី (Empowerment of Women) សំដៅទៅលើដំណើរការក្នុងការជួយស្ត្រីផ្នែកសង្គមកិច្ច សេដ្ឋកិច្ច នយោបាយ និងច្បាប់ ដើម្បីឱ្យស្ត្រីអាចនឹងធ្វើសកម្មភាពក្នុងការពង្រឹងសិទ្ធិសមត្ថភាព ការទទួលបាននូវសេវាសាធារណៈ ការគ្រប់គ្រងធនធាន និងការចូលរួមដោយស្មើភាពនៅក្នុងកិច្ចការដែលពីមុន គេហាមឃាត់ ឬកម្រិតស្ត្រីមិនឱ្យចូលរួម។

៧. ការបញ្ជ្រាបយេនឌ័រ (Gender Mainstreaming) សំដៅទៅលើវិធីសាស្ត្រនៃការដាក់បញ្ចូលកង្វល់ពាក់ព័ន្ធនឹងយេនឌ័រទៅក្នុងការវិភាគ ការរៀបចំ និងការតាមដានត្រួតពិនិត្យគោលនយោបាយ កម្មវិធី និងគម្រោងអភិវឌ្ឍន៍នានា ដើម្បីធានាដល់ការកាត់បន្ថយវិសមភាព និងគម្លាតយេនឌ័រ។

៨. ការប្រគល់ ឬការធ្វើវិមជ្ឈការមុខងារ (Assignment of Function) សំដៅទៅលើការផ្ទេរភាពជាម្ចាស់នៃមុខងារ ការទទួលខុសត្រូវ សិទ្ធិអំណាច និងធនធានុសិទ្ធិទាំងអស់ដែលចាំបាច់ ទៅឱ្យរដ្ឋបាលនីមួយៗ នៃរដ្ឋ-

បាល ថ្នាក់ក្រោមជាតិ ដើម្បីគ្រប់គ្រង និងអនុវត្តមុខងារ។

៩. ការប្រែប្រួលអាកាសធាតុ ឬបម្រែបម្រួលអាកាសធាតុ (Climate Change) សំដៅទៅលើការប្រែប្រួលសីតុណ្ហភាពនៃបរិយាកាសនៅជុំវិញភពផែនដី ជាពិសេសការកើនកំដៅ (ដែលអាចបណ្តាលឱ្យប្រែប្រួលដល់របបទឹកភ្លៀង មានទឹកជំនន់ មានព្យុះ និងគ្រោះមហន្តរាយផ្សេងៗទៀត) ដែលបណ្តាលមកពីការកើនឡើងនូវកំហាប់ ឧស្ម័នផ្ទះកញ្ចក់។ ឧស្ម័នផ្ទះកញ្ចក់ គឺជាស្រទាប់បរិយាកាសនៅជុំវិញភពផែនដីដែលផ្សំឡើងដោយសារចំហាយទឹក ឧស្ម័នកាបូនិច មេតាន ឌីអាសូតម៉ូណូអុកស៊ីត និងអូសូន ហើយបើឧស្ម័នទាំងនេះកើតឡើងដោយធម្មជាតិ នោះឧស្ម័ន ផ្ទះកញ្ចក់នេះមានតួនាទីថែរក្សាសីតុណ្ហភាពសមស្របសម្រាប់ទ្រទ្រង់ជីវិតសត្វ និងរុក្ខជាតិនៅលើភពផែនដី។

១០. ការផ្ទេរមុខងារ (Transfer of Function) សំដៅទៅលើការប្រគល់ ឬការធ្វើប្រតិភូកម្មនូវមុខងារទៅឱ្យរដ្ឋបាលនីមួយៗនៃរដ្ឋបាលថ្នាក់ក្រោមជាតិ ដោយភ្ជាប់ជាមួយនូវធនធាន និងសមត្ថភាព។

១១. ការពិគ្រោះយោបល់ និងការចូលរួម (Consultation and Participation) មានន័យថា ជាដំណើរការនៃការអនុវត្តការងារ និងការធ្វើសេចក្តីសម្រេចចិត្តរបស់ក្រុមប្រឹក្សា ដែលក្រុមប្រឹក្សាត្រូវជួបពិភាក្សា និង ពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋនៅមូលដ្ឋាន ព្រមទាំងលើកទឹកចិត្ត និងសម្របសម្រួលឱ្យមានការចូលរួមរបស់ប្រជាពលរដ្ឋនៅមូលដ្ឋាន នៅគ្រប់ផ្នែកទាំងអស់នៃអភិបាលកិច្ច ដើម្បីស្វែងយល់ និងឆ្លើយតបតម្រូវការ របស់ប្រជាពលរដ្ឋ។

១២. ការរៀបចំស្ថាប័នឡើងវិញ (Institutional Restructuring) សំដៅទៅលើការសិក្សាពិនិត្យ និងការរៀបចំឡើងវិញនូវរចនាសម្ព័ន្ធ ប្រព័ន្ធ នីតិវិធី តួនាទី ភារកិច្ច និងការទទួលខុសត្រូវរបស់អង្គភាពនានារបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ឬក្រសួង ស្ថាប័ន។

១៣. ការលើកកម្ពស់គុណភាពជីវិតរបស់ប្រជាពលរដ្ឋក្នុងមូលដ្ឋាន (Promotion of Life Quality of the Local Residents) សំដៅទៅលើកិច្ចខិតខំប្រឹងប្រែងដើម្បីបង្កើត និងធ្វើឱ្យមាននិរន្តរភាពនូវបរិយាកាសមួយ ប្រកបដោយសន្តិភាព សុវត្ថិភាពនិងសុខុមាលភាព លើកកម្ពស់ការអភិវឌ្ឍសង្គមនិងសេដ្ឋកិច្ច និងលើកកម្ពស់ ផាសុកភាពនិងគុណភាពជីវិតនៃប្រជាពលរដ្ឋក្នុងមូលដ្ឋាន។

១៤. ការលើកស្ទួយសមធម៌ (Promotion of Equity) មានន័យថា ការគិតគូរ និងយកចិត្តទុកដាក់ជាពិសេសទៅលើតម្រូវការខុសៗគ្នារបស់ស្ត្រី បុរស យុវជន និងកុមារ ព្រមទាំងតម្រូវការខុសៗគ្នារបស់ក្រុមជនងាយរងគ្រោះ រាប់បញ្ចូលទាំងប្រជាពលរដ្ឋក្រីក្រ និងជនជាតិដើមភាគតិច។

១៥. ការវិភាគយេនឌ័រ (Gender Analysis) សំដៅទៅលើដំណើរការនៃការពិនិត្យ និងកំណត់ឱ្យបានច្បាស់អំពីស្ថានភាព តួនាទី តម្រូវការ និងផលប្រយោជន៍ខុសគ្នាៗរវាងស្ត្រី បុរសនៅក្នុងការប្រកបការងារ និងជីវិតរស់នៅ និងនៅក្នុងគោលនយោបាយ ផែនការ គម្រោង និងកម្មវិធីអភិវឌ្ឍន៍នានា ដើម្បីធ្វើឱ្យកិច្ចអន្តរាគមន៍ និងដំណោះ ស្រាយនានា មានការឆ្លើយតបទៅនឹងស្ថានភាព និងតម្រូវការទាំងនោះ។

១៦. ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ (Democratic Development) សំដៅទៅលើការអភិវឌ្ឍដែលដំណើរ

ការដោយមានលក្ខណៈ (១)ភាពជាតំណាងសាធារណៈ (២)ស្វ័យភាពរបស់មូលដ្ឋាន (៣)ការពិគ្រោះយោបល់និងការចូលរួម (៤)ការឆ្លើយតបនិងគណនេយ្យភាព (៥)ការលើកកម្ពស់គុណភាពជីវិតរបស់ប្រជាពលរដ្ឋក្នុងមូលដ្ឋាន (៦)ការលើកស្ទួយសមធម៌ (៧)តម្លាភាពនិងសុចរិតភាព និង (៨)វិធានការប្រឆាំងអំពើពុករលួយនិងការរំលោភអំណាច។

១៧. ការអភិវឌ្ឍស្ថាប័ន (Institutional Development) សំដៅទៅលើការបង្កើតរចនាសម្ព័ន្ធ ប្រព័ន្ធ នីតិវិធីក្រម ឬនិយាមការងារ និងការអភិវឌ្ឍសមត្ថភាពរបស់ស្ថាប័នណាមួយ ឬរដ្ឋបាលថ្នាក់ក្រោមជាតិ។

១៨. គណនេយ្យភាព (Accountability) គឺការកាតព្វកិច្ចរបស់អ្នកដែលទទួលបាននូវការទទួលខុសត្រូវនិងសិទ្ធិអំណាចដើម្បីឆ្លើយបំភ្លឺ និងទទួលខុសត្រូវចំពោះទង្វើនានារបស់ខ្លួន រួមទាំងផលវិបាកដែលកើតឡើងពីទង្វើទាំងនោះ។

១៩. គណនេយ្យភាពខ្សែទទឹង (Horizontal Accountability) សំដៅទៅលើខ្សែគណនេយ្យភាពរវាងមន្ទីរ អង្គភាពរបស់ក្រសួង ស្ថាប័នថ្នាក់ជាតិ ជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលខ្លួនប្រតិបត្តិនៅក្នុងដែនសមត្ថកិច្ចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនោះ។

២០. គណនេយ្យភាពខ្សែបណ្តោយ (Vertical Accountability) សំដៅទៅលើខ្សែគណនេយ្យភាពរវាងរដ្ឋបាលថ្នាក់ក្រោមជាតិជាមួយក្រសួង ស្ថាប័នថ្នាក់ជាតិ ឬរវាងមន្ទីរ អង្គភាពរបស់ក្រសួង ស្ថាប័នដែលប្រតិបត្តិនៅថ្នាក់ក្រោមជាតិ ជាមួយក្រសួង ស្ថាប័នសាមី។

២១. គណនេយ្យភាពចំពោះប្រជាពលរដ្ឋ ឬគណនេយ្យភាពពីលើទៅក្រោម (Accountability to Citizens or Downward Accountability) សំដៅទៅលើខ្សែគណនេយ្យភាពរវាងរដ្ឋបាលថ្នាក់ក្រោមជាតិជាមួយ ប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ ឧទាហរណ៍ :

- រដ្ឋបាលថ្នាក់ក្រោមជាតិឆ្លើយតបទៅនឹងតម្រូវការជាអាទិភាពរបស់ប្រជាពលរដ្ឋ ជាពិសេសស្ត្រី កុមារ ក្រុមជនងាយរងគ្រោះ និងជនជាតិដើមភាគតិច និងផ្តល់សេវាសាធារណៈប្រកបដោយប្រសិទ្ធភាព
- រដ្ឋបាលថ្នាក់ក្រោមជាតិរៀបចំឱ្យមានយន្តការសម្រាប់ការចូលរួមប្រជាពលរដ្ឋនៅក្នុងដំណើរការរៀបចំនិង អនុវត្តផែនការនិងថវិកា និងសេចក្តីសម្រេចនានារបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- រដ្ឋបាលថ្នាក់ក្រោមជាតិរៀបចំឱ្យមានយន្តការសម្រាប់ការពារសិទ្ធិនិងផលប្រយោជន៍របស់ប្រជាពលរដ្ឋនិង ផ្តល់ព័ត៌មានដល់ប្រជាពលរដ្ឋ

២២. គណនេយ្យភាពផ្ទៃក្នុង (Internal Accountability) សំដៅទៅលើគណនេយ្យភាពនៅក្នុងអង្គការចាត់តាំងមួយរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ឬនៅក្នុងរង្វង់រដ្ឋបាលមួយនៃរដ្ឋបាលថ្នាក់ក្រោមជាតិ។ ឧទាហរណ៍ :

- គណនេយ្យភាពរវាងគណៈអភិបាលនិងទីចាត់ការនានានៃរដ្ឋបាលខេត្ត "ក" ជាមួយនឹងក្រុមប្រឹក្សាខេត្ត "ក"
- គណនេយ្យភាពនៅក្នុងគណៈអភិបាលខេត្ត "ក"
- គណនេយ្យភាពនៅក្នុងទីចាត់ការនីមួយនៃរដ្ឋបាលខេត្ត "ក"។

២៣. គណនេយ្យភាពផ្នែកគោលនយោបាយ (Political Accountability) សំដៅទៅលើគណនេយ្យភាពរបស់អ្នកជាប់ឆ្នោតចំពោះប្រជាពលរដ្ឋ ឬអ្នកបោះឆ្នោត តាមរយៈការបំពេញតួនាទីនៅក្នុងអំឡុងអាណត្តិរបស់ខ្លួន។

២៤. គណនេយ្យភាពផ្នែកច្បាប់ (Legal Accountability) សំដៅទៅលើគណនេយ្យភាពចំពោះមុខច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានាជាធរមាន។

២៥. គណនេយ្យភាពផ្នែករដ្ឋបាល (Administrative Accountability) សំដៅទៅលើគណនេយ្យភាព ដែលពាក់ព័ន្ធនឹងការរៀបចំប្រព័ន្ធគ្រប់គ្រង នីតិវិធីប្រតិបត្តិស្តង់ដារ និងនិយាមការងាររបស់បុគ្គល និងអង្គការចាត់តាំងទៅតាមឋានានុក្រម។

២៦. គណនេយ្យភាពផ្នែកហិរញ្ញវត្ថុ (Financial Accountability) សំដៅទៅលើគណនេយ្យភាពដែលពាក់ព័ន្ធនឹងការរៀបចំប្រព័ន្ធ និងនីតិវិធីគ្រប់គ្រងថវិកា និងហិរញ្ញវត្ថុ ស្របទៅតាមច្បាប់ និងគោលការណ៍ហិរញ្ញវត្ថុ សាធារណៈ។

២៧. គណនេយ្យភាពផ្នែកសង្គម (Social Accountability) សំដៅទៅលើសកម្មភាព និងយន្តការនានា ដែលប្រជាពលរដ្ឋអាចប្រើប្រាស់ដើម្បីទាមទារឱ្យរដ្ឋមានគណនេយ្យភាពចំពោះខ្លួន ព្រមទាំងសកម្មភាពនានារបស់ រដ្ឋាបាលភិបាល សង្គមស៊ីវិល និងតួអង្គដទៃទៀត ក្នុងការលើកកម្ពស់ការអនុវត្តសកម្មភាព និងយន្តការទាំងនោះ។

២៨. គណនេយ្យភាពអន្តររដ្ឋបាល (Inter-governmental Accountability) សំដៅទៅលើគណនេយ្យភាពរវាងក្រសួង ស្ថាប័ន មន្ទីរ ទីភ្នាក់ងារនានារបស់ក្រសួង ស្ថាប័ន ជាមួយនឹងរដ្ឋបាលនានានៃរដ្ឋបាលថ្នាក់ក្រោមជាតិ។ ឧទាហរណ៍ :

- គណនេយ្យភាពរវាងក្រសួង ស្ថាប័ន ជាមួយនឹងរដ្ឋបាលរាជធានី ខេត្ត ឬរដ្ឋបាលក្រុង ស្រុក ខណ្ឌ ឬរដ្ឋបាល ឃុំ សង្កាត់
- គណនេយ្យភាពរវាងមន្ទីរ ទីភ្នាក់ងារនានារបស់ក្រសួង ស្ថាប័ន ជាមួយនឹងរដ្ឋបាលរាជធានី ខេត្ត ឬរដ្ឋបាល ក្រុង ស្រុក ខណ្ឌ ឬរដ្ឋបាលឃុំ សង្កាត់

២៩. គណនេយ្យភាពអន្តររដ្ឋបាលថ្នាក់ក្រោមជាតិ (Intra-SNA Accountability) សំដៅទៅលើគណនេយ្យភាពរវាងរដ្ឋបាលថ្នាក់ក្រោមជាតិ ឬរវាងអង្គការចាត់តាំងនានានៃរដ្ឋបាលថ្នាក់ក្រោមជាតិដែលមានប្រភេទដូចគ្នា ឬប្រភេទផ្សេងគ្នា។ ឧទាហរណ៍ :

- គណនេយ្យភាពរវាងរដ្ឋបាលខេត្ត“ក” និងរដ្ឋបាលខេត្ត“ខ”
- គណនេយ្យភាពរវាងរដ្ឋបាលរាជធានី ខេត្ត រដ្ឋបាលក្រុង ស្រុក ខណ្ឌ និងរដ្ឋបាលឃុំ សង្កាត់
- គណនេយ្យភាពរវាងក្រុមប្រឹក្សាខេត្ត“ក”និងក្រុមប្រឹក្សាខេត្ត“ខ”
- គណនេយ្យភាពរវាងក្រុមប្រឹក្សារាជធានី ខេត្ត ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ និងក្រុមប្រឹក្សាឃុំ សង្កាត់

- គណនេយ្យភាពរវាងគណៈអភិបាលខេត្ត "ក" និងគណៈអភិបាលខេត្ត "ខ"
- គណនេយ្យភាពរវាងគណៈអភិបាលរាជធានី ខេត្ត គណៈអភិបាលក្រុង ស្រុក ខណ្ឌ និងមេឃុំ ចៅសង្កាត់។

៣០. តម្រូវការផ្នែកមូលធន (Capital Requirement) សំដៅលើតម្រូវការផ្នែកហេដ្ឋារចនាសម្ព័ន្ធរូបវន្តសម្រាប់បម្រើឱ្យការបំពេញការងាររបស់ស្ថាប័ននានា។

៣១. តម្រូវការយេនឌ័រ (Gender Need) បែងចែកជាពីរ គឺតម្រូវការយេនឌ័រចំពោះមុខ និងតម្រូវការយេនឌ័រជាយុទ្ធសាស្ត្រ។

- តម្រូវការយេនឌ័រចំពោះមុខ សំដៅលើតម្រូវការ ឬសេចក្តីត្រូវការរបស់បុរស និងស្ត្រីសម្រាប់បំពេញនូវជីវភាពរស់នៅប្រចាំថ្ងៃ។
- តម្រូវការយេនឌ័រជាយុទ្ធសាស្ត្រ សំដៅដល់ធនធាន សម្ភារៈ ឧបករណ៍ សេវាកម្ម ឬសកម្មភាពនានា ដែលអាចជួយពង្រីកឱកាស បង្កើនការចូលរួម ឬគ្រប់គ្រងតួនាទីយេនឌ័ររបស់បុរសនិងស្ត្រី និងការងារ។ នៅពេលដែលតម្រូវការទាំងនោះត្រូវបានបំពេញ អំណាចនៃទំនាក់ទំនងរវាងបុរសនិងស្ត្រី និងការបែងចែកការងារតាមយេនឌ័រពិតជាអាចកែប្រែបានច្រើន ហើយអាចជួយរួមចំណែកលើកកម្ពស់សមភាពយេនឌ័រថែមទៀតផង។ តម្រូវការយេនឌ័រជាយុទ្ធសាស្ត្រ អាចប្រើប្រាស់រយៈពេលយូរជាងធម្មតា ហើយមើលមិនសូវឃើញជារូបរាងច្បាស់លាស់ទេ ដូចជាការផ្តល់នូវឱកាសទទួលបានតំណែងក្នុងឆាកនយោបាយ តំណែងក្នុងថ្នាក់ធ្វើសេចក្តីសម្រេច ការលុបបំបាត់ឧបសគ្គផ្លូវច្បាប់ ក៏ដូចជាការរើសអើងនៃសិទ្ធិកាន់កាប់ដីធ្លី ឬឥណទានជាដើម។

ដោយសារទំនាក់ទំនង តួនាទី និងសិទ្ធិអំណាច ដែលសង្គម សហគមន៍ និងគ្រួសារបានផ្តល់ដល់ស្ត្រី បុរសមានលក្ខណៈខុសគ្នា ដូចនេះសេចក្តីត្រូវការរបស់ពួកគេក៏មានលក្ខណៈខុសគ្នាទៅតាមនោះដែរ។ ដូច្នេះ វាមានសារៈសំខាន់ណាស់ក្នុងការយល់ដឹង និងវិភាគបែងចែកឱ្យបានច្បាស់ពីតម្រូវការទាំងនោះ ដើម្បីធ្វើឱ្យកម្មវិធី គម្រោង និងផែនការអភិវឌ្ឍន៍នានា បានឆ្លើយតបទៅនឹងតម្រូវការពិតប្រាកដរបស់ស្ត្រីនិងបុរសនៅក្នុងសហគមន៍ និងមូលដ្ឋាន។

៣២. តម្លាភាព និងសុចរិតភាព (Transparency and Integrity) មានន័យថា ជាការចាត់ចែង និងគ្រប់គ្រងកិច្ចការនានា រាប់បញ្ចូលទាំងកិច្ចការ ហិរញ្ញវត្ថុ ដោយអនុលោមតាមបទដ្ឋានខ្ពស់បំផុតនៃសុចរិតភាព និងច្បាប់ ក្នុងលក្ខណៈបើកចំហ ប្រកបដោយតម្លាភាព ការចូលរួម និងការឆ្លើយតប។

៣៣. តួនាទី (Role) សំដៅទៅលើសំណុំសកម្មភាពដែលផ្តល់ដោយច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត ទៅឱ្យបុគ្គលិក ឬរដ្ឋបាលនីមួយៗនៃរដ្ឋបាលថ្នាក់ក្រោមជាតិ។

៣៤. តួនាទីយេនឌ័រ (Gender Role) សំដៅលើតួនាទី ឬភារកិច្ចសម្រាប់ក្មេងស្រី ក្មេងប្រុស ស្ត្រី បុរស ដែលកំណត់ឡើងដោយសង្គម។ ដោយសារតួនាទីយេនឌ័រត្រូវបានបង្កើតឡើងដោយសារសង្គម ដូច្នេះតួនាទីនេះអាចកែប្រែ ឬប្រែប្រួលគ្រប់ពេលវេលា ហើយខុសៗគ្នា ទៅតាមទំនៀមទម្លាប់ និងវប្បធម៌នៃប្រទេសនីមួយៗ។ តួនាទីយេនឌ័រមាន ឥទ្ធិពលប៉ះពាល់ដល់ទំនាក់ទំនងរវាងបុរស និងស្ត្រី ហើយឥទ្ធិពលនេះអាចបង្កឱ្យមានវិសមភាព

នៃឱកាស និងការរំពឹងទុករបស់បុរស និងស្ត្រីនៅក្នុងសង្គម និងកិច្ចអភិវឌ្ឍ។

៣៥. ទ្រព្យសម្បត្តិសាធារណៈ (Public Goods) គឺជាទ្រព្យសម្បត្តិ និងសេវាសាធារណៈទាំងឡាយដែលបុគ្គលគ្រប់រូបអាចប្រើប្រាស់បានក្នុងពេលដំណាលគ្នា ដោយពុំមានការបន្ថយនូវលទ្ធភាព និងតម្លៃក្នុងការប្រើប្រាស់របស់បុគ្គលណាមួយឡើយ។

៣៦. ទំនាក់ទំនងអន្តររដ្ឋបាល (Inter-governmental Relations) សំដៅទៅលើទំនាក់ទំនងរវាងក្រសួង ស្ថាប័ន មន្ទីរ ទីភ្នាក់ងារនានារបស់ក្រសួង ស្ថាប័ន ជាមួយនឹងរដ្ឋបាលនានានៃរដ្ឋបាលថ្នាក់ក្រោមជាតិ។

៣៧. ទំនាក់ទំនងអន្តររដ្ឋបាលថ្នាក់ក្រោមជាតិ (Intra-SNA Relations) សំដៅទៅលើទំនាក់ទំនងរវាងរដ្ឋបាលថ្នាក់ក្រោមជាតិ ឬរវាងអង្គការចាត់តាំងនានានៃរដ្ឋបាលថ្នាក់ក្រោមជាតិដែលមានប្រភេទដូចគ្នាឬប្រភេទផ្សេងគ្នា។

៣៨. ធាតុចូល (Input) សំដៅទៅលើអ្វីៗដែលចូលរួមចំណែកក្នុងការបង្កើតនូវលទ្ធផល (Output)។

៣៩. នីតិវិធីប្រតិបត្តិស្តង់ដារ (Standard Operating Procedure) សំដៅទៅលើនីតិវិធីស្តីពីកិច្ចការរដ្ឋបាល (រួមទាំងការគ្រប់គ្រងបុគ្គលិក និងការគ្រប់គ្រងការិយាល័យ) និងនីតិវិធីស្តីពីកិច្ចការហិរញ្ញវត្ថុ (រួមទាំងកិច្ច លទ្ធកម្ម) ដែលធានាឱ្យមានតម្លាភាព សុចរិតភាព និងប្រសិទ្ធភាពក្នុងការបំពេញការងាររបស់រដ្ឋបាលនីមួយៗ នៃរដ្ឋបាលថ្នាក់ក្រោមជាតិ។

៤០. បញ្ហាយេនឌ័រ (Gender Issue) សំដៅលើផលប៉ះពាល់ជាអវិជ្ជមានដែលកើតមកពីផ្នត់គំនិត ឬការប្រព្រឹត្តមកលើបុរស ស្ត្រី ឬក្មេងប្រុស ក្មេងស្ត្រីរបស់គ្រួសារ សហគមន៍ និងសង្គម តាមរយៈការបែកការងារពលកម្ម ការអប់រំ សិទ្ធិអំណាច លំដាប់ថ្នាក់ ឋានៈ និងតួនាទី។ ដូចជាការកំណត់ថាក្មេងស្រីមិនគួររៀនច្រើនបានបណ្តាលឱ្យមានផលប៉ះពាល់ជាអវិជ្ជមានដល់ស្ត្រី និងក្មេងស្រី ពុំសូវមានចំណេះដឹងខ្ពស់ មានការលំបាកក្នុងការចូលរួមក្នុងការងារសង្គម ទទួលព័ត៌មានជាដើម។

៤១. បន្សុំាទៅនឹងការប្រែប្រួលអាកាសធាតុ (Climate Change Adaptation) គឺជាលទ្ធភាពកែតម្រូវរបស់មនុស្ស សត្វ រុក្ខជាតិ និងប្រព័ន្ធអេកូឡូស៊ីទៅនឹងការប្រែប្រួលអាកាសធាតុ ដើម្បីកាត់បន្ថយនូវផលប៉ះពាល់អវិជ្ជមាននៃការប្រែប្រួលអាកាសធាតុ សំដៅទាញយកកាលានុវត្តភាព ឬដោះស្រាយផលវិបាកនៃការប្រែប្រួល អាកាសធាតុ។ បន្សុំាអាចកើតឡើងដោយឯកឯង ឬដោយការគ្រោងទុកជាមុន។

៤២. ភាពជាតំណាងសាធារណៈ (Public Representation) មានន័យថា ក្រុមប្រឹក្សាត្រូវអនុវត្តការងារក្នុងនាមនិងធ្វើជាតំណាងឱ្យប្រជាពលរដ្ឋ ទាំងអស់នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

៤៣. ភារកិច្ច (Duty) សំដៅទៅលើកិច្ចការនានាដែលបុគ្គលិក ឬរដ្ឋបាលនីមួយៗនៃរដ្ឋបាលថ្នាក់ក្រោមជាតិមានកាតព្វកិច្ចត្រូវអនុវត្ត។

៤៤. មុខងារ (Function) សំដៅទៅលើសកម្មភាពរបស់រដ្ឋាភិបាលក្នុងការឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់សហគមន៍ តាមរយៈទង្វើប្រកបដោយនិរន្តរភាព ហើយផ្តល់ផលប្រយោជន៍ដល់សហគមន៍។ ខ

ទាហរណ៍ សហគមន៍ត្រូវការទឹកស្អាតសម្រាប់ប្រើប្រាស់ក្នុងជីវភាពប្រចាំថ្ងៃរបស់ខ្លួន។ រដ្ឋបាលណាមួយនៃរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវទទួលយកនូវមុខងារក្នុងការផ្តល់នូវទឹកស្អាតដល់សហគមន៍ប្រើប្រាស់ជាប្រចាំតាមរយៈការបង្កើតហេដ្ឋារចនាសម្ព័ន្ធទឹកស្អាត ព្រមទាំងយន្តការសម្រាប់គ្រប់គ្រង ថែទាំ ត្រួតពិនិត្យ គុណភាពទឹក។ល។

៤៥. មុខងារជាកាតព្វកិច្ច (Obligatory Functions) គឺជាមុខងារដែលផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ តាមរយៈច្បាប់ព្រះរាជក្រឹត្យ អនុក្រឹត្យ ឬប្រកាស តាមសំណើរបស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាល សម្រាប់គោលបំណងជាកាតព្វកិច្ចមួយ ឬច្រើនដែលបានកំណត់ដោយក្រសួង ស្ថាប័នថ្នាក់ជាតិ។

៤៦. មុខងារជាជម្រើស (Permissive Functions) គឺមុខងារដែលរដ្ឋបាលថ្នាក់ក្រោមជាតិមានឆន្ទានុសិទ្ធិក្នុងការបង្កើតការជំរុញ និងការធ្វើឱ្យមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ ដើម្បីឆ្លើយតបដោយផ្ទាល់ទៅនឹងតម្រូវការជាក់ស្តែងរបស់ប្រជាពលរដ្ឋនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ដោយមិនមានការរំលោភ ឬផ្ទុយនឹងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តរបស់ជាតិ។

៤៧. មូលនិធិផ្ទេរគ្មានភ្ជាប់លក្ខខណ្ឌ (Unconditional Fund) គឺជាមូលនិធិដែលក្រុមប្រឹក្សាត្រូវប្រើប្រាស់ដើម្បី ៖

- បំពេញភារកិច្ចតាមផ្លូវច្បាប់
- បំពេញមុខងារ ភារកិច្ចក្នុងការបង្កើត ការជំរុញ និងការធ្វើឱ្យមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ
- ចំណាយផ្នែករដ្ឋបាលរបស់ខ្លួន និង
- ជ្រើសរើស គ្រប់គ្រង ចាត់ចែង និងអនុវត្តមុខងារជាជម្រើសនានា។

៤៨. មូលនិធិផ្ទេរមានភ្ជាប់លក្ខខណ្ឌ (Conditional Fund) គឺជាមូលនិធិដែលក្រុមប្រឹក្សាត្រូវប្រើប្រាស់ ៖

- ដើម្បីគ្រប់គ្រងចាត់ចែង និងអនុវត្តមុខងារជាកាតព្វកិច្ចមួយឬច្រើនដែលត្រូវបានផ្ទេរឱ្យក្រុមប្រឹក្សាតាមការប្រគល់មុខងារ ឬការធ្វើប្រតិភូកម្មមុខងារ ឬ
- ដើម្បីបន្តគ្រប់គ្រង ចាត់ចែង និងអនុវត្តមុខងារជាជម្រើសមួយឬច្រើនដែលក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាលធ្លាប់បានអនុវត្ត ឬ
- សម្រាប់គោលបំណងជាកាតព្វកិច្ចមួយឬច្រើនដែលបានកំណត់។

៤៩. យេនឌ័រ (Gender) សំដៅលើផ្នត់គំនិត ឬការប្រព្រឹត្តរបស់គ្រួសារ សហគមន៍ និងសង្គមដែលពាក់ព័ន្ធនឹងការបែងចែកការងារ ពលកម្ម ការអប់រំ សិទ្ធិអំណាច លំដាប់ថ្នាក់ ឋានៈ និងតួនាទីដល់កូនស្រី និងកូនប្រុស ឬស្ត្រី និងបុរស។ ដូចជាការកំណត់របស់គ្រួសារលើការសិក្សារបស់កូនស្រី កូនប្រុស ការកំណត់ការងារសម្រាប់ក្មេងស្រី ក្មេងប្រុស រួមទាំងការងារផ្ទះសម្បែងជាដើម។

៥០. រចនាសម្ព័ន្ធប្រតិបត្តិការ (Operational Structure) ត្រូវអនុវត្តទៅតាមទស្សនទានពីរ គឺផ្នែកជួរមុខ និងផ្នែកទ្រទ្រង់។

- ផ្នែកជួរមុខ (Front Office) គឺជាផ្នែកដែលត្រូវធ្វើទំនាក់ទំនងដោយផ្ទាល់ជាមួយអ្នកប្រើប្រាស់សេវា។ ដើម្បីឱ្យផ្នែកជួរមុខមានសមត្ថភាពគ្រប់គ្រាន់ក្នុងការផ្តល់សេវាជូនអ្នកប្រើប្រាស់សេវា មន្ត្រីរាជការ ឬភ្នាក់ងារដែលបម្រើការងារនៅផ្នែកនេះ ត្រូវតែយល់ដឹងជារួម និងតាមវិស័យជំនាញនូវសេវាសាធារណៈនោះ និង ត្រូវមានអាកប្បកិរិយាល្អ យកចិត្តទុកដាក់ចំពោះសេចក្តីត្រូវការ និងជួយបំភ្លឺចម្ងល់ផ្សេងៗរបស់អ្នកប្រើប្រាស់សេវា។ ផ្នែកជួរមុខ មានភារកិច្ចផ្តល់ព័ត៌មានពន្យល់អំពីនីតិវិធីនៃការទទួលសេវាបញ្ជូននិងបែងចែក សំណុំឯកសារទៅតាមវិស័យជំនាញទទួលប្រាក់កម្រៃសេវា ព្រមទាំងផ្តល់លទ្ធផល និងសេចក្តីសម្រេចពាក់ព័ន្ធនឹងការស្នើសុំសេវាទៅអ្នកប្រើប្រាស់សេវាវិញ។ ក្នុងករណីចាំបាច់ត្រូវផ្តល់ការណែនាំបន្ថែម និងជួយសម្រួលដល់ការបំពេញបែបបទ និងការទទួលពាក្យស្នើសុំពីអ្នកប្រើប្រាស់សេវាទាំងឡាយណាដែលពុំមានការយល់ដឹងច្បាស់លាស់ដូចជាករណីអ្នកមិនចេះអក្សរជាដើម។
- ផ្នែកទ្រទ្រង់ (Back Office) គឺជាផ្នែកដ៏សំខាន់សម្រាប់ធានាឱ្យផ្នែកជួរមុខទទួលបានជោគជ័យ។ ផ្នែក ទ្រទ្រង់មានភារកិច្ចពិនិត្យពាក្យស្នើសុំនិងឯកសារនានា លើកយោបល់ និងបញ្ជូនតាមលំដាប់លំដោយទៅសមត្ថកិច្ចពាក់ព័ន្ធ ដើម្បីសម្រេច និងប្រគល់លទ្ធផលទៅផ្នែកជួរមុខវិញ។

៥១. រចនាសម្ព័ន្ធមុខងារ (Functional Structure) សំដៅលើរបៀបរបបធ្វើការងារដែលធ្វើទៅតាមនីតិវិធី និង បទប្បញ្ញត្តិដែលបានកំណត់ ដោយមិនគិតពីលទ្ធផល ប្រសិទ្ធភាព និងការពេញចិត្តរបស់អ្នកប្រើប្រាស់សេវាឡើយ។

៥២. រដ្ឋបាលថ្នាក់ក្រោមជាតិ (Sub-national Administration) សំដៅទៅលើរដ្ឋបាលរាជធានី រដ្ឋបាលខេត្ត រដ្ឋ-បាលក្រុង រដ្ឋបាលស្រុក រដ្ឋបាលខណ្ឌ រដ្ឋបាលឃុំ និងរដ្ឋបាលសង្កាត់ ដែលរដ្ឋបាលនីមួយៗមានក្រុមប្រឹក្សាមួយជាតំណាង។

៥៣. រដ្ឋបាលឯកភាព (Unified Administration) គឺការរៀបចំឱ្យមានក្រុមប្រឹក្សានៅរដ្ឋបាលថ្នាក់ក្រោមជាតិមួយ ដែលអាចម្ចាស់ការក្នុងការគ្រប់គ្រង ចាត់ចែងមុខងារ និងធនធាន រាប់ទាំងហិរញ្ញវត្ថុ បុគ្គលិក ទ្រព្យ សម្បត្តិរបស់ខ្លួន ហើយក្រុមប្រឹក្សានីមួយៗនោះ មានសមត្ថភាពសម្របសម្រួលប្រកបដោយប្រសិទ្ធភាពនូវ សកម្មភាពនៃការផ្តល់សេវាកម្ម និងការអភិវឌ្ឍផ្សេងៗទៀត ដែលមាននៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន រួមទាំង ការផ្តល់សេវាកម្ម និងការអភិវឌ្ឍដែលធ្វើឡើងដោយក្រសួង ស្ថាប័ននានារបស់រាជរដ្ឋាភិបាល សំដៅឆ្លើយតប សេចក្តីត្រូវការរបស់ប្រជាពលរដ្ឋនៅមូលដ្ឋាន។

៥៤. វិធានការប្រឆាំងអំពើពុករលួយ និងការរំលោភអំណាច (Measures to Fight Corruption and Abuse of Power) មានន័យថា ជាការប្រកាន់យកនូវវិធាននៃច្បាប់ ព្រមទាំងការប្រឆាំង និងរាយការណ៍អំពីអំពើពុករលួយ និងការរំលោភអំណាច។

៥៥. វិធីសាស្ត្រផ្អែកតាមកម្មវិធី (Program-based Approaches) សំដៅទៅលើវិធីសាស្ត្រដែលជំរុញឱ្យមានកិច្ច

សហប្រតិបត្តិការក្នុងការអភិវឌ្ឍ ដោយផ្អែកលើគោលការណ៍នៃការប្រមូលផ្តុំនូវការគាំទ្រនានា សម្រាប់អនុវត្តកម្មវិធីដែលរដ្ឋាភិបាលធ្វើជាម្ចាស់។ ធាតុសំខាន់ៗទាំងបួននៃវិធីសាស្ត្រផ្អែកតាមកម្មវិធី រួមមាន (១)រដ្ឋាភិបាលជាអ្នកដឹកនាំ (២)ស្ថិតនៅក្រោមក្របខ័ណ្ឌកម្មវិធីនិងថវិកាតែមួយ (៣)សម្របសម្រួល និងធ្វើសុខដុមនីយកម្មនីតិវិធីសម្រាប់ផ្តល់ហិរញ្ញប្បទាន និង(៤)ខិតខំប្រឹងប្រែងក្នុងការប្រើប្រាស់ប្រព័ន្ធ និងនីតិវិធីរបស់រដ្ឋាភិបាល។

៥៦. វិធីសាស្ត្រផ្អែកតាមវិស័យ (Sector-wide Approaches) សំដៅទៅលើវិធីសាស្ត្រផ្អែកតាមកម្មវិធីសម្រាប់ប្រតិបត្តិការនៅក្នុងកម្រិតវិស័យទាំងមូល។ ឧទាហរណ៍ ការប្រើប្រាស់វិធីសាស្ត្រផ្អែកតាមកម្មវិធីសម្រាប់អនុវត្តកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ។

៥៧. សនិទានភាព (Rationale) គឺជាសេចក្តីពន្យល់អំពីមូលហេតុ ឬហេតុផលចម្បងៗដែលនាំឱ្យមានការរៀបចំ និងអនុវត្តកម្មវិធី គម្រោង សកម្មភាព ឬវិធានការណាមួយ។

៥៨. សមធម៌យេនឌ័រ (Gender Equity) គឺជាដំណើរការនៃការប្រព្រឹត្តដោយយុត្តិធម៌ទៅលើស្ត្រី និងបុរស សំដៅឆ្ពោះទៅសមភាពយេនឌ័រ តាមរយៈគោលនយោបាយ ច្បាប់ និងវិធានការនានាដើម្បីកែសម្រួលនូវភាពលំអៀងដែលមាននៅក្នុងសង្គមចំពោះស្ត្រីនិងបុរស។ ក្នុងនោះសំដៅលើវិធានការ ឬសកម្មភាពពិសេសជាក់លាក់ក្នុងការបង្កឱកាស ការលើកទឹកចិត្ត ការជំរុញដើម្បីឈានទៅរកភាពស្មើគ្នារវាងបុរស និងស្ត្រីនៅក្នុងការងារសង្គម និងនៅក្នុងគ្រួសារ (សមភាពយេនឌ័រ)។ ឧទាហរណ៍ ការប្រើប្រាស់គោលការណ៍សមធម៌យេនឌ័រក្នុងការលើកទឹកចិត្តឱ្យស្ត្រីបានចូលរួមជាបុគ្គលិករបស់ក្រុមប្រឹក្សា តាមរយៈការផ្តល់អាទិភាពដល់បេក្ខនារី ឬកំណត់ចំនួនជាក់លាក់ និងការពង្រឹងសមត្ថភាពជាដើម។

៥៩. សមភាពយេនឌ័រ (Gender Equality) សំដៅទៅលើភាពគ្មានការរើសអើងដែលប្រកាន់លើភេទណាមួយនៅក្នុងការបែងចែកធនធាន ផលប្រយោជន៍ ឬនៅក្នុងការទទួលបានសេវានានា។ សមភាពយេនឌ័រអាចវាស់វែងបានដោយការពិនិត្យមើលអំពី ការមានកាលានុវត្តភាពស្មើគ្នា ឬការទទួលបាននូវលទ្ធផលដូចគ្នារបស់ស្ត្រីបុរស។ ក្នុងនោះសំដៅលើភាពស្មើគ្នាលើការចូលរួម ការទទួលបាន ការគ្រប់គ្រង និងការធ្វើសេចក្តីសម្រេចរវាងបុរស និងស្ត្រីទៅលើធនធាន ទ្រព្យសម្បត្តិ និងសកម្មភាពផ្សេងៗក្នុងវិស័យសាធារណៈ និងឯកជន។

៦០. សវនកម្មផ្ទៃក្នុងផ្នែកហិរញ្ញវត្ថុ (Financial Internal Audit) គឺជាដំណើរការនៃការត្រួតពិនិត្យទៅលើប្រតិបត្តិការ និងកិច្ចបញ្ជីកាហិរញ្ញវត្ថុដែលធ្វើឡើងដោយសវនករផ្ទៃក្នុងដែលជាមន្ត្រី បុគ្គលិកនៅក្នុងអង្គភាព ស្ថាប័នរបស់ខ្លួនផ្ទាល់ ដើម្បីធានាដល់ភាពត្រឹមត្រូវនៃការអនុវត្តថវិកាទៅតាមគោលការណ៍ និងនីតិវិធីដែលបានកំណត់។

៦១. សវនកម្មផ្ទៃក្រៅផ្នែកហិរញ្ញវត្ថុ (Financial External Audit) គឺជាដំណើរការនៃការត្រួតពិនិត្យទៅលើប្រតិបត្តិការ និងកិច្ចបញ្ជីកាហិរញ្ញវត្ថុដែលធ្វើឡើងដោយសវនករឯករាជ្យ ដើម្បីធានាដល់ភាពត្រឹមត្រូវនៃការអនុវត្តថវិកាទៅតាមគោលការណ៍ និងនីតិវិធីដែលបានកំណត់។

៦២. សវនកម្មផ្នែកសង្គម (Social Audit) សំដៅទៅលើដំណើរការដែលប្រជាពលរដ្ឋចូលរួមជាមួយរដ្ឋាភិបាល ស្ថាប័នឯករាជ្យ ឬអង្គការសង្គមស៊ីវិលក្នុងការតាមដាន ត្រួតពិនិត្យ វាយតម្លៃ និងផ្តល់យោបល់ទៅលើការអនុវត្ត

សកម្មភាព ការផ្តល់សេវាសាធារណៈកម្មវិធី ឬគម្រោងជាក់លាក់ណាមួយរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

៦៣. សវនកម្មយេនឌ័រ (Gender Audit) សំដៅទៅលើវិធី និងដំណើរការសម្រាប់ធ្វើការប៉ាន់ប្រមាណ ដើម្បីឱ្យស្ថាប័ននានាមើលឃើញពីទំហំ និងកម្រិតនៃការប្តេជ្ញាចិត្ត ការគាំទ្រ និងការយកចិត្ត ទុកដាក់របស់ថ្នាក់ដឹកនាំ និងបុគ្គលិកលើការដោះស្រាយ និងឆ្លើយតបនឹងបញ្ហាយេនឌ័រក្នុងកម្មវិធី និងដំណើការផ្ទៃក្នុងរបស់ស្ថាប័ន និងដើម្បីកំណត់បាននូវដំណោះស្រាយ ឬកិច្ចអន្តរាគមន៍សមស្រប ឈានឆ្ពោះទៅការលើកកម្ពស់សមភាពយេនឌ័រ។

៦៤. ស្តង់ដារគណនេយ្យភាព (Accountability Standard) សំដៅទៅលើគណនេយ្យភាពដែលបានកំណត់សម្រាប់មន្ត្រី បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការបំពេញការងាររបស់ខ្លួន។

៦៥. ស្តង់ដារបំពេញការងារ (Performance Standard) សំដៅទៅលើនិយាមដែលបានកំណត់សម្រាប់ការអនុវត្តការងាររបស់មន្ត្រី បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ។

៦៦. ស្តង់ដារសមធម៌យេនឌ័រ (Gender Equity Standard) សំដៅទៅលើស្តង់ដារដែលត្រូវបានប្រើប្រាស់ ដើម្បីធានាដល់ការអនុវត្តប្រកបដោយសមធម៌រវាងស្ត្រី និងបុរស។

៦៧. ស្តង់ដារសមភាពយេនឌ័រ (Gender Equality Standard) សំដៅទៅលើស្តង់ដារដែលត្រូវបានប្រើប្រាស់ ដើម្បីធានាដល់ការអនុវត្តប្រកបដោយសមភាពរវាងស្ត្រី និងបុរស។

៦៨. ស្វ័យភាពរបស់មូលដ្ឋាន (Local Autonomy) មានន័យថា ស្ថានភាពដែលក្រុមប្រឹក្សាអាចម្ចាស់ការចាត់ចែងគ្រប់គ្រងនូវកិច្ចការ ដែលបានប្រគល់ ឬធ្វើប្រតិភូកម្មដោយច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌប្រកបដោយប្រសិទ្ធភាព។

៦៩. សិទ្ធិអំណាច (Authority) សំដៅទៅលើលទ្ធភាពតាមផ្លូវច្បាប់ក្នុងការអនុវត្តនូវការទទួលខុសត្រូវដែលផ្ទេរទៅឱ្យរដ្ឋបាលនីមួយៗនៃរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីកំណត់ និងដោះស្រាយតម្រូវការរបស់ប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

៧០. សេដ្ឋកិច្ចវិមាត្រ (Economy of Scale) សំដៅទៅលើការផ្ទេរមុខងារ ការទទួលខុសត្រូវ និងសិទ្ធិអំណាចទៅឱ្យរដ្ឋបាលណាមួយនៃរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលអាចអនុវត្តមុខងារនោះ ប្រកបដោយប្រសិទ្ធភាព និង ភាពស័ក្តិសិទ្ធិ។

៧១. សេវាសាធារណៈ (Public Service) : រាល់សកម្មភាពទាំងឡាយដែលធ្វើឡើងដោយស្ថាប័នមាន សមត្ថកិច្ច និងស្ថាប័នទទួលសមត្ថកិច្ចក្នុងគោលដៅបម្រើផលប្រយោជន៍សាធារណៈ។ ស្ថាប័នមានសមត្ថកិច្ចក្នុងន័យនេះ សំដៅលើស្ថាប័នរដ្ឋ ឬភ្នាក់ងាររដ្ឋ ឬអាជ្ញាធរគ្រប់លំដាប់ថ្នាក់របស់រដ្ឋដែលបំពេញការងារតាមដែនសមត្ថកិច្ច របស់ខ្លួន។ ស្ថាប័នទទួលសមត្ថកិច្ច ក្នុងន័យនេះ សំដៅលើផ្នែកឯកជន និងសង្គមស៊ីវិលដែលទទួលបានសិទ្ធិ និងភារកិច្ចពីរដ្ឋ ហើយដែលស្ថិតនៅក្រោមការគ្រប់គ្រងត្រួតពិនិត្យរបស់រដ្ឋ ឬភ្នាក់ងាររដ្ឋ។_

៧២. ហេដ្ឋារចនាសម្ព័ន្ធ (Infrastructure) សំដៅទៅលើរចនាសម្ព័ន្ធ ប្រព័ន្ធ នីតិវិធី ក្រមប្រតិយាម និងបណ្តាញទំនាក់ទំនងការងារ ព្រមទាំងហេដ្ឋារចនាសម្ព័ន្ធរូបវន្តនានា។

៧៣. ហេដ្ឋារចនាសម្ព័ន្ធស្ថាប័ន (Institutional Infrastructure) សំដៅទៅលើរចនាសម្ព័ន្ធ ប្រព័ន្ធ នីតិវិធី ក្រមប្រតិយាម និងបណ្តាញទំនាក់ទំនងការងាររបស់អង្គភាពនីមួយៗ។

# រូបថតវគ្គបណ្ដុះបណ្ដាលស្ដីពី ” លើកកម្ពស់ការយល់ដឹង និងភ្ជាប់ទំនាក់ទំនងសង្គមស៊ីវិលជាមួយកម្មវិធីជាតិ សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ” រាជធានី និង២៣ខេត្ត ក្នុងព្រះរាជាណាចក្រកម្ពុជា


































































អង្គការផេក
មជ្ឈមណ្ឌលភ្នំពេញ ជាន់ទី៣ កែងវិថីព្រះសីហនុ
(២៧៤) និងវិថីសុធារស (៣) សង្កាត់ទន្លេបាសាក់
ខណ្ឌចំការមន ភ្នំពេញ កម្ពុជា
ប្រអប់សំបុត្រ ១៤៩
ទូរសព្ទ័លេខ: (៨៥៥_២៣) ២១៧ ៨៥៥
ទូរសា: (៨៥៥_២៣) ២១៧ ៨៥៦
អ៊ីម៉ែល: pact@pactworld.org
www.pactcambodia.org

អង្គការ វី ប៊ី អិន ខេ
ផ្ទះលេខ ២៨ ផ្លូវ ៨០ (កែង ផ្លូវ៧៥)
សង្កាត់ស្រះចក ខណ្ឌដូនពេញ ភ្នំពេញ
ប្រអប់សំបុត្រ ២៣០៧
ទូរសព្ទ័លេខ: (៨៥៥_២៣) ៧២២ ១១៥
ទូរសា: (៨៥៥_២៣) ៧២២ ១១៧
អ៊ីម៉ែល: vbnkoffice@nbnk.org
www.vbnk.org

ឧបត្ថម្ភដោយ:
THE WORLD BANK
គជអប NCDD